


ប្រទេសកម្ពុជា

# បោសសម្អាតចេញពីដងវិថី

## ការឃុំខ្លួនដោយបំពាន និងអំពើរំលោភផ្សេងៗលើ អ្នកប្រកបរបរផ្លូវភេទនៅក្នុងប្រទេសកម្ពុជា

HUMAN RIGHTS WATCH

HUMAN RIGHTS WATCH

# ច្រាសសម្អាតចេញពីដងទថី

## ការឃុំខ្លួនដោយបំពាន
## និងអំពើរំលោភផ្សេងៗ លើ
## អ្នកប្រកបរបរផ្លូវភេទនៅក្នុងប្រទេសកម្ពុជា

Copyright © 2010 Human Rights Watch
All rights reserved.
Printed in the United States of America
ISBN: 1-56432-661-1
Cover design by Rafael Jimenez

Human Rights Watch
350 Fifth Avenue, 34th floor
New York, NY 10118-3299 USA
Tel: +1 212 290 4700, Fax: +1 212 736 1300
hrwnyc@hrw.org

Poststraße 4-5
10178 Berlin, Germany
Tel: +49 30 2593 06-10, Fax: +49 30 2593 0629
berlin@hrw.org

Avenue des Gaulois, 7
1040 Brussels, Belgium
Tel: + 32 (2) 732 2009, Fax: + 32 (2) 732 0471
hrwbe@hrw.org

64-66 Rue de Lausanne
1202 Geneva, Switzerland
Tel: +41 22 738 0481, Fax: +41 22 738 1791
hrwgva@hrw.org

2-12 Pentonville Road, 2nd Floor
London N1 9HF, UK
Tel: +44 20 7713 1995, Fax: +44 20 7713 1800
hrwuk@hrw.org

27 Rue de Lisbonne
75008 Paris, France
Tel: +33 (1)43 59 55 35, Fax: +33 (1) 43 59 55 22
paris@hrw.org

1630 Connecticut Avenue, N.W., Suite 500
Washington, DC 20009 USA
Tel: +1 202 612 4321, Fax: +1 202 612 4333
hrwdc@hrw.org

Web Site Address: http://www.hrw.org

ខែកក្កដា ឆ្នាំ២០១០

1-56432-661-6

# ច្រាសសម្អាតចេញពីដងវិថី

## *ការឃុំខ្លួនដោយបំពាន និងអំពើរំលោភផ្សេងៗ លើ អ្នកប្រកបរបរផ្លូវភេទនៅក្នុងប្រទេសកម្ពុជា*

**ផែនទី** ........................................ **1**

**I. សេចក្ដីសង្ខេប** ........................................ **2**

*អនុសាសន៍សំខាន់ៗ* ........................................ 15

**II. វិធីសាស្ត្រ** ........................................ **18**

**III. ការងារផ្លូវភេទនៅក្នុងប្រទេសកម្ពុជា** ........................................ **22**

*ចំនួន និងដើមហេតុ* ........................................ 22

*ការពាក់ព័ន្ធរបស់សង្គមស៊ីវិលជាមួយអ្នកប្រកបរបរផ្លូវភេទ* ........................................ 28

*ការងារផ្លូវភេទក្រោមច្បាប់កម្ពុជាបច្ចុប្បន្ន* ........................................ 29

*គោលការណ៍ណែនាំ និងសេចក្ដីពន្យល់ច្បាប់ឆ្នាំ២០០៨* ........................................ 38

*ប្រវត្តិយូរលង់នៃការបង្ក្រាបអ្នកប្រកបរបរផ្លូវភេទ* ........................................ 40

**IV. អំពើរំលោភបំពានលើអ្នកប្រកបរបរផ្លូវភេទ** ........................................ **49**

*អំពើឃោរឃៅនៅតាមដងវិថី និងអំពើរំលោភបំពានផ្សេងៗ* ........................................ 51

*អំពើរំលោភបំពានអំឡុងពេលចាប់ខ្លួន និងក្នុងពេលឃុំឃាំងរបស់នគរបាល* ........................................ 53

*ការឃុំខ្លួន សំណូក និងការយាយីនៅឯមន្ទីរសង្គមកិច្ចរាជធានី* .................................. 68

*អំពើរំលោភនៅឯមជ្ឈមណ្ឌលសង្គមកិច្ចរដ្ឋាភិបាល* .......................................................73

*ទីជម្រករបស់អង្គការក្រៅរដ្ឋាភិបាល និងការឃុំខ្លួនដោយបំពាន* ................................. 82

**V.** ច្បាប់អន្តរជាតិ ................................................................................................................ **87**

**VI.** និទណ្ឌភាព និងការបណ្តែតបណ្តោយឲ្យមានការរំលោភបំពាន ........................................ **94**

*ការខកខានស៊ើបអង្កេត និងផ្តន្ទាទោសចំពោះអំពើរំលោភបំពាន* ................................. 94

*ការគាបសង្កត់របស់សហរដ្ឋអាមេរិកឲ្យដោះស្រាយបញ្ហាការជួញដូរ*
*ធ្វើឲ្យស្ថានការអាក្រក់ កាន់តែអាក្រក់ឡើង* ........................................................................... 99

**VII.** អនុសាសន៍ ...................................................................................................................**106**

*ចំពោះរដ្ឋាភិបាលកម្ពុជា៖* ...........................................................................................106

*ចំពោះក្រសួងមហាផ្ទៃ៖* ...............................................................................................106

*ចំពោះក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖* ........................................109

*ចំពោះសាលារាជធានីភ្នំពេញ៖* ...................................................................................... 110

*ចំពោះរដ្ឋសភាជាតិនៃប្រទេសកម្ពុជា*................................................................................. 110

*ចំពោះទីភ្នាក់ងារអង្គការសហប្រជាជាតិ និងរដ្ឋាភិបាលម្ចាស់ជំនួយពាក់ព័ន្ធ មានជាអាទិ៍*
*សហរដ្ឋអាមេរិក សហគមន៍អឺរ៉ុប ជប៉ុន និងអូស្ត្រាលី៖*......................................................111

*ចំពោះរដ្ឋាភិបាលសហរដ្ឋអាមេរិក៖* ...............................................................................113

*ចំពោះអង្គការមិនមែនរដ្ឋាភិបាល ដែលជួយជនរងគ្រោះនៃអំពើជួញដូរ*
*និងអ្នកប្រកបរបរផ្លូវភេទ៖*........................................................................................113

**សេចក្តីបន្ថែម I ៖ លិខិតផ្ញើជូនរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា .................................................. 115**

*លិខិតផ្ញើជូនក្រសួងមហាផ្ទៃ៖ ផ្ញើនៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១០*..................................115

*លិខិតផ្ញើជូនក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖ ផ្ញើនៅ ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១០* ....................................................................................................... 120

**VIII. សេចក្តីថ្លែងអំណរគុណ ............................................................................................ 125**

# ផែនទី



Province where research was conducted for this report
ខេត្តដែលបាន ស្រាវជ្រាវសម្រាប់របាយការណ៍នេះ
Social Affairs center
មជ្ឈមណ្ឌលសង្គមកិច្ច
ប្រទេសឡាវ
LAOS
ប្រទេសថៃឡង់ដ៍
THAILAND
ឧត្តរមានជ័យ
ODAR MEANCHEY
ព្រះវិហារ
PREAH VIHEAR
ស្ទឹងត្រែង
STUNG TRENG
រតនគីរី
RATANAKIRI
បន្ទាយមានជ័យ
BANTEAY MEANCHEY
Sisophon
សៀមរាប
SIEM REAP
Siem Reap
Battambang
បាត់ដំបង
BATTAMBANG
ប៉ៃលិន
PAILIN
កម្ពុជា
CAMBODIA
កំពង់ធំ
KAMPONG THOM
ក្រចេះ
KRATIE
មណ្ឌលគីរី
MONDULKIRI
ពោធិសាត់
PURSAT
កំពង់ឆ្នាំង
KAMPONG CHHNANG
កំពង់ចាម
KAMPONG CHAM
កំពង់ស្ពឺ
KAMPONG SPEU
រាជធានីភ្នំពេញ
Phnom Penh
Prey Speu
ព្រៃស្ពឺ
Koh Kor
កោះគរ
ព្រៃវែង
PREY VENG
ប្រទេសវៀតណាម
VIET NAM
កោះកុង
KOH KONG
KANDAL
កណ្ដាល
ស្វាយរៀង
SVAY RIENG
ឈូងសមុទ្រសៀម
Gulf of Siam
តាកែវ
TAKEO
កំពត
KAMPOT
ព្រះសីហនុ
SIHANOUKVILLE
កែប
KEP
0
50
100 km
© 2010 Giulio Frigieri / Human Rights Watch

# I. សេចក្តីសង្ខេប

បន្ទាប់ពីការសួរចម្លើយពួកយើងខ្ញុំ ប៉ូលីសបានរុញខ្ញុំចូលទៅក្នុងបន្ទប់ ដែលមានគ្រែបត់មួយនៅក្នុងនោះ - វាជាកន្លែងសំរាប់ប៉ូលីសឃុំពួកចោរ។ នៅយប់ដំបូង ប៉ូលីសប្រាំនាក់បានរំលោភខ្ញុំ និងនៅយប់ទីពីរ ប៉ូលីសប្រាំមួយនាក់ផ្សេងទៀត រំលោភខ្ញុំ។ ពួកគេបានវាយខ្ញុំ ព្រោះពេលនោះខ្ញុំបានប្រកែកតវ៉ា។

*-ស្ត្រីប្រកបរបរផ្លូវភេទ បានពិពណ៌នាពីការប្រព្រឹត្តមកលើខ្លួននាង បន្ទាប់ ពីការចាប់ខ្លួននាងជាមួយស្ត្រីប្រកបរបររកស៊ីផ្លូវភេទដទៃទៀត ពី សួនច្បារនៅក្បែរវិមានឯករាជ្យ ក្នុងរាជធានីភ្នំពេញ។*

ប៉ូលីសបីនាក់បានវាយដំច្រំធាក់ខ្ញុំខ្លាំងណាស់...ប៉ូលីសម្នាក់ក្នុងចំណោមពួកគេទាំងបីនាក់ បានយកកាំភ្លើងមកភ្ជង់ក្បាលខ្ញុំ រួចកេះកៃ ប៉ុន្តែអត់ផ្ទុះគ្រាប់ទេ។ ពួកគេទាត់កញ្ជឹងករបស់ខ្ញុំ ចង្កេះរបស់ខ្ញុំនិងវាយក្បាលរបស់ខ្ញុំ និងខ្លួនខ្ញុំជាមួយដងអំបោស។ វាយប្រហែលកន្លះម៉ោង។

*-ស្រីស្រស់* (Transgender Woman) *ប្រកបរបរផ្លូវភេទ ឃុំខ្លួននៅឯប៉ុស្តិ៍នគរបាលមួយ នៅរាជធានីភ្នំពេញ។*

ក្រោយពីពេលដែលខ្ញុំមកដល់បានពីរថ្ងៃ ខ្ញុំបានព្យាយាមរត់គេចខ្លួន តែគេចាប់ខ្ញុំបានវិញ។ ពួកអ្នកយាមប្រាំនាក់បានវាយដំខ្ញុំ។ ពួកគេវាយដៃរបស់ខ្ញុំ ពេលខ្ញុំយកដៃមករងមុខ និងក្បាលពីការវាយដំ ។ អ្នកយាមម្នាក់គំរាមអារកខ្ញុំ ប្រសិន បើខ្ញុំព្យាយាមរត់គេចជាលើកទីពីរ និងនិយាយថានឹង ដុតសពខ្ញុំចោលនៅ ទីនោះ។

*-ស្ត្រីប្រកបរបរផ្លូវភេទជាប់ឃុំឃាំងនៅមជ្ឈមណ្ឌលសង្គមកិច្ចព្រៃស្ពឺក្បែររាជធានីភ្នំពេញ។*

នៅក្នុងប្រទេសកម្ពុជា ជនដែលមានមុខងារការពារច្បាប់ ជាញឹកញាប់គឺជាជនដែលប្រព្រឹត្ត អំពើរំលោភបំពានដ៏អាក្រក់បំផុត។ ជាពិសេស ស្ត្រីប្រកបរបរផ្លូវភេទ ដឹងការពិតទាក់ទងនឹង រឿងនេះ។ ស្ត្រី និង កុមារ ដែលពាក់ព័ន្ធក្នុងមុខរបរផ្លូវភេទ ប្រឈមមុខនឹងការវាយដំ ការ រំលោភសេពសន្ថវៈ ការបៀតបៀនកេរ្តិ៍ឈ្មោះ ការជំរិតយកលុយ ការចាប់ខ្លួន និងឃុំខ្លួនដោយបំពាន ការធ្វើការងារដោយបង្ខំ និងការប្រព្រឹត្តបែប បន្ទាបបន្ថោក និងឃោរឃៅដទៃទៀត ក្នុងកណ្តាប់ដៃរបស់នគរបាល ឆ្មាំសន្តិសុខ ការពារសួនច្បារសាធារណៈ មន្ត្រីរដ្ឋាភិបាល និងជនទាំងឡាយដែលធ្វើការនៅក្នុង មជ្ឈមណ្ឌល និងការិយាល័យ ដែលគ្រប់គ្រងដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា។

អ្នកប្រកបរបរផ្លូវភេទ បានប្រាប់អង្គការឃ្លាំមើលសិទ្ធិមនុស្សថា មន្ត្រីនគរបាល បានវាយលើពួកគេដោយប្រើកណ្តាប់ដៃ ព្រនង់ ដំបងឈើ និងប្រើដំបងឆក់។ មន្ត្រីនគរបាល បានគំរាមកំហែង អ្នកប្រកបរបរផ្លូវភេទ ដោយអាវុធផងដែរ។ ក្នុង ឱកាសខ្លះ មន្ត្រីនគរបាលបានរំលោភសេពសន្ថវៈស្ត្រីប្រកបរបរផ្លូវភេទ ក្នុងអំឡុង ពេលដែលពួកគេស្ថិតក្នុង ការឃុំឃាំងរបស់នគរបាល។ អ្នកប្រកបរបរផ្លូវភេទខ្លះ បានពិពណ៌នាអំពីស្ថានភាពនៃការជាប់ឃុំឃាំងរបស់ពួកគេ នៅក្នុងមជ្ឈមណ្ឌល សង្គមកិច្ច ថា  ជាការគួរឲ្យរន្ធត់ ជាមួយនឹងការដាក់កំហិតដល់សេរីភាព ក្នុងការធ្វើ ដំណើរ ទទួលរងឬបានឃើញការវាយដំ ឬការរំលោភសេពសន្ថវៈ និងមានអាហារ និងការថែទាំសុខភាពមិនគ្រប់គ្រាន់។

អំពើហិង្សា និងការរំលោភភាគច្រើនផ្សេងទៀត ដែលប្រព្រឹត្តដោយនគរបាលនៅរាជធានីភ្នំ ពេញ ហាក់ដូចជាអាក្រក់ជាងនៅក្នុងខេត្តបាត់ដំបង បន្ទាយមានជ័យ និងសៀមរាប និង បណ្តាខេត្តដទៃទៀត ដែលអង្គការឃ្លាំមើលសិទ្ធិមនុស្សបាន ស្រាវជ្រាវ។ មន្ត្រីនគរបាល នៅតាមស្ថានីយ៍នគរបាលនានា ក្នុងខណ្ឌដូនពេញ និង ខណ្ឌចំការមនក្នុងរាជធានីភ្នំពេញ លេចធ្លោខាងការប្រព្រឹត្តអំពើរំលោភ ។ ស្ថានីយ៍ នគរបាលទាំងនេះ

មានការប្រាស្រ័យទាក់ទងច្រើនបំផុត ជាមួយអ្នកប្រកបរបរផ្លូវ ភេទ ពីព្រោះស្ថានីយ៍ទាំងនេះ ស្ថិតនៅក្បែរសួនច្បារសាធារណៈ ជាទីកន្លែងដែល មានអ្នកប្រកបរបរផ្លូវភេទភាគច្រើនទៅទីនោះជាញឹកញាប់។

ការជំរិតយកលុយ និងការទារឲ្យបង់ប្រាក់សំណូក ដោយនគរបាល មានភាពល្បីរន្ទឺនៅគ្រប់ខេត្តទាំងអស់ ដែលអង្គការឃ្លាំមើលសិទ្ធិមនុស្សបានសិក្សាស្រាវជ្រាវ។ ពេលខ្លះនគរបាលបានបង្ខំឲ្យអ្នកប្រកបរបរផ្លូវភេទ បង់ប្រាក់លោះមួយចំនួន ឬក្នុងករណីដ៏អាក្រក់បំផុតនោះគឺ បានបង្ខំស្ត្រីឲ្យរួមភេទជាមួយពួកគេជាថ្នូរនឹង ការដោះលែង។ ស្ត្រីប្រកបរបរផ្លូវភេទ បានប្រាប់អង្គការឃ្លាំមើលសិទ្ធិមនុស្សថា នគរបាលបានយកលុយរបស់ពួកគេ និងវត្ថុមានតម្លៃផ្សេងៗ។ អ្នកប្រកបរបរផ្លូវភេទដែលយើងបានជួបនិយាយជាមួយគ្រប់រូប ដែលរួមមានទាំងកុមារក្នុងមុខរបរនេះផងសុទ្ធតែបានបង់ប្រាក់សំណូកឲ្យនគរបាលនៅក្នុងដំណាក់កាលណាមួយ។

នៅក្នុងរាជធានីភ្នំពេញ នគរបាលមិនមែនជាកងកម្លាំងសន្តិសុខតែម្នាក់ឯង ដែលរំលោភស្ត្រីប្រកបរបរផ្លូវភេទប៉ុណ្ណោះទេ។ ស្ត្រីប្រកបរបរផ្លូវភេទ បានរាយការណ៍មកអង្គការឃ្លាំមើលសិទ្ធិមនុស្សផងដែរ អំពីឧប្បត្តិហេតុហិង្សាពាក់ព័ន្ធនឹងឆ្មាំសន្តិសុខការពារសួនច្បារសាធារណៈរបស់សាលារាជធានីភ្នំពេញ។ ក្នុងខែវិច្ឆិកា ឆ្នាំ២០០៩ នីកាបានពណ៌នាអំពីការវាយដំប្រព្រឹត្តឡើងនាពេលថ្មីៗដោយឆ្មាំសន្តិសុខ - ដែលជានិយោជិករបស់សាលារាជធានីភ្នំពេញ - នៅឯសួនច្បារក្បែរ ផ្សារចាស់ក្នុងរាជធានីភ្នំពេញ។ នាងបាននិយាយថា៖

> មុនដំបូង សន្តិសុខម្នាក់បានដើរមករកខ្ញុំ ហើយទាត់ខ្ញុំ ... បន្ទាប់មកសន្តិសុខ បីនាក់បានមកដល់ដែរ។ សន្តិសុខពីរនាក់ចាប់ដៃទាំងពីររបស់ខ្ញុំជាប់ ដោយទុកឲ្យសន្តិសុខពីរនាក់ទៀតវាយខ្ញុំ។ ពួកគេទះកំភ្លៀងខ្ញុំ។ ពួកគេដូចជាស្រវឹងស្រាបន្តិច។ ពួកគេវាយក្បាលខ្ញុំនឹងដំបងឫស្សី និងវិទ្យុទាក់ទងរបស់ពួកគេ និងវាយដំសព្វកន្លែងទាំងអស់។ ពួកគេចាប់ហែកអាវខ្ញុំ។ មាននគរបាលបានធ្វើ ដំណើរ

> កាត់តាមនោះដែរ តែគាត់មិនចូលមកជួយខ្ញុំទេ សន្តិសុខបន្តវាយខ្ញុំ ជិត កន្លះម៉ោង។ មនុស្សជាច្រើននាក់បានឃើញសន្តិសុខវាយដំខ្ញុំ តែគេរាល់គ្នាខ្លាច មិនហ៊ានជួយខ្ញុំទេ។ មេសន្តិសុខ ប្រាប់កូនចៅផ្សេងទៀតថា បើឃើញខ្ញុំទៅទី នោះម្តងទៀត ត្រូវវាយខ្ញុំឲ្យងាប់។

*ឧប្បត្តិហេតុហិង្សា ការចាប់ខ្លួន និងឃុំខ្លួនខុសច្បាប់ខ្លះ ដែលបានប្រព្រឹត្តទៅលើ អ្នកប្រកបរបរផ្លូវភេទ គឺមានលក្ខណៈបែបឱកាសនិយម។ ការធ្វើការងារនៅតាម ដងផ្លូវ និងនៅលើសួនច្បារ នាំឲ្យអ្នកប្រកបរបរផ្លូវភេទងាយទទួលរងគ្រោះពី នគរបាល និងឆ្មាំសន្តិសុខការពារសួនច្បារ ហើយដែលនគរបាល និងសន្តិសុខ ទាំងនេះ ដឹងខ្លួនថា នឹងមិនមាននរណាមកចាប់ខ្លួនពួកគេឲ្យទទួលខុសត្រូវចំពោះ អំពើរំលោភ ដែលពួកគេបានប្រព្រឹត្តនោះឡើយ។ ការរំលោភដទៃទៀត កើតឡើង ក្នុងពេលមានការចាត់ វិធានការបង្ក្រាប និងចុះចាប់ប្រមូលជាទៀងទាត់ ដោយ នគរបាល និងអាជ្ញាធរខណ្ឌ ជាពិសេសនៅពេលសំដៅចាប់តែអ្នកប្រកបរបរផ្លូវភេទ និងនៅ ពេលផ្សេងទៀតសំដៅចាប់អ្នកប្រកបរបរផ្លូវភេទ ក្នុងចំណោមក្រុម ប្រជាពលរដ្ឋដទៃទៀត ដែលគេចាត់ទុកថាជា កាកសំណល់សង្គម ដែលគេឃើញ នៅតាមដងផ្លូវ។*

*អ្នកប្រកបរបរផ្លូវភេទ ប្រឈមមុខនឹងគ្រោះថ្នាក់ដ៏ច្រើនដោយសារការងារប្រចាំថ្ងៃ របស់ពួកគេដូចជា អំពើហិង្សា ការរំលោភសេពសន្ថវៈ ការប្លន់ ការបៀតបៀនកេរ្តិ៍ខ្មាស់ និងការរំលោភបំពានដទៃទៀត ដែលប្រព្រឹត្តដោយអតិថិជន បុគ្គលដទៃទៀត និង អ្នករដ្ឋការ។ របាយការណ៍នេះ ពិនិត្យត្រឹមតែស្ថានភាពជាក់លាក់អំពីការរំលោភ ដោយនគរបាល សន្តិសុខការពារសួនច្បារនៅរាជធានីភ្នំពេញ និងនិយោជិតនៅឯ មជ្ឈមណ្ឌលសង្គមកិច្ចដែលគ្រប់គ្រងដោយរដ្ឋាភិបាល។*

*ជាទូទៅ អាជ្ញាធរមិនបែងចែករវាងនីតិជនដែលរងការជួញដូរ និងនីតិជនក្នុងការងារ ប្រកបរបរផ្លូវភេទដោយស្ម័គ្រចិត្តទេ។ ពួកគេបញ្ជូនអ្នកប្រកបរបរផ្លូវភេទ រួមទាំង ជនរងគ្រោះដោយការជួញដូរ និងកុមារ ទៅមន្ទីរសង្គមកិច្ចរាជធានី ដែលក្រោយមក*

បញ្ជូនពួកគេទៅកាន់មណ្ឌលរបស់អង្គការក្រៅរដ្ឋាភិបាល ឬមណ្ឌលសង្គមកិច្ចរដ្ឋាភិបាល (ដែលគ្រប់គ្រងដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា)។ មានតែនគរបាលជំនាញខាងប្រឆាំងការជួញដូរមនុស្សប៉ុណ្ណោះ បែងចែកជនរងគ្រោះនៃការជួញដូរ និងកុមារ ពីអ្នកប្រកបរបរផ្លូវភេទស្ម័គ្រចិត្ត និងបញ្ជូនស្ត្រី និងកុមារ ដែលគេជួញដូរ ទៅកាន់មណ្ឌលប្រឆាំងការជួញដូរជាក់លាក់។ ទោះជាយ៉ាងណាក៏ដោយ យោងតាមស្ត្រីប្រកបរបរផ្លូវភេទ មានសមាជិកមួយចំនួនរបស់ នគរបាលជំនាញប្រឆាំងការជួញដូរ ក្នុងរាជធានីភ្នំពេញ បានជាប់ពាក់ព័ន្ធក្នុងការព្យាយាមជំរិតទារលុយពីស្ត្រីប្រកបរបរផ្លូវភេទ ។ ការបោសសម្អាតតាមដងផ្លូវភាគច្រើនដឹកនាំដោយនគរបាលសណ្តាប់ធ្នាប់ ថ្នាក់សង្កាត់ ខណ្ឌ ឬរាជធានី។

## ការរំលោភបំពាននៅឯមជ្ឈមណ្ឌលសង្គមកិច្ច

នគរបាល ឬមន្ត្រីសង្គមកិច្ចរាជធានី ជាញឹកញយបញ្ជូនអ្នកប្រកបរបរផ្លូវភេទ និង អ្នកដទៃទៀត ដែលគេបានចាប់ខ្លួនក្នុង ការបង្រ្កាប ទៅកាន់មណ្ឌលសង្គមកិច្ចរបស់ រដ្ឋាភិបាល ឬទៅកាន់មណ្ឌលដែលគ្រប់គ្រងដោយអង្គការមិនមែនរដ្ឋាភិបាល។ ក្នុងឆ្នាំ២០០៨ ក្រុមអង្គការសិទ្ធិមនុស្សក្នុងស្រុក និងការិយាល័យឧត្តមស្នងការ អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) បានចងក្រងជាឯកសារ នូវការរំលោភ និងស្ថានភាពទាំងឡាយ ក្នុងមជ្ឈមណ្ឌលសង្គមកិច្ចពីរកន្លែងរបស់ រដ្ឋាភិបាល គឺកោះគរ (ឬកោះរំដួល) និងព្រៃស្ពឺ រួមមានទាំងករណីមរណភាពប្រកប ដោយភាពមន្ទិលសង្ស័យ ការរំលោភសេពសន្ថវៈ ទារុណកម្ម ការវាយដំ និងការដាក់ កំហិតលើសេរីភាពធ្វើដំណើរដោយខុសច្បាប់។

មជ្ឈមណ្ឌលទាំងនោះ ជាគុកនរក។ ក្នុងខែមិថុនា ឆ្នាំ២០០៨ រដ្ឋាភិបាលបាន ដោះលែងអ្នកជាប់ឃុំឃាំងទាំងអស់ពីមណ្ឌលកោះគរ ដែលមានទីតាំងនៅលើកោះ មួយ ដែលធ្លាប់ជាទីកន្លែងឃុំឃាំងរបស់ខ្មែរក្រហម។ បច្ចុប្បន្ននេះ មជ្ឈមណ្ឌលនោះ មិនសកម្មទៀតទេ

*និងឈប់ទទួលយកមនុស្សទៅដាក់ឃុំទៀតហើយ ទោះជានៅមាន បុគ្គលិកមណ្ឌលម្នាក់ ឬក៏ពីរនាក់រស់នៅទីនោះក៏ដោយ។*

*អ្នកប្រកបរបរផ្លូវភេទ អ្នកសុំទាន អ្នកប្រើប្រាស់គ្រឿងញៀន កុមាររស់តាមចិញ្ចើមថ្នល់ និងអ្នកគ្មានផ្ទះសម្បែង ដែលគេឃុំទុកនៅព្រៃស្ពឺ បានរាយការណ៍អំពីរបៀបដែល សមាជិកបុគ្គលិកនៅឯមណ្ឌលព្រៃស្ពឺ បានវាយទាត់ធាក់ ចាប់រំលោភសេពសន្ថវៈ និងធ្វើបាបអ្នកជាប់ឃុំ រួមទាំងកុមារ។ ស្ត្រីប្រកបរបរផ្លូវភេទ ដែលគេឃុំនៅព្រៃស្ពឺ នៅខែមិថុនា នាពេលថ្មីៗនេះ ត្រូវបានគេទុកឲ្យនៅតែក្នុងបន្ទប់ និងអនុញ្ញាតឲ្យ ចាកចេញពីបន្ទប់ទៅផ្ងូតទឹក បានត្រឹមតែពីរដងប៉ុណ្ណោះក្នុងមួយថ្ងៃ ក្នុងទឹកស្រះ កខ្វក់ ឬត្រូវដើរអែមតាមដោយឆ្មាំសន្តិសុខ នៅពេលត្រូវទៅប្រើបង្គន់។ មជ្ឈមណ្ឌល នេះមិនមានសម្ភារៈគ្រប់គ្រាន់ បុគ្គលិកគ្មានការហ្វឹកហ្វឺន និងគ្មានកម្មវិធីស្តារនីតិ សម្បទាទេ។*

*បុប្ផា ត្រូវបានគេចាប់ខ្លួនច្រើនលើកច្រើនសារមកហើយ។ នាងបានពិពណ៌នាឲ្យ អង្គការឃ្លាំមើលសិទ្ធិមនុស្ស ដឹងអំពីឧប្បត្តិហេតុមួយក្នុងឆ្នាំ២០០៨ ពេលដែល នគរបាល ខណ្ឌចាប់ខ្លួននាង។ ពេលនាងមិនព្រមអោយលុយទៅពួកគេ ពួកគេបាន ចាប់បោះនាងឡើងលើរថយន្ត ដែលជាកម្មសិទ្ធិរបស់មន្ទីរសង្គមកិច្ចរាជធានី ហើយ បានបញ្ជូននាងទៅព្រៃស្ពឺ។ នាងបាននិយាយថា៖*

> ប្រាំបួនថ្ងៃដែលខ្ញុំជាប់នៅក្នុងមណ្ឌលព្រៃស្ពឺ គឺវាពិបាកជាងការរស់នៅក្នុងឋាននរកទៅទៀត។ នៅថ្ងៃមកដល់ អ្នកយាមបានវាយខ្ញុំពីរដង យកដំបងឈើវាយលើត្រគាករបស់ខ្ញុំ... អាហារកខ្វក់មែនទែន... គេយកទឹកពីស្រះឲ្យផឹក... នៅក្នុងបន្ទប់គេដាក់ធុងសម្រាប់ឲ្យប្រើជាបង្គន់... យប់មួយនោះ អ្នកយាមបាន មករួមភេទជាមួយស្ត្រីស្អាតៗពីរនាក់ ដែលដេកជាប់នឹងខ្ញុំនៅក្នុងបន្ទប់។ ស្ត្រីទាំង នេះត្រូវបានគេដោះលែងនៅថ្ងៃបន្ទាប់។ ខ្ញុំមានផ្ទុកមេរោគអេដស៍ ហើយ ខ្ញុំខកខានមិនបានលេបថ្នាំពន្យារអាយុប៉ុន្មានថ្ងៃនោះ។

ជាលទ្ធផលនៃការស្វែងរកការគាំទ្ររបស់អ្នកប្រកបរបរផ្លូវភេទ និងក្រុមសិទ្ធិមនុស្ស អំពីស្ថានភាពរំលោភក្នុងមជ្ឈមណ្ឌលព្រៃស្ពឺ ក្នុងខែកក្កដាឆ្នាំ២០០៩ មន្ទីរសង្គមកិច្ចរាជធានីបានប្រកាសថា ខ្លួនឈប់បញ្ជូនស្ត្រីប្រកបរបរផ្លូវភេទ ទៅកាន់ទីនោះហើយ។ ជាជំនួសវិញ ស្ត្រីប្រកបរបរផ្លូវភេទដែលចាប់ដោយនគរបាល ត្រូវតែបញ្ជូន ទៅតាមអង្គការក្រៅរដ្ឋាភិបាលដែលមានផ្តល់សេវាគាំទ្រ។

ទោះជាយ៉ាងណាក៏ដោយ អង្គការឃ្លាំមើលសិទ្ធិមនុស្សបានដឹងថា យ៉ាងហោចណាស់ ស្ត្រីប្រកបរបរផ្លូវភេទចំនួន ២០ នាក់ ត្រូវបានឃុំឃាំងនៅឯព្រៃស្ពឺ តាំងពីខែកក្កដាឆ្នាំ២០០៩មក។ ទោះបីជាចំនួននេះ បង្ហាញពីការថយចុះនូវចំនួនស្ត្រីប្រកប របរផ្លូវភេទដែលគេឃុំឃាំងនៅទីនោះតាំងពីឆ្នាំ២០០៨ ក៏ដោយ ដោយមាន ការលំបាកចូលទៅកាន់មណ្ឌលនេះ ចំនួននេះត្រូវបានគេពិចារណាថាជាចំនួន សារុបជាអប្បបរមាប៉ុណ្ណោះ។ ខណៈដែលស្ត្រីប្រកបរបរផ្លូវភេទ ត្រូវបានគេបញ្ជូន ទៅតាមមណ្ឌលអង្គការក្រៅរដ្ឋាភិបាល ដោយសារតែមានសំពាធពីក្រុមអ្នកគាំទ្រ អ្នកប្រកបរបរផ្លូវភេទ ប៉ុន្តែក្រុមដទៃទៀត រួមទាំងអ្នកគ្មានផ្ទះសម្បែង ត្រូវបានគេបន្ត បញ្ជូនទៅកាន់ព្រៃស្ពឺ។ ស្ត្រីប្រកបរបរផ្លូវភេទដែលគេឃុំឃាំងនៅឯព្រៃស្ពឺក្នុងខែ មិថុនា ឆ្នាំ២០១០ បានប្រាប់ អង្គការឃ្លាំមើលសិទ្ធិមនុស្សថា បុគ្គលិកមណ្ឌល សង្គមកិច្ច បានព្រមានពួកគេថា ពួកគេនឹងប្រឈមនឹងការឃុំឃាំងរហូតដល់ទៅ បីខែ ក្នុងមណ្ឌលព្រៃស្ពឺ ប្រសិនបើពួកគេត្រូវបានគេចាប់ខ្លួន និងបញ្ជូនមកមន្ទីរ សង្គមកិច្ចជាលើកទីពីរ។

អង្គការឃ្លាំមើលសិទ្ធិមនុស្ស មានកង្វល់ណាស់ ដែលមជ្ឈមណ្ឌលព្រៃស្ពឺនៅតែបើក។ ប្រសិនបើមិនមានការប្តេជ្ញាចិត្តខាងនយោបាយពីរដ្ឋាភិបាលកម្ពុជាដើម្បីដោះស្រាយការរំលោភធ្ងន់ធ្ងរទៅលើ អ្នកស្នាក់នៅក្នុងមណ្ឌលទាំងនេះទេ អង្គការឃ្លាំមើលសិទ្ធិមនុស្ស មានជំនឿថាមណ្ឌលទាំងពីរនោះ ដែលនៅឯកោះគរ និងព្រៃស្ពឺ គួរតែបិទជា អចិន្ត្រៃ។

---

1 យុន សាមៀន និង បេថានី លិនសាយ "ក្រុមសិទ្ធិមនុស្សចោទរដ្ឋាភិបាលពីការធ្វើទណ្ឌកម្មលើអ្នកក្រីក្រនៅរាជធានី ភ្នំពេញ" កាសែត ឌឹ ឃែមបូឌា ដេលី ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៩។

*មណ្ឌលដែលគ្រប់គ្រងដោយអង្គការមិនមែនរដ្ឋាភិបាល ដែលព្រមទទួលយកស្ត្រីប្រកបរបរផ្លូវភេទ តាមការបញ្ជូននិងប្រគល់ពីមន្ទីរសង្គមកិច្ច មានបទដ្ឋាន និងនីតិវិធីប្រតិបត្តិការផ្សេងៗគ្នា ប៉ុន្តែមានស្ថានភាពប្រសើរច្រើនជាងស្ថានភាពនៅក្នុង មជ្ឈមណ្ឌលសង្គមកិច្ចរបស់រដ្ឋាភិបាល។ មណ្ឌលរបស់អង្គការមិនមែនរដ្ឋាភិបាល ភាគច្រើនមិនឃុំឃាំងនីតិជនទេ ប៉ុន្តែផ្តល់សេវាកម្ម និងជម្រើសលើមូលដ្ឋាន ព្រមព្រៀង។*

*ទោះជាយ៉ាងណាក៏ដោយ ក្នុងឆ្នាំ២០០៩ ស្ត្រីប្រកបរបរផ្លូវភេទ បានប្រាប់អង្គការ ឃ្លាំមើលសិទ្ធិមនុស្សថា មណ្ឌលអង្គការក្រៅរដ្ឋាភិបាលចំនួនពីរ បានឃុំឃាំង ពួកគេដោយបំពានអស់ពេលបីបួនថ្ងៃរហូតដល់បីបួនសប្តាហ៍។ ស្ត្រីប្រកបរបរ ផ្លូវភេទពីរនាក់ ដែលមានផ្ទុកមេរោគអេដស៍ បានរាយការណ៍ផងដែរថា មណ្ឌល អង្គការក្រៅរដ្ឋាភិបាលមួយ បានបដិសេធសំណើររបស់ពួកគេដើម្បីទទួលបាន ថ្នាំពន្យារជីវិត ។ អង្គការក្រៅរដ្ឋាភិបាលដែលជាប់ចោទ បានបដិសេធថា មិនមាន ជនណាម្នាក់ត្រូវបានឃុំឃាំងខ្លួនផ្ទុយនឹងឆន្ទះរបស់ពួកគេទេ និងបានប្រកែកដោយ លើកហេតុផលផងដែរថា ពួកគេត្រូវការពេលវេលាគ្រប់គ្រាន់ ដើម្បីផ្តល់ការប្រឹក្សាយោបល់ដល់ស្ត្រី និងកុមារី ដើម្បីឲ្យពួកគេជឿ និងស្នាក់នៅរៀនជំនាញ។ តាមពិត អង្គការក្រៅរដ្ឋាភិបាលមិនមានសិទ្ធិខាងផ្លូវច្បាប់ ដើម្បីរក្សាទុកជនណាម្នាក់ ប្រឆាំង នឹងឆន្ទះរបស់ពួកគេឡើយ ហើយទោះបីជាការរក្សាទុកអ្នកណាម្នាក់ តែក្នុងរយៈពេលមួយម៉ោងពីរ ឬមួយថ្ងៃពីរក៏ដោយ គឺចាត់ទុកជាការដកហូតសេរីភាពដោយខុសច្បាប់។ តាំងពីពេលនោះមក អង្គការក្រៅរដ្ឋាភិបាលដែលជាប់ចោទទាំងនោះ បានជូនដំណឹង ដល់អង្គការឃ្លាំមើលសិទ្ធិមនុស្សថា ពួកគេបានផ្លាស់ប្តូរគោលនយោបាយរបស់ពួកគេហើយ និងលែងឃុំឃាំងបុគ្គលណាម្នាក់ទៀតហើយ ទោះក្នុង រយៈពេល ខ្លីក៏ដោយ។ មិនមានករណីថ្មីនៃការឃុំឃាំងដោយអង្គការក្រៅរដ្ឋាភិបាល ត្រូវបានរាយការណ៍ មកអង្គការឃ្លាំមើលសិទ្ធិមនុស្សទេនៅក្នុងឆ្នាំ២០១០នេះ។*

## ការបោសសម្អាត និង ការបង្ក្រាបទៀងទាត់តាមកាលកំណត់

*កំឡុងពេលនៃការបង្ក្រាបលើអ្នកប្រកបរបរផ្លូវភេទ ដែលធ្វើឡើងដោយនគរបាល និង អាជ្ញាធរដទៃទៀត បានប្រមូលផ្តុំយ៉ាងសំខាន់នូវចំណាប់អារម្មណ៍ពីសារព័ត៌មាន ក្នុងឆ្នាំ២០០៨ និងឆ្នាំ២០០៩ ដែលការបង្ក្រាបបែបនេះបានបន្តធ្វើជាច្រើនឆ្នាំមកហើយ។ មានការផ្តល់ហេតុផលសំអាងផ្សេងៗជាច្រើន ចំពោះការបង្ក្រាបតាមកាលកំណត់ ទាំងនេះ។*

*ហេតុផលមួយដែលបានផ្តល់ឲ្យដោយអាជ្ញាធរមូលដ្ឋានគឺដើម្បី "រៀបចំសណ្តាប់ធ្នាប់ តាមដងផ្លូវ" និងថែរក្សាសណ្តាប់ធ្នាប់សង្គម។ អ្នកប្រកបរបរផ្លូវភេទ និងអ្នកគ្មាន ផ្ទះសម្បែង កុមាររស់តាមចិញ្ចើមថ្នល់ អ្នកសុំទាន និងអ្នកប្រើប្រាស់គ្រឿងញៀន នៅតាមដងផ្លូវនៃរាជធានីភ្នំពេញ ត្រូវបានឡោមព័ទ្ធចាប់ និងឃុំខ្លួន ក្នុងប្រតិបត្តិការ ដែលអនុញ្ញាតពីអភិបាល និងអភិបាលរងរាជធានីភ្នំពេញ។*

*អាជ្ញាធររាជធានី បានធ្វើសេចក្តីថ្លែងជាសាធារណៈផងដែរថា អាជ្ញាធរត្រូវចាប់ អ្នកប្រកបរបរផ្លូវភេទនិងឃុំឃាំងពួកគេ ដើម្បីបង្ការការរីករាលដាលជំងឺអេដស៍។ ឧទាហរណ៍ ពីរបីថ្ងៃមុនពិធីបុណ្យ "អុំទូក" ប្រចាំឆ្នាំរបស់ប្រទេសកម្ពុជា គឺនៅថ្ងៃទី២៩ ខែតុលា ឆ្នាំ២០០៩ លោក សុខ ពេញវុធ អភិបាលរងខណ្ឌដូនពេញ បានផ្តល់ ហេតុផលចំពោះការចាប់ខ្លួនស្ត្រីប្រកបរបរផ្លូវភេទចំនួន ១៧ នាក់ ដែលបញ្ជូនទៅ មន្ទីរសង្គមកិច្ចរាជធានី ដោយនិយាយថា "យើងមិនចង់ឃើញអ្នកប្រណាំងទូក នាំយក មេរោគអេដស៍/ជំងឺអេដស៍ទៅចម្លងឲ្យប្រពន្ធរបស់ពួកគេទេ។ យើងចង់ការពារបុរស ទាំងនោះ ពីការឆ្លងមេរោគ ពេលពួកគេមកចូលរួមក្នុងពិធីនេះ ហើយភ្លេចគិតពី សុខភាព និងសុវត្ថិភាព។" ការបោសសម្អាតតាមដងផ្លូវ និងការបង្ក្រាបតាមទីកន្លែង សេវាកម្សាន្តនានា មានការកើនឡើងក្នុងអំឡុងពេលនៃព្រឹត្តិការណ៍តំបន់ ឬអន្តរជាតិ ធំៗ ដែលរៀបចំឡើងក្នុងរាជធានីភ្នំពេញ និងអំឡុងពិធីសាធារណៈសំខាន់ៗ ដូចជាថ្ងៃ បុណ្យចូលឆ្នាំខ្មែរ (ពាក់កណ្តាលខែមេសា) និងថ្ងៃបុណ្យអុំទូក (ចុងខែតុលា ដើម ខែវិច្ឆិកា)។*

ហេតុផលមួយទៀតនោះគឺ ការចាប់អារម្មណ៍តាមនឹកឃើញរបស់អាជ្ញាធរ ក្នុង ការប្រយុទ្ធប្រឆាំងពេស្យាចារ និងអំពើអធម៌របស់អជ្ញាធរ ដែលជាញឹកញយ បណ្ដាលមកពីមានចំណាប់អារម្មណ៍របស់ម្ចាស់ជំនួយ និងការដាក់បញ្ហាជួញដូរ បញ្ចូលគ្នាជាមួយបញ្ហាការរោរផ្លូវភេទ។

## ការបញ្ចូលបញ្ហាជួញដូរជាមួយបញ្ហាមុខរបរផ្លូវភេទ

អំពើជួញដូរស្ត្រី និងកុមារ សម្រាប់ពេស្យាចារ គឺជាបញ្ហាមួយនៅក្នុងប្រទេសកម្ពុជា ដែលដុតបញ្ឆេះដោយអំពើពុករលួយ និងការខ្វះឆន្ទះនយោបាយក្នុងការនាំខ្លួនជនជួញដូរមនុស្សមកផ្ដន្ទាទោស។ ថ្វីបើមានកិច្ចប្រឹងប្រែងរបស់រដ្ឋាភិបាល និងអង្គការ មិនមែនរដ្ឋាភិបាល ក្នុងការលើកកម្ពស់ការយល់ដឹង និងការពារជនរងគ្រោះនៃ ការជួញដូរក៏ដោយ ក៏ស្ត្រី និងកុមារ នៅតែបន្តទទួលរងនូវការជួញដូរ ក្នុងប្រទេស កម្ពុជាដដែល។

កិច្ចប្រឹងប្រែងប្រឆាំងការជួញដូរមនុស្ស មានទាំងផលវិបាកជាវិជ្ជមាន និងផលវិបាក ជាអវិជ្ជមាន។ គំនិតផ្ដួចផ្ដើមមួយចំនួនរបស់រដ្ឋាភិបាល បានផ្ដោតលើបញ្ហាការ ជួញដូរ និងបញ្ហាមុខរបរផ្លូវភេទរួមបញ្ចូលគ្នាតែម្ដង និងបានស្វះស្វែងលុបបំបាត់ មុខរបរផ្លូវភេទ ថាជាមធ្យោបាយ ក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរ។ នៅក្នុង ឆ្នាំ២០០៧ ក្រសួងមហាផ្ទៃបានដឹកនាំយុទ្ធនាការប្រឆាំងនឹងការជួញដូរ និងមុខរបរ ផ្លូវភេទ ដែលយុទ្ធនាការនោះ បានតម្រូវឲ្យនគរបាលបង្ក្រាបទីកន្លែងកម្សាន្តនានា ជាទីកន្លែងដែលស្ត្រី និងកុមារលក់ភេទ។ នគរបាល និងមន្ត្រីដទៃទៀតក្នុងរាជធានី ភ្នំពេញ បានដឹកនាំជាទ្រង់ទ្រាយធំនូវការបង្ក្រាប និងបោសសម្អាត ស្ត្រីប្រកបរបរ ផ្លូវភេទចេញពីដងផ្លូវ និងសួនច្បារនៃរាជធានីភ្នំពេញ។ នគរបាលបានបិទផ្ទះបន ជាច្រើនកន្លែងក្នុងប្រទេសផងដែរ។

*ក្នុងខែកុម្ភៈ ឆ្នាំ២០០៨ ប្រទេសកម្ពុជាបានអនុម័តច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរ មនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដោយមានការជំរុញទឹកចិត្តពីម្ចាស់ជំនួយ បរទេស ជាពិសេស សហរដ្ឋអាមេរិក។ រដ្ឋបាលសហរដ្ឋអាមេរិកក្នុងរជ្ជកាល លោក ប៊ូស កាលនោះ បានជំរុញប្រទេសកម្ពុជាឲ្យអនុម័តច្បាប់ប្រឆាំងការជួញដូរ ដ៏ទូលំ ទូលាយមួយ តាមរយៈ ការវាយតម្លៃប្រចាំឆ្នាំ លើបញ្ហាជួញដូរមនុស្សនៅក្នុងប្រទេស កម្ពុជា របស់ក្រសួងការបរទេសសហរដ្ឋអាមេរិក។*

*ច្បាប់ប្រឆាំងការជួញដូរមនុស្ស មានចំណុចវិជ្ជមានខ្លះក្នុងការស្វះស្វែងដាក់ជាបទ ព្រហ្មទណ្ឌលើសកម្មភាពជាក់លាក់ ស្របតាមបទដ្ឋានអន្តរជាតិ រួមទាំង ការរំលោភ ផ្លូវភេទដោយបង្ខំ និងទម្រង់ការរំលោភបង្ខំដទៃទៀត។ ទោះជាយ៉ាងណាក៏ដោយ ទិដ្ឋភាពនៃច្បាប់នេះ ដែលដាក់ជាបទព្រហ្មទណ្ឌលើការរំលោភផ្លូវភេទ មានឥទ្ធិពល អវិជ្ជមានច្រើន ដែលសម្របសម្រួលឲ្យនគរបាល ប្រព្រឹត្តអំពើឃោរឃៅ អំពើហិង្សា និងការជំរិតទារប្រាក់ពីអ្នកប្រកបរបរផ្លូវភេទ ពីជនដែលត្រូវគេជួញដូរ និងកុមារ ក្នុងមុខរបរផ្លូវភេទ។ បទប្បញ្ញត្តិព្រហ្មទណ្ឌស្តីពី "អំពើអូសទាញ" ប្រព្រឹត្តដោយ អ្នកប្រកបរបរផ្លូវភេទជានីតិជន និងនិយមន័យដ៏ទូលំទូលាយស្តីពី "សញ្ចារកម្ម" ដែលគ្របដណ្តប់លើសកម្មភាពទាំងឡាយទាក់ទងនឹង "ការជួយ ឬការពារអំពើ ពេស្យាចាររបស់ជនដទៃ" រួមទាំងអំពើ "រារាំងដល់ការបង្ការ ការជួយ ឬការអប់រំ ជាថ្មី" របស់អ្នកប្រកបរបរផ្លូវភេទ គឺធ្វើអោយប្រឈមនឹងការជាប់ទោសពីបទ ព្រហ្មទណ្ឌ ចំពោះការអនុវត្តសិទ្ធិមូលដ្ឋានស្របច្បាប់ ដូចជាសកម្មភាពស្វែងរក ការគាំទ្រដ៏ជាក់លាក់ចំពោះអ្នកប្រកបរបរផ្លូវភេទ ឬសកម្មភាពអប់រំផ្សព្វផ្សាយ ។ បទល្មើសបន្ថែមទាំងនេះដែលមានចែងក្នុងច្បាប់ បានផ្តល់នូវហេតុផលសំអាង បន្ថែមទៀត សម្រាប់ឲ្យមានការបោសសម្អាតកាន់តែខ្លាំងខ្លាឡើងៗក្នុងឆ្នាំ២០០៨ និង ឆ្នាំ២០០៩។ ក៏ប៉ុន្តែ ទោះជាមានការផ្តោតកិច្ចខិតខំប្រឹងប្រែងប្រឆាំងនឹងការជួញដូរមនុស្សក៏ដោយ ក៏គ្មានករណី នៃការចាប់ខ្លួនណាមួយ ដែលស៊ើបអង្កេតដោយអង្គការ ឃ្លាំមើលសិទ្ធិមនុស្ស*

ត្រូវបាននគរបាលប៉ុនប៉ង ដើម្បីបែងចែករវាងស្ត្រី និងកុមារ ក្នុងមុខរបរផ្លូវភេទដោយស្ម័គ្រចិត្ត និងអ្នកទាំងឡាយដែលជាជនរងគ្រោះនៃ ការជួញដូរទេ។ អ្នកប្រកបរបរផ្លូវភេទងាយទទួលរងនូវការចាប់ឃុំឃាំងពីនគរបាល និងបញ្ជូនទៅកាន់មន្ទីរសង្គមកិច្ចរាជធានី ហើយជាយថាហេតុ បញ្ជូនបន្តទៅកាន់មណ្ឌលរបស់អង្គការក្រៅរដ្ឋាភិបាល ឬមណ្ឌលសង្គមកិច្ចព្រៃស្ពឺ។

មុនពេលអនុម័តច្បាប់ឆ្នាំ២០០៨ នគរបាលដែលចាប់អ្នកប្រកបរបរផ្លូវភេទ មិនអាច ចោទប្រកាន់ពួកគេពីបទអូសទាញទេ ពីព្រោះតែវាមិនមែនជាបទល្មើស។ ច្បាប់ប្រឆាំងការជួញដូរពីមុនរបស់ប្រទេសកម្ពុជា គឺច្បាប់ឆ្នាំ១៩៩៦ ស្តីពីការបង្ក្រាប អំពើពង្រត់ និងលក់ដូរមនុស្ស និងអំពើធ្វើអាជីវកម្មលើមនុស្ស បានដាក់ទោសជាបទព្រហ្មទណ្ឌចំពោះភាគីទីបីដែលពាក់ព័ន្ធ ក្នុងអំពើពេស្យាចារដូចជា មេបន និង "ការបើកទីកន្លែងប្រព្រឹត្តអំពើអនាចារ ឬអំពើអាសអាភាស។"

ចាប់តាំងពីច្បាប់ឆ្នាំ២០០៨ ចូលជាធរមានមក មន្ត្រីនគរបាល តែងតែគំរាមកំហែង ប្រើប្រាស់នូវបទបញ្ញត្តិស្តីពី "អំពើអូសទាញ" ជាមធ្យោបាយដើម្បីជំរិតយកលុយពីអ្នកប្រកបរបរផ្លូវភេទ ដោយប្រាប់ពួកគេថា ប្រសិនបើពួកគេមិនឲ្យលុយទេ ពួកគេអាចជាប់គុក ឬបញ្ជូនដោយបង្ខំទៅកាន់មណ្ឌលរបស់រដ្ឋាភិបាល ពីព្រោះការងាររបស់ពួកគេខុសច្បាប់។ ជាក់ស្តែង មានភស្តុតាងតិចតួចណាស់ដែលថា បទប្បញ្ញត្តិនេះត្រូវបានគេអនុវត្តតាមអ្វី ដូចដែលវាបានចែង ឬមានការនាំអ្នកប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិច្បាប់នេះមកកាត់ទោស។ ផ្ទុយទៅវិញ ច្បាប់នេះហាក់ដូចជាត្រូវបានប្រើប្រាស់ជាចម្បង ដោយនគរបាល ដើម្បីជាមធ្យោបាយដោះសារយ៉ាងងាយស្រួលសំរាប់ប្រព្រឹត្តសកម្មភាពខុសច្បាប់ទៅលើអ្នកប្រកបរបរផ្លូវភេទជាបន្តទៀត។

ក្នុងឆ្នាំ២០០៨ សកម្មជនខាងការងារមេរោគអេដស៍/ជំងឺអេដស៍ បុគ្គលិកខាងការងារសុខភាព និងក្រុមអ្នកប្រកបរមុខរបរផ្លូវភេទ បានលើកកង្វល់អំពីការកើនឡើងនៃ

*អំពើរំលោភបំពានពីអាជ្ញាធរ និងការលំបាករបស់ពួកគេ ក្នុងការចូលទៅប្រាស្រ័យអ្នកប្រកបរបរផ្លូវភេទ - ដែលពួកគេភាគច្រើនត្រូវបង្ខំចិត្ត ឲ្យប្រកបរបរនេះដោយលាក់ កំបាំង ពីព្រោះតែភ័យខ្លាចការចាប់ខ្លួន។*

*ដើម្បីដោះស្រាយកង្វល់របស់អ្នកប្រកបរបរផ្លូវភេទ និងរបស់សកម្មជននានា អំពីបញ្ហារំលោភបំពាន រួមទាំង បញ្ហាទាំងឡាយដែលជាលទ្ធផលចេញមកពីច្បាប់ថ្មីនៅក្នុងខែវិច្ឆិកាឆ្នាំ២០០៨ ក្រុមការងារអន្តរក្រសួងប្រឆាំងការជួញដូរមនុស្សកំរិតខ្ពស់របស់រដ្ឋាភិបាលបានចេញ "គោលការណ៍ណែនាំស្តីពីការអនុវត្តច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។" យោងតាមគោលការណែនាំនេះ សិទ្ធិរបស់ជនរងគ្រោះនៃអំពើជួញដូរ និងសិទ្ធិរបស់បុគ្គលពេស្យាចារត្រូវតែគោរព។ គោលការណ៍នេះចែងថាបុគ្គលពេស្យាចារ ត្រូវចាត់ទុកជា "ជនរងគ្រោះនៃអំពើសញ្ចារកម្ម។ អំពើពេស្យាចារមិនមែនជាបទល្មើសទេ ដូច្នេះអ្នកប្រកបរបរពេស្យាចារផ្ទាល់ខ្លួន ពុំត្រូវទទួលការផ្តន្ទាទោសក្រោមច្បាប់ថ្មីនេះឡើយ។"*

*ខណៈពេលដែលកិច្ចខិតខំប្រឹងប្រែងទាំងនេះមានលក្ខណៈវិជ្ជមាន ក្នុងការផ្តល់ទិសដៅខ្លះៗអំពីរបៀបនៃការអនុវត្តច្បាប់នេះ បែរជាគោលការណ៍នេះមិនលើកយកបទប្បញ្ញត្តិស្តីពីអំពើអូសទាញ មកនិយាយពន្យល់ទៅវិញ ហើយជានិច្ចកាលការអនុវត្តនៅតែជាបញ្ហាដដែល។ សេចក្តីពន្យល់ច្បាប់ឆ្នាំ២០០៨ ស្ថិតក្នុងដំណើរការបង្កើតផងដែរ។*

*សហរដ្ឋអាមេរិក គឺជាប្រទេសម្ចាស់ជំនួយមួយនៃបណ្តាប្រទេសម្ចាស់ជំនួយទ្វេភាគី ដ៏ធំបំផុតនានារបស់ប្រទេសកម្ពុជា និងជាប្រទេសគាំទ្រដ៏ចម្បងលើកិច្ចប្រឹងប្រែង ប្រឆាំងការជួញដូរមនុស្ស។ ស្ថិតក្រោមរដ្ឋបាលរដ្ឋកាលលោកប៊ូស សហរដ្ឋអាមេរិក មានការទទួលខុសត្រូវមួយចំនួនក្នុងគាំទ្រ និងជំរុញឲ្យប្រតិបត្តិច្បាប់ ដែលដាក់ ទោសជាបទល្មើសព្រហ្មទណ្ឌលើអ្នកប្រកបរបរផ្លូវភេទ ដោយមិនពិចារណាឲ្យបាន គ្រប់គ្រាន់លើបរិបទនៅមូលដ្ឋាន*

*- បរិបទមួយដែលនគរបាលមានប្រវត្តិប្រព្រឹត្ត អំពើរំលោភបំពានជាយូរអង្វែងមកហើយ ទៅលើអ្នកប្រកបរបរផ្លូវភេទ ជាមួយនឹង និទណ្ឌភាព។*

*ប្រទេសកម្ពុជាញាំញី មិនត្រឹមតែដោយការរំលោភដ៏រីករាលដាល ប្រព្រឹត្តដោយមន្ត្រី នានាប៉ុណ្ណោះទេ ប្រទេសនេះថែមទាំងមាននិទណ្ឌភាពសម្រាប់ជនប្រព្រឹត្តល្មើស ផងដែរ។ មកទល់សព្វថ្ងៃនេះ មិនមែនមានតែមន្ត្រីនគរបាលតែមួយទេ ដែលជាអ្នក ត្រូវទទួលខុសត្រូវ ចំពោះបទល្មើសដែលប្រព្រឹត្តលើអ្នកប្រកបរបរផ្លូវភេទ គឺមាន ឆ្មាំសន្តិសុខ មន្ត្រីរដ្ឋាភិបាល ឬនិយោជិតនៅមជ្ឈមណ្ឌលសង្គមកិច្ចរបស់ក្រសួង សង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទាផងដែរ។  ការរំលោភអំណាច និងអំពើ និទណ្ឌភាពដ៏រីករាលដាល បាននាំឲ្យជនរងគ្រោះ រួមទាំងអ្នកប្រកបរបរផ្លូវភេទ ដែលត្រូវបានរំលោភបំពានដោយនគរបាល ឬអាជ្ញាធរដទៃទៀត មានការភ័យខ្លាច ឬមានជំនឿតិចតួចលើប្រព័ន្ធយុត្តិធម៌ ដើម្បីដាក់ពាក្យបណ្ដឹងព្រហ្មទណ្ឌ។ អំពើ និទណ្ឌភាព ជារឿងធម្មតាទៅហើយ នៅក្នុងប្រទេសកម្ពុជា តែបញ្ហានិទណ្ឌភាព នេះនៅតែមិនទាន់ត្រូវ បានបំបាត់ចោលបាននៅឡើយ ដើម្បីដាក់ជំនួសមកវិញនូវ នីតិរដ្ឋជាដរាបរៀងទៅ។*

*ចំពោះសាវតានេះ ប្រទេសកម្ពុជា គួរតែពិនិត្យមើលឡើងវិញនូវច្បាប់ និងគោលនយោបាយនានារបស់ខ្លួន ទាក់ទងនឹងការជួញដូរមនុស្ស និងការងារខាងការប្រកប របរផ្លូវភេទ។ ជាជាង ការការពារជនរងគ្រោះនៃអំពើល្មើស ដូចជាបទល្មើសជួញដូរ និងពេស្យាកម្មដោយបង្ខំ ច្បាប់ និងគោលនយោបាយទាំងនេះ តែងតែត្រូវបានមន្ត្រី រំលោភអំណាច កេងយកផលប្រយោជន៍ ។*

## អនុសាសន៍សំខាន់ៗ

*អង្គការឃ្លាំមើលសិទ្ធិមនុស្ស សូមផ្ដល់អនុសាសន៍ដល់រដ្ឋាភិបាលកម្ពុជាដូចតទៅ ៖*

- *បញ្ឈប់ការចាប់ខ្លួន និងឃុំខ្លួនដោយបំពានលើ អ្នកប្រកបរបរផ្លូវភេទ - រួមទាំង ស្ត្រី បុរស កុមារ និងស្រីស្រស់ដែលប្រកបរបរផ្លូវភេទ - ជនរងគ្រោះនៃ អំពើ ជួញដូរ និងអ្នកដទៃទៀត រួមទាំង អ្នកប្រើប្រាស់គ្រឿង ញៀន អ្នកគ្មានផ្ទះ សម្បែង អ្នកសុំទាន កុមារអនាថា និងអ្នកជំងឺវិកលចរិត។*

- *បង្កើតគណៈកម្មាការពិសេសមួយ ដើម្បីស៊ើបអង្កេតហ្មត់ចត់ និងឯករាជ្យទៅលើ អំពើហិង្សា និង ការជំរិតទារលុយទាំងអស់ ដែលប្រព្រឹត្តដោយមន្ត្រីប្រតិបត្តិ ច្បាប់ ថ្នាំសន្តិសុខការពារសួនច្បារ និងបុគ្គលិក ឬអ្នកស្ម័គ្រចិត្តក្នុងមណ្ឌល សង្គមកិច្ច។ គណៈកម្មាការនេះ គួរតែបង្កើតឡើងភ្លាម មានអំណាចកោះហៅ សាក្សី និងផលិតរបាយការណ៍សាធារណៈ។ គណៈកម្មាការគួរមានអំណាច ដាក់ចេញ នូវអនុសាសន៍ សម្រាប់ការស៊ើបអង្កេតខាងព្រហ្មទណ្ឌ ដើម្បីធ្វើឲ្យ ប្រាកដថា ជនប្រព្រឹត្តល្មើសនឹងត្រូវបាននាំមកផ្តន្ទាទោសចំពោះបទល្មើសរបស់ ពួកគេ។*

- *បិទមជ្ឈមណ្ឌលសង្គមកិច្ចព្រៃស្លី និងកោះគរជាស្ថាពរ រួមទាំងមណ្ឌល សង្គមកិច្ចដទៃទៀត ដែលបានឃុំឃាំងប្រជាពលរដ្ឋដោយរំលោភលើ ច្បាប់ជាតិ និងច្បាប់អន្តរជាតិ។*

- *ព្យួរការអនុវត្ត បទប្បញ្ញត្តិស្តីពី "អំពើអូសទាញ" ក្នុងច្បាប់ស្តីពីការបង្ក្រាបអំពើជួញ ដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទរហូតទាល់តែមានការ ដោះស្រាយចំពោះបញ្ហាដ៏រីករាលដាល នៃការរំលោភលើអ្នកប្រកបរបរផ្លូវភេទ។ បទបញ្ញត្តិនេះ ផ្តល់ឲ្យនគរបាលនូវអំណាចបន្ថែមដើម្បីជំរិតទាលុយ និង ប្រព្រឹត្តអំពើហិង្សាលើអ្នកប្រកបរបរផ្លូវភេទ និងសម្រួលឲ្យមានការរំលោភ។*

- *ពិគ្រោះយោបល់ជាមួយក្រុមអ្នកប្រកបរបរផ្លូវភេទ ដើម្បីរួមគ្នាបង្កើតកម្មវិធី និង សេវា ដែលអាចបង្កើនសមត្ថភាពដល់ អ្នកប្រកបរបរផ្លូវភេទ និង ទប់ទល់បញ្ហាំងយ៉ាង*

*ពិតប្រាកដពីសេចក្តីត្រូវការរបស់ពួកគេ។ សេចក្តីត្រូវការមានរួមទាំងជំនួយ ផ្នែកច្បាប់ ការថែទាំសុខភាព ការថែទាំកុមារ និងការហ្វឹកហ្វឺនវិជ្ជាជីវៈ ប្រសិនបើអ្នកប្រកបរបរផ្លូវភេទកំណត់ថាវាពាក់ព័ន្ធសម្រាប់ពួកគេ។*

# II. វិធីសាស្ត្រ

*របាយការណ៍នេះធ្វើឡើង ដោយផ្អែកលើការស្រាវជ្រាវក្នុងប្រទេសកម្ពុជា នៅចន្លោះខែកក្កដា ឆ្នាំ២០០៩ និង ខែមេសា ឆ្នាំ២០១០។ ការសម្ភាសន៍ពិស្តារ គឺធ្វើឡើងជាភាសា ខ្មែរជាមួយនឹងអ្នកប្រកបរបរផ្លូវភេទនៅក្នុងរាជធានីភ្នំពេញ និងនៅក្នុងខេត្ត បាត់ដំបង បន្ទាយមានជ័យ និងសៀមរាប។ យើងបានជួបអ្នកប្រកបរបរផ្លូវភេទ ចំនួន៩៤ នាក់ ដែលមានអាយុរវាងពី១៦ឆ្នាំ និង៤៥ឆ្នាំ នៅតាមដងវិថី សួនច្បារ ផ្ទះបន និងបន្ទប់ដែលពួកគេជួលសម្រាប់រស់នៅ និងនៅក្នុងការិយាល័យអង្គការ មិនមែនរដ្ឋាភិបាល ដែលធ្វើការជាមួយអ្នកប្រកបរបរផ្លូវភេទ។ ការសម្ភាសន៍នេះ មានរាប់បញ្ចូលទាំងស្រីស្រស់ប្រកបរបរផ្លូវភេទផងដែរ។ មិនមានការប៉ុនប៉ង ណាមួយ ដើម្បីសម្ភាសន៍បុរសប្រកបរបរផ្លូវភេទទេ ពីព្រោះការសម្ភាសន៍បឋម ជាមួយអ្នកប្រកបរបរផ្លូវភេទ និងក្រុមសិទ្ធិមនុស្ស បានចង្អុលបង្ហាញថា បុរសប្រកបរបរផ្លូវភេទ មិនត្រូវបានគេ បោសសម្អាត និងបង្ក្រាបទេ ដូច្នេះ របាយការណ៍នេះមិនបានផ្ដោតលើក្រុមនេះឡើយ។*

*យ៉ាងហោចណាស់ អ្នកដែលបានសម្ភាសន៍ចំនួន ៥ នាក់គឺជាកុមារ។*[2] *កុមារបីនាក់បានប្រាប់អង្គការឃ្លាំមើលសិទ្ធិមនុស្សថា ពួកគេមានអាយុ ១៨ ឆ្នាំ ប៉ុន្តែឯកសាររបស់ពួកគេបង្ហាញថាពួកគេមានអាយុ ១៦ ឬ១៧ ឆ្នាំតែប៉ុណ្ណោះ។ ពីព្រោះតែយើងមិនមានលទ្ធភាពពិនិត្យផ្ទៀងផ្ទាត់ឯកសាររបស់អ្នកប្រកបរបរផ្លូវភេទទាំងអស់ ដែលយើងបានសម្ភាសន៍ វាអាចមាន អ្នកដទៃៗទៀត គឺជាកុមារផងដែរ ក៏ប៉ុន្តែពួកគេ*

2 នៅក្នុងរបាយការណ៍នេះ ពាក្យថា “កុមារី” និងពាក្យថា “កុមារ” គឺនិយាយសំដៅទៅរកជនទាំងឡាយដែលមានអាយុក្រោម ១៨ ឆ្នាំ។ អនុសញ្ញាស្ដីពីសិទ្ធិកុមារចែងថា “សម្រាប់គោលបំណងនៃអនុសញ្ញានេះ កុមារគឺជាមនុស្សមានអាយុក្រោម ១៨ ឆ្នាំ លើកលែងតែក្រោមច្បាប់ដែលត្រូវអនុវត្តចំពោះកុមារ នីតិភាពត្រូវបានកំណត់ទាបជាងនេះ។” អនុសញ្ញាស្ដីពីសិទ្ធិកុមារ (CRC), បានអនុម័តនៅថ្ងៃទី២០ វិច្ឆិកា ១៩៨៩ តាមសេចក្ដីសម្រេចចិត្តរបស់មហាសន្និបាតលេខ 44/25, ឧបសម្ព័ន្ធ, 44 អ.ស.ប GAOR Supp. (No. 49) លេខ 167, U.N. Doc. A/44/49 (1989), ចូលជាធរមានថ្ងៃទី២ ខែកញ្ញា ឆ្នាំ១៩៩០, កម្ពុជាចូលជាសមាជិកនៅថ្ងៃទី ១៥ តុលា ១៩៩២។

បង្ហាញខ្លួនឯងថាមានអាយុច្រើន ពីព្រោះតែពួកគេភ័យខ្លាចថា ត្រូវគេបញ្ជូនទៅកាន់មណ្ឌលសំរាប់កុមារ។ យ៉ាងហោចណាស់មាន នីតិជនដែលត្រូវបានសម្ភាសន៍ប្រាំមួយនាក់  គឺជាកុមារនៅពេលដែលពួកគេចូលទៅក្នុងការងារផ្លូវភេទ ពីដំបូង និងយ៉ាងហោចណាស់ក៏មានម្នាក់ដែរ ដែលមានវ័យ ១៣ឆ្នាំ។ ការងារ ផ្លូវភេទគឺជាទម្រង់ដ៏អាក្រក់បំផុតមួយនៃទម្រង់ដ៏អាក្រក់បំផុតទាំងឡាយ នៃពលកម្ម កុមារ និងហេតុដូច្នេះ ត្រូវហាមឃាត់សម្រាប់អនីតិជន។

ចំណោមអ្នកប្រកបរបរផ្លូវភេទទាំង៩៤ នាក់ ដែលយើងបានជួប យើងបានសម្ភាសន៍ពិស្តារជាបុគ្គលជាមួយអ្នកប្រកបរបរផ្លូវភេទចំនួន ៥១ នាក់ និងបានសន្ទនា និងពិភាក្សាជាក្រុម ជាមួយអ្នកប្រកបរបរផ្លូវភេទចំនួន ៤៣នាក់។

នៅក្នុងរាជធានីភ្នំពេញ យើងបាន សម្ភាសន៍ពិស្តារជាបុគ្គលជាមួយអ្នកប្រកបរបរផ្លូវភេទចំនួន ៣៨ នាក់ រួមទាំងស្រីស្រស់ចំនួន ៤ នាក់ផងដែរ។ យើងបានធ្វើការពិភាក្សាជាក្រុមជាមួយអ្នកប្រកបរបរផ្លូវភេទចំនួនពីរក្រុម និងស្ត្រីទទួលភ្ញៀវតាម រង្គសាលដែលគេបញ្ជូនទៅកាន់មណ្ឌលអង្គការក្រៅរដ្ឋាភិបាល ពីមន្ទីរសង្គមកិច្ចរាជធានី[3] និងជាមួយសមាជិកសមាគមអ្នកប្រកបរបរផ្លូវភេទ និងអង្គការមិនមែនរដ្ឋាភិបាលដទៃទៀត ដែលគាំទ្រសិទ្ធិរបស់អ្នកប្រកបរបរផ្លូវភេទ។

នៅក្នុងខេត្តបាត់ដំបង បន្ទាយមានជ័យ និងសៀមរាប អង្គការឃ្លាំមើលសិទ្ធិមនុស្សបានសម្ភាសន៍ពិស្តារជាបុគ្គលជាមួយអ្នកប្រកបរបរផ្លូវភេទចំនួន ១៣ នាក់ និងបានធ្វើកិច្ចសន្ទនាជាមួយ អ្នកប្រកបរបរផ្លូវភេទជាច្រើននាក់នៅតាមសួនច្បារ និងនៅតាមដងវិថី។ អង្គការឃ្លាំមើលសិទ្ធិមនុស្ស បានសម្ភាសន៍អ្នកតំណាងនានាមកពីអង្គការសហប្រជាជាតិ ម្ចាស់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើការលើ

---

3 ស្ត្រីធ្វើការជាអ្នកទទួលភ្ញៀវក្នុងរង្គសាលត្រូវបានចាប់ខ្លួន អំឡុងពេលមានការឆ្មក់ចូលក្នុងរង្គសាលដោយនគរបាលប្រឆាំងការជួញដូរ។ ពួកគេត្រូវបានគេបញ្ជូនទៅមន្ទីរសង្គមកិច្ចរាជធានីភ្នំពេញ និងនៅថ្ងៃបន្ទាប់ បញ្ជូនទៅកាន់ជម្រករបស់អង្គការមិនមែនរដ្ឋាភិបាល។

ការរំលោភផ្លូវភេទ ការរំលោភប្រឆាំងការជួញដូរ និងសិទ្ធិមនុស្ស រួមទាំងអង្គការនានាដែល គ្រប់គ្រងមណ្ឌលស្នាក់នៅផងដែរ។

ឈ្មោះ និងអត្តសញ្ញាណពិស្តារ របស់អ្នកទាំងឡាយដែលយើងបានជួប មិនត្រូវបាន បង្ហាញក្នុងរបាយការណ៍នេះទេដើម្បីការពារសុវត្ថិភាពរបស់ពួកគេ។ យើងប្រើ ឈ្មោះក្លែង សម្រាប់អ្នកប្រកបរបរផ្លូវភេទ ដែលបាននិយាយនៅក្នុងរបាយការណ៍នេះ។ អ្នកទាំងអស់ដែលបានសម្ភាសន៍ ត្រូវបានប្រាប់អំពីគោលបំណងនៃកិច្ចសម្ភាសន៍ ភាពស្ម័គ្រចិត្តនៃអ្នកផ្តល់សម្ភាសន៍ និងអំពីមធ្យោបាយនៃការប្រើប្រាស់ព័ត៌មាន។ អ្នកផ្តល់សម្ភាសន៍ទាំងអស់ បានផ្តល់ការយល់ព្រមដោយផ្ទាល់មាត់ឲ្យសម្ភាសន៍។ អ្នកទាំងអស់ ត្រូវបានជម្រាបឲ្យដឹងថា ពួកគេអាចមិនឆ្លើយសំណួរ ឬអាចស្នើរ បញ្ឈប់សម្ភាសន៍នៅពេលណាក៏បាន។

ប្រភពផ្សេងទៀតដែលយើងបានពិគ្រោះយោបល់ជាមួយ រួមមានឯកសារ ច្បាប់ និងគោលនយោបាយរបស់រដ្ឋាភិបាលកម្ពុជា របាយការណ៍របស់អង្គការមិនមែន រដ្ឋាភិបាល អត្ថបទព័ត៌មានពីបណ្តាញព័ត៌មានជាតិ និងអន្តរជាតិ និងកំណត់ហេតុ សម្ភាសន៍ពី អង្គការសិទ្ធិមនុស្សនៅក្នុងប្រទេស។

ការស្រាវជ្រាវនេះ បានផ្តោតជាពិសេសទៅលើការរំលោភបំពាន ដែលប្រព្រឹត្តដោយ នគរបាល ឆ្មាំសន្តិសុខការពារសួនច្បារសាធារណៈ និងបុគ្គលិកដែលធ្វើការនៅតាម មណ្ឌល និងមន្ទីររបស់ក្រសួងសង្គមកិច្ច។ វាហួសពីទំហំនៃរបាយការណ៍នេះ ដើម្បី ពិចារណាអំពីអំពើជួញដូរ អំពើហិង្សានិងអំពើរំលោភដទៃៗទៀត ដែលអ្នកប្រកបរបរ ផ្លូវភេទជួបប្រទះ នៅពេលស្ថិតក្នុងកណ្តាប់ដៃរបស់អតិថិជន ឬជនដទៃទៀត ហើយ យើងក៏មិនបានស្រាវជ្រាវជាក់លាក់អំពីការអនុវត្តរបស់រដ្ឋាភិបាល ស្របតាមការ ទទួលខុសត្រូវរបស់ខ្លួន ដើម្បីការពារកុមារពីអំពើពេស្យាចារ និងដើម្បីកំណត់ និង ដកយកកុមារដែលពាក់ព័ន្ធ ចេញពីការរំលោភផ្លូវភេទ និងផ្តល់ជំនួយសមស្របដល់ ពួកគេ ។

*អង្គការឃ្លាំមើលសិទ្ធិមនុស្ស បានស្វះស្វែងរកការពន្យល់ពីរដ្ឋាភិបាលកម្ពុជាក្នុងលិខិតមួយ ដែលបានផ្ញើជូនទៅក្រសួងមហាផ្ទៃ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា នៅថ្ងៃទី១៩ ខែមេសា ដែលស្នើសុំព័ត៌មាន និងសុំការឆ្លើយតប ចំពោះអំពើរំលោភទាំងឡាយ ដែលយើងបានចងក្រងទុកជាឯកសារ។ លិខិតនេះ មានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ ១ ។ ចំពោះការសរសេរលិខិតនេះ អង្គការឃ្លាំមើលសិទ្ធិ មនុស្សមិនបានទទួលការឆ្លើយតបទេ។*

# III. ការជួញដូរផ្លូវភេទនៅក្នុងប្រទេសកម្ពុជា

## ចំនួន និងដើមហេតុ

*ការដោះដូរផ្លូវភេទដើម្បីប្រាក់ បានប្រព្រឹត្តទៅអស់ពេលជាច្រើនទសវត្សរ៍មកហើយ នៅក្នុងប្រទេសកម្ពុជា។ នៅក្នុងអំឡុងរបបឃោរឃៅខ្មែរក្រហមពីឆ្នាំ១៩៧៥-១៩៧៩ ខ្មែរក្រហមបានលប់បំបាត់ទាំងស្រុងនូវការជួញដូរផ្លូវភេទ។ នៅពេលនោះ ខ្មែរក្រហមបានព្យាយាមប្រើកម្លាំងបង្កើតសង្គមកសិករស្មើភាពមួយ- ដោយសម្លាប់វរជន បញ្ញាជន និងជនគ្រប់រូបដែលគេសង្ស័យពីសកម្មភាពទីផ្សារសេរី។ ប្រជាពលរដ្ឋកម្ពុជា ប្រហែល ១.៥ លាននាក់ ត្រូវបានសម្លាប់។ សកម្មភាពណាក៏ដោយ ដែលគេចាត់ ទុកថា ខុសសីលធម៌ រួមទាំងពេស្យាចារ ការរួមភេទមុនរៀបអាពាហ៍ពិពាហ៍ ការរួមភេទរវាងដៃគូភេទដូចគ្នា និងអំពើផិតក្បត់ប្តីឬប្រពន្ធ ត្រូវបានដាក់ទណ្ឌកម្ម ដោយប្រហារជីវិត។*

*ក្នុងអំឡុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា (១៩៧៩-១៩៨៩) ជាពេលដែលប្រទេសកម្ពុជាកាន់កាប់ដោយ កងទ័ពវៀតណាម ការជួញដូរផ្លូវភេទត្រូវបានគេគ្រប់គ្រងយ៉ាងតឹងរឹងបំផុត។ ជាធម្មតា រដ្ឋអំណាចបានចាប់និងឃុំឃាំងអ្នកប្រកបរបរផ្លូវភេទ ដោយការបញ្ជូនពួកគេទៅកាន់កន្លែងដែលជាអតីតមន្ទីរឃុំឃាំងរបស់ខ្មែរក្រហមនៅកោះគរ ស្ថិតក្នុងភូមិកោះគរ ខេត្តកណ្តាល។ តាំងពីឆ្នាំ១៩៨១ កន្លែងនោះគ្រប់គ្រងដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ មកទល់នឹងឆ្នាំ២០០៨ ក្រសួងនេះបានប្រើប្រាស់កន្លែងនោះ ដើម្បីឃុំខ្លួនអ្នកប្រកបរបរផ្លូវភេទ (សូមមើលចំណងជើងរងស្តីពី "ការរំលោភបំពាននៅមជ្ឈមណ្ឌលសង្គមកិច្ចរបស់រដ្ឋាភិបាល" ក្នុងផ្នែកទី IV)។*

*ជាមួយនឹងការមកដល់របស់បុគ្គលិករក្សាសន្តិភាពជាច្រើនពាន់នាក់ក្នុងឆ្នាំ១៩៩២ ដែលជាផ្នែកមួយនៃអាជ្ញាធរបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិនៅកម្ពុជា (អ៊ុនតាក់)*

*ការងារផ្លូវភេទអាចមើលឃើញច្រើនឡើងៗ ដោយមានសង្កាត់ភ្លើង ក្រហម បើកព្រោងព្រាតនៅតាមផ្នែកផ្សេងៗ នៃរាជធានីភ្នំពេញ និងខេត្ត ហើយ ដែលវាមានតម្រូវការសេវាផ្លូវភេទពី បុរសបរទេស និងបុរសក្នុងស្រុក។*

*អ្នកប្រកបរបរផ្លូវភេទ ដែលធ្វើការក្នុងផ្ទះបន ជាទូទៅ ត្រូវបានគេនិយាយថាជាអ្នកប្រកបរបរផ្លូវភេទ "ដោយផ្ទាល់" នៅក្នុងប្រទេសកម្ពុជា។ ធម្មតា ផ្ទះបនជាផ្ទះតូចមួយដែលជួល អ្នកប្រកបរបរផ្លូវភេទពី ១ ទៅ ២០ នាក់។ វាជាទូទៅត្រូវបានចាត់ចែងដោយអ្នកគ្រប់គ្រង ម្នាក់ដែលគេស្គាល់ផងដែរថាជាម៉ែយ៉ែម (ប្រសិនបើជាស្ត្រី)។ អ្នកប្រកបរបរផ្លូវភេទខ្លះ ត្រូវបានជួលដោយអ្នកគ្រប់គ្រងដោយផ្ទាល់ ឯអ្នកដទៃទៀតគ្រាន់តែជួលបន្ទប់ក្នុង ផ្ទះបន ដើម្បីប្រកបការងារបម្រើផ្លូវភេទ។ ផ្ទះបនជាច្រើនមានសញ្ញាដែលសរសេរថា "កន្លែងម៉ាស្សា និង/ឬ កោសជប់"។*[4]

*អ្នកប្រកបរបរផ្លូវភេទដោយផ្ទាល់ ក្នុងបន្ទប់ម៉ាស្សា (ដែលផ្តល់ទាំងសេវាម៉ាស្សា និង ផ្លូវភេទ) នៅក្នុងកន្លែងខារ៉ាអូខេ  តាមរង្គសាល ភោជនីយដ្ឋាន និងក្លិបរាត្រី។ កន្លែងទាំងនេះជាធម្មតា ជួលស្ត្រីអោយបំរើការងារ ដែលភ្ញៀវអាចយកចេញក្រៅបរិវេណ បានតាមតម្លៃឈ្នួលណាមួយ។ ការរួមភេទជាធម្មតាកើតឡើងនៅកន្លែងផ្សេងទៀត ដែលជាញឹកញាយគឺនៅក្នុងសណ្ឋាគារ។ នៅតំបន់ជនបទវិញ ហាងខារ៉ាអូខេ ជាញឹកញាយមាននៅផ្នែកខាងមុខនៃផ្ទះបន ហើយពួកគេអាចមានបន្ទប់នៅផ្នែកខាងក្រោយនៃជំនួញនេះ ដែលដំណើរការស្រដៀងគ្នានឹងផ្ទះបន។ ទន្ទឹមគ្នានេះដែរ មានអ្នកប្រកបរបរផ្លូវភេទដែលធ្វើការងាររបស់គេនៅតាមដងវិថី ឬនៅតាមសួន សាធារណៈ*

4 កោសជប់ ជាជម្រើសនៃវិធីព្យាបាលផ្សេងពីការព្យាបាលដោយឱសថ ដែលគេស្គាល់ជាទូទៅនៅអាស៊ីអាគ្នេយ៍ ដូចជាការធ្វើសសៃ ដែលគេប្រើប្រេងសម្រាប់លាបរឹតលើស្បែក ជាធម្មតាលាប លើទ្រូង ខ្នង ឬស្មា និងបន្ទាប់មកគេយកកាក់ឬសេនមកកោសខ្លាំងៗ លើកន្លែងនោះ។

ដោយឯករាជ្យ ឬដួនកាលធ្វើការឲ្យថៅកែ។ ស្ត្រីទទួលភ្ញៀវ ស្ត្រីចាប់សរសៃ ឬស្ត្រីលក់ស្រាបៀរ[5] អាចពាក់ព័ន្ធក្នុងការងារផ្លូវភេទម្តងម្កាលផងដែរ។[6]

មិនមានតួលេខជាក់លាក់អំពីចំនួនអ្នកប្រកបរបរផ្លូវភេទក្នុងប្រទេសកម្ពុជាទេ។ ការធ្វើការប៉ាន់ស្មានអំពីតួលេខនេះមានការលំបាក ជាពិសេស ដោយសារតែទិដ្ឋភាពជាច្រើននៃការងារខាងផ្លូវភេទ គឺជាការមិនស្របច្បាប់។ តួលេខខ្លះ បានការជឿជាក់តាមរយៈការប្រើតៗគ្នា ថ្វីបើវិធីសាស្ត្រនៃការបានតួលេខនេះមក មិនដែលមានការបញ្ជាក់ក៏ដោយ។[7] ការសិក្សាស្រាវជ្រាវមួយដោយ ថូម៉ាស ស្តេនហ្វាត ដែលផ្តល់មូលនិធិដោយ យូអេសអេអាយឌី (USAID) ក្នុងឆ្នាំ២០០៣ - ជាការសិក្សាមួយក្នុងចំណោមការសិក្សាមួយចំនួន ដោយប្រើ ការប៉ាន់ប្រមាណ បែបស្ថិតិ ផ្អែកលើការរាប់ចំនួនជាក់ស្តែង - បានសន្និដ្ឋានថាមានស្ត្រីប្រកបរបរផ្លូវភេទ ដោយផ្ទាល់ និងដោយប្រយោលប្រមាណជា ២០,៨២៩នាក់ នៅក្នុងប្រទេសកម្ពុជា ដោយមាន ៥,២៥០នាក់នៅក្នុងរាជធានីភ្នំពេញ។[8] តាមតួលេខនេះ ភាគច្រើនមាន អាយុពី ១៨ឆ្នាំឡើងទៅ។[9] របាយការណ៍ឆ្នាំ ២០០៦ របស់ក្រសួងសុខាភិបាល បាន និយាយថា

---

5 ក្នុងប្រទេសកម្ពុជា ស្ត្រីបម្រើស្រាបៀរជាទូទៅត្រូវបានគេស្គាល់ថាជា "នារីលក់ស្រាបៀរ" ដែលក្រុមហ៊ុនជួលឲ្យលក់ស្រាបៀរក្នុងហាងខារ៉ាអូខេ ភោជនីយដ្ឋាន និងរង្គសាល។

6 យូណេស្កូ (បាងកក) ចេន ឌែបែលយូ ដឺ លីន វ៉ាន វិចាអាដេន "ការរៀបចំការងារផ្លូវភេទក្នុង សម័យបច្ចុប្បន្ននៅកម្ពុជា ៖ ការជាប់ទាក់ទិននឹង ការបង្ការនិងការថែទាំមេរោគអេដស៍" ឆ្នាំ២០០២ គេហទំព័រ http://74.125.153.132/search?q=cache:zjw6_ZDdVsJ:www2.unescobkk.org/hivaids/fulltextdb/aspUploadFiles/Sex%2520work%2520paper%2520organization%2520and%2520AIDS.doc+different+types+of+sex+work+%22Cambodia%22&cd=3&hl=en&ct=clnk (បានចូលមើលគេហទំព័រនេះនៅថ្ងៃទី ១១ ខែមេសា ឆ្នាំ២០១០)។ ការងារផ្លូវភេទនៅក្នុងប្រទេសកម្ពុជា មានការរៀបចំក្នុងទំរង់ផ្សេងៗគ្នា៖ អ្នកប្រកបរបរផ្លូវភេទនៅតាមផ្ទះបន អ្នកប្រកបរបរផ្លូវភេទនៅតាមហាងខារ៉ាអូខេ អ្នកប្រកបរបរផ្លូវភេទនៅតាមដងវិថី អ្នកប្រកបរបរផ្លូវភេទឯករាជ្យ - អ្នកប្រកបរបរផ្លូវភេទ 'បែបឱកាសនិយម' អ្នកប្រកបរបរផ្លូវភេទដោយផ្ទាល់ និងដោយប្រយោល។

7 ស្តេនហ្វាត ធី "ការរាប់ចំនួនស្ត្រី និងកុមារដែលត្រូវបានគេជួញដូរក្នុងប្រទេសកម្ពុជា៖ ការចុះសិក្សាអង្កេតដោយផ្ទាល់" ដោយមានការឧបត្ថម្ភគាំទ្រពី USAID, រាជធានីភ្នំពេញ ថ្ងៃទី៦ ខែតុលា ឆ្នាំ២០០៣ ទំព័រ២។ មាននៅគេហទំព័រ http://slate.msn.com/Features/pdf/Trfciiif.pdf (បានចូលមើលនៅថ្ងៃទី១១ មេសា ២០១០)។ ការសិក្សានេះ និយាយយោងទៅរកតួលេខដែលមានការដកស្រង់ជាញឹកញយមកហើយ ក្នុងរបាយការណ៍នានារបស់អង្គការមិនមែនរដ្ឋាភិបាល គឺចំនួនរវាង 80,000 – 100,000 នៃស្ត្រីប្រកបរបរផ្លូវភេទក្នុងប្រទេសកម្ពុជា ដែលតួលេខនេះនៅតែជាចំណោទបញ្ហា ព្រោះតែការខ្វះខាតព័ត៌មានស្តីពីរបៀបដែលចំនួននេះត្រូវបានគេគណនា ។

8 ដូចគ្នា ទំព័រ២៥

9 ដូចគ្នា។ ការសិក្សានេះកត់ត្រាពីចំនួនសិក្សាជាគំរូប្រមាណ ៥,៣១៧ នាក់នៃស្ត្រីប្រកបរបរផ្លូវភេទ ដែលក្នុងនោះមាន ១៩៨នាក់ មានអាយុក្រោម ១៨ ឆ្នាំ ឬ ៣.៤ ភាគរយ។

ស្ត្រីប្រកបរបរផ្លូវភេទដោយផ្ទាល់មាន ៦,០០០ នាក់ និងស្ត្រីប្រកបរបរ ផ្លូវភេទដោយប្រយោលមាន ២៦,០០០ នាក់។[10] ស្ត្រីប្រកបរបរផ្លូវភេទជាច្រើននាក់ជា ជនជាតិវៀតណាម។[11] បន្ថែមលើនេះទៀត មានស្រីស្រស់ និងបុរសប្រកបរបរ ផ្លូវភេទ ប៉ុន្តែមិនមានតួលេខជាក់លាក់ទេ។

ខណៈពេលដែលស្ត្រីមួយចំនួនចូលប្រកបរបរផ្លូវភេទដោយស្ម័គ្រចិត្ត មានស្ត្រីដទៃទៀត ចូលក្នុងរបរនេះដោយការជួញដូរ ឬការបង្ខិតបង្ខំ។ ស្តេនហ្វាត ប៉ាន់ស្មានថា ក្នុងចំនួន ជាគំរូនៃចំនួនស្ត្រីប្រកបរបរផ្លូវភេទ ២០,៨២៩ នាក់ មាន ស្ត្រី និងកុមារ ២,៤៨៨ នាក់ ត្រូវបានគេ ជួញដូរដើម្បីការងារផ្លូវភេទក្នុងប្រទេសកម្ពុជា ឬប្រហែលជា ១២ ភាគរយ។ តួលេខនេះ ស្រដៀងគ្នានឹងការសិក្សាឆ្នាំ២០០៦ ដែលដឹកនាំដោយ វ៉ាយ សាយឌីន និង មាលា ក្នុង ចំណោមស្ត្រីនៅតាមផ្ទះបនចំនួន២៥០ នាក់ (ស្ត្រីទាំងអស់) ដែលបាន រកឃើញថា ១៤ ភាគរយត្រូវបានគេជួញដូរ ចំណែក៨៦ ភាគរយជ្រើសរើសការងារ ផ្លូវភេទដោយខ្លួនឯង។[12]

ប្រជាពលរដ្ឋចូលក្នុងការងារផ្លូវភេទ ដោយសារហេតុផលផ្សេងៗ ដែលមិនមែនដើម្បី តែហេតុផលនៃការងារនេះទេនៅកម្ពុជា។ ហេតុផលដ៏ចម្បងនោះគឺសេដ្ឋកិច្ច។ កម្ពុជាជាប្រទេសក្រីក្របំផុតមួយនៃប្រទេសក្រីក្របំផុតមួយចំនួននៅអាស៊ីអាគ្នេយ៍ ដែលស្ថិតនៅលំដាប់ទី ៨៧ ក្នុងចំណោមប្រទេស ១៣៥ លើលំដាប់លិបិក្រមរបស់ អង្គការសហប្រជាជាតិស្តីពីមនុស្សក្រីក្រ មានកំរិតក្រោម ប្រទេសភូមា ដែលស្ថិតនៅ លេខរៀងទី៧៧។[13] នៅប្រទេសកម្ពុជា ប្រជាពលរដ្ឋ៤០ភាគរយ រកចំណូលបានទាប ជាង

---

10 ក្រសួងសុខាភិបាល មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែកនិងកាមរោគ, របាយការណ៍សិក្ខាសាលាមតិទូទៅ, "ការវាយតម្លៃពី បញ្ហាមេរោគអេដស៍ និងការធ្វើនិទស្សសម្រាប់កម្ពុជា ២០០៦-២០១២" ថ្ងៃទី២៥-២៩ ខែមិថុនា ឆ្នាំ២០០៧។ មាននៅគេហទំព័រ http://data.unaids.org/pub/Report/2008/Cambodia_hiv_estimation_report_2006_en.pdf (បានចូលមើលនៅថ្ងៃទី១១ មេសា ២០១០)។

11 ស្តេនហ្វាត ធី "ការរាប់ចំនួនស្ត្រី និងកុមារដែលត្រូវបានគេជួញដូរក្នុងប្រទេសកម្ពុជា៖ ការចុះសិក្សាអង្កេតដោយផ្ទាល់" ថ្ងៃទី៦ ខែតុលា ឆ្នាំ២០០៣។

12 ចូណា វ៉ាយ, លិម សាយឌីន និង កែ កន្ថាមាលា, ស្ថានភាពស្ត្រីប្រកបរបរផ្លូវភេទ និងស្ត្រីបម្រើសេវាកម្សាន្តក្នុងប្រទេសកម្ពុជា ៖ ការរកឃើញចេញពីការ សិក្សាបែបបរិមាណ (ភ្នំពេញ៖ មជ្ឈមណ្ឌលសម្រាប់ការសិក្សាជាន់ខ្ពស់) ឆ្នាំ២០០៦។

13យូអិនឌីភី (UNDP), "របាយណ៍អភិវឌ្ឍន៍មនុស្ស២០០៩៖ កម្ពុជា" ឆ្នាំ២០០៩, មាននៅគេហទំព័រ http://hdrstats.undp.org/en/countries/country_fact_sheets/cty_fs_KHM.html (បានចូលមើលនៅថ្ងៃទី១៦ មិថុនា ២០១០)។

*១.២៥ ដុល្លារអាមេរិកក្នុងមួយថ្ងៃ។[14] ចំនួនចុះឈ្មោះចូលរៀន សារុបដោយប្រៀបធៀបសម្រាប់កុមារី ក្នុងកំរិតមធ្យមសិក្សាគឺ ២៨នាក់ លើរាល់កុមារី ១០០នាក់ ដែលមានអាយុគ្រប់សំរាប់ចូលសាលាមធ្យមសិក្សា។ ក្នុងបរិយាកាសសេដ្ឋកិច្ចបច្ចុប្បន្ន ស្ត្រីប្រឈមនឹងឱកាសមានការងារធ្វើនៅមានកម្រិតខ្លាំងមែនទែន ហើយ ការងារផ្លូវភេទ ហាក់ដូចជាជម្រើសខាងសេដ្ឋកិច្ច ដ៏ទាក់ទាញមួយ។*

*យោងតាមរបាយការណ៍របស់ធនាគារអភិវឌ្ឍន៍អាស៊ីឆ្នាំ២០០៤ "វិសមភាពយេនឌ័ មានលក្ខណៈដោយអន្ទើនៅក្នុងទីផ្សារការងារកម្ពុជា។ អាកប្បកិរិយាជាប្រពៃណីចំពោះ ការអប់រំសម្រាប់កុមារី និងការងារ 'សមស្រប' សម្រាប់ស្ត្រី និងបុរស បានធ្វើឲ្យកើតមានជាបន្តទៀតនូវវិសមភាពដែលមានស្រាប់ និងបានបន្តអោយភាពខុសគ្នាក្នុង ការងារនៅតែមានជាដរាប។"[15] របាយការណ៍បញ្ជាក់ថា ស្ត្រីដែលគេបានជួលឲ្យធ្វើការងារក្នុងប្រទេសកម្ពុជាភាគច្រើន គឺក្នុងវិស័យកាត់ដេរ ឬក្នុងវិស័យមិនផ្លូវការ។[16] ខណៈពេលដែលកម្មកររោងចក្រតម្បាញ និងកាត់ដេរម្នាក់រកប្រាក់ចំណូលបាន ចន្លោះពី ៤៥ដុល្លារ ទៅ ៨០ដុល្លារ[17] ក្នុងមួយខែ អ្នកប្រកបរបរផ្លូវភេទ អាចរកប្រាក់ចំណូលប្រចាំខែបានចាប់ពី ៩០ដុល្លារ ដល់ ១៦០ដុល្លារ។[18] អ្នកប្រកបរបរផ្លូវភេទ ជាច្រើននាក់ ក្នុងចំណោមអ្នកទាំងឡាយដែលអង្គការឃ្លាំមើលសិទ្ធិមនុស្សបានសម្ភាសន៍ បានចូលក្នុងការងារផ្លូវភេទ ដោយសារតែសម្ពាធខាងសេដ្ឋកិច្ច (ជាញឹកញយ វាកើតចេញមកពី*

---

14 យូអិនឌីភី (UNDP), "របាយណ៍អភិវឌ្ឍន៍មនុស្ស២០០៩ ៖ កម្ពុជា" ២០០៩, មាននៅគេហទំព័រ http://hdr.undp.org/en/media/HDR_2009_EN_Complete.pdf, (បានចូលមើលនៅថ្ងៃទី៧ កក្កដា ២០១០)។

15 យូនីហ្វែម (UNIFEM), ធានាគារពិភពលោក, អេឌីប៊ី (ADB), យូអិនឌីភី (UNDP) និងឌីអេហ្វអាយ/យូខេ (DFID/UK) ក្នុងកិច្ចសហប្រតិបត្តិការជាមួយ ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន "ការចែករំលែកយុត្តិធម៌សម្រាប់ស្ត្រី ៖ ការវាយតម្លៃយេនឌ័នៅកម្ពុជា" ខែមេសា ឆ្នាំ២០០៤ ទំព័រ៦ មាននៅគេហទំព័រ http://www.adb.org/Documents/Reports/Country-Gender-Assessments/cga-cam.pdf (បានចូលមើលនៅថ្ងៃទី១១ ខែមេសា ឆ្នាំ២០១០)

16 ដូចគ្នា

17 វិទ្យាស្ថានដើម្បីអភិវឌ្ឍន៍ការសិក្សា "ការស្ទាបស្ទង់ពីប្រាក់ឈ្នួលអាចរស់បាន សម្រាប់ឧស្សាហកម្មកាត់ដេរនៅកម្ពុជា" ខែកុម្ភៈ ឆ្នាំ២០០៩ មាននៅគេហទំព័រ http://www.fes.or.id/fes/download/Survey_Result_Cambodia.pdf(បានចូលមើលនៅថ្ងៃទី១១ ខែមេសា ឆ្នាំ២០១០)។

18 លទ្ធផលនៃសកម្មភាពស្រាវជ្រាវ របស់សម្ព័ន្ធភាពកម្ពុជាប្រយុទ្ធប្រឆាំងនឹងមេរោគអេដស៍ ជំងឺអេដស៍ ដែលមានចំណងជើងថា "បរិស្ថានគោលនយោបាយស្តីពីសិទ្ធិទទួលបានជាសកលនិងសិទ្ធិធ្វើការងាររបស់ស្ត្រីបម្រើសេវាកម្សាន្ត/ស្ត្រីប្រកបរបរផ្លូវភេទ" ចេញផ្សាយក្នុងខែកក្កដា ឆ្នាំ២០០៩ ទំព័រ៩។

បញ្ហាសុខភាពរបស់សមាជិកគ្រួសារ ឬការគ្មានដីធ្លី) និងការខ្វះខាតឱកាសដទៃទៀតសម្រាប់ការអប់រំ និងការមានការងារធ្វើ។

ស្ត្រីមួយចំនួនដែលពីដំបូងត្រូវបានគេជួញដូរ ឲ្យធ្វើការងារផ្លូវភេទ បានគេចខ្លួនចេញពីស្ថានភាពកេងប្រវ័ញ្ចនោះ ហើយក្រោយមកបន្តពាក់ព័ន្ធក្នុងការងារផ្លូវភេទ ដោយស្ម័គ្រចិត្ត។ ស្ត្រីមួយចំនួនក្នុងចំនោម ស្ត្រីទាំងនេះឥឡូវនេះគឺជាសមាជិកសកម្មនៃចលនាសិទ្ធិស្ត្រីប្រកបរបរផ្លូវភេទក្នុងប្រទេសកម្ពុជា។ ការមាក់ងាយ និងការរើសអើងទៅលើអ្នកប្រកបរបរផ្លូវភេទក្នុងសង្គមកម្ពុជា គួបផ្សំនឹងការខ្វះខាតជម្រើសសេដ្ឋកិច្ចដែលអាចរស់បានផង ធ្វើឲ្យអ្នកប្រកបរបរផ្លូវភេទ និងជនរងគ្រោះនៃការ ជួញដូរ តែងតែមានអារម្មណ៍ ថាពួកគេគ្មានជម្រើសអ្វីច្រើនទេ ក្រៅតែពីបន្តនៅក្នុងការងារផ្លូវភេទនេះ ។ ដូចជា មករា អាយុ២២ឆ្នាំ បានប្រាប់អង្គការឃ្លាំមើលសិទ្ធិ មនុស្សថា៖

> គេលក់ខ្ញុំឲ្យទៅផ្ទះបនមួយនៅភ្នំពេញ តម្លៃ៥០០ដុល្លារ នៅឆ្នាំ២០០១ [ នៅពេលដែលនាងមានអាយុ១៤ឆ្នាំ ]។ នៅពេលខ្ញុំចេញពីផ្ទះបន ខ្ញុំអត់ដឹងថាខ្ញុំធ្វើអ្វីផ្សេងកើតទេ។ គ្រួសារខ្ញុំក្រណាស់ ខ្ញុំមិនអាចទៅរកពឹងពួកគាត់បានទេ ដូច្នេះខ្ញុំក៏ធ្វើជាស្រីលក់ខ្លួនតាំងពីពេលនោះមក។ លុយដែលខ្ញុំរកបានពីការងារនេះ គឺសម្រាប់តែចិញ្ចឹមខ្លួនខ្ញុំ កូនខ្ញុំ និងប្តីខ្ញុំដែលជាអ្នកដើររើសអេតចាយ។[19]

មិនមានស្រីស្រស់ណាម្នាក់ដែលសម្ភាសន៍ដោយអង្គការឃ្លាំមើលសិទ្ធិមនុស្ស ត្រូវបានគេជួញដូរទេ។ ប៉ុន្តែពួកគេទាំងអស់បានពិពណ៌នាអំពីភាពក្រីក្រ រួមផ្សំនឹង ការ រើសអើងផ្អែកលើមូលដ្ឋានអត្តសញ្ញាណខាងភេទ និងចរិកលក្ខណៈខាងភេទរបស់ ពួកគេ ថាជាមូលហេតុ ដែលនាំអោយពួកគេចូលទៅក្នុងការងារផ្លូវភេទ។ ដូចជា ស្រីកែវបានប្រាប់អង្គការឃ្លាំមើលសិទ្ធិមនុស្សថា ៖

19 អង្គការឃ្លាំមើលសិទ្ធិមនុស្សសម្ភាសន៍ជាមួយ មករា អាយុ២២ឆ្នាំ នៅរាជធានីភ្នំពេញ ថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៩។

ខ្ញុំចាកចេញពីផ្ទះ ដោយសារតែមានការរើសអើងពីឪពុកម្ដាយខ្ញុំ ចំពោះចរិកភេទទីបី របស់ខ្ញុំ។ ខ្ញុំបានក្លាយទៅជាអ្នករកស៊ីលក់ភេទ បន្ទាប់ពីខ្ញុំចាកចេញពីផ្ទះ និងដើរ តាមមិត្តភក្តិរបស់ខ្ញុំ ក្នុងការរកលុយចិញ្ចឹមជីវិត តាមរយៈការរួមភេទ។[20]

**ការពាក់ព័ន្ធរបស់សង្គមស៊ីវិលជាមួយអ្នកប្រកបរបរផ្លូវភេទ**

*ក្នុងប្រទេសកម្ពុជា អង្គការមិនមែនរដ្ឋាភិបាលមួយចំនួនធំ ធ្វើការលើបញ្ហានានា ដែលប៉ះពាល់ដល់ស្ត្រី និងកុមារ។ អង្គការខ្លះនៃអង្គការទាំងនេះ ផ្ដោតលើការជួយដល់ជនរងគ្រោះនៃអំពើជួញដូរ និងទម្រង់ផ្សេងៗនៃអំពើហិង្សាប្រឆាំងនឹងស្ត្រីភេទ ខ្លះផ្ដោតជាក់លាក់លើសិទ្ធិកុមារ ឬសិទ្ធិស្ត្រី និងមួយចំនួនតូចផ្ដោតជាពិសេសលើការគាំទ្រសិទ្ធិរបស់អ្នកប្រកបរបរផ្លូវភេទ។ អង្គការមិនមែនរដ្ឋាភិបាលដែលផ្ដល់សេវា ជម្រកសំរាប់ជនរងគ្រោះនៃអំពើហិង្សា បានដើរតួនាទីយ៉ាងសំខាន់ ក្នុងការផ្ដល់សេវា ចាំបាច់ជាច្រើន ជាពិសេសក្នុងប្រទេសដូចជាកម្ពុជា ដែលសេវាកម្មរបស់រដ្ឋាភិបាល មានមិនគ្រប់គ្រាន់ ឬអត់មាន។ អង្គការក្រៅរដ្ឋាភិបាលដែលផ្ដល់ជម្រក បានចូលរួមចំណែកជាវិជ្ជមានដោយការជួយដល់ជនរងគ្រោះនៃអំពើរំលោភបំពានបានធូរស្បើយពីរបួសផ្លូវចិត្ត និងរៀនសូត្រចាប់យកជំនាញថ្មី និងដោយការជួយដល់នគរបាល និងតុលាការក្នុងការនាំយកជនជួញដូរមនុស្ស និងជនរំលោភមកវិនិច្ឆ័យទោស។*

*ទោះបីជាយ៉ាងណាក៏ដោយ ក៏មានការចោទសួរជាច្រើនថា តើអង្គការមិនមែនរដ្ឋាភិបាលជានិច្ចកាលគោរពសិទ្ធិមនុស្សរបស់អ្នកទាំងឡាយដែលពួកគេស្វះស្វែងការពារដែរឬទេ។ ជាឧទាហរណ៍ មានជម្រកអង្គការមិនមែនរដ្ឋាភិបាលខ្លះ មានគោលនយោបាយដ៏យូរអង្វែង (មកទល់ពេលថ្មីៗនេះ) ដែលគោលនយោបាយនោះបានបង្ខំឲ្យជនរងគ្រោះនៃអំពើជួញដូរ និងអ្នកប្រកបរបរផ្លូវភេទ ស្នាក់នៅក្នុងជម្រកផ្ទុយនឹងឆន្ទៈរបស់ពួកគេ។*

20 អង្គការឃ្លាំមើលសិទ្ធិមនុស្សសម្ភាសន៍ជាមួយ ស្រី កែវ នៅរាជធានីភ្នំពេញ ថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០០៩។

បន្ថែមទៅនឹងអង្គការមិនមែនរដ្ឋាភិបាល ដែលផ្តោតការយកចិត្តទុកដាក់លើបញ្ហា ជួញដូរ និងការការពារស្ត្រីពីអំពើហិង្សា ចាប់តាំងពីឆ្នាំ១៩៩៨មក មានអង្គការជា សមាជិក មួយចំនួនត្រូវបានបង្កើតឡើងដោយអ្នកប្រកបរបរផ្លូវភេទ និងដើម្បី អ្នកប្រកបរបរផ្លូវភេទ ដោយមានការគាំទ្រពីដំបូងពីអង្គការមិនមែនរដ្ឋាភិបាល ដទៃទៀត។ អង្គការទាំងនេះមានតួនាទីសំខាន់ តំណាងឲ្យផលប្រយោជន៍អ្នកប្រកប របរផ្លូវភេទ ដោយផ្តល់ជាដំបូន្មាន និងផ្តល់ការគាំទ្រដល់សមាជិករបស់ពួកគេ ផ្តល់ការអប់រំផ្ទាល់អំពីបញ្ហាមេរោគអេដស៍ និងតស៊ូមតិក្នុងនាមអ្នកប្រកបរបរផ្លូវភេទ ជាមួយរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាលដទៃទៀត និងស្ថាប័ននានា។ បណ្តាញការងារស្ត្រីរួបរួមគ្នា (WNU) ដែលជាបណ្តាញ ធំជាងគេ ត្រូវបានបង្កើតឡើង ក្នុង ឆ្នាំ២០០០ និងមានសមាជិកយ៉ាងហោចណាស់ចំនួន ៥,០០០ នាក់ក្នុងបណ្តាខេត្ត ចំនួន ១៣ ក្នុងប្រទេសកម្ពុជា។ អង្គការដទៃទៀតមានជាអាទិ៍ សហជីពស្ត្រីរកស៊ីផ្លូវភេទកម្ពុជា និង បណ្តាញបុរសស្ត្រីអភិវឌ្ឍន៍កម្ពុជា (CNMWD) ដែលផ្តោតការយកចិត្តទុកដាក់លើ ស្រីស្រស់ប្រកបរបរផ្លូវភេទ។

## ការងារផ្លូវភេទ ក្រោមច្បាប់កម្ពុជាបច្ចុប្បន្ន

មាត្រា៤៦ នៃរដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣ ចែងថា "អំពើលក់ដូរមនុស្ស អំពើធ្វើអាជីវកម្មផ្នែកពេស្យាកម្ម និងអំពើអាសអាភាស ដែលប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរ របស់នារីត្រូវហាមឃាត់។" នាពេលថ្មីៗនេះ អំពើជាច្រើនទាក់ទងនឹងការងារផ្លូវភេទ គឺខុសច្បាប់ នៅក្នុងប្រទេសកម្ពុជា ស្ថិតក្រោមច្បាប់ ដែលអនុម័តក្នុងឆ្នាំ២០០៨ ដែល គ្របដណ្តប់លើអំពើជួញដូរមនុស្ស និងការងារផ្លូវភេទ។ មានដូចជា អំពើអូសទាញ និងអំពើមួយចំនួនប្រព្រឹត្តដោយភាគីទីបីដែលជួយ អំពើពេស្យាចាររបស់អ្នកដទៃ គឺជាបទល្មើសព្រហ្មទណ្ឌ។

*មកដល់ពេលថ្មីៗនេះ ក្របខណ្ឌច្បាប់កម្ពុជា គឺនៅផ្អែកយ៉ាងទូលំទូលាយលើច្បាប់ ដែលធ្វើឡើងដោយអាជ្ញាធរបណ្ដោះអាសន្នរបស់អង្គការសហប្រជាជាតិ នៅប្រទេសកម្ពុជា(អ៊ុនតាក់)។*[21] *ច្បាប់អ៊ុនតាក់ឆ្នាំ១៩៩២ បានដាក់ទោសជាបទល្មើសព្រហ្មទណ្ឌលើភាគីទីបី ដែលពាក់ព័ន្ធក្នុងពេស្យាចារកុមារ ប៉ុន្តែមិនមានបទបញ្ញត្តិណាមួយដាក់ទោសជាបទល្មើសព្រហ្មទណ្ឌលើទិដ្ឋភាពណាមួយនៃការជួរផ្លូវភេទរបស់ នីតិជនទេ។*[22]

*ច្បាប់អ៊ុនតាក់ត្រូវបានបង្គ្រប់ដោយការធ្វើច្បាប់បន្ថែមក្នុងឆ្នាំ១៩៩៦ និងឆ្នាំ២០០៨ ដែលដាក់ជាបទល្មើសព្រហ្មទណ្ឌលើទិដ្ឋភាពបន្ថែមនៃការជួរផ្លូវភេទ។ ច្បាប់ស្ដីពីការបង្ក្រាបអំពើពង្រត់ និងលក់ដូរមនុស្ស និងអំពើធ្វើអាជីវកម្មលើមនុស្ស ដែលបានអនុម័តក្នុងឆ្នាំ១៩៩៦ ជាបន្ថែមពីលើការដាក់ទោសជាបទព្រហ្មទណ្ឌ នៃអំពើជួញដូរ ស្ត្រី និងកុមារឲ្យធ្វើពេស្យាចារ បានដាក់ទោសជាបទព្រហ្មទណ្ឌផងដែរ ដល់ភាគីទីបី ដែលពាក់ព័ន្ធនឹងអំពើពេស្យាចារ ដូចជាអំពើសញ្ចារកម្ម និងអំពើអានាចារ - បើក "កន្លែងសម្រាប់ប្រព្រឹត្តអំពើអានាចារ ឬអំពើអាសអាភាសផ្សេងៗ។"*[23] *បទល្មើស ទាំងពីរ*

21 អ៊ុនតាក់ បង្កើតឡើងក្នុងប្រទេសកម្ពុជាក្នុងឆ្នាំ១៩៩២ ដើម្បីធានាដល់ការអនុវត្តកិច្ចព្រមព្រៀងស្ដីពីដំណោះស្រាយនយោបាយរួមនៃជម្លោះនៅកម្ពុជា ដែលបានចុះហត្ថលេខានៅ ទីក្រុងប៉ារីស នាថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១។ ក្នុងចំណោមកិច្ចការដទៃទៀត អាណត្តិការងារអ៊ុនតាក់មានរាប់បញ្ចូលទាំងការទទួលខុសត្រូវចំពោះសិទ្ធិមនុស្ស និងរក្សានូវការអនុវត្តតាមច្បាប់ និងថែរក្សាសណ្ដាប់ធ្នាប់។

22 មាត្រា៤២(៣) នៃច្បាប់អ៊ុនតាក់ចែងថា ជនណាដែលល្បួង អូសទាញ ឬបង្វែងគំនិតអនីតិជនដើម្បីធ្វើពេស្យាចារ ឬធ្វើអាជីវកម្មពេស្យាចារលើអនីតិជន ទោះបីមានការព្រមព្រៀងក៏ដោយ ត្រូវផ្ដន្ទាទោសដាក់គុកពី ២ ឆ្នាំដល់ ៦ ឆ្នាំ។

23 ព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ ០២៩៦/០១ ច្បាប់ស្ដីពីការបង្ក្រាបអំពើពង្រត់និងលក់ដូរមនុស្ស និងអំពើធ្វើអាជីវកម្មលើមនុស្ស ដែលអនុម័តដោយរដ្ឋសភាជាតិនៅថ្ងៃទី១៦ ខែមករា ឆ្នាំ១៩៩៦។ ច្បាប់ស្ដីពីការបង្ក្រាប អំពើពង្រត់និងលក់ដូរមនុស្ស និងអំពើធ្វើអាជីវកម្មលើមនុស្ស ឆ្នាំ១៩៩៦ មាត្រា៤ ចែងថា "នឹងត្រូវចាត់ទុកជាសញ្ចារិក ឬសញ្ចារិកា ឬជនមេពេស្យា ជនណាដែលទំនុកបម្រុង ឬការពារជនណាម្នាក់ ឬច្រើននាក់ ទោះបីតាមមធ្យោបាយណាក៏ដោយ ហើយដោយបានដឹងជាមុននូវអំពើពេស្យាចាររបស់ជននោះ ឬក៏ទាក់ទាញភ្ញៀវឲ្យជននោះ ក្នុងគោលដៅពេស្យាចារ ឬ ដែលចែកភាគផល ដែលបានមកពីអំពើពេស្យាចារជាប្រក្រតី ទោះជាក្នុងទ្រង់ទ្រាយណាក៏ដោយ ឬដែលយកស្ត្រី ឬបុរស ទោះបីតាមមធ្យោបាយណាក៏ដោយ ទៅបង្ហាត់បង្រៀនបញ្ចុះបញ្ចូលឲ្យធ្វើជាស្ត្រី ឬបុរសពេស្យាចារ ឬដែលធ្វើជាអ្នកកណ្ដាល ទោះបីតាមរូបភាពណាក៏ដោយ បង្កើតឲ្យមានទំនាក់ទំនងរវាងបុរសពេស្យា ឬស្ត្រីពេស្យា ជាមួយនឹងមេបនពេស្យាចារ ឬជាមួយអ្នកផ្ដល់កម្រៃលើពេស្យាចារអ្នកដទៃ ឬដែលឲ្យបុរស ឬស្ត្រីនៅក្នុងផ្ទះរបស់ខ្លួន ឬកន្លែងណាមួយ ក្នុងគោលដៅឲ្យជនទាំងនោះ ធ្វើពេស្យាចារយកប្រាក់ឲ្យខ្លួន។" ច្បាប់ស្ដីពីការបង្ក្រាប អំពើពង្រត់ និងលក់ដូរមនុស្ស និងអំពើធ្វើអាជីវកម្មលើមនុស្សឆ្នាំ១៩៩៦ មាត្រា៧ ចែងថា "ជនណាដែលបើកកន្លែងសម្រាប់ប្រព្រឹត្តអំពើអនាចារ ឬអំពើអាសអាភាសផ្សេងៗ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី (១) ឆ្នាំដល់ (៥) ឆ្នាំ និងពិន័យជាប្រាក់ពី (៥.០០០.០០០៛០០) "ប្រាំលានរៀល" ដល់ (៣០.០០០.០០០៛០០) "សាមសិបលានរៀល"។ ក្នុងករណីមិនរាងចាល ត្រូវផ្ដន្ទាទោសទ្វេជាពីរ។" មាត្រា៨ ចែងថា "ជនណាដែលបានប្រព្រឹត្តអំពើអនាចារ លើអនីតិជនអាយុក្រោម ១៥ ឆ្នាំ ទោះបីអនីតិជននោះស្ម័គ្រចិត្តក្ដី ឬដោយទិញក្មេងនោះពីអ្នកដទៃក្ដី ឬទិញពីជនជាមេពេស្យាក្ដី ជននោះត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី១០ ឆ្នាំដល់២០ ឆ្នាំ។ ក្នុងករណីមិនរាងចាល ត្រូវយក

នៅក្នុងច្បាប់ឆ្នាំ១៩៩៦ បានផ្តល់នូវមូលដ្ឋានច្បាប់ សម្រាប់នគរបាល ឆ្មក់ចូល ផ្ទះបន ឬទីកន្លែងកម្សាន្តដទៃទៀត ដែលទំនងជាកើតមានការប្រកបរបរ ផ្លូវភេទ។ អំពើអនាចារ មិនត្រូវបានកំនត់និយមន័យនៅក្នុងច្បាប់ទេ ហើយបទល្មើសក៏ មិនត្រូវបានកែប្រែដែរនៅក្នុងច្បាប់ឆ្នាំ២០០៨។ ក្នុងខែតុលា ឆ្នាំ២០០៨ ច្បាប់អ៊ុនតាក់ ត្រូវបានដាក់ជំនួសដោយក្រមព្រហ្មទណ្ឌថ្មី។

ក្នុងខែកុម្ភះ ឆ្នាំ២០០៨ រដ្ឋាភិបាលកម្ពុជាបានអនុម័តច្បាប់ស្តីពី ការបង្ក្រាបអំពើ ជួញដូរមនុស្សនិង អំពើធ្វើអាជីវកម្មផ្លូវភេទ ដែលច្បាប់នេះមានអនុភាពនិរាករណ៍ ច្បាប់ឆ្នាំ១៩៩៦។[24] លើការរំលោភផ្លូវភេទ ច្បាប់នេះដាក់ជាបទល្មើសព្រហ្មទណ្ឌលើ ភាគីទីបី ដែលពាក់ព័ន្ធនឹងការរំលោភផ្លូវភេទ, ពេស្យាចារកុមារ និងអំពើអួសទាញ។

យោងតាមអ្នកធ្វើសេចក្តីព្រាងច្បាប់នេះ ច្បាប់នេះមានបំណងនាំប្រទេសកម្ពុជាឲ្យ ដើរស្របទៅនឹងអនុសញ្ញាមួយចំនួន ពោលគឺអនុសញ្ញាស្តីពីសិទ្ធិកុមារ និងពិធីសារ បន្ថែមលើអនុសញ្ញានេះ ពាក់ព័ន្ធនឹងការលក់កុមារ ពេស្យាកម្មកុមារ និងកាមសាស្ត្រ កុមារ ដែលបានផ្តល់សច្ចាប័នដោយប្រទេសកម្ពុជាក្នុងខែឧសភាឆ្នាំ២០០២ និង ស្របតាមពិធីសារប៉ាឡឺម៉ូ (Palermo Protocol) ស្តីពីការទប់ស្កាត់ ការបង្ក្រាប និងការ ផ្តន្ទាទោសការជួញដូរមនុស្ស (ពីពេលនេះតទៅហៅត្រឹមតែ ពិធីសារប៉ាឡឺម៉ូ) ដែល កម្ពុជាបានផ្តល់សច្ចាប័នក្នុងឆ្នាំ២០០៦។

ក្នុងចំណាប់អារម្មណ៍ចំពោះច្បាប់ឆ្នាំ២០០៨ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌បានថ្លែងថា ច្បាប់ថ្មីត្រូវការជាចាំបាច់ ព្រោះច្បាប់ឆ្នាំ១៩៩៦ "នៅមានការខ្វះចន្លោះជាច្រើន"

---

អតិបរមានៃទោសមកអនុវត្ត។ តុលាការអាចយកអនុទោសត្រង់ស្ថានបន្ថយសិទ្ធិពលរដ្ឋ និងហាមស្នាក់អាស្រ័យមកផ្តន្ទាទោសបន្ថែមលើ មូលទោសខាងលើនេះបាន។"

24 ច្បាប់ស្តីពីការបង្ក្រាប អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ *ព្រះរាជាណាចក្រកម្ពុជា* លេខ១៤០ ច.ល ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ មានត្រា៥០ ចែងថា ច្បាប់ស្តីពីការបង្ក្រាបអំពើពង្រត់ និងលក់ដូរមនុស្ស និងអំពើធ្វើអាជីវកម្មលើមនុស្ស ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើតាម ព្រះរាជក្រមលេខ ជស/រកម/០២៩៦/០១ ត្រូវទុកជានិរាករណ៍។ ច្បាប់នេះត្រូវមានអាទិភាព ប្រសិនបើបទបញ្ញត្តិនៃច្បាប់ផ្សេងទៀត មិនស្របគ្នានឹងបទបញ្ញត្តិនៃច្បាប់នេះ។ ("ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិង អំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ២០០៨") ។

*និងការអនុវត្តពុំសូវមានប្រសិទ្ធិភាព។[25] ក្រសួងយុត្តិធម៌ បានធ្វើកិច្ចសហប្រតិបត្តិការ ជាមួយវិទ្យាស្ថានអភិវឌ្ឍផ្នែកច្បាប់នៃប្រទេសជប៉ុនក្រោមការឧបត្ថម្ភគាំទ្រផ្នែកហិរញ្ញវត្ថុពីអង្គការយូនីសេហ្វប្រចាំនៅកម្ពុជា បានរៀបចំច្បាប់ថ្មី ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។[26]*

*ច្បាប់ឆ្នាំ២០០៨ បានអនុម័តយកនិយមន័យនៃអំពើជួញដូរមនុស្សរបស់ពិធីសារ ប៉ាឡឺម៉ូ ដោយផ្តល់ឲ្យមន្ត្រីប្រតិបត្តិច្បាប់នូវមូលដ្ឋានបន្ថែមទៀតក្នុងការចាប់ខ្លួន និង ផ្តន្ទាទោសអ្នកជួញដូរមនុស្ស។ ច្បាប់ឆ្នាំ២០០៨ ផ្តល់ភាពលំអិតពីជាតុផ្សំនិមួយៗនៃ អំពើជួញដូរមនុស្សតាមពិធីសារប៉ាឡឺម៉ូ ដោយដាក់ទោជា បទល្មើសព្រហ្មទណ្ឌ ដោយឡែកៗពីគ្នា ដូចជា ការនាំយកចេញដោយមិនស្របច្បាប់ ការនាំយក អនីតិជនចេញដោយមិនស្របច្បាប់[27] ការនាំយកចេញដោយមិនស្របច្បាប់ "ដោយ មានគោលដៅ"[28] អំពើលក់-ដូរមនុស្ស[29]*

---

25 ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ២០០៨ ចំណាប់អារម្មណ៍របស់ឯកឧត្តម អង្គ វង្ស វឌ្ឍានា រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៨។

26 ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ២០០៨ មាត្រា៨ ចែងកំណត់និយមន័យនៃការនាំយកចេញដោយមិនស្របច្បាប់ ថាជា ១-ការធ្វើឲ្យមនុស្សម្នាក់ផ្លាស់ទីពីទីកន្លែងដែលគេកំពុងរស់នៅទៅកាន់ទីកន្លែងដទៃដែលស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ខ្លួន ឬរបស់តតិយជនតាមមធ្យោបាយបង្ខិតបង្ខំ គម្រាមកំហែង បោកបញ្ឆោត បំពានដោយអំណាច ឬលួងលោម, ឬ ២-ការនាំយកអនិតិជន ឬជនដែលនៅក្រោមអាណាព្យាបាលទូទៅ ឬនៅក្រោមហិតូបត្ថម្ភ ឬនៅក្រោមអ្នកគ្រប់គ្រងស្របច្បាប់ ដោយគ្មានអំណាចតាមផ្លូវច្បាប់ ឬយុត្តិកម្មតាមផ្លូវច្បាប់ ចេញពីការគ្រប់គ្រងស្របច្បាប់នៃឪពុកម្តាយ អ្នកថែរក្សា ឬអ្នកអាណាព្យាបាលរបស់គេ។

27 ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ២០០៨ មាត្រា៩ ចែងកំណត់និយមន័យនៃ ការនាំយកអនីតិជនចេញដោយមិនស្របច្បាប់ ថាជា ការនាំយកចេញដោយមិនស្របច្បាប់ "អនីតិជន ឬជនណាម្នាក់ដែលនៅក្រោមអាណាព្យបាលទូទៅ ឬនៅក្រោមហិតូបត្ថម្ភ ឬនៅក្រោមការគ្រប់គ្រងស្របច្បាប់"។

28 ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ២០០៨ មាត្រា១០ ចែងកំណត់និយមន័យនៃ ការនាំយកចេញដោយមិនស្របច្បាប់ដោយមានគោលដៅថា ជាការនាំយកចេញដោយមិនស្របច្បាប់ ក្នុងគោលដៅស្វែងរកប្រយោជន៍ ឈ្លានពានខាងផ្លូវភេទ ផលិតរូបអាសអាភាស រៀបអាពាហ៍ពិពាហ៍ផ្ទុយពីឆន្ទៈរបស់ជនរងគ្រោះ សុំកូន ឬទម្រង់ណាមួយនៃការកេងប្រវ័ញ្ចផ្សេងទៀត។ ពាក្យ "ទម្រង់ណាមួយនៃការកេងប្រវ័ញ្ចន៍ផ្សេងទៀត" រាប់ទាំងការកេងប្រវ័ញ្ចលើ ពេស្យាចារជនដទៃ រូបភាពនិងសម្ភារអាសអាភាស សកម្មភាពដទៃទៀតនៃពាណិជ្ជកម្មផ្លូវភេទ ពលកម្មដោយបង្ខំ ឬសេវាដោយបង្ខំដទៃទៀត ទាសភាព ឬការប្រព្រឹត្តស្រដៀងគ្នានឹងទាសភាព ការបញ្ចាំខ្លួនដោះបំណុល សេវគតិភាពដោយមិនស្ម័គ្រចិត្ត ពលកម្មកុមារ ឬការដកហូតសរីរាង្គ។"

29 ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ២០០៨ មាត្រា១៣ ចែងពីអំពើលក់ ដូរមនុស្ស ថាជាការប្រគល់អោយដោយខុសច្បាប់នូវការគ្រប់គ្រងលើជនណាម្នាក់ទៅជនដទៃ ឬទទួលយកដោយខុសច្បាប់នូវការប្រគល់ការគ្រប់គ្រងលើជនណាម្នាក់ពីជនដទៃ ដោយផ្តោះប្តូរទៅនឹងរបស់មានតម្លៃអ្វីមួយ ដោយរាប់បញ្ចូលទាំងសេវា និងមនុស្សផង។

ការដឹកជញ្ជូនដោយមាន គោលដៅ[30] អំពើនាំឆ្លងដែន[31] ការចាប់ពង្រត់ ការឃុំឃាំង ឬការបង្ខាំង[32] ដូច្នេះ វាអាស្រ័យលើនគរបាល ព្រះរាជអាជ្ញា និងចៅក្រម ដើម្បីកំណត់ជាចុងក្រោយនូវ បទល្មើស ដែលសមស្របបំផុត ដែលត្រូវយកមកចោទប្រកាន់ជនប្រព្រឹត្តអំពើជួញដូរ។[33]

ច្បាប់ឆ្នាំ២០០៨ គ្របដណ្តប់ផងដែរលើ បទល្មើសទាក់ទងនឹងអំពើពេស្យាចារ និង ពេស្យាចារកុមារ។[34] អំពើពេស្យាចារ ត្រូវបានគេឲ្យនិយមន័យថាជាការរួមភេទជាមួយជនណាម្នាក់ដែលមិនកំណត់ ឬអំពើគ្រប់រូបភាពផ្សេងទៀត ដែលទាក់ទងនឹង ភេទ ដោយផ្តោះប្តូរនឹងវត្ថុមានតម្លៃអ្វីមួយ។[35] អំពើពេស្យាចារកុមារ ត្រូវបានគេឲ្យនិយមន័យថាជាអំពើរួមភេទ ឬអំពើគ្រប់រូបភាពផ្សេងទៀត រវាងអនីតិជនជាមួយជន ដទៃ ដើម្បីផ្តោះប្តូរទៅនឹងវត្ថុមានតម្លៃអ្វីមួយ។[36] បទបញ្ញត្តិស្តីពីការជួញដូរផ្លូវភេទ និង ពេស្យាចារកុមារ ពង្រីកវិសាលភាព នៃអំពើដែលជាបទល្មើសដែលមានចែងក្នុង ច្បាប់ឆ្នាំ១៩៩៦។

---

30 ច្បាប់ស្តីពីការបង្ក្រាប អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ២០០៨ មាត្រា១៧ ចែងពីការដឹកបញ្ជូនដោយមានគោលដៅ ថាជាការដឹកជញ្ជូនជនដទៃ ដោយដឹងថាថាជននោះ ត្រូវបាននាំយកចេញដោយមិនស្របច្បាប់ ជ្រើសរើស លក់-ដូរ ឬដឹកជញ្ជូន ក្នុងគោលដៅដើម្បីស្វែងរកប្រយោជន៍ឈ្លានពានខាងផ្លូវភេទ ផលិតរូបភាពអាសអាភាស រៀបអាពាហ៍ពិពាហ៍ផ្ទុយពីឆន្ទៈរបស់ជនរងគ្រោះ សុំកូន ឬទម្រង់នៃការកេងប្រវ័ញ្ចផ្សេងៗទៀត។

31 ច្បាប់ស្តីពីការបង្ក្រាប អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ២០០៨ មាត្រា១៨ ចែងពី អំពើនាំឆ្លងដែន ថា ជនណាដែលនាំយកជនដទៃ ដោយដឹងថាជននោះ ត្រូវបាននាំយកចេញដោយមិនស្របច្បាប់ ជ្រើសរើស លក់ដូរ ឬដឹកជញ្ជូនទៅក្រៅព្រះរាជាណាចក្រកម្ពុជា។

32 ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ២០០៨ មាត្រា២១ ចែងពី ការចាប់ពង្រត់ (ចាប់ខ្លួន) ការឃុំឃាំង ឬការបង្ខាំង ថា បុគ្គលដែលចាប់ឃុំឃាំង ឬបង្ខាំងអ្នកដទៃ ដោយគ្មានអំណាចតាមផ្លូវច្បាប់។

33 មាត្រា ៣ នៃពិធីសារ ប៉ាឡឺម៉ូ ចែងថា អំពើជួញដូរមនុស្សគឺជា "ការជ្រើសរើសសមាជិកថ្មី ការដឹកជញ្ជូន ការផ្លាស់ប្តូរកន្លែងសំចត ឬក៏ទទួលអោយមនុស្សចូលដោយតាមមធ្យោបាយគំរាមកំហែង ឬការប្រើប្រាស់កម្លាំង ឬក៏បែបបទនៃការបង្ខិតបង្ខំផ្សេងទៀត នៃការចាប់ជំរិត ការក្លែងបន្លំ ការឆបោក ការប្រើអំណាចដោយ រំលោភបំពាន ឬក៏ការធ្វើអោយមានការឈឺចាប់ ឬក៏ ការផ្តល់អោយ ឬក៏ទទួលនូវការចំណាយ ឬអត្ថប្រយោជន៍ ដើម្បីសម្រេចនូវការយល់ព្រមពីជនណាម្នាក់ ដែលត្រួតត្រាលើជនម្នាក់ផ្សេងទៀត ក្នុងបំណងធ្វើអាជីវកម្ម។ អំពើធ្វើអាជីវកម្ម រាប់បញ្ចូលទាំង ផ្នែកអប្បរមានៃការធ្វើអាជីវកម្មលើពេស្យាចារនៃជនដទៃ ឬអំពើអាជីវកម្មផ្លូវភេទ ពលកម្ម ឬសេវាដោយបង្ខំ ទាសភាព ឬការប្រព្រឹត្តស្រដៀងគ្នានឹងទាសភាព សេវគតិភាព ឬការដកហូតសរីរាង្គ។" មិនចាត់ទុកថា ជាការយល់ព្រមចំពោះអំពើអាជីវកម្មដោយចេតនាទេ កាលណាមានការប្រើមធ្យោបាយណាមួយដូចជាការប្រើល្បិចកល ការបង្ខិតបង្ខំ ។ល។ ចំពោះកុមារវិញ ទោះបីជាមានការយល់ព្រមក៏ដោយ ហើយការប្រើទម្រង់ណាមួយក៏ដោយនៃការបង្ខិតបង្ខំ ឬការប្រើល្បិចកល និងការជ្រើសរើស ឬនាំយកកុមារចូលក្នុងស្ថានភាពអាជីវកម្ម គឺមានលក្ខណៈគ្រប់គ្រាន់ដើម្បីចាត់ចូលជាការជួញដូរ។

34 ជំពូក ៤ នៃច្បាប់ ដែលមាត្រា ២៣ ដល់ មាត្រា៣៧ ចែងពីបទល្មើសផ្សេងៗ ដែលជាការលប់បំបាត់ អំពើពេស្យាចារ និងអំពើពេស្យាចារកុមារ ។

35 មាត្រា ២៣ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ២០០៨ ។

36 មាត្រា ២៣ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ២០០៨ ។

*នៅក្រោមច្បាប់ឆ្នាំ១៩៩៦ អំពើសញ្ចារកម្ម និងអំពើអនាចារ ជា បទល្មើសព្រហ្មទណ្ឌ ដែលមានការដាក់ទោសយ៉ាងតឹងរ៉ឹងចំពោះអំពើអនាចារ ដែល ពាក់ព័ន្ធនឹងកុមារអាយុក្រោម ១៥ឆ្នាំ។ បទល្មើសថ្មីក្នុងច្បាប់ឆ្នាំ២០០៨ រាប់បញ្ចូល នូវអំពើអាសអាភាស រូបភាព និងសម្ភារៈអាសអាភាស ការទិញពេស្យាចារកុមារ ការផ្តល់ទីកន្លែងសម្រាប់ធ្វើពេស្យាចារ និង សញ្ចារកម្ម។*[37]

*ច្បាប់ឆ្នាំ២០០៨ មិនដាក់ជាបទល្មើសព្រហ្មទណ្ឌចំពោះអតិថិជនរបស់ អ្នកប្រកបរបរ ផ្លូវភេទជានីតិជនទេ។ ប៉ុន្តែច្បាប់នេះ តម្រូវឲ្យដាក់ទណ្ឌកម្មដល់ជនទាំងឡាយណា ដែលជាប់ពាក់ព័ន្ធនឹងពេស្យាចារកុមារ រួមទាំងអតិថិជន ប៉ុន្តែមិនដាក់ទណ្ឌកម្មលើ កុមារទេ។*[38]

*ច្បាប់ឆ្នាំ២០០៨ ដាក់ជាបទល្មើសព្រហ្មទណ្ឌ នីតិជនប្រកបរបរផ្លូវភេទ ដែល អូសទាញនៅទីសាធារណៈ។ តាមមាត្រា២៤ ជនណាអូសទាញដោយចេតនា ជនដទៃក្នុងទីសាធារណៈ ក្នុងគោលដៅប្រព្រឹត្តអំពើពេស្យាផ្ទាល់ខ្លួន ត្រូវផ្តន្ទាទោស ដាក់ពន្ធនាគារពី១ ថ្ងៃដល់ ៦ ថ្ងៃ និងពិន័យជាប្រាក់ ៣,០០០ រៀលដល់ ១០,០០០ រៀល (ប្រហែល $០.៧៥ ដុល្លារ ទៅ $២.៥០ដុល្លារ)។ ច្បាប់នេះ លើកលែងកុមារ អាយុក្រោម ១៨ ឆ្នាំ ពីការចោទប្រកាន់ពីបទអូសទាញ។*

*ច្បាប់ឆ្នាំ២០០៨ ដាក់ទោសជាបទល្មើសព្រហ្មទណ្ឌផងដែរចំពោះអំពើសញ្ចារកម្ម ដែលជាទូទៅត្រូវបានគេពិចារណាថាជាការសម្របសម្រួល ឬផ្តល់ឲ្យជនណាម្នាក់ នូវសេវាផ្លូវភេទ។ មាត្រា២៥ ផ្តល់និយមនៃអំពើសញ្ចារកម្មដូចតទៅនេះ ៖ ទាញយក ប្រយោជន៍ហិរញ្ញវត្ថុ ពីអំពើពេស្យាចាររបស់ជនដទៃ ជួយ ឬការពារអំពើពេស្យាចារ*

37 សូមមើលមាត្រា ២៣-៤១ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ២០០៨ ។

38 មាត្រា ២៣ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ២០០៨ ។

*របស់ជនដទៃ, ជ្រើសរើស អូសទាញ ឬបណ្តុះបណ្តាលបុគ្គលណាមួយឲ្យប្រព្រឹត្តិ អំពើពេស្យាចារ ឬធ្វើការគាបសង្កត់លើបុគ្គលណាមួយ ដើម្បីឲ្យបុគ្គលនោះធ្វើ ពេស្យាចារ។*

*មាត្រា២៥ ឲ្យនិយមន័យសញ្ជារកម្ម ក្នុងលក្ខណៈទូលំទូលាយ ត្រង់ថា សញ្ជារកម្ម រាប់បញ្ចូលមិនត្រឹមតែ ជាការទទួលអត្ថប្រយោជន៍ហិរញ្ញវត្ថុពី អំពើពេស្យាចារ ប៉ុណ្ណោះទេ ប៉ុន្តែវារាប់បញ្ចូលនូវសកម្មភាពមួយចំនួនផងដែរដូចជា "ជួយ ឬ ការពារ អំពើពេស្យាចាររបស់ជនដទៃ។"[39] ត្រង់នេះមានន័យថា អ្នកណាក៏ដោយនឹងត្រូវចាត់ ទុកថា បានជួយអំពើពេស្យាចារ ដូចជា អ្នករត់ម៉ូតូឌុប ឬអ្នកធ្វើការខាងការអប់រំ ផ្សព្វផ្សាយ ដល់ស្ត្រីប្រកបរបរផ្លូវភេទ ដែលចែកស្រោម អនាម័យ ក៏អាចទទួលខុសត្រូវ ចំពោះអំពើពេស្យាកម្មផងដែរ។ និយមន័យដ៏ទូលំទូលាយនៃមាត្រានេះ ប្រថុយនឹង ការដាក់ទោសជាបទល្មើសព្រហ្មទណ្ឌ ចំពោះការអនុវត្តស្របច្បាប់នូវសិទ្ធិមូលដ្ឋាន នានា ដូចជាសកម្មភាពស្វែងរកការគាំទ្រសំរាប់អ្នកប្រកបរបរផ្លូវភេទ។*

*បន្ថែមលើសនេះទៀត មាត្រា២៥(៣) ឲ្យនិយមន័យសញ្ជារកម្ម ដែលមានរាប់បញ្ចូល នូវអំពើទាំងឡាយដែលអាចត្រូវបានបកស្រាយថាជា "អំពើរារាំងដល់ការបង្ការ ការជួយ ឬការអប់រំជាថ្មីដោយទីភ្នាក់ងារសាធារណៈ ឬដោយអង្គការឯកជន ដែល មាននីតិសម្បទា ដែលធ្វើឡើងដើម្បីជាគុណប្រយោជន៍ដល់បុគ្គល ដែលប្រព្រឹត្ត ពេស្យាចារ ឬកំពុងមានគ្រោះដោយការធ្វើពេស្យាចារ។"[40] ការឲ្យវិសាលភាព*

---

39 សូមមើលមាត្រា២៥ នៃច្បាប់ស្តីពីការបង្រ្កាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ២០០៨ ដែលចែងថា "អំពើសញ្ជារកម្មនៅក្នុងច្បាប់នេះមានន័យថា ១-ទាញយកអត្ថប្រយោជន៍ហិរញ្ញវត្ថុពីអំពើពេស្យាចាររបស់ជនដទៃ, ២-ជួយឬការពារអំពើពេស្យាចាររបស់ជនដទៃ, ៣-ជ្រើសរើស អូសទាញ ឬបណ្តុះបណ្តាលបុគ្គលណាមួយឲ្យធ្វើអំពើពេស្យាចារ, ៤-ធ្វើការគាបសង្កត់លើបុគ្គលណាមួយ ដើម្បីឲ្យបុគ្គលនោះធ្វើពេស្យាចារ។ អំពើដូចខាងក្រោមនេះ ត្រូវចាត់ទុកថាដូចគ្នានឹងសញ្ជារកម្ម ៖ ១-អំពើធ្វើជាអន្តរការីរវាងបុគ្គលដែលធ្វើជាពេស្យាចារ និងបុគ្គលដែលប្រកបអាជីវកម្ម ឬឲ្យលាភការដល់ពេស្យាចារជនដទៃ, ២-អំពើរបស់ជនណាដែលបានជួយសម្រួល ឬបិទបាំងនូវធនធាន ដែលខ្លួនបានដឹងថាបានមកពីអំពើសញ្ជារកម្ម, ៣-អំពើរារាំងដល់ការបង្ការ ការជួយ ឬការអប់រំជាថ្មី ដោយទីភ្នាក់ងារសាធារណៈ ឬដោយអង្គការឯកជន ដែលមាននីតិសម្បទា ដែលធ្វើឡើងដើម្បីជាគុណប្រយោជន៍ ដល់បុគ្គលដែលប្រព្រឹត្តពេស្យាចារ ឬកំពុងមានគ្រោះ ដោយការធ្វើពេស្យាចារ។"

40 មាត្រា២៥ (៣) នៃច្បាប់ស្តីពីការបង្រ្កាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ២០០៨ ។ យោងតាមមាត្រា២៥ បទល្មើសនេះស្មើនឹងអំពើសញ្ជារកម្ម ដែលត្រូវផ្តន្ទាទោស តាមមាត្រា២៦ ដែលត្រូវដាក់ពន្ធនាគារពី ២ ឆ្នាំ ដល់ ៥ ឆ្នាំ។

*បទល្មើសនៃអំពើសញ្ចារកម្ម ទូលំទូលាយពេក នាំឲ្យអាចនិយាយបានថា ពួកមិត្ត អប់រំមិត្ត ឬក្រុមគ្រួសារ ឬមិត្តរបស់អ្នកប្រកបរបរផ្លូវភេទ ដែលព្យាយាមធ្វើអន្តរាគមន៍ ក្នុងពេលមានការលុកលុយពីនគរបាល អាចនឹងមានទោសបាន។ អង្គការឃ្លាំមើលសិទ្ធិមនុស្ស បានទទួលរបាយការណ៍ពី អង្គការមិនមែនរដ្ឋាភិបាលមួយចំនួន ដែលថា នគរបាលប្រើប្រាស់បទប្បញ្ញត្តិនេះជាមធ្យោបាយ ដើម្បីគំរាមកំហែង និងរាំងខ្ទប់កិច្ចខិតខំប្រឹងប្រែងរបស់បុគ្គលិកខាងអប់រំផ្ទាល់ៗ*[41] *បទបញ្ញត្តិនេះ មានលក្ខណៈស្រពិចស្រពិលជាខ្លាំង សំរាប់ការអនុវត្តជាសក្កានុពល ដោយវារំលោភ គោលការណ៍ច្បាប់ គោលការណ៍ច្បាស់លាស់ និង គោលការណ៍បានដឹងជាមុន [គោលការណ៍គ្មានច្បាប់ចែងគ្មានបទល្មើស] ដែលតម្រូវថា ច្បាប់ព្រហ្មទណ្ឌ ត្រូវតែកំណត់អោយមានលក្ខណៈគ្រប់គ្រាន់ ចង្អៀត និងចំៗ ចំពោះ អំពើ ឬសកម្មភាពជាក់លាក់មួយ។ នេះគឺជាអ្វីដែលតម្រូវដោយមាត្រា១៥ នៃកតិការសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលតម្រូវថាបទល្មើសព្រហ្មទណ្ឌទាំងអស់ ត្រូវតែចែងអោយពិស្តារគ្រប់គ្រាន់នៅក្នុងច្បាប់ៗ*[42]

*នៅឆ្នាំ២០០៨ សកម្មជនខាងការងារប្រយុទ្ធប្រឆាំងនឹងមេរោគអេដស៍និងជំងឺអេដស៍ អ្នកធ្វើការងារខាងសុខភាព និងក្រុមអ្នកប្រកបរបរផ្លូវភេទ បានបញ្ចេញកង្វល់អំពីកំណើននៃការរំលោភបំពានពីសំណាក់អាជ្ញាធរ និងការលំបាករបស់ពួកគេ ក្នុងការចូលទៅជួបប្រាស្រ័យជាមួយអ្នកប្រកបរបរផ្លូវភេទ - អ្នកប្រកបរបរផ្លូវភេទជាច្រើន បង្ខំខ្លួនប្រកបរបរនេះដោយលួចលាក់ ព្រោះតែការភ័យខ្លាចពីការចាប់ខ្លួន។ ការធ្លាក់ ចូលចាប់ និងការបិទផ្ទះបន ជំរុញឲ្យអ្នកប្រកបរបរផ្លូវភេទជាច្រើន បង្វិលពីការធ្វើការ តាមផ្ទះបន មកជាការធ្វើការងារតាមដងវិថី ឬនៅតាមទីកន្លែងកម្សាន្តនានាដូចជា រង្គសាល ខារាអូខេ*

---

41 អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសន៍ជាមួយអង្គការលីកាដូ ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ និងអង្គការបណ្តាញបុរសស្ត្រីអភិវឌ្ឍន៍កម្ពុជា (CNMWD) នៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០០៩ រាជធានីភ្នំពេញ។

42 កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា១៥ និងសូមមើល ម៉ែនហ្វ្រិត ណ៉ូវីត *កតិកាសញ្ញា អង្គការសហប្រជាជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ៖ សេចក្តីអត្ថាធិប្បាយលើកតិកាសញ្ញា ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ* បោះពុម្ពលើកទី២ ដោយមានការកែប្រែ (ខេល អែម រ៉េន៖ អិនហ្វេល ឆ្នាំ២០០៥) ទំព័រ៣៦១។

*ឬកន្ទែងម៉ាស្សា។ បញ្ហានេះធ្វើឲ្យមានការលំបាកកាន់តែច្រើនឡើង។ សម្រាប់អ្នកធ្វើការខាងការអប់រំ ផ្ទាល់ ក្នុងការទាក់ទងអ្នកប្រកបរបរផ្លូវភេទ។*

*នៅរាជធានីភ្នំពេញ អង្គការសុខភាពគ្រួសារអន្តរជាតិ ដែលជាអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិមួយ ផ្តោតការយកចិត្តទុកដាក់លើបញ្ហាសុខភាពសាធារណៈ និងការអភិវឌ្ឍ ដែលបំពេញការងារក្នុងប្រទេសកម្ពុជា បានរាយការណ៍ថា លទ្ធភាពរបស់ពួកគេក្នុងការអប់រំផ្ទាល់ ក្នុងចំណោមអ្នកប្រកបរបរផ្លូវភេទនៅតាមផ្ទះបន បានធ្លាក់ចុះពី ៩៦ ភាគរយ ក្នុងខែតុលា-ធ្នូ ឆ្នាំ២០០៧ មកនៅ ៨៤ ភាគរយ ក្នុងខែមករា-មីនា ឆ្នាំ២០០៨ និងក្នុងចំណោមអ្នកប្រកបរបរផ្លូវភេទ "ឯករាជ្យ" ពី ៩០ ភាគរយមកនៅ ៨០ភាគរយ។[43] ពួកគេបានកត់សម្គាល់ពីកំណើនតិចតួចក្នុងចំនួនអ្នកប្រកបរបរផ្លូវភេទ "ឯករាជ្យ" ក្នុងអំឡុងពេលទន្ទឹមគ្នានោះ។[44] អ្នកប្រកបរបរផ្លូវភេទខ្លះ បានប្រាប់អង្គការឃ្លាំមើលសិទ្ធិមនុស្សថា ពួកគេឈប់ដាក់ស្រោមអនាម័យតាមខ្លួនហើយ ពីព្រោះ "ជនណាក៏ដោយដែលគេរកឃើញមានស្រោមអនាម័យជាប់ខ្លួន នឹងត្រូវចាប់ខ្លួន"។[45]*

43 អង្គការសុខភាពគ្រួសារអន្តរជាតិ(FHI) "ច្បាប់ប្រឆាំងការជួញដូរមនុស្ស និងឥទ្ធិពលរបស់វាទៅលើអ្នកបម្រើការងារផ្នែកសេវាកម្សាន្ត" អ្នកធ្វើការផ្នែកសេវាកម្សាន្ត និងកម្មវិធីអតិថិជន ថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៨។
44 របាយការណ៍របស់អង្គការសុខភាពគ្រួសារអន្តរជាតិ (FHI) មិនបានផ្តល់និយមន័យនៃអ្នក "ប្រកបបុខរបរឯករាជ្យ" ទេ ប៉ុន្តែនៅក្នុងបរិបទនេះ វាទំនងដូចជាមានន័យសំដៅដល់ ជនទាំងឡាយដែលមិនធ្វើការនៅតាមផ្ទះបន។
45 ស៊ូ សុទ្ធាវី ប្រធានអង្គការបណ្តាញបុរសស្ត្រីអភិវឌ្ឍន៍កម្ពុជា រាជធានីភ្នំពេញ ថ្ងៃទី២៥ កក្កដា ឆ្នាំ២០០៩។

## គោលការណ៍ណែនាំ និងសេចក្តីពន្យល់ច្បាប់ ឆ្នាំ២០០៨

*នៅក្នុងកិច្ចប្រឹងប្រែងមួយ ដើម្បីសម្រាលកង្វល់ខ្វះដែលលើកឡើងដោយក្រុមសង្គមស៊ីវិលអំពីការកើនឡើងនូវ អំពើរំលោភបំពានលើអ្នកប្រកបរបរផ្លូវភេទ ដែលប្រព្រឹត្តដោយអាជ្ញាធរនានានោះ នៅក្នុងខែវិច្ឆិកា ឆ្នាំ២០០៨ ក្រុមការងារដឹកនាំការប្រយុទ្ធប្រឆាំងអំពើជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មលើពលកម្មមនុស្ស ការធ្វើអាជីវកម្ម ផ្លូវភេទលើស្ត្រីនិងកុមារ បានដាក់ចេញនូវ "គោលការណ៍ណែនាំ ស្តីពីការអនុវត្តច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។" ខណៈដែលគោលការណ៍ណែនាំនេះ ជាឧបករណ៍ មានប្រយោជន៍ប្រកបដោយសក្តានុពលសម្រាប់អាជ្ញាធរនៅគ្រប់លំដាប់ជាន់ថ្នាក់ ប្រតិបត្តិច្បាប់នេះ បែជាគោលការណ៍ណែនាំទាំងនេះ មិនមានអនុភាពអនុវត្តទៅវិញ។ ហើយមកទល់នឹងខែមេសា ឆ្នាំ២០១០ វាហាក់បីដូចជា មន្ត្រីរដ្ឋាភិបាល នគរបាល និងអង្គការក្រៅរដ្ឋាភិបាល មួយចំនួនមិនបានដឹងថាមានគោលការណ៍នេះផងទេ។*

*គោលការណ៍ណែនាំនេះ បានចែងយ៉ាងច្បាស់ៗថា សិទ្ធិរបស់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស និងអ្នកប្រកបរបរផ្លូវភេទ ត្រូវតែគោរព។ អ្នកប្រកបរបរផ្លូវភេទត្រូវចាត់ទុកជា "ជនរងគ្រោះនៃអំពើសញ្ចារកម្ម។ អំពើពេស្យាចារ មិនមែនជា បទល្មើសទេ ដូច្នេះបុគ្គលពេស្យាចារ មិនត្រូវទទួលរងនូវការដាក់ទណ្ឌកម្ម ថាជាអ្នកប្រព្រឹត្តិបទល្មើសទេក្រោមច្បាប់ថ្មីនេះ។"*

*គោលការណ៍ណែនាំនេះ ចែងថា ប្រតិបត្តិការបង្ក្រាប អាចអនុវត្តទៅបាន លុះត្រាណាតែមានការស្រាវជ្រាវ ស៊ើបអង្កេតជាមុន និងប្រមូលបាននូវភស្តុតាង ហើយរាល់ការឆែកឆេរទីតាំង និងការប្រមូលភស្តុតាង ត្រូវគោរពអោយបានមឺងម៉ាត់ ទៅតាមគោលការណ៍ដែលច្បាប់បានកំណត់។ ទ្រព្យសម្បត្តិជាកម្មសិទ្ធិរបស់ជនរងគ្រោះនៃអំពើជួញដូរ ឬអ្នកប្រកបរបរផ្លូវភេទ ដែលត្រូវបានដកហូត ត្រូវប្រគល់ឲ្យពួកគេ វិញ។*

*គោលការណ៍ណែនាំនេះក៏ចែងផងដែរថា សកម្មភាពបង្ក្រាបដែលអាជ្ញាធរអាចធ្វើបាន គប្បីត្រូវផ្អែកលើហេតុការណ៍ជាក់ស្តែងដូចជា៖ " បើមានបណ្តឹង ពីប្រជាពលរដ្ឋដែល រស់នៅជុំវិញទីតាំងនៃអំពើសញ្ចារកម្ម  បើមានបណ្តឹងថាមានជនរងគ្រោះណាម្នាក់ ត្រូវគេបង្ខំឲ្យប្រកបរបរពេស្យាចារ បើសិនជាមានពេស្យាចារកុមារ និងប្រសិនជា អំពើសញ្ចារកម្ម ធ្វើឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈ។"[46]*

*គោលការណ៍**ណែនាំ**នេះ គ្របដណ្តប់ផងដែរលើការ**ដោះស្រាយចំពោះ** ជនរងគ្រោះ នៃការជួញដូរនិងអ្នកប្រកបរបរផ្លូវភេទ ដោយចែងថា ត្រូវសម្ភាសន៍**យកព័ត៌មានពី** ជនរងគ្រោះដោយគ្មានការ**អូសបន្លាយ** ពេលវេលា ឬដោយគ្មានការ**បង្ខាំង ជនរងគ្រោះទុក។ បើជនរងគ្រោះជាអនិតិជន** ត្រូវប្រគល់ទៅអោយមន្ទីរសង្គមកិច្ច **អតីតយុទ្ធជន និងយុវនីតិសម្បទា** ចំណែកឯ**ជនរងគ្រោះជានីតិជន ត្រូវផ្អែកលើការ** យល់ព្រម **បើពួកគេយល់ព្រមត្រូវប្រគល់ទៅអោយមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា តែបើមិនមិនយល់ព្រមទេ "ត្រូវអនុញ្ញាតិអោយពួកគេ វិលត្រឡប់ ទៅលំនៅដ្ឋានរបស់ពួកគេវិញ។"***

*លើសពីគោលការណ៍ណែនាំនេះ ក្រសួងយុត្តិធម៌ដោយមានការគាំទ្រពី អង្គការ យូនីសេហ្វ ក៏កំពុងតែព្រាងសេចក្តីពន្យល់ លើមាត្រានីមួយៗនៃច្បាប់ ដើម្បីជួយដល់ ការបកស្រាយនិងការអនុវត្តន៍។ ឧទាហរណ៍ សេចក្តីពន្យល់ច្បាប់ផ្តល់នូវសេចក្តី ពិស្តារអំពីអ្វីជា អំពើអូសទាញ និងអ្វីដែល មិនមែនជាអំពើអូសទាញ ក្រោម មាត្រា ២៥(៣)។ ទោះជាយ៉ាងណាក៏ដោយ ដោយហេតុថា សេចក្តីពន្យល់ច្បាប់ គ្មានអានុភាពច្បាប់សំរាប់អនុវត្ត នោះសេចក្តីពន្យល់ទាំងនេះ នឹងមិនទំនងជាផ្តល់ កិច្ចការពារគ្រប់គ្រាន់ ទាក់ទងនឹងបទប្បញ្ញត្តិទាំងឡាយ ដែលមានចែងក្នុងច្បាប់ ឡើយ។*

46 គោលការណ៍ណែនាំស្តីពីការអនុវត្តច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។ បកប្រែមិនផ្លូវការដោយយូអិនអាយអេភី (UNIAP)។

## ប្រវត្តយូរលង់នៃការបង្ក្រាបអ្នកប្រកបរបរផ្លូវភេទ

*ការចាប់ខ្លួន អំពើឃោរឃៅ និងអំពើរំលោភបំពានរបស់នគរបាល លើអ្នកប្រកបរបរផ្លូវភេទក្នុងប្រទេសកម្ពុជា បានកើតឡើងជាច្រើនទសវត្សរ៍មកហើយ។ ក្នុងកាលៈទេសៈជាច្រើន វិធានការបង្ក្រាបទាំងនេះធ្វើឡើងដោយអាជ្ញាធរមូលដ្ឋាន ប៉ុន្តែពួកគេក៏ត្រូវបានបញ្ជាពីថ្នាក់ដឹកនាំជាន់ខ្ពស់របស់រដ្ឋាភិបាលកម្ពុជាឲ្យធ្វើការបង្ក្រាបផងដែរ។ វិធានការបង្ក្រាបបែបនេះ ទទួលរងការរិះគន់ដដែលៗពីអង្គការសិទ្ធិមនុស្ស ក្នុងស្រុក និងអន្តរជាតិ និងអង្គការខាងការប្រយុទ្ធប្រឆាំងនឹងមេរោគអេដស៍/ជំងឺ អេដស៍។*[47]

*យោងតាមប្រភពផ្សាយព័ត៌មាន ក្នុងឆ្នាំ១៩៩៤ មួយឆ្នាំបន្ទាប់ពីការបោះឆ្នោតទូទៅដែលគាំទ្រដោយអ៊ុនតាក់ នគរបាលបានចាប់អ្នកប្រកបរបរផ្លូវភេទមួយចំនួន ដែលមិនដឹងតួលេខច្បាស់ និងបានផាកពិន័យជាប្រាក់ដល់ម្ចាស់ផ្ទះបនជាច្រើនរយនាក់ នៅក្នុងវិធានការបង្ក្រាប សកម្មភាពប្រកបរបរផ្លូវភេទនៅរាជធានីភ្នំពេញ។ ម្ចាស់ ផ្ទះបនមិនដែលត្រូវបាននាំយកមកកាត់ទោស ឬផ្ទះបនត្រូវបានបិទជាស្ថាពរទេ។ អង្គភាពនគរបាលប្រឆាំងពេស្យាចារនៅរាជធានីភ្នំពេញ បានពន្យល់ថា ពួកគេត្រូវបានណែនាំឲ្យចាប់អ្នកប្រកបរបរផ្លូវភេទទាំងអស់ យកមក"អប់រំ" និងដោះលែងពួកគេវិញក្នុងរយៈពេល ៤៨ម៉ោង។ មេអង្គភាពនេះបានប្រាប់អ្នកសារព័ត៌មានថា "ខ្ញុំគិតថាវាមិនមែនជាការជោគជ័យ១០០ភាគរយនោះទេប៉ុន្តែយ៉ាងហោចណាស់*

47របាយការណ៍នានាស្តីពីវិធានការបង្ក្រាបអ្នកប្រកបរបរផ្លូវភេទ តាំងពីឆ្នាំ១៩៩៤ មានជាអាទិ៍ ៖ អិនឌូឆាយណា ដាយចេស ថ្ងៃទី៩ ខែសីហា ឆ្នាំ១៩៩៥, លោកថូម៉ាស ហាំម៉ាបឺក "របាយការណ៍ដាក់ជូនមហាសន្និបាតអង្គការសហប្រជាជាតិ" ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ១៩៩៨, គ្រិស សេធី "ការបង្ក្រាបរបស់នគរបាល ជួយបោសម្អាតពេស្យាចារកុមារ" គ្រិះស្ទាន សាយអិន ម៉ូនិទ័រ ថ្ងៃទី៨ ខែមករា ឆ្នាំ១៩៩៨, ដេប្រា បយ "រួមគ្នា អ្នកប្រកបរបរផ្លូវភេទមានសម្លេងខ្លាំង" អ៊ិនធីប្រេស សឺវិស ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៩, សហជីពស្រ្តីរកស៊ីផ្លូវភេទកម្ពុជា និងសមាគមន៍អភិវឌ្ឍន៍ស្រ្តីកម្ពុជា "ការស្ទង់មតិអំពីការរំលោភសិទ្ធិមនុស្សរបស់អ្នកប្រកបរបរផ្លូវភេទដោយនគរបាលក្នុងខណ្ឌទួលគោក" ខែសីហា/កញ្ញា ឆ្នាំ២០០២, ខាធីម៉ាក "នគរបាលកម្ពុជា បិទផ្ទះបនដែលមានកុមារបំរើផ្លូវភេទជាច្រើនកន្លែង" ឌឹ អ៊ីនឌិភិនឌិន ថ្ងៃទី២៥ ខែមករា ឆ្នាំ២០០៣, " នគរបាលបិទកន្លែងម៉ាស្សា ក្នុងវិធានការបង្ក្រាបចុងក្រោយបំផុត" ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០៥។ មាននៅគេហទំព័រ http://www.asiafinest.com/forum/index.php?showtopic=36323 (បានចូលមើលគេហទំព័រនេះ ថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១០)។

47 ក្រសួងការបរទេសសហរដ្ឋអាមេរិក, ការិយាល័យប្រជាធិបតេយ្យ សិទ្ធិមនុស្ស និងការងារ "របាយការណ៍ស្តីពីប្រទេសកម្ពុជា អំពី ការអនុវត្តសិទ្ធិមនុស្ស ឆ្នាំ២០០១" ថ្ងៃទី៤ ខែមីនា ឆ្នាំ ២០០២។

នគរបាលពួកយើងបានបញ្ឈប់ពួកស្ត្រីពេស្យា ដែលអង្គុយ ឬដើរចរច្រប់ នៅតាមដង វិថីនៃ [សង្កាត់ភ្លើងក្រហម] ទួលគោក ដែលបង្ករឲ្យខូចខាតដល់សោភ័ណភាព រាជធានី និងវប្បធម៌ ហើយស្ត្រីពេស្យាមួយចំនួនទទួលស្គាល់ថា ការធ្វើជាស្ត្រីពេស្យា មិនល្អទេ។”[48]

ក្នុងខែវិច្ឆិកា ឆ្នាំ១៩៩៧ នគរបាលបានចាប់ផ្តើមធ្វើយុទ្ធនាការបង្រ្កាបមួយទៀតលើ ផ្ទះបន ដែលចាប់ប្រមូលបានអ្នកប្រកបរបរផ្លូវភេទជាង៥០០នាក់ មកដល់ខែមករា ឆ្នាំ១៩៩៨។ អ្នកប្រកបរបរផ្លូវភេទ និងអង្គការមិនមែនរដ្ឋាភិបាល ដែលគាំទ្រស្ត្រី និងកុមារ បានរាយការណ៍ពី អំពើព្រៃផ្សៃរបស់នគរបាលប្រព្រឹត្តិលើ អ្នកប្រកបរបរ ផ្លូវភេទក្នុង អំឡុងពេលបង្រ្កាប។[49]

នៅពេលខ្លះ ការបង្គាប់បញ្ជាឲ្យបិទចោលតំបន់ភ្លើងក្រហម ត្រូវបានចេញដោយ នាយករដ្ឋមន្ត្រីខ្លួនឯងផ្ទាល់។ ឧទាហរណ៍ នៅចុងឆ្នាំ២០០១ លោកហ៊ុន សែន ខ្លួនឯងបានចេញបទបញ្ជាមួយ ឲ្យបិទផ្ទះបន បន្ទាប់ពីមានជម្លោះបាញ់ប្រោះមួយ នៅ ពេលយប់អាធ្រាតក្នុងរាជធានីភ្នំពេញ។ ក្រសួងការបរទេសសហរដ្ឋអាមេរិក បានកត់សម្គាល់នៅក្នុងរបាយការណ៍ឆ្នាំ២០០២ របស់ខ្លួន អំពីការអនុវត្តសិទ្ធិមនុស្ស នៅក្នុង ប្រទេសកម្ពុជាថា ៖ “ក្នុងខែធ្នូ [ឆ្នាំ២០០១] រដ្ឋាភិបាលបានចាប់ផ្តើមការបង្រ្កាប ជាទូទៅមួយលើសកម្មភាពពេស្យាចារ ដែលធ្វើឲ្យស្ត្រីពេស្យា កាន់តែងាយរងគ្រោះ ដោយអំពើបំភិតបំភ័យ អំពើហិង្សា អំពើចោរកម្ម រំលោភសេពសន្ថវៈ និងជំងឺ។”[50]

រលកថ្មីៗនៃការបិទផ្ទះបនបានប្រព្រឹត្តិឡើងនៅចុងឆ្នាំ២០០៧ បន្ទាប់ពីក្រសួង មហាផ្ទៃ បានចាប់ផ្តើមបើកយុទ្ធនាការប្រឆាំងអំពើជួញដូរមនុស្ស រត់ពន្ធមនុស្ស អាជីវកម្មលើមនុស្ស

48 ម៉ាង ចាន់ណូ “បោះជំហាន ដើម្បី ដាក់ពេស្យាចារអោយទៅជាមុខរបរស្របច្បាប់ ” *ភ្នំពេញប៉ុស្តិ* ថ្ងៃទី២៧ ខែមករា ឆ្នាំ១៩៩៥។

49 គ្រិស សេធី ធី “ការបោសម្អាតរបស់នគរបាល ជួយពេស្យាកម្មកុមារ ៖ កម្ពុជាអនុញ្ញាតឲ្យមានជំនួញផ្លូវភេទ ប៉ុន្តែឥឡូវសំដៅចាប់ជនទាំងឡាយ ដែលបង្ខំក្មេងស្រីឲ្យចូលក្នុងជំនួញនេះ” គ្រិស្ទាន សាយអិន ម៉និត័រ ថ្ងៃទី៨ ខែមករា ១៩៩៨។

50 ក្រសួងការបរទេសសហរដ្ឋអាមេរិក, ការិយាល័យប្រជាធិបតេយ្យ សិទ្ធិមនុស្ស និងការងារ “របាយការណ៍ស្តីពីប្រទេសកម្ពុជា អំពី ការអនុវត្តសិទ្ធិមនុស្ស ឆ្នាំ២០០១” ថ្ងៃទី៤ ខែមីនា ឆ្នាំ២០០២។

និងការប្រកបរបរផ្លូវភេទ ក្នុងខែកក្កដា។[51] ផែនការនោះ បាន ផ្តល់អំណាចដល់នគរបាលយុត្តិធម៌ និងនគរបាលប្រឆាំងការជួញដូរ នៅគ្រប់កម្រិត ខេត្ត និងរាជធានី ចាប់អនុវត្តវិធានការនានា បង្ក្រាបទីកន្លែងកម្សាន្ត ដើម្បីទប់ស្កាត់ អំពើជួញដូរ និងការប្រកបរបរផ្លូវភេទ។ ជាផ្នែកមួយនៃយុទ្ធនាការនេះ នគរបាល ខេត្តបាត់ដំបង និងបន្ទាយមានជ័យបានបិទចោលតំបន់ផ្ទះបនក្នុងខេត្តទាំងពីរ នៅចុងឆ្នាំ២០០៧ និងដើមឆ្នាំ២០០៨។ នៅខេត្តបន្ទាយមានជ័យវិធានការបង្ក្រាបនេះ បានចាប់ផ្តើមធ្វើឡើងនៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៨ ខណៈពេលដែលនគរបាល មានចំនួនច្រើនជាងប្រាំរថយន្ត បានធ្វើដំណើរទៅតំបន់ភ្លើងក្រហម។ នគរបាល បានចាប់អ្នកប្រកបរបរផ្លូវភេទ និងម្ចាស់ផ្ទះបន និងបានបញ្ជាឲ្យបិទផ្ទះបនទាំងអស់ ក្នុង ស្រុកសេរីសោភ័ណ និងស្រុកមង្គលបូរី។ អ្នកប្រកបរបរផ្លូវភេទ ត្រូវបានឃុំឃាំង រហូតដល់ពីរថ្ងៃ ដើម្បីសួរយកចម្លើយ និងបន្ទាប់មកឲ្យពួកគេត្រឡប់ទៅស្រុកភូមិ របស់ពួកគេវិញ ឬប្រគល់អោយទៅមណ្ឌលដែលគ្រប់គ្រងដោយ អង្គការក្រៅ រដ្ឋាភិបាល បន្ទាប់ពីការព្រមានថាពួកគេនឹងត្រូវចាប់ខ្លួន ប្រសិនបើពួកគេត្រឡប់មក តំបន់ភ្លើងក្រហមម្តងទៀត។[52]

ការរំលោភបំពានប្រឆាំងនឹងអ្នកប្រកបរបរផ្លូវភេទ បានទាក់ទាញចំណាប់អារម្មណ៍ពី បណ្តាញសារព័ត៌មាន បន្ទាប់ពីការអនុម័តច្បាប់ថ្មីប្រឆាំងនឹងអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ ដែលបានជំរុញឲ្យមានការតវ៉ាពីក្រុមស្វែងរកការគាំទ្រសំរាប់ អ្នកប្រកបរបរផ្លូវភេទ។ ការដាក់បញ្ចូលលាយលំគ្នានូវអំពើជួញដូរមនុស្ស និង ការងារផ្លូវភេទ និងការផ្តាប់ផ្តន់មន្ត្រីសហរដ្ឋអាមេរិក និងម្ចាស់ជំនួយ បាននាំឲ្យមាន រលកនៃការចាប់ខ្លួន និងការឆ្មក់ចូលផ្ទះបន ដែលលោកឧត្តមសេនីទោ ប៊ិត គឹមហុង

51 "ផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស រត់ពន្ធមនុស្ស អំពើធ្វើអាជីវិកម្មមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រីនិងកុមារ" ក្រសួងមហាផ្ទៃ រាជរដ្ឋាភិបាលកម្ពុជា លេខ០១២ ផ.ក. ចុះហត្ថលេខា នៅរាជធានីភ្នំពេញ ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៧។
52 អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសន៍ជាមួយអ្នកប្រកបរបរផ្លូវភេទឯករាជ្យ និងស្ត្រីខារាអូខេ ចំនួនប្រាំពីរនាក់ នៅក្នុងទីរួមខេត្តបាត់ដំបង ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៩, អង្គការឃ្លាំមើលសិទ្ធិមនុស្ស សម្ភាសន៍ជាមួយបុគ្គលិកអង្គការអាដ័ហុក និងសមាគមន៍ស្ត្រីកម្ពុជាដើម្បីសន្តិភាព និងការអភិវឌ្ឍន៍, ខេត្តបាត់ដំបង ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៩។

*នាយកនៃនាយកដ្ឋានប្រឆាំងការជួញដូរមនុស្សរបស់ក្រសួងមហាផ្ទៃ បានមាន ប្រសាសន៍ដូច្នេះ ក្នុងខែធ្នូ ឆ្នាំ២០០៨ ៖*

> ការឆ្មក់ចូលផ្ទះបន និងការចុះប្រមូលអ្នករកស៊ីផ្លូវភេទតាមដងវិថី បានបង្ហាញពី ការប្តេជ្ញារបស់រដ្ឋាភិបាលដើម្បីបញ្ចប់អំពើជួញដូរមនុស្សសំរាប់ផ្លូវភេទ ... ច្បាប់ ថ្មី ជាវិធានការមួយនៃវិធានការមួយចំនួន ធ្វើឡើងដោយរដ្ឋាភិបាលកម្ពុជា ក្នុង រយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ ដើម្បីបង្ហាញថា វាជាការបង្ក្រាបអាជីវកម្ម ផ្លូវភេទ។[53]

*លោកគឹមហុង បានច្រានចោលរបាយការណ៍ដែលថា ការអនុម័តច្បាប់ថ្មីនេះ បាននាំ ឲ្យមានការរំលោភបំពានមួយចំនួន ពីព្រោះលោកបាននិយាយថា លោកមិនបាន ទទួលបណ្តឹងណាមួយពីជនរងគ្រោះទេ[54] ក៏ប៉ុន្តែ សូម្បីតែ រដ្ឋាភិបាលសហរដ្ឋអាមេរិក ក៏ទទួលស្គាល់ថា ការបង្ក្រាបរបស់នគរបាល មិនបានផលទេ ក្នុងការកំណត់ និងជួយ ជនរងគ្រោះនៃអំពើជួញដូរ ។[55] ក្នុងឆ្នាំ២០០៩ នគរបាល និងអាជ្ញាធរមូលដ្ឋាន បានបន្តចាប់ខ្លួនអ្នកប្រកបរបរផ្លូវភេទ ដែលធ្វើការនៅតាមដងវិថី និងសួនច្បារ សាធារណៈ អំឡុងពេលបោសសម្អាត និងចុះចាប់ប្រមូលម្តងម្កាល នៅពេលរាត្រី ។ ក្នុងរាជធានីភ្នំពេញ ការបោសសម្អាតទាំងនេះបានធ្វើឡើងជាពិសេស នៅតាមដងវិថី និងតាមសួនច្បារនៅជិត*

---

53 "កម្ពុជា ប្រឈមមុខនឹងបញ្ហាប្រតិបត្តិច្បាប់ប្រឆាំងការជួញដូរផ្លូវភេទថ្មី" អាហ្សង់ ហ្វ្រង់ប្រេស ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៨។

54ដូចគ្នា

55 ក្រសួងការបរទេសសហរដ្ឋអាមេរិក, *របាយការណ៍ស្តីពីការជួញដូរមនុស្សឆ្នាំ២០០៩ - ប្រទេសកម្ពុជា* ថ្ងៃទី១៦ខែមិថុនាឆ្នាំ២០០៩ សរសេរថា ចំពោះប្រទេសកម្ពុជា ៖

> ពីព្រោះតែច្បាប់ថ្មីនេះ គ្របដណ្តប់លើបទល្មើសដ៏ច្រើន  មន្ត្រីរដ្ឋាភិបាលមិនគ្រប់គ្នាទាំងអស់ទេ ដែលចេះកំនត់ឲ្យឃើញពី ភាពខុសគ្នារវាង មាត្រានៃច្បាប់ស្តីពី បទល្មើសជួញដូរមនុស្ស និងបទល្មើសមិនជួញដូរ ដូចជាអំពើពេស្យាចារ រូបភាពនិងសម្ភារៈអាសអាភាស និងការ រំលោភផ្លូវភេទលើកុមារ។ ជាលទ្ធផល មន្ត្រីប្រតិបត្តិច្បាប់បានផ្តោតតែទៅលើបទល្មើសដែលពាក់ព័ន្ធនឹងអំពើពេស្យាចារ ហើយនគរបាល ជាច្រើនរូប តុលាការ និងមន្ត្រីរដ្ឋាភិបាលដទៃទៀត ហាក់ដូចជាជឿថា ការអនុវត្តមាត្រាទាំងអស់នៃច្បាប់នេះ ដែលទាក់ទងនឹងអំពើ ពេស្យាចារ  គឺជាការចូលរួមចំណែកក្នុងកិច្ចប្រឹងប្រែងប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស។
>
> បន្ទាប់ពីការអនុម័តច្បាប់ កងកម្លាំងនគរបាលកម្ពុជាបានដឹកនាំការបង្ក្រាបជាច្រើនលើកលើ ផ្ទះបន និងឃុំឃាំងស្ត្រីក្នុងមុខរបរពេស្យាចារ មួយចំនួនធំ ប៉ុន្តែខកខានក្នុងការចាប់ខ្លួន ស៊ើបអង្កេត ឬចោទប្រកាន់ជនមួយចំនួនធំ ដែលពាក់ព័ន្ធនឹងបទល្មើសជួញដូរមនុស្ស។ បន្ថែម លើសនេះទៀត ស្ត្រីក្នុងរបរពេស្យាសចារដែលត្រូវបានគេឃុំខ្លួនអាចមានរាប់បញ្ចូលទាំង ជនរងគ្រោះនៃអំពើជួញដូរ ថ្វីបើនគរបាលបាន ធ្វើការប៉ុនប៉ងខ្លះៗ ដើម្បីកំណត់រក ជួយ ឬការពារពួកគេក៏ដោយ។ មាននៅគេហទំព័រ http://www.unhcr.org/refworld/ docid/ 4a4214c82d.html, (បានចូលមើលគេហទំព័រនេះ ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១០)។

*វត្តភ្នំ ផ្សារចាស់ ក្នុងខណ្ឌដូនពេញ វិមានឯករាជ្យ ក្នុង ខណ្ឌចំការមន នៅក្នុងខណ្ឌទួលគោក ខណ្ឌ៧មករា និងខណ្ឌឫស្សីកែវ។*

*ការបោសសម្អាត និងចុះចាប់ប្រមូល គឺជាព្រឹត្តិការណ៍ធ្វើឡើងម្តងហើយម្តងទៀត ជាទៀងទាត់ ដែលរឹតបណ្តឹងនៅពេលមានព្រឹត្តិការណ៍សំខាន់ៗនៅក្នុងរាជធានី ដូចជាថ្ងៃបុណ្យជាតិ ទស្សនកិច្ចរបស់អ្នកការទូត ឬព្រឹត្តិការណ៍អន្តរជាតិធំៗ។ អ្នកប្រកបរបរផ្លូវភេទ ត្រូវបានគេព័ទ្ធចាប់ប្រមូលយកទៅ ឃុំខ្លួនចំនួនពីរបីថ្ងៃ នៅឯ មន្ទីរសង្គមកិច្ចរាជធានី និងជាញឹកញយត្រូវបានដោះលែងវិញ បន្ទាប់ពីព្រឹត្តិការណ៍ នោះកន្លងផុតទៅ។ អ្នកប្រកបរបរផ្លូវភេទអាចត្រូវបានចាប់ក្នុងយុទ្ធនាការ បោសសម្អាតទ្រង់ទ្រាយធំ តាមដងវិថី ដែលគេចាប់ប្រមូលទាំងអ្នកគ្មានផ្ទះសម្បែង កុមាររស់តាមចិញ្ចើមថ្នល់ អ្នកសុំទាន និងអ្នកប្រើប្រាស់គ្រឿងញៀនផងដែរ។*

*ការចាប់ខ្លួនមួយចំនួន បានកើតឡើងដោយមិនមានមូលដ្ឋានច្បាប់ទាល់តែសោះ។ អ្នកប្រកបរបរផ្លូវភេទមួយចំនួន បានប្រាប់អង្គការឃ្លាំមើលសិទ្ធិមនុស្សអំពីរបៀបដែល នគរបាលបានចាប់ពួកគេបែបងាយៗ ដើម្បីប្លន់ ឬជម្រិតទារលុយពីពួកគេ ចាប់រំលោភសេពសន្ថវៈលើពួកគេ ឬឲ្យពួកគេលាងសម្អាតបង្គន់ ឬការិយាល័យក្នុង ស្ថានីយ៍នគរបាល។*

*ការបោសសម្អាត តាមសួនច្បាររាជធានីភ្នំពេញ និងតាមដងវិថីនានា ត្រូវបានអនុវត្ត ដោយ ឈរលើមូលដ្ឋាននៃការរៀបចំសណ្តាប់ និងសន្តិសុខសាធារណៈ  តាម បទបញ្ជារបស់អភិបាលខណ្ឌ អភិបាលក្រុងឬខេត្ត ឬក្រសួងមហាផ្ទៃ។[56] ការបោស សម្អាតទាំងនេះដឹកនាំធ្វើដោយនាយនគរបាលតាមខណ្ឌ ច្រើនជាងនគរបាល ប្រឆាំងការជួញដូរមនុស្ស។*

56 ចៅហ្វាយស្រុក/ខណ្ឌ ឬអភិបាលខេត្ត/ក្រុង រាជធានី ជាអ្នកដឹកនាំកម្លាំងដែលគេហៅថា "*គណៈបញ្ជាការឯកភាព*" ដែលមានតួនាទី ដោះស្រាយចំពោះសណ្តាប់ធ្នាប់ និង សន្តិសុខសាធារណៈក្នុងតំបន់គ្រប់គ្រងរបស់ពួកគេ។

*លិខិតមួយច្បាប់របស់ក្រសួងមហាផ្ទៃ ផ្ញើជូនអង្គការសម្ព័ន្ធខ្មែរជំរឿននិងការពារ សិទ្ធិមនុស្ស (លីកាដូ) ក្នុងខែកញ្ញា ឆ្នាំ២០០៨ បានសរសេរថា ការបោសសម្អាតនោះ ធ្វើឡើងដើម្បីរៀបចំសណ្តាប់ធ្នាប់សាធារណៈ។*

> ស្ត្រីរកស៊ីផ្លូវភេទ បានធ្វើអោយបាត់បង់ សណ្តាប់ធ្នាប់ក្នុងទីសាធារណៈ និងធ្វើឲ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរ និងសីលធម៌ សង្គមជាតិ ។ មិនតែប៉ុណ្ណោះមានក្រុមខ្លះបានរៀបចំជាបណ្តាញទាក់ថ្កក់បុរសៗដែលធ្វើដំណើរតាមដងផ្លូវ ហើយពេលខ្លះពួកគេបានរៀបចំជាអន្ទាក់ ដើម្បីគំរាមសំឡុតយកសម្ភារៈ លុយកាក់ពីភ្ញៀវទៀតផង ។ ដោយមានការដឹកនាំពីឯកឧត្តម កែប ជុតិមា អភិបាលរាជធានីភ្នំពេញ និងដើម្បីអនុវត្តគោលការណ៍របស់ គណៈបញ្ជាការ ឯកភាពរាជធានីភ្នំពេញ គណៈបញ្ជាការឯកភាពខណ្ឌដូនពេញ បានចុះត្រួត ពិនិត្យ និងប្រមែប្រមូលនារីរកស៊ីផ្លូវភេទ ជនអនាថា អ្នកដើរសុំទាន និងក្មេង ហិតកាវ ដែលតែងតែស្នាក់នៅលើវាលស្មៅ តាមសួនច្បារ តាមចិញ្ចើមថ្នល់ និងតាមសំយ៉ាបផ្ទះ ដែលធ្វើឲ្យប៉ះពាល់ដល់សន្តិសុខសណ្តាប់ធ្នាប់ សង្គម ... ការប្រមូលស្ត្រីរកស៊ីផ្លូវភេទ ក្មេងអនាថា ក្មេងហិតកាវ អ្នកសុំទានតាមដងផ្លូវ និងតាមសួនច្បារ របស់សាលាខណ្ឌដូនពេញ គឺជាតួនាទី និងភារកិច្ច ក្នុងការ រក្សាសន្តិសុខសណ្តាប់ធ្នាប់សង្គម ។[57]

*ទស្សនៈនេះ ត្រូវបានបញ្ជាក់នៅក្នុងអត្ថាធិប្បាយរបស់រដ្ឋាភិបាលក្នុងខែសីហា ឆ្នាំ២០០៩ លើរបាយការណ៍របស់ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សអង្គការ សហប្រជាជាតិ ៖*

> ប៉ូលីសរាជធានីភ្នំពេញ បានចាប់ផ្តើមធ្វើការបោសសំអាតអ្នករកស៊ីផ្លូវភេទ អ្នកសុំទាន ក្មេងតាមចិញ្ចើមផ្លូវ អ្នកញៀនថ្នាំ ជនពិការ និងជនដទៃទៀត ក្នុង គោលបំណង ... ដើម្បីរៀបចំទីក្រុងឲ្យមានសោភ័ណភាពដើម្បីទាក់ទាញភ្ញៀវ ទេសចរជាតិ និងអន្តរជាតិ ចូលមកធ្វើទស្សនកិច្ចនិងកំសាន្តនៅទីក្រុងភ្នំពេញ តាមរយៈការលើកស្ទួយវិស័យ ទេសចរ ហើយជនអានាថាតាមចិញ្ចើមផ្លូវទាំងនោះ

---

57 លិខិតលេខ១២១៩ ស.ជ.ណ. ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ផ្ញើទៅអង្គការលីកាដូ ពាក់ព័ន្ធនឹងលទ្ធផលស៊ើបអង្កេតរបស់រដ្ឋាភិបាល ចំពោះករណីរំលោភបំពាន ដែលគេបានរាយការណ៍ថា បានប្រព្រឹត្តិនៅមជ្ឈមណ្ឌលសង្គមកិច្ចរាជធានី របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

> ក៏ជាធនធានមនុស្សសម្រាប់ធ្វើការលើវិស័យកសិកម្មដែលត្រូវលើកទឹកចិត្ត និង ជំរុញឲ្យគាត់វិលត្រឡប់ទៅលំនៅដ្ឋានរបស់គាត់នៅតាមខេត្ត ក្រុង ដើម្បីឲ្យគាត់ប្រកបមុខរបរស្រែចំការវិញ។[58]

*លោកម៉ាន់ ឈឿន អតីតអភិបាលរងរាជធានីភ្នំពេញ បានប្រាប់អ្នកសារព័ត៌មានអំឡុងពេលនៃការបង្រ្កាបមួយ ក្នុងខែកក្កដា ឆ្នាំ២០០៩ ថា អ្នកគ្មានទីលំនៅ និង អ្នកប្រកបរបរផ្លូវភេទ បានធ្វើឲ្យខូចសោភ័ណភាពរាជធានីភ្នំពេញ។[59] មន្ត្រីមួយរូប ទៀត គឺអភិបាលរងខណ្ឌដូនពេញ លោកសុខ ពេញវុធ បានប្រាប់កាសែតភ្នំពេញ ប៉ុស្ដិ៍ថា គ្រប់ខណ្ឌទាំងអស់ក្នុងរាជធានី បានទទួលបទបញ្ជាឲ្យចាប់ប្រមូលអ្នក រស់តាមដងផ្លូវ ដែល នៅពេលនោះ ការបោសសម្អាតត្រូវធ្វើឡើងពីរដង ក្នុងមួយ សប្តាហ៍។ គាត់និយាយថា "ខណ្ឌដូនពេញជាបេះដូងនៃទេសចរ នយោបាយ និង សេដ្ឋកិច្ចរបស់រាជធានី។ ដើម្បីរក្សាបាននូវភាពស្អាតបាតរបស់រាជធានី ... យើងត្រូវ តែចាត់វិធានការបោសសម្អាត រហូតទាល់តែលែងមានមនុស្សរស់តាមដងផ្លូវ។[60]*

*ក្នុងខែឧសភា ឆ្នាំ២០០៩ នគរបាលបានឃុំខ្លួនអ្នកប្រកបរបរផ្លូវភេទ អ្នកប្រើគ្រឿងញៀន និងជនដទៃទៀតក្នុងខណ្ឌដូនពេញ ក្នុង "យុទ្ធនាការបោសសម្អាតវិថី" មុនកិច្ចប្រជុំថ្នាក់ រដ្ឋមន្ត្រីអាស៊ាន-សហភាពអឺរ៉ុប ក្នុងរាជធានីភ្នំពេញ។ លោកសុខ សម្បត្តិ អភិបាលខណ្ឌ ដូនពេញ បានលើកហេតុផលសំរាប់តម្រូវការរៀបចំអោយមាន "សន្តិសុខណ្តាប់ធ្នាប់ សង្គមដ៏ពេញលេញ" មុនកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីអាស៊ាន-សហភាពអឺរ៉ុប ក្នុងរាជធានី ភ្នំពេញ ដោយនិយាយថា អាជ្ញាធរនឹងបន្តបោសសម្អាត អ្នករកស៊ីផ្លូវភេទ និងជន សង្ស័យប្រើប្រាស់គ្រឿងញៀន ចេញពីដងផ្លូវ ហើយ គាត់បាននិយាយពីប្រតិបត្តិការ នោះថា*

---

58 ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ប្រចាំប្រទេសកម្ពុជា ដោយមានការធ្វើអត្ថាធិប្បាយពីរាជរដ្ឋាភិបាល នៃប្រទេសកម្ពុជា "របាយការណ៍ប្រចាំឆ្នាំ ២០០៨/៩" របាយការណ៍ ខែមករា ២០០៨ - មិថុនា ២០០៩ កថាខណ្ឌ ២៩ ទំព័រ៤៤។

59 យុន សាមាន និងបេថានី លិនសាយ "ក្រុមសិទ្ធិមនុស្សចោទរដ្ឋាភិបាលពីការដាក់ទោសលើអ្នកក្រីក្ររស់នៅភ្នំពេញ" *កាសែត ឌឹ ឃែមបូឌា ដេលី* ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៩។

60 វង្ស សុខេង និងស៊ីបាស្ទៀន ស្ត្រេងហ្វីអូ "ការឃុំខ្លួន ត្រូវបានគេថ្កោលទោសថាជា 'ការបង្កើតភាពរន្ធត់' " ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៩។

*"យើងត្រូវឆ្លើយតបទៅនឹងបំណងប្រាថ្នា [សាលារាជធានីភ្នំពេញ] ដើម្បីធ្វើយ៉ាងណាឲ្យមានសន្តិសុខសណ្តាប់ធ្នាប់សង្គម"។ "យើងនឹងបន្តបោសសម្អាតអ្នកប្រើប្រាស់គ្រឿងញៀន និងអ្នករកស៊ីផ្លូវភេទ ដែល មាននៅតាមដងផ្លូវ និងមាត់ទន្លេនៅពេលយប់។"[61]*

*ជាច្រើនខែ ក្នុងឆ្នាំ២០០៩ ដោយមានបទបញ្ជាពីរដ្ឋបាលមូលដ្ឋាន អាជ្ញាធរបានបង្កើនការបោសសម្អាតនៅតាមសួនច្បារសាធារណៈ និងតាមដងវិថីនានា ក្បែរវត្តភ្នំស្ថិតនៅកណ្តាលខណ្ឌដូនពេញ។ ជាឧទាហរណ៍ យោងតាមមន្ត្រីខណ្ឌ ដូនពេញ នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៩ កម្លាំងចម្រុះ[62] របស់ខណ្ឌដូនពេញបាន ចុះអនុវត្តការបោសសម្អាតក្រោមបញ្ជាផ្ទាល់ របស់អភិបាលរាជធានីភ្នំពេញ និង អភិបាលខណ្ឌដូនពេញ។[63] មន្ត្រីរូបនោះបានប្រាប់អ្នកសារព័ត៌មានថា "គោលបំណងនៃការបោសសម្អាតគឺដើម្បីបញ្ឈប់ស្ថានភាពអនាធិបតេយ្យ ដែល បង្ករឡើងដោយស្ត្រីប្រកបរបរផ្លូវភេទ ដែលឈរបក់ដៃហៅភ្ញៀវ ធ្វើឲ្យប៉ះពាល់ ប្រពៃណីជាតិខ្មែរ និងបង្ករឲ្យមានអសន្តិសុខនិងសណ្តាប់ធ្នាប់សង្គម ។"[64]*

*អាជ្ញាធររាជធានី បានថ្លែងជាសាធារណៈផងដែរថា ស្ត្រីប្រកបរបរផ្លូវភេទជាគោលដៅនៃការចាប់ខ្លួននិងឃុំខ្លួន ជាពិសេស ដើម្បីបង្ការការរីករាលដាល មេរោគអេដស៍។ ជាឧទាហរណ៍ យោងតាមសេចក្តីរាយការណ៍ពីសារព័ត៌មាន នគរបាលបានចាប់ខ្លួនស្ត្រីប្រកបរបរផ្លូវភេទចំនួន ១៧ នាក់នៅមុនពិធីបុណ្យអុំទូក ក្នុងខែវិច្ឆិកា ឆ្នាំ២០០៩ នៅរាជធានីភ្នំពេញ (ជាពិធីដែលមានប្រជាពលរដ្ឋជាច្រើនពាន់នាក់ចូលរួម ដែលធ្វើដំណើរពីតំបន់ជនបទមកកាន់រាជធានីភ្នំពេញ ដើម្បីមើល*

61 ឆន ចាន់ស៊ី និងស៊ីម៉ុន ម៉ាក "អាជ្ញាធរបន្តបោសសម្អាតជនកាកសង្គម" *កាសែត ឌឹ ឃែមបូឌាដេលី* ថ្ងៃទី២៣-២៤ ខែឧសភា ឆ្នាំ២០០៩។
62 មានការចូលរួមពីនគរបាលស្រុក/ខណ្ឌ មន្ត្រីស្រុក/ខណ្ឌ មេឃុំ និងមន្ត្រីនគរបាល និងក្រោមការដឹកនាំរបស់របស់អភិបាលស្រុក/ខណ្ឌ។
63 វស្នី "អាជ្ញាធរខណ្ឌដូនពេញប្រមូលបាន ស្ត្រីប្រកបរបរផ្លូវភេទចំនួន១៩នាក់ក្នុងយុទ្ធនាការព័ទ្ធចាប់មួយនៅជុំវិញវត្តភ្នំ" *កាសែតកម្ពុជាថ្មី* ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៩។
64ដូចគ្នា។

និងចូលរួមក្នុងការប្រណាំងទូក)។ លោកសុខ ពេញវុធ អភិបាលរងខណ្ឌដូនពេញ ផ្តល់ហេតុផលចំពោះការបោសសម្អាត ដោយប្រាប់ទៅអ្នកសារព័ត៌មានថា "យើងមិនចង់ឃើញអ្នកប្រណាំងទូក នាំយកជំងឺដូចជាមេរោគអេដស៍/ជំងឺអេដស៍ ត្រឡប់ទៅឲ្យប្រពន្ធរបស់ពួកគេទេនៅឯផ្ទះទេ។ យើងត្រូវការការពារបុរសទាំងនេះ ពីព្រោះពួកគេរវល់តែសប្បាយចូលរួមក្នុងពិធីនេះ ហើយភ្លេចពីរឿងសុខភាព និង សុវត្ថិភាព។"[65]

នៅថ្ងៃទី៤ ខែមីនា ឆ្នាំ២០១០ នាយករដ្ឋមន្ត្រីហ៊ុន សែន បានអំពាវនាវម្តងទៀត ឲ្យនគរបាលបង្កើនសកម្មភាពរបស់ខ្លួនប្រឆាំងនឹងអំពើជួញដូរមនុស្ស និងល្បែងស៊ីសង ដោយនិយាយថា "ខ្ញុំសូមអោយ ឆ្នាំ២០១០ គឺជាឆ្នាំដែលត្រូវចាត់វិធានការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស និងល្បែងស៊ីសងខុសច្បាប់គ្រប់រូបភាព។"[66] លោកនាយករដ្ឋមន្ត្រីក៏បានថ្លែងត្រង់ៗផងដែរ ពីការប្រព្រឹត្តខុសឆ្គងរបស់មន្ត្រីជាន់ខ្ពស់ ក្នុងកិច្ចប្រឹងប្រែងរបស់ពួកគេប្រឆាំងនឹងការជួញដូរមនុស្ស និងល្បែងស៊ីសង ដោយមានប្រសាសន៍ថា "ខ្ញុំសោកស្តាយណាស់ ចំពោះការប្រព្រឹត្តមិនត្រឹមត្រូវរបស់ថ្នាក់ដឹកនាំមួយចំនួន ដែលបានជ្រៀតជ្រែកចូលការងាររបស់តុលាការ និងការងាររបស់មន្ត្រីប្រតិបត្តិច្បាប់ . . . វប្បធម៌និទណ្ឌភាពមិនអាចទទួលយកបានឡើយ។" ទោះជាយ៉ាងណាក៏ដោយ លោកនាយករដ្ឋមន្ត្រីខកខានមិនបាននិយាយពីអំពើរំលោភបំពានរបស់ នគរបាលថ្នាក់មូលដ្ឋានទេ។ ជាលទ្ធផលនៃការអំពាវនាវរបស់នាយករដ្ឋមន្ត្រី ហ៊ុន សែននេះ នគរបាលបានចាប់ខ្លួន និងឃុំខ្លួនអ្នកប្រកបរបរផ្លូវភេទជាច្រើននាក់ ដោយបញ្ជូន ពួកគេទៅកាន់មន្ទីរសង្គមកិច្ចរាជធានី និងបន្ទាប់មកប្រគល់ទៅអោយ អង្គការ មិនមែនរដ្ឋាភិបាល។

---

65 ម៉ុម គន្ធា "នគរបាលរាជធានីចាប់អ្នកសង្ស័យជាពេស្យាចារចំនួន១៧នាក់" *ការសែតភ្នំពេញប៉ុស្តិ៍* ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០៩។

66 វង្ស សុខេង និងខួត សុភ័ក្រ ចាក្រីយ៉ា "ហ៊ុន សែន ប្រាប់មន្ត្រី កុំអោយជ្រៀតជ្រែកចូលក្នុងយុទ្ធនាការបង្ក្រាប" *ការសែត*ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី៥ ខែមីនា ឆ្នាំ២០១០។ គេហទំព័រ http://www.phnompenhpost.com/index.php/2010030533129/National-news/hun-sen-tells-officials-not-to-meddle-with-vice-crackdown.html (បានចូលមើលគេហទំព័រនេះ ថ្ងៃទី១១ មេសា ២០១០)។

## IV. អំពើរំលោភបំពានលើអ្នកប្រកបរបរផ្លូវភេទ

*អ្នកប្រកបរបរផ្លូវភេទ ដែលធ្វើការនៅតាមសួនច្បារ និងតាមដងវិថី នៃរាជធានី ភ្នំពេញ រាយការណ៍ថា ពួកគេប្រឈមមុខនឹងអំពើរំលោភដ៏រីករាលដាល នៅពេល ស្ថិតក្នុង កណ្តាប់ដៃរបស់អាជ្ញាធរ។ អំពើរំលោភទាំងនេះមានជាអាទិ៍ ការឃុំឃាំងដោយបំពាន ការរំលោភលើសិទ្ធិទទួលបាននីតិវិធីត្រឹមត្រូវ ការវាយដំ ហិង្សាលើរូបរាងកាយ ការរំលោភសេពសន្ថវៈ ការយាយីផ្លូវភេទ ពលកម្មដោយបង្ខំ ការជំរិតយកលុយ ការរឹបអូសយកសម្ភារៈមានជាប់នឹងខ្លួន និងការធ្វើបាបបែប អមនុស្សធម៌ផ្សេងៗទៀត។ ជនប្រព្រឹត្តអំពើរំលោភទាំងនេះមាន មន្ត្រីនគរបាល ក្រុមសន្តិសុខការពារសួនច្បារ ក្រុមសន្តិសុខខណ្ឌ បុគ្គលិក និងពួកសន្តិសុខនៅមន្ទីរ និងមណ្ឌលសង្គមកិច្ច។ នៅទីប្រជុំជនខេត្តបាត់ដំបង និង ស៊ីសូផុន ក្នុងខេត្ត បន្ទាយមានជ័យ និងនៅខេត្តសៀមរាប អង្គការឃ្លាំមើលសិទ្ធិមនុស្ស បានរកឃើញថា នគរបាលជំរិតយកលុយ មានសភាពរីករាលដាលខ្លាំង ក៏ប៉ុន្តែឧប្បត្តិហេតុនៃអំពើ ហិង្សាដោយនគរបាល និងការចាប់ឃុំខ្លួនដោយបំពាន មានតិចជាងនៅរាជធានី ភ្នំពេញ។ អំពើរំលោភបំពាន នៅរាជធានីភ្នំពេញ មានលក្ខណៈដុះស្លែទៅហើយ ដែលវាជាគំរូនិទណ្ឌភាព ដែលអនុញ្ញាតអោយមានជាបន្តរន្ទូវអំពើរំលោភបំពាន។ ការសិក្សាឆ្នាំ២០០២ ដោយសហជីពស្ត្រីរកស៊ីផ្លូវភេទកម្ពុជា បានរកឃើញថា ៧២ ភាគរយនៃស្ត្រីប្រកបរបរផ្លូវភេទ ចំនួន ៩០ នាក់ ដែលយកធ្វើជាគំរូសំរាប់ការស្ទង់មតិ ក្នុងតំបន់ទួលគោក និងឫស្សីកែវនៃរាជធានីភ្នំពេញ បានប្រឈមមុខនឹងការរំលោភ សិទ្ធិមនុស្សមួយចំនួន ដែលប្រព្រឹត្តដោយនគរបាល ហើយពួកគេទាំងអស់គ្នាសុទ្ធតែ បានឃើញផ្ទាល់ភ្នែកអំពើរំលោភទាំងនោះ។*[៦៧]

---

67 សហជីពស្ត្រីរកស៊ីផ្លូវភេទកម្ពុជា និងសមាគមអភិវឌ្ឍន៍ស្ត្រីកម្ពុជា *ការស្ទាបស្ទង់មតិអំពី ការរំលោភសិទ្ធិមនុស្សរបស់អ្នកប្រកបរបរផ្លូវភេទ ដោយនគរបាលនៅក្នុងខណ្ឌទួលគោក* ភ្នំពេញ ឆ្នាំ២០០២ ទំព័រ៣-៤។

អំឡុងពេលបោសសម្អាត មន្ត្រីនគរបាលមួយចំនួនបានប្ញន់យក ឬជំរិតយកលុយពីអ្នកប្រកបរបរផ្លូវភេទ វាយដំ និងបៀតបៀនកេរ្តិ៍ខ្មាស់របស់ពួកគេ។ នៅមជ្ឈមណ្ឌលរបស់រដ្ឋាភិបាល ជាកន្លែងដែលអ្នកប្រកបរបរផ្លូវភេទ ត្រូវបានឃុំឃាំងដោយបំពាន ពួកឆ្មាំសន្តិសុខមណ្ឌលបានរំលោភសេពសន្ថវៈ និងវាយដំពួកគេ។

ជនទាំងឡាយដែល ប្រកបរបរផ្លូវភេទដោយស្ម័គ្រចិត្ត ជនរងគ្រោះនៃអំពើជួញដូរ មនុស្ស និងកុមារប្រកបរបរផ្លូវភេទ សុទ្ធតែបានប្រឈមមុខនឹងការរំលោភបំពានពី សំណាក់នគរបាល។ គ្មាននរណាម្នាក់ដែលត្រូវបានសម្ភាសន៍ដោយអង្គការ ឃ្លាំមើលសិទ្ធិមនុស្ស និយាយថា នគរបាលបានសួរនាំពួកគេ ដើម្បីកំណត់រកថា តើពួកគេអាចជា ជនរងគ្រោះនៃអំពើជួញដូរ ឬក៏ ពួកគេមានអាយុក្រោម ១៨ឆ្នាំ ឡើយ។ ការប្រកបរបរផ្លូវភេទ ត្រូវបានគេចាត់ជាទម្រង់អាក្រក់បំផុតមួយ នៃពលកម្ម កុមារ ហើយមិនមានជនណាម្នាក់ដែលស្ថិតក្រោមអាយុ១៨ឆ្នាំ ត្រូវ អនុញ្ញាតឲ្យពាក់ព័ន្ធនឹងការងារបែបនេះឡើយ។ ក្រោមច្បាប់អន្តរជាតិ រដ្ឋាភិបាលមានករណីយកិច្ច ដើម្បី កំណត់រកអ្នករងគ្រោះនៃអំពើជួញដូរមនុស្ស និងកុមារដែលពាក់ព័ន្ធក្នុងទម្រង់ដ៏អាក្រក់បំផុតនៃពលកម្មកុមារ និងត្រូវបញ្ជូនពួកគេទៅរកសេវាសមស្រប។[68]

នគរបាលក្នុងប្រទេសកម្ពុជា ប្រតិបត្តិការនៅកម្រិតឃុំ/សង្កាត់ ស្រុក/ខណ្ឌ និង ខេត្ត/ក្រុង។ ផ្នែកឯកទេសប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ប្រតិបត្តិការ នៅកម្រិតខេត្ត/ក្រុងរាជធានី។ ផ្នែកនេះតែងតែ ដឹកនាំការស៊ើបអង្កេតករណីជួញដូរ មនុស្ស និងឆ្មក់ចូលអាគារនានាដូចជា ផ្ទះបន និងកន្លែងម៉ាស្សា។ ក៏ប៉ុន្តែ នគរបាល ដែលទទួលបន្ទុកដឹកនាំការបង្ក្រាបលើអ្នកប្រកកបរបរផ្លូវភេទនៅតាមដងវិថី អ្នកគ្មាន ផ្ទះសម្បែង អ្នកប្រើប្រាស់គ្រឿងញៀន និងកុមាររស់តាមចញ្ចើមថ្នល់ ជាធម្មតាគឺជានគរបាលរដ្ឋបាលខាងសណ្តាប់ធ្នាប់ ដែលប្រតិបត្តិការនៅកម្រិតសង្កាត់ ខណ្ឌ និង រាជធានី។

68 មាត្រា៧ នៃអនុសញ្ញាលេខ១៨២ របស់អង្គការពលកម្មអន្តរជាតិ ស្តីពីទម្រង់អាក្រក់បំផុតនៃពលកម្មកុមារ។

## អំពើឃោរឃៅនៅតាមដងវិថី និងអំពើរំលោភបំពានផ្សេងៗ

> បញ្ហាធំសម្រាប់ខ្ញុំគឺ ការធ្វើបាបរបស់ប៉ូលីស។ ប៉ូលីសដេញចាប់ស្រីៗរកស៊ីផ្លូវភេទ
> នៅតាមសួនស្ទើររាល់យប់ . . . ប៉ូលីសដែលកាចជាងគេ គឺប៉ូលីសមកពីសង្កាត់ វត្តភ្នំ។
> ពួកស្រីៗ ដឹងគ្រប់គ្នាថាប៉ូលីសទាំងអស់នេះកាចសាហាវណាស់។ ជួនកាល
> ប៉ូលីសបាញ់ដំពាមកៅស៊ូបំបែកពួកយើង នៅពេល ឃើញពួកយើង
> ឈរផ្តុំគ្នានៅកន្លែងណាមួយក្នុងសួន។ ខ្ញុំខ្លាចប៉ូលីសវាយខ្ញុំ ដូច្នេះខ្ញុំឈរប្រុង
> ប្រយ័ត្នគ្រប់ពេល ដែលខ្ញុំនៅសួនច្បារ។ ពេលឃើញប៉ូលីសមក ខ្ញុំរត់គេច
> យ៉ាងលឿន។
> *– មករា សម្ភាសន៍ក្នុងខែសីហា ឆ្នាំ២០០៩ ក្នុងរាជធានីភ្នំពេញ។*

*អ្នកប្រកបរបរផ្លូវភេទលេងល្បែង "បិទពួន" ជាមួយនគរបាល ឆ្មាំសន្តិសុខខណ្ឌ និង ឆ្មាំសន្តិសុខការពារសួនច្បារសាធារណៈ ដើម្បីជៀសវាងបានពី ការចាប់ខ្លួន វាយដំ និងជំរិតយកលុយ។ កុលាប អាយុ២៩ឆ្នាំ ជាអ្នកប្រកបរបរផ្លូវភេទតាមដងផ្លូវ ក្នុង ខណ្ឌទួលគោក បាននិយាយថា ៖*

> ប៉ូលីសនិយាយថា ពួកយើងខ្ញុំរត់ដូចមាន់អញ្ចឹង ម្តងរត់ទៅខាងនេះ ម្តងរត់ទៅ
> ខាងនោះ នៅពេលមានការដេញពួកយើងចេញពីផ្លូវ។ ពេលខ្ញុំឃើញប៉ូលីស
> ខាងទួលគោកមក ខ្ញុំដើរទៅផ្លូវម្ខាងទៀត ដែលត្រួតត្រាដោយប៉ូលីសខណ្ឌ ផ្សេង។
> ហើយពេលខ្ញុំឃើញប៉ូលីស ពីខណ្ឌឫស្សីកែវមក ខ្ញុំរត់ទៅផ្លូវដែលស្ថិត
> នៅក្រោមខណ្ឌទួលគោក។ ធ្វើបែបនេះ ខ្ញុំអាចគេចផុតពីការចាប់ខ្លួនបាន។
> ប៉ូលីសខាងខណ្ឌទួលគោក ពេលមកគឺ មកចាប់យើង ចំណែកឯប៉ូលីសពី
> ខណ្ឌឫស្សីកែវ ពេលមកគឺ មកវាយយើង។[69]

*ប៉ូលីសពីសង្កាត់វត្តភ្នំ ប្រើចំពាមកៅស៊ូ បាញ់គ្រាប់ដុំថ្ម បណ្តេញយើងចេញពីសួន។ មីនា បានពន្យល់ថា "ដុំថ្មដែលប៉ូលីសបាញ់ពីចំពាមកៅស៊ូ បានត្រូវចំលើស្មាខ្ញុំ កាល ពីប្រាំខែមុន*

---

69 អង្គការឃ្លាំមើលសិទ្ធិមនុស្សសម្ភាសន៍ជាមួយ កុលាប នៅភ្នំពេញ ថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៩។

*ដែលកាលនោះខ្ញុំកំពុងតែនៅលើសួនច្បារក្បែរផ្សារចាស់។ ខ្ញុំលាបប្រេងកូឡានៅលើស្នាមដាំ ហើយពីរបីថ្ងៃក្រោយមក វាក៏រលុបបាត់ទៅវិញ ។"*[70] *ចន្ទ ពិពណ៌នាអំពីឧប្បត្តិហេតុក្នុង ខែកក្កដា ដោយនិយាយថា "គ្រាប់ឃ្លីបាញ់ចេញពីចំពាមកៅស៊ូរបស់ប៉ូលីស បានត្រូវចំលើដៃខ្ញុំ កាលពីពីរសប្តាហ៍មុននេះ។ ខ្ញុំឈឺចុកចាប់ណាស់។"*[71]

*ជួនកាលនគរបាលបង្ខំអ្នកប្រកបរបរផ្លូវភេទ ឲ្យរួមភេទ ឬធ្វើសកម្មភាពបែប បន្ទាបបន្ថោក ជាមួយនឹងអតិថិជនខ្លួន ជាការ "សម្តែង"។ ក្នុងខែមេសា ឆ្នាំ២០០៨ ដារា អានី និងស្រីណា បានមើលឃើញផ្ទាល់ភ្នែកនូវ សកម្មភាពដែល មន្ត្រី នគរបាលបួននាក់ ប្រើកាំភ្លើងក្នុងបង្ខំស្ត្រីប្រកបរបរផ្លូវភេទម្នាក់ និងអតិថិជនរបស់នាងអោយសម្តែងការរួមភេទនៅលើសួនច្បារក្បែរផ្សារចាស់។ បន្ទាប់ពីសម្តែងរួច នគរបាលបានដោះលែងពួកគេ។*[72]

*អ្នកប្រកបរបរផ្លូវភេទខ្លះនិយាយថា ក្រុមសន្តិសុខការពារសួនច្បារ ដែលធ្វើការក្រោមសមត្ថកិច្ចរបស់សាលារាជធានីភ្នំពេញ ប្រើអំពើហិង្សាច្រើនជាង មន្ត្រីនគរបាលទៅទៀត។*[73] *នីកា អាយុ២៨ឆ្នាំបាននិយាយថា ឆ្មាំសន្តិសុខសួនច្បារឯកសណ្ឋានបីបួននាក់ បានវាយដំនាង នៅពេលនាងកំពុងនិយាយទូរស័ព្ទ នៅម៉ោង១១.៣០នាទីយប់ ក្នុងខែតុលា ឆ្នាំ២០០៩ ព្រោះតែនាងមានភាពយឺតយ៉ាវក្នុងការធ្វើតាមបញ្ជារបស់ពួកគេឲ្យទៅនៅកន្លែងងងឹត។ នាងនិយាយថា ៖*

> ដំបូង សន្តិសុខម្នាក់បានដើរមក ហើយទាត់ខ្ញុំ ... បន្ទាប់មកសន្តិសុខបីនាក់ផ្សេងទៀតបានមកដល់ដែរ។ សន្តិសុខពីរនាក់ចាប់ដៃទាំងពីររបស់ខ្ញុំជាប់ដោយទុកឲ្យពីរនាក់ទៀតវាយខ្ញុំ។ ពួកគេទះកំភ្លៀងខ្ញុំ។ ពួកគេដូចជាស្រវឹង

---

70 អង្គការឃ្លាំមើលសិទ្ធិមនុស្សសម្ភាសន៍ជាមួយ មីនា នៅភ្នំពេញ ថ្ងៃទី៧ ខែសីហា ឆ្នាំ២០០៩។
71 អង្គការឃ្លាំមើលសិទ្ធិមនុស្សសម្ភាសន៍ជាមួយ ចន្ទ នៅភ្នំពេញ ថ្ងៃទី៧ ខែសីហា ឆ្នាំ២០០៩។
72 អង្គការឃ្លាំមើលសិទ្ធិមនុស្សសម្ភាសន៍ជាមួយ អានី ស្រីណា និងដារា នៅភ្នំពេញ ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០០៩។
73 អង្គការឃ្លាំមើលសិទ្ធិមនុស្សសម្ភាសន៍ជាមួយ នីកា ស្រីណា ដារា និងឌីណា នៅភ្នំពេញ ថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០០៩។

ស្រាបន្តិច។ ពួកគេវាយក្បាលខ្ញុំនឹងដំបងឫស្សី និងវិទ្យុទាក់ទងរបស់ពួកគេ និងវាយសព្វកន្លែងទាំងអស់។ ពួកគេចាប់ហែកអាវខ្ញុំ។ ប៉ូលីសបានមកកាត់តាមនោះដែរ តែគេអត់រវល់ជួយខ្ញុំទេ សន្តិសុខបន្តវាយខ្ញុំជិតកន្លះម៉ោង។ មនុស្សជាច្រើននាក់បានឃើញសន្តិសុខវាយខ្ញុំ តែគេរាល់គ្នាខ្លាច មិនហ៊ាន ជួយខ្ញុំទេ។ ប្រធានសន្តិសុខ ប្រាប់កូនចៅផ្សេងទៀតថាបើឃើញខ្ញុំទៅទីនោះ ម្តងទៀត ត្រូវវាយខ្ញុំឲ្យងាប់។[74]

*ទាំងនគរបាលនិងក្រុមសន្តិសុខការពារសួនច្បារ ជាទូទៅគំរាមកំហែង និងបំភិតបំភ័យ អ្នកប្រកបរបរផ្លូវភេទ។ ពួកគេគំរាមអ្នកប្រកបរបរផ្លូវភេទដោយ ការប្រើហិង្សាជា បន្ថែមទៀត ប្រសិនបើពួកគេហានវិលត្រឡប់មកសួនច្បារម្តងទៀត ឬប្រសិនបើ ពួកគេចាប់ខ្លួនបានពាក់ព័ន្ធនឹងការប្រកបរបរផ្លូវភេទ។ ស្រីស្រស់ក៏ប្រឈមមុខនឹង ការគំរាមកំហែងផងដែរ ដោយសារតែ អត្តសញ្ញាណ និងចរិកលក្ខណៈខាងផ្លូវភេទ របស់ពួកគេ។ ស្រីស្រស់ប្តូរចរិកលក្ខណៈពីបុរសទៅជាស្ត្រី ដែលប្រកបរបរផ្លូវភេទ បាននិយាយថា ៖*

ជួនកាល ប៉ូលីសស្រែកជេរយើងថា "ពួកអាខ្ទើយ [ពាក្យមើលងាយចំពោះស្រីស្រស់] ពួកឯងអោយគេរុករន្ធគូថ។ ពួកឯងមានជំងឺអេដស៍ ហើយដើរចម្លងគេឯង ។ ពួកឯងសមតែបាញ់ឲ្យងាប់ទេ។"[75]

## អំពើរំលោភបំពានអំឡុងពេលចាប់ខ្លួន និងក្នុងពេលឃុំឃាំងរបស់នគរបាល

ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនជនណាម្នាក់ នឹងអាចធ្វើទៅបានលុះត្រាតែអនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់។
*— មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣។*

---

74 អង្គការឃ្លាំមើលសិទ្ធិមនុស្សសម្ភាសន៍ជាមួយ នីកា នៅភ្នំពេញ ថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៩។
75 អង្គការឃ្លាំមើលសិទ្ធិមនុស្សសម្ភាសន៍ជាមួយ នារី នៅភ្នំពេញ ថ្ងៃទី៨ ខែសីហា ឆ្នាំ២០០៩។

*នីតិវិធីព្រហ្មទណ្ឌប្រទេសកម្ពុជា ចែងថា ជនណាក៏ដោយអាចនឹងត្រូវចាប់ខ្លួនដោយមិនបាច់មានដីការតុលាការ ក្នុងពេលជននោះកំពុងតែប្រព្រឹត្ត ឬ ភ្លាមៗបន្ទាប់ពីបានប្រព្រឹត្តបទល្មើសមជ្ឈឹម ឬឧក្រិដ្ឋជាក់ស្តែង។[76] ទោះបីជាអំពើអូសទាញគឺជាអំពើខុសច្បាប់ដូចដែលបានពិពណ៌នាខាងលើក៏ដោយ ក៏បុគ្គលពេស្យាចារមិនខុសច្បាប់ទេក្នុងប្រទេសកម្ពុជា ហើយឋានៈជាអ្នកប្រកបរបរផ្លូវភេទ មិនមែនជាមូលដ្ឋានសម្រាប់ការចាប់ខ្លួនឡើយ។ ទោះជាយ៉ាងនេះក្តី ក៏ អ្នកប្រកបរបរផ្លូវភេទប្រឈមនឹងការចាប់ខ្លួនដោយបំពាន ឬខុសច្បាប់ ជារៀងរាល់ថ្ងៃ។ អ្នកប្រកបរបរផ្លូវភេទដែលត្រូវបានគេចាប់ខ្លួន គឺមានតិចតួចបំផុត ដែលត្រូវបានចោទប្រកាន់ពីបទល្មើសទាក់ទងនឹងពេស្យាចារ ។*

*ជនណាដែល ត្រូវបានឃាត់ខ្លួន ត្រូវបាន ប្រាប់ឲ្យដឹងជាបន្ទាន់ពីមូលហេតុ នៃ សេចក្តីសម្រេចឃាត់ខ្លួននោះ។[77] ក្រោមច្បាប់កម្ពុជា រយៈពេលអតិបរមានៃការឃាត់ខ្លួនរបស់នគរបាលគឺ ៤៨ ម៉ោង។[78] ជនសង្ស័យនៃបទល្មើសព្រហ្មទណ្ឌ មានសិទ្ធិជួប មេធាវី ឬជនណាម្នាក់ទៀត ក្នុងរយៈពេល ២៤ ម៉ោង កន្លងផុតទៅ នៃការឃាត់ខ្លួនរបស់នគរបាល។[79]*

*តាមក្រមព្រហ្មទណ្ឌថ្មីរបស់ប្រទេសកម្ពុជា ជនណាក៏ដោយដែលចាប់ ដែលឃុំឃាំង ឬដែលបង្ខាំងជនណាម្នាក់ទៀតដោយខុសច្បាប់ អាចជាប់ពន្ធនាគាររហូតដល់ ១០ ឆ្នាំ ប្រសិនបើការចាប់ ការឃុំឃាំង ឬការបង្ខាំង នោះមានរយៈពេលលើសពីមួយខែ និងពី ៣ ទៅ ៥ ឆ្នាំបើ ការចាប់ ការឃុំឃាំង ឬការបង្ខាំងនោះតិចជាងមួយខែ ហើយ ពី ១ ឆ្នាំទី ៣ ឆ្នាំ*

---

76 ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧  មាត្រា៨៧។
77 ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧  មាត្រា៩៧។
78 ក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧  មាត្រា៩៦។ មន្ត្រីនគរបាលយុត្តិធម៌ អាចឃាត់បុគ្គលដែលអាចផ្តល់ព័ត៌មានស្តីអំពីរឿងហេតុបានដែរ ប្រសិនបើលក្ខខ័ណ្ឌខាងក្រោមនេះ ត្រូវបានបំពេញ ៖ បុគ្គលដែលអាចផ្តល់ព័ត៌មាន ប្រកែកមិនព្រមផ្តល់ព័ត៌មាន និងមានការយល់ព្រមជាលាយលក្ខណ៍អក្សរ ឲ្យធ្វើការឃាត់ខ្លួនពីព្រះរាជអាជ្ញា។
79 ក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧  មាត្រា៩៨។

*បើការចាប់ ការឃុំឃាំង ឬការបង្ខាំងនោះតិចជាង ៤៨ ម៉ោង។*[80] *ប្រសិនបើការឃុំឃាំងខុសច្បាប់មានមានប្រើអំពើទារុណកម្ម ឬអំពើឃោរឃៅ នោះ ការដាក់ទណ្ឌកម្ម នឹងកើនរហូតដល់ពី ១៥ ទៅ ៣០ ឆ្នាំ។*[81]

*ការចាប់ខ្លួនអ្នកប្រកបរបរផ្លូវភេទ ជាញឹកញយធ្វើឡើងដោយមិនស្របច្បាប់ និង ដោយបំពាន។ អ្នកប្រកបរបរផ្លូវភេទដែលបានសម្ភាសន៍ដោយអង្គការឃ្លាំមើល សិទ្ធិមនុស្ស បាននិយាយថា នគរបាលកម្រប្រាប់ពួកគេឲ្យដឹងពីមូលហេតុ នៃការ ឃាត់ខ្លួនពួកគេ និងថាតើពួកគេត្រូវជាប់ចោទពីបទល្មើសអ្វី។ អ្នកប្រកបរបរផ្លូវភេទ តែងតែមានការភ័យខ្លាចក្នុងការសួរមន្ត្រីនគរបាលពីមូលហេតុនៃការចាប់ខ្លួន។ កញ្ញា ជាស្ត្រីម្នាក់ ក្នុងចំណោមក្រុមស្ត្រីប្រកបរបរផ្លូវភេទចំនួនប្រាំនាក់ ដែលអង្គការ ឃ្លាំមើលសិទ្ធិមនុស្សបានជួបភ្លាមៗបន្ទាប់ពី មន្ទីរសង្គកិច្ចរាជធានីបានដោះលែង ពួកគេក្នុងខែសីហា ឆ្នាំ២០០៩។ នាងនិយាយថា ៖*

> យើងខ្លាច និងភ័យព្រួយ ពេលដែលប៉ូលីសចាប់ពួកយើង ដូច្នេះយើងមិនហ៊ាន សួរនាំមន្ត្រីប៉ូលីស ពីហេតុផលដែលគេចាប់ខ្លួនយើងទេ។ យើងដឹងថា ប្រសិន បើយើងសួរច្រើន ឬនិយាយច្រើន យើងប្រាកដជាត្រូវប៉ូលីសវាយ ឬទះតប់ជា មិនខាន។ នៅឯសួនច្បារ ប៉ូលីសប្រាប់យើងថា ប្រសិនបើយើងជាស្រីពេស្យា គេចាប់យើងហើយ។[82]

*នីតា អាយុ១៨ ឆ្នាំ ជាអ្នកប្រកបរបរផ្លូវភេទម្នាក់ទៀត ដែលត្រូវបាននគរបាល សង្កាត់ទន្លេបាសាក់ ចាប់ខ្លួន អំឡុងខែកក្កដា ឆ្នាំ២០០៩ បានប្រាប់អង្គការឃ្លាំមើល សិទ្ធិមនុស្សថា ៖"ពេលប៉ូលីសចាប់ពួកខ្ញុំយកមកដល់ប៉ុស្តិ៍ប៉ូលីស ខ្ញុំបានតមាត់*

80 ក្រមព្រហ្មទណ្ឌ មាត្រា២៥៣
81 ក្រមព្រហ្មទណ្ឌ មាត្រា២៥៤
82 អង្គការឃ្លាំមើលសិទ្ធិមនុស្សសម្ភាសន៍ជាមួយ កញ្ញា នៅភ្នំពេញ ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០០៩។

ជាមួយប៉ូលីស ខ្ញុំសួរថាហេតុអ្វីក៏ចាប់ខ្ញុំយកមកប៉ុស្តិ៍។ ប៉ូលីស មិនប្រាប់ខ្ញុំពី ហេតុផលអីទេ ហើយបានទះកំភ្លៀងខ្ញុំប្រាំដង។[83]

នគរបាល ជួនកាល ប្រាប់អ្នករកស៊ីផ្លូវភេទអំឡុងពេលចាប់ខ្លួនពួកគេថា អំពើ ពេស្យាចារ គឺជាការខុសច្បាប់ ដោយទោះបីជា អំពើអូសទាញ គឺជាបទព្រហ្មទណ្ឌ តែមួយគត់ ដែលអ្នកប្រកបរបរផ្លូវភេទអាចប្រព្រឹត្ត ដែលនគរបាលអាចប្រើប្រាស់វា ជាហេតុផលសំអាង ដើម្បីចាប់ខ្លួនពួកគេ។ ប៉ុន្តែនគរបាលមិនដែលបាន ដាក់អ្នក ប្រកបរបរផ្លូវភេទណាមួយអោយជាប់ចោទ ពីបទអូសទាញទេ។[84]

មិនមានអ្នកប្រកបរបរផ្លូវភេទ ដែលយើងបានជួបសន្ទនាជាមួយ ដែលជាអ្នកត្រូវបាន ឃុំខ្លួន ឬចាប់ខ្លួន បានដឹងពីការចោទប្រកាន់ផ្លូវការណាមួយ ប្រឆាំងនឹងពួកគេទេ។ ពួកគេម្នាក់ៗសុទ្ធតែធ្លាប់ត្រូវបានគេចាប់ឃុំឃាំង ជាមធ្យមក៏ពីរដងដែរ។

ខណៈពេលដែលអ្នកប្រកបរបរផ្លូវភេទខ្លះ ត្រូវបានគេចាប់ឃុំឃាំង នៅស្ថានីយ៍ នគរបាល និងត្រូវបានដោះលែងវិញដោយមិនមាននគរបាល ធ្វើកំណត់ហេតុ ឬ ចោទប្រកាន់ ក៏មានករណីដទៃទៀតដែរ ដែលអ្នកប្រកបរបរផ្លូវភេទ បានប្រាប់ អង្គការឃ្លាំមើលសិទ្ធិមនុស្សថា នគរបាលបានសួរ និងកត់ត្រាពីប្រវត្តិផ្ទាល់ខ្លួន របស់ពួកគេ និងបានឲ្យពួកគេផ្តិតមេដៃនៅលើក្រដាស ដែលសរសេរនោះ ។ អ្នកប្រកបរបរផ្លូវភេទខ្លះនិយាយថា នគរបាលបានសួរ និងកត់ត្រាប្រវត្តិរបស់ពួកគេ (ឈ្មោះ អាយុ ថ្ងៃខែឆ្នាំកំណើត ភូមិកំណើតពួកគេ និងឈ្មោះឪពុកម្តាយ) និងបាន ថតរូបរបស់ពួកគេ។ មន្ត្រីនគរបាលអាចមានសរសេរអ្វីផ្សេង អំពីហេតុផលនៃការ

---

83 អង្គការឃ្លាំមើលសិទ្ធិមនុស្សសម្ភាសន៍ជាមួយ នីតា នៅភ្នំពេញ ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០៩។

84 អង្គការឃ្លាំមើលសិទ្ធិមនុស្ស បានស្នើសុំព័ត៌មានអំពី ចំនួនមនុស្សដែលគេចោទប្រកាន់ពីបទអូសទាញ តាមរយៈលិខិតមួយផ្ញើជូន ឯកឧត្តម ឧបនាយករដ្ឋមន្ត្រីនិងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅថ្ងៃទី១៩ មេសា ២០១០ (សូមមើលសេចក្តីបន្ថែមទី ១) ប៉ុន្តែរដ្ឋមន្ត្រីខកខានមិនបានឆ្លើយ តបឡើយ។

ចាប់ខ្លួន មុនពេលឲ្យអ្នកប្រកបរបរផ្លូវភេទ ផ្តិតមេដៃលើឯកសារនោះ ប៉ុន្តែពួកគេ និយាយថា ពួកគេមិនត្រូវបានប្រាប់អោយដឹងអំពីអ្វីដែលបានសរសេរពិតប្រាកដលើ ឯកសារនោះទេ។

អ្នកប្រកបរបរផ្លូវភេទជាច្រើន មិនដឹងពីអ្វីដែលត្រូវបានសរសេរពិតប្រាកដលើ ឯកសារដែលពួកគេកំពុងតែចុះហត្ថលេខាទេ និងនិយាយថា ពួកគេមិនត្រូវបានប្រាប់អោយដឹងពីមូលហេតុនៃការឃុំខ្លួន ឬពីបទល្មើសដែលពួកគេបានប្រព្រឹត្ត ឡើយ។ ពួកគេមិនបានទទួលការប្រឹក្សាខាងផ្លូវច្បាប់ ឬក៏ជួបជាមួយអ្នកណាម្នាក់ទៀតដែលអាចធ្វើជាតំណាងឲ្យផលប្រយោជន៍របស់ពួកគេទេ និងពួកគេមិនមានឱកាសដើម្បីសួរដេញដោលពីហេតុផលនៃ ការចាប់ខ្លួន និងឃុំខ្លួនរបស់ពួកគេដែរ។

អំពើហិង្សា ដែលជួនកាលមានសភាពធ្ងន់ធ្ងរ ជាធម្មតាប្រព្រឹត្តក្នុងពេលដែលកំពុងចាប់ខ្លួន។ អ្នកប្រកបរបរផ្លូវភេទ បានប្រាប់អង្គការឃ្លាំមើលសិទ្ធិមនុស្ស ពីរបៀបដែលនគរបាលឃុំឃាំងពួកគេ ដោយប្រើកម្លាំងហួសប្រមាណ តាមរយៈការវាយដំ ទាត់ជាក់ទះកំភ្លៀងពួកគេ វាយពួកគេនឹងដំបង កាំភ្លើង ឬវិទ្យុទាក់ទង ឬអូសកញ្ឆក់ ដៃរបស់ពួកគេ ឬបោចទាញសក់ក្បាលរុញឡើងម៉ូតូ។ ក្រុមឆ្មាំសន្តិសុខរបស់ខណ្ឌ និងឆ្មាំសន្តិសុខសួនច្បារក្នុងឯកសណ្ឋាន បានវាយដំអ្នកប្រកបរបរផ្លូវភេទផងដែរ មុនពេលប្រគល់ពួកគេទៅឲ្យនគរបាល ឬមុនពេលដោះលែងពួកគេទៅវិញ។[85]

លក្ខិណា អាយុ៣៥ ឆ្នាំ ត្រូវបានចាប់ខ្លួនក្នុង ខែសីហា ឆ្នាំ២០០៩ នៅសួនច្បារវត្តភ្នំ ពិពណ៌នាពីការចាប់ខ្លួនរបស់នាងដោយមន្ត្រីនគរបាលម្នាក់។ នាងបានរំឭកថា ៖

> នៅពាក់កណ្តាលយប់ ប៉ូលីសម្នាក់បានជិះម៉ូតូឡើងលើសួន ដេញតាមចាប់អ្នករកស៊ីផ្លូវភេទ ។ គាត់ចាប់ខ្ញុំបាន ចាប់ក្របួចសក់ខ្ញុំ និងអូសខ្ញុំឡើងលើ ម៉ូតូគាត់។

---

85 អង្គការឃ្លាំមើលសិទ្ធិមនុស្សសម្ភាសន៍ជាមួយ ស្រីកែវ នៅភ្នំពេញ ថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០០៩។

> គាត់ចោទខ្ញុំថាខ្ញុំប្រឹងរត់គេចចេញពីគាត់ ហើយគាត់ចាប់យកខ្ញុំទៅប៉ុស្តិ៍ប៉ូលីសវត្តភ្នំ។[86]

*នគរបាលបានវាយអ្នកប្រកបរបរផ្លូវភេទជាមួយនឹងកណ្តាប់ដៃរបស់ពួកគេ ឬដំបង និងប្រើដំបងឆក់ ឆក់ពួកគេ ទាត់និងទះអ្នកណាដែលតវ៉ាមិនឲ្យចាប់ខ្លួន។ ការប្រព្រឹត្តបែបឃោរឃៅ ត្រូវបានប្រព្រឹត្តទៅលើអ្នកទាំងឡាយណា ដែលគេបានចាប់ហើយតែព្យាយាមរត់គេចចេញពីនគរបាល មានជាអាទិ៍ ការប្រើកាំភ្លើងបំភិតបំភ័យលើអ្នកប្រកបរបរផ្លូវភេទ។ ម៉ាលីស បានពិពណ៌នាអំពីឧប្បត្តិហេតុមួយក្នុង ខែឧសភា ឆ្នាំ២០០៩ នៅពេលដែលនគរបាលនៅខណ្ឌដូនពេញ បានប្រើប្រាស់ដំបងឆក់ទៅលើអ្នកប្រកបរបរផ្លូវភេទ ៖*

> ខ្ញុំបានឃើញផ្ទាល់ភ្នែក ប៉ូលីសពីរនាក់កាន់ដំបងឆក់ ជិះម៉ូតូដេញឆក់ ពួកស្រីរកស៊ីផ្លូវភេទ ប្រហែលបីខែមកហើយ។ ខ្ញុំក៏បានឃើញប៉ូលីស ប្រើដំបងឆក់លើស្រីរកស៊ីផ្លូវភេទ កាលពីពេលចូលឆ្នាំខ្មែរនេះផងដែរ [ខែមេសា ឆ្នាំ២០០៩]។[87]

*ស្ត្រីប្រកបរបរផ្លូវភេទម្នាក់ ដែលសម្ភាសន៍ដោយអង្គការឃ្លាំមើលសិទ្ធិមនុស្ស បាននិយាយថា ដៃរបស់នាងមិនអាចធ្វើចលនាបានពេញលេញដូចមុនទេ ចាប់តាំងពីនគរបាលឆក់នាង ជាមួយដំបងឆក់ អំឡុងពេលគេចាប់នាង កាលពីប្រាំឆ្នាំកន្លងមកនៅក្នុងខណ្ឌទួលគោក។[88]*

*ជនទាំងឡាយដែលមានផ្ទុកមេរោគអេដស៍ អាចទទួលរងការប្រមាថ និងហិង្សា ដោយគ្មានក្តីអាណិតអាសូរឡើយ។ ឧទាហរណ៍ នារី ដែលជាស្រីស្រស់ប្រកប របរផ្លូវភេទដែលដូរចរិកលក្ខណៈពីបុរស មកស្ត្រី បានរងការចាប់ខ្លួនក្នុងខែមេសា ឆ្នាំ២០០៩ពីសួនច្បារក្បែរផ្សារចាស់ បាននិយាយថា "នៅពេលខ្ញុំប្រាប់ប៉ូលីសថា ខ្ញុំមានផ្ទុកជំងឺអេដស៍*

86 អង្គការឃ្លាំមើលសិទ្ធិមនុស្សសម្ភាសន៍ជាមួយ លក្ខិណា នៅភ្នំពេញ ថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៩។
87 អង្គការឃ្លាំមើលសិទ្ធិមនុស្សសម្ភាសន៍ជាមួយ ម៉ាលីស នៅភ្នំពេញ ថ្ងៃទី៧ ខែសីហា ឆ្នាំ២០០៩។
88 អង្គការឃ្លាំមើលសិទ្ធិមនុស្សសម្ភាសន៍ជាមួយ ស្រីដា នៅភ្នំពេញ ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៩។

*និងខ្ញុំត្រូវលេបថ្នាំពន្យាអាយុ នគរបាលកាន់តែវាយខ្ញុំខ្លាំងឡើង និងចោទខ្ញុំថាបានដើរចម្លងអេដស៍ទៅអ្នកផ្សេង។"*[89]

*កុមារ ជាពិសេសអ្នកប្រកបរបរផ្លូវភេទដែលមានអាយុរវាង១៦ ឬ១៧ឆ្នាំ ក៏ស្ថិតក្នុងចំណោមជនទាំងឡាយ ដែលគេបានបោសសម្អាតផងដែរ និងដែលប្រឈមនឹងការរំលោភផងដែរ។ ប៉ុន្តែ ជាជំនួសឲ្យការជួយដល់កុមារដែលគេប្រមូលបាន បានរួចផុតពីអំពើពេស្យាចារ នគរបាល ជាទូទៅ ប្រព្រឹត្តចំពោះកុមារទាំងនោះដោយ រំលោភបំពានដូចគ្នានឹង អ្វីដែលពួកគេធ្វើចំពោះនីតិជនដែរ។*

*នីតា អាយុ១៧ ឆ្នាំ បានប្រាប់អង្គការឃ្លាំមើលសិទ្ធិមនុស្សអំពីការចាប់ខ្លួននាងដោយនគរបាលសង្កាត់ទន្លេបាសាក់ក្នុង ខែកក្កដា ឆ្នាំ២០០៩ ដូច្នេះថា ៖*

> នៅឯសួនច្បារ ប៉ូលីសមកពីសង្កាត់ទន្លេបាសាក់ បានបង្ខំខ្ញុំ និងមិត្តខ្ញុំពីរនាក់ឲ្យចូលក្នុងឡានពួកគេ។ ពេលយើងមកដល់ប៉ុស្តិ៍ប៉ូលីស ខ្ញុំតវ៉ាពីរឿងចាប់ខ្លួន។ ប៉ូលីសម្នាក់ទះកំភ្លៀងខ្ញុំប្រាំដង។ ពេលប៉ូលីសអោយពួកខ្ញុំ និងអ្នកឯទៀតឡើងទៅជាន់លើ ហើយគ្រាន់តែខ្ញុំដើរយឺតជាងគេបន្តិច ប៉ូលីសម្នាក់វាយក្បាលខ្ញុំនឹងវិទ្យុទាក់ទងរបស់គាត់។[90]

*នគរបាលវាយដំ ទាត់ ឬទះកំភ្លៀងអ្នកជាប់ឃុំ ជាពិសេសអ្នកទាំងឡាយដែលមិនធ្វើតាមបញ្ជា ឬក៏យឺតយ៉ាវក្នុងការឆ្លើយតបនឹងសំណួររបស់ពួកគេ។ អ្នកប្រកបរបរ ផ្លូវភេទបាននិយាយថា នគរបាលនៅឯសង្កាត់វត្តភ្នំ ក្នុងខណ្ឌដូនពេញ ជាទូទៅ ប្រព្រឹត្តអំពើហិង្សា។ នារីដែលជាស្រីស្រស់ប្រកបរបរផ្លូវភេទ ដែលប្តូរចរិកលក្ខណៈ ពីបុរស មកស្ត្រីដែលទទួលរងការចាប់ខ្លួនក្នុង ខែមេសា ឆ្នាំ២០០៩ បានពិពណ៌នាពីអំពើទារុណកម្មប្រព្រឹត្តដោយនគរបាលទាំងនេះដូច្នេះថា ៖*

---

89 អង្គការឃ្លាំមើលសិទ្ធិមនុស្សសម្ភាសន៍ជាមួយ សុភាវី នៅភ្នំពេញ ថ្ងៃទី៨ ខែសីហា ឆ្នាំ២០០៩។
90 អង្គការឃ្លាំមើលសិទ្ធិមនុស្សសម្ភាសន៍ជាមួយ នីតា នៅភ្នំពេញ ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០៩។

> ប៉ូលីសបីនាក់បានវាយខ្ញុំយ៉ាងខ្លាំង នៅប៉ុស្តិ៍ប៉ូលីសសង្កាត់វត្តភ្នំ បន្ទាប់ពីចាប់យកខ្ញុំពីសួនច្បារ ។ ប៉ូលីសម្នាក់យកកាំភ្លើងភ្ជង់ក្បាលខ្ញុំ រួចកេះកៃ ប៉ុន្តែអត់ផ្ទុះគ្រាប់ទេ។ ពួកគេទាត់កញ្ចឹងករបស់ខ្ញុំ ចង្កេះរបស់ខ្ញុំ និងវាយ ក្បាលរបស់ខ្ញុំ និងខ្លួនខ្ញុំជាមួយដងអំបោស។ វាយប្រហែលកន្លះម៉ោង។ ខ្ញុំបានលើកដៃសំពះអង្វរពួកគេ ឲ្យឈប់វាយខ្ញុំ។ ប៉ូលីសសាហាវណាស់ ហើយពួកគេមិនប្រាប់ពីហេតុផលដែលពួកគេវាយធ្វើបាបខ្ញុំទេ។[91]

*ក្រមព្រហ្មទណ្ឌរបស់ប្រទេសកម្ពុជា ហាមឃាត់អំពើទារុណកម្ម។ អំពើទារុណកម្មជាបទល្មើស ដែលត្រូវផ្តន្ទាទោស ដាក់ពន្ធនាគារពី ៧ឆ្នាំ ដល់ទៅ ២០ឆ្នាំ ដែលទណ្ឌកម្មជាប់ពន្ធនាគាររយៈពេលវែង ដោយគិតពីស្ថានទម្ងន់ទោស ឬក៏ទារុណកម្មបានប្រព្រឹត្តដោយអ្នករាជការសាធារណៈ ។*[92]

*អ្នកប្រកបរបរផ្លូវភេទ ដែលសម្ភាសន៍ដោយអង្គការឃ្លាំមើលសិទ្ធិមនុស្ស បាន រាយការណ៍ថា នគរបាលបានរំលោភពួកគេ និងអ្នកខ្លះបានឃើញនគរបាល រំលោភអ្នកប្រកបរបរផ្លូវភេទដទៃទៀត។ អ្នកប្រកបរបរផ្លូវភេទម្នាក់បានប្រាប់ពីរបៀប ដែលនគរបាលរំលោភបួកនាង នៅក្នុងកន្លែងឃុំឃាំងរបស់នគរបាល ក្នុងខែកញ្ញា ឆ្នាំ២០០៧ ដូច្នេះថា ៖*

> ប៉ូលីសប្រាំនាក់ស្លៀកពាក់ស៊ីវិល បានមកយកខ្ញុំ និងមិត្តខ្ញុំពីរនាក់ទៀត ពីសួនច្បារជិតវិមានឯករាជ្យ ទៅកន្លែងប៉ូលីស នៅម្តុំផ្សារដើមគរ (ការិយាល័យកណ្តាលប្រឆាំងបទល្មើស របស់ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ)។ នៅឯកន្លែងប៉ូលីស មានប៉ូលីសបួននាក់ បានសួរចម្លើយខ្ញុំ។ បន្ទាប់ពីសួររួច ពួកគេរុញខ្ញុំចូលទៅក្នុងបន្ទប់ ដែលនៅក្នុងនោះ មានគ្រែបត់មួយ - វាជាកន្លែងសំរាប់ឃុំឃាំងពួកចោរ។ ប៉ូលីសប្រាំនាក់រំលោភខ្ញុំ នៅយប់ដំបូង និងប៉ូលីសប្រាំមួយនាក់ផ្សេង ទៀតរំលោភខ្ញុំនៅយប់ទីពីរ។ ពួកគេវាយខ្ញុំអំឡុងពេលរំលោភខ្ញុំ ព្រោះខ្ញុំ ប្រកែក។[93]

---

91 អង្គការឃ្លាំមើលសិទ្ធិមនុស្សសម្ភាសន៍ជាមួយ នារី នៅភ្នំពេញ ថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០០៨។

92 ក្រមព្រហ្មទណ្ឌ មាត្រា២១០, ២១២, និង២១៣។ ក្រមនេះត្រូវបានអនុម័តរួចហើយ ក៏ប៉ុន្តែមានតែផ្នែកទី ១ ប៉ុណ្ណោះចូលជាធរមាន។ ផ្នែកដទៃទៀតនឹងចូលជាធរមានមួយឆ្នាំក្រោយពីការអនុម័ត។

93 អង្គការឃ្លាំមើលសិទ្ធិមនុស្សសម្ភាសន៍ជាមួយ លីនដា នៅភ្នំពេញ ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០៨។

ជួលកាល នគរបាលរំលោភសេពសន្ថវៈលើស្រ្តីប្រកបរបរផ្លូវភេទ ដើម្បីជាថ្នូរនឹងការដោះលែង ជាពិសេសប្រសិនជាពួកគេមិនមានប្រាក់អោយខ្លួន និងប្រសិនបើពួកគេស្អាតៗទាក់ចិត្តផងដែរនោះ។ ចន្ថា ដែលគេចាប់ខ្លួនក្នុងខែកក្កដា ឆ្នាំ២០០៩ ពីសួនច្បារក្បែរវិមានឯករាជ្យ បាននិយាយថា នគរបាលទាមទាររួមភេទជាមួយនាងជាថ្នូរនឹងការដោះលែង បើមិនដូច្នេះទេនាងនឹងត្រូវបញ្ជូនទៅមណ្ឌលរបស់អង្គការ មិនមែនរដ្ឋាភិបាល។ នាងបានប្រកែកទៅនឹងការទាមទារនោះ ហើយនៅពេលដែលមន្រ្តីនគរបាលរូបនោះបានដើរចេញទៅប្រាប់នគរបាលផ្សេងទៀតអោយទៅរកទិញស្រោមអនាម័យអោយខ្លួន នាងក៏បានរត់ចេញពីប៉ុស្តិ៍ភ្លាមដែរ។[94]

ការសិក្សាដទៃទៀតបានបង្ហាញនូវភស្តុតាងថា អំពើហិង្សាប្រព្រឹត្តដោយនគរបាល មានលក្ខណៈរីករាលដាល។ ការសិក្សាមួយក្នុងឆ្នាំ២០០៦ ដែលផ្តល់មូលនិធិដោយ USAID ដែលបានធ្វើឡើងដោយអ្នកសិក្សាស្រាវជ្រាវបរទេស រួមជាមួយក្រុមគាំទ្រអ្នកប្រកបរបរផ្លូវភេទក្នុងប្រទេស បានរកឃើញថា ប្រមាណជាពាក់កណ្តាលនៃចំនួន ស្ត្រី និងស្រីស្រស់ប្រកបរបរផ្លូវភេទ ១,០០០ នាក់ ដែលបានសម្ភាសមតិក្នុងរាជធានីភ្នំពេញ បានរាយការណ៍ពីការវាយដំមកលើពួកគេដោយនគរបាល ។ មួយភាគបី បាន រាយការណ៍ថា នគរបាលបានរំលោភបូកលើពួកគេ។[95] ការសិក្សាកត់សំគាល់ថា "នគរបាល តំណាងអំពើគំរាមកំហែងដ៏ធំបំផុតចំពោះអ្នកប្រកបរបរផ្លូវភេទ ពីព្រោះមន្រ្តីនគរបាលជាច្រើនមិនមែនត្រឹមតែយាយី វាយដំលើរាងកាយ រំលោភសេព សន្ថវៈ និងលួចរបស់របរពីពួកគេប៉ុណ្ណោះទេ ប៉ុន្តែ ពីព្រោះតែនគរបាលមិនការពារ ពួកគេពីការវាយប្រហារនៃអ្នកដទៃផងដែរ។[96] ការសិក្សាក្នុងឆ្នាំ២០០២ ដោយសហជីពស្រ្តីរកស៊ីផ្លូវភេទកម្ពុជា បានរកឃើញថាការរំលោភសិទ្ធិមនុស្ស ប្រព្រឹត្ត

94 អង្គការឃ្លាំមើលសិទ្ធិមនុស្សសម្ភាសន៍ជាមួយ ចន្ថា នៅភ្នំពេញ ថ្ងៃទី៧ ខែសីហា ឆ្នាំ២០០៩។

95 ចេនឃិន, ខារ៉ូល, ស៊ីភីយូ (CPU) ឌែបែលយូអិនយូ (WNU) និងសែនបីរី ស៊ី "អំពើហិង្សានិងការ ប្រឈមនឹងមេរោគអេដស៍ ក្នុងចំណោមអ្នកប្រកបរបរផ្លូវភេទ ក្នុងរាជធានីភ្នំពេញ ប្រទេសកម្ពុជា" រៀបចំចងក្រងឡើងសំរាប់ USAID ខែមីនា ឆ្នាំ២០០៦។ មាននៅគេហទំព័រ http://www.hivpolicy.org/Library/HPP001702.pdf, (បានចូលមើលគេហទំព័រនេះ ថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០១០)

96 ចេនឃិន ទំព័រ១៧

ដោយនគរបាលមានជាអាទិ៍ អំពើវាយដំលើរាងកាយ អំពើរំលោភសេពសន្ថវៈ ការចាប់ខ្លួន និងឃុំខ្លួនដោយបំពាន ការបង្ខំឲ្យដុសលាងបង្គន់ និងឲ្យធ្វើសសៃ និងឲ្យលុយនគរបាល។[97]

"លោះ" ជាភាសាខ្មែរមានន័យថាបង់សំណូក។ អ្នកប្រកបរបរផ្លូវភេទ បានពិពណ៌នាអំពីរបៀបដែលនគរបាលទាមទារអោយពួកគេបង់លុយលោះ ជាថ្នូរនឹងការដោះលែងពួកគេពីការឃុំឃាំរបស់នគរបាល។ ប្រសិនបើពួកគេមិនបង់លុយលោះទេ នគរបាលនឹងបញ្ជូនពួកគេទៅកាន់កន្លែងឃុំឃាំងរបស់ក្រសួងសង្គមកិច្ច ឬមណ្ឌលរបស់អង្គការក្រៅរដ្ឋាភិបាល ។ អ្នកប្រកបរបរផ្លូវភេទទាំងអស់ ដែលសម្ភាសន៍ដោយអង្គការឃ្លាំមើលសិទ្ធិមនុស្ស រួមទាំងកុមារផង សុទ្ធតែបានបង់ប្រាក់លោះឲ្យទៅនគរបាលយ៉ាងហោចណាស់ក៏ម្តងដែរ ហើយដែលពួកគេភាគច្រើនបានបង់ប្រាក់លោះច្រើនជាងមួយលើក។ អ្នកប្រកបរបរផ្លូវភេទ អាចបង់ប្រាក់លោះដោយខ្លួនឯងផ្ទាល់ ឬក៏មិត្តភក្តិ សាច់ញាតិ ឬមេការរបស់ពួកគេ អាចមកកាន់ប៉ុស្តិ៍ នគរបាលដើម្បីបង់លុយលោះ ជានាសុំដោះលែងពួកគេ។ តម្លៃលោះ មានចាប់ពី ១០ដុល្លារ ដល់ ២០០ដុល្លារ។[98] អ្នកជាប់ឃុំផ្សេងទៀត មានដូចជា អ្នកប្រើគ្រឿង ញៀនក៏ប្រឈមនឹងការប្រព្រឹត្តដូចគ្នានេះ ដោយនគរបាលផងដែរ។[99] ស្រីស្រស់ មួយរូបបានពិពណ៌នាអំពីឧប្បត្តិហេតុមួយនៅចុងឆ្នាំ២០០៧ ខណៈដែលនគរបាល ខណ្ឌដូនពេញ បានចាប់ខ្លួននាងដូច្នេះថា ៖

> ខ្ញុំបានប្រាប់ប៉ូលីសថា ខ្ញុំមិនមានលុយ ៥០ដុល្លារទេ តែពួកគេមិនជឿខ្ញុំឡើយ។ ប៉ូលីសដាក់ខ្ញុំចូលទៅក្នុងបន្ទប់ឃុំឃាំង។ បន្ទប់នោះក្តៅ ងងឹត និងពិបាកដក

---

97 សហជីពស្ត្រីរកស៊ីផ្លូវភេទកម្ពុជា និងសមាគមន៍អភិវឌ្ឍន៍ស្ត្រីកម្ពុជា "*ការស្ទាបស្ទង់មតិអំពីការរំលោភសិទ្ធិមនុស្សរបស់អ្នកប្រកបរបរផ្លូវភេទ ដោយនគរបាលក្នុងខណ្ឌទួលគោក*" ភ្នំពេញ ឆ្នាំ២០០២ ទំព័រ៣-៤។

98 អ្នកប្រកបរបរផ្លូវភេទទាំងអស់ដែលបានសម្ភាសន៍ដោយអង្គការឃ្លាំមើលសិទ្ធិមនុស្ស បានប្រាប់អំពីតម្លៃលោះខ្លួន ដែលពួកគេបានបង់គឺមាន ក្នុងតម្លៃទាំងនេះ។

99 អង្គការឃ្លាំមើលសិទ្ធិមនុស្ស *ស្បែកដាច់ដាប់ខ្សែភ្លើង ៖ ការចាប់ខ្លួនខុសច្បាប់ ការឃុំខ្លួនតាមអំពើចិត្ត និងទារុណកម្មលើអ្នកប្រើប្រាស់គ្រឿងញៀនក្នុងប្រទេសកម្ពុជា* ថ្ងៃទី២៥ ខែមករា ឆ្នាំ២០១០។ គេហទំព័រ http://www.hrw.org/en/reports/2010/01/25/skin-cable-o.

> ដង្ហើមណាស់។ ខ្ញុំអត់មានទឹកផឹកទេ។ ខ្ញុំត្រូវគេទុកអោយនៅទីនោះប្រាំថ្ងៃ។ នៅពេលថ្ងៃ ពួកគេឲ្យខ្ញុំសម្អាតការិយាល័យ និងបង្គន់ ហើយបន្ទាប់មក ដាក់ខ្ញុំចូលទៅក្នុងបន្ទប់ឃុំឃាំងវិញ។ នៅទីបំផុត ខ្ញុំក៏យល់ព្រម រកលុយបង់អោយ ពួកគេ ៥0 ដុល្លារ។[100]

*តុលា ដែលមានអាយុ ២០ ឆ្នាំ បានពិពណ៌នាអំពី ការចាប់ខ្លួននាងជាលើកដំបូងក្នុងខែកក្កដា ឆ្នាំ២០០៩ ដូច្នេះថា ៖*

> នៅក្នុងកន្លែងប៉ូលីស [ខណ្ឌដូនពេញ] ប៉ូលីសបានសួរពួកយើងថា មានមេការ [អ្នកគ្រប់គ្រង] ឬក៏អត់។ ប៉ូលីសបានអោយខ្ញុំ និងអ្នកផ្សេងទៀតដែលចាប់មក ជាមួយគ្នា ទូរស័ព្ទទៅមេការ ដើម្បីហៅអោយមកលោះយកយើងចេញទៅវិញ។ មានស្រីៗ ១៥នាក់ ក្នុងចំនោម ២០នាក់ [អ្នកប្រកបរបរផ្លូវភេទ] មានមេការគេ មកលោះពីប៉ូលីស ហើយក៏ត្រូវបានគេអោយចេញ។ នៅសល់ប៉ុន្មាននាក់មាន ទាំងខ្ញុំផង គេដាក់អោយនៅកន្លែងប៉ូលីសបីថ្ងៃ ទើបបញ្ជូនទៅមន្ទីរសង្គមកិច្ច និងបន្ទាប់មកគេបញ្ជូនទៅមណ្ឌលអង្គការ។

*នៅក្នុងខែបន្ទាប់ នគរបាលចាប់ តុលា បានម្តងទៀត តែម្តងនេះនគរបាលឃុំនាងទុកនៅស្ថានីយនគរបាល មួយយប់ មុននឹងបញ្ជូននាងទៅមន្ទីរសង្គមកិច្ច និងបន្ទាប់មកទៅមណ្ឌលអង្គការមិនមែនរដ្ឋាភិបាល ដោយសារតែនាងគ្មានប្រាក់បង់អោយនគរបាល។ នាងបាននិយាយថា៖*

> មេប៉ុស្តិ៍បានសួរពួកយើងថាតើយើងមានអ្នកមកលោះទេ។ គាត់និយាយថា បើយើងបង់លុយអោយគាត់ ក្នុងម្នាក់ ៥0 ដុល្លារ យើងនឹងត្រូវបានដោះលែង ភ្លាម។ យើងប្រាប់គាត់ថា យើងអត់មានលុយទេ។ ពីព្រោះតែយើងគ្មានលុយ ប៉ូលីសបានហៅខាងសង្គមកិច្ច ឲ្យមកយកពួកយើងទៅ ។[101]

---

100 អង្គការឃ្លាំមើលសិទ្ធិមនុស្សសម្ភាសន៍ជាមួយ ស្រីម៉ុម នៅភ្នំពេញ ថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០០៩។

101 អង្គការឃ្លាំមើលសិទ្ធិមនុស្សសម្ភាសន៍ជាមួយ តុលា នៅភ្នំពេញ ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០០៩។

អ្នកប្រកបរបរផ្លូវភេទប្អូនទាក់ផ្សេងទៀត បាន អះអាងបញ្ជាក់ដូចៗគ្នាពី រឿងរបស់តុលា នៅពេលសម្ភាសន៍នៅឯការិយាល័យអង្គការមិនមែនរដ្ឋាភិបាលមួយ។

អ្នកប្រកបរបរផ្លូវភេទនៅក្នុងខេត្តសៀមរាប បាននិយាយផងដែរថា ពួកគេបានបង់ប្រាក់សំណូកឲ្យទៅនគរបាលដើម្បីទទួលបានការដោះលែង។ ក្នុងខែសីហា ឆ្នាំ២០០៩ អ្នកប្រកបរបរផ្លូវភេទអាយុ ២២ឆ្នាំម្នាក់ បានស្ថិតក្នុងការឃុំឃាំងរបស់នគរបាលអស់ពេលពីរថ្ងៃ បន្ទាប់ពីនគរបាលឆ្មក់ចូលក្នុងវង្គសាលមួយ ដែលជាទីកន្លែងធ្វើការរបស់នាងក្នុងក្រុងសៀមរាប។ នាងបាននិយាយថា "ម្ដាយឪពុកខ្ញុំបានបង់លុយ៥០ដុល្លារឲ្យនគរបាល នៅពេលខ្ញុំកំពុងតែស្ថិតក្នុងការឃុំឃាំងរបស់នគរបាលខេត្ត"។[102]

ក្នុងការឆ្មក់ចូលមួយផ្សេងទៀត ក្នុងខែសីហាឆ្នាំ២០០៩ ក្នុងវង្គសាលដែលកាន់កាប់ដោយជនបរទេស ស្ត្រីទទួលភ្ញៀវបានចោទប្រកាន់ថា នគរបាលប្រឆាំងការជួញដូរ មនុស្សរាជធានីភ្នំពេញ បានលួចយកលុយ និងព្យាយាមទារប្រាក់សំណូក។ ស្ត្រី ទទួលភ្ញៀវបានអះអាងថា បុគ្គលិកវង្គសាលទាំងអស់ត្រូវបានគេឃុំខ្លួន និងបញ្ជូន ទៅមន្ទីរសង្គមកិច្ចរាជធានី ទោះបីជាពួកគេមិនមែនជាអ្នកប្រកបរបរផ្លូវភេទ និង មិនមែនជា "អ្នករាំស្រាត" ដូចការចោទប្រកាន់របស់នគរបាលក៏ដោយ។ សិរី ជាស្ត្រី ទទួលភ្ញៀវម្នាក់បាននិយាយដូច្នេះថា ៖

> នៅប្រមាណជាម៉ោង ៨ យប់ នគរបាលស្លៀកពាក់ស៊ីវិលពីនាក់ បានមកធីកក្នុងវង្គសាល។ ស្ត្រីទាំងអស់ស្ថិតក្នុងសម្លៀកបំពាក់សិចស៊ី ប៉ុន្តែ គ្មានអ្នកណាម្នាក់ស្រាតទេ ហើយពួកយើងខ្លះ កំពុងតែរាំតាមបទខ្មែរ។ នៅប្រហែលជា ម៉ោង៩ សមត្ថកិច្ចចម្រុះមួយក្រុមធំបានមកដល់ រួមមានទាំងចៅសង្កាត់មកពី

102 អង្គការឃ្លាំមើលសិទ្ធិមនុស្សសម្ភាសន៍ជាមួយ ស្រី ម៉ី នៅខេត្តសៀមរាប ថ្ងៃទី២១ ខែសីហា ឆ្នាំ២០០៩។

សង្កាត់ផ្សារកណ្ដាល និងសង្កាត់ផ្សារចាស់ មន្ត្រីខណ្ឌមកពីបីបួនខណ្ឌ និង នគរបាល។ ពួកគេបានចូលមកក្នុងរង្គសាល ថតរូបពួកយើង និងប្រាប់យើង ឲ្យនៅស្ងៀមមួយកន្លែង និងកុំអោយទៅណាឲ្យសោះ។ ពួកគេនិយាយថា ពួកយើងរាំស្រាត និងហៅយើងថាជាពួកស្រីខូច។ នគរបាលខ្លះបានបើកថតតុ ដែលមានដាក់លុយ និងឆែកកាបូបលុយរបស់ពួកយើង និងបានប៉ុនប៉ងយក លុយ ប៉ុន្តែបានឈប់ទៅវិញ បន្ទាប់ពីមេ របស់ពួកគេ បានប្រាប់ឲ្យពួកគេឈប់។ គ្នាយើងខ្លះបានបាត់លុយមួយចំនួន។

*យោងតាមការប្រាប់អោយដឹងរបស់សិរី ស្ត្រីទាំងអស់ រួមទាំង អ្នកគិតលុយ អ្នកបោស សម្អាត ចុងភៅ អ្នកលាយស្រា អ្នករត់តុ ស្ត្រីទទួលភ្ញៀវ និងអ្នកយាម ត្រូវបានគេបញ្ជូន ដោយផ្ទាល់ទៅកាន់មន្ទីរសង្គមកិច្ចរាជធានី។ នាងបានពន្យល់ដូច្នេះថា៖*

នៅពេលដែលពួកយើងខ្ញុំជាច្រើននាក់ តវ៉ាជាមួយប៉ូលីស ថា ពួកយើងមិនមែន ជាស្រីខូច ប៉ូលីសនិយាយថា បើសិនជា ពួកយើងជាមនុស្សល្អ យើងមិនមែនត្រូវ គេចាប់ដាក់ក្នុងឡានប៉ូលីសទេ។ នៅពេលដែលយើងនៅក្នុងឡាន ប៉ូលីសនិយាយ ថា បើយើងចង់រួចខ្លួន ត្រូវបង់លុយម្នាក់ៗ ២០០ដុល្លារ និងឲ្យហៅសាច់ញាតិ មកធានានោះនឹងត្រូវបានដោះលែងវិញហើយ។

*នគរបាលដែលចាប់ខ្លួនអ្នកប្រកបរបរផ្លូវភេទ តែងតែលួចយករបស់របរពីពួកគេ មានដូច ជា លុយ ទូរស័ព្ទដៃ និងគ្រឿងអលង្ការ។ ភាគច្រើនលើសលប់នៃស្ត្រីប្រកបរបរផ្លូវភេទ ដែលសម្ភាសន៍ដោយអង្គការឃ្លាំមើលសិទ្ធិមនុស្ស សុទ្ធតែត្រូវបានទទួលរងនូវ ការ លួចលុយ ឬរបស់របរ។ ដោយសារតែការលួចដោយនគរបាល ជារឿងសាមញ្ញពេក ជាហេតុធ្វើអោយអ្នកប្រកបរបរផ្លូវភេទព្យាយាមលាក់លុយរបស់ពួកគេ។ ប៉ុន្តែ នគរបាល ដែលតែងតែជាបុរស ឆែកឆេរពួកគេដោយរាវរកពេញទាំងខ្លួន តាំងតែ ពីក្នុងខោស្លីប យ៉ាងកំរោល ។ នគរបាលផ្តល់ហេតុផលផ្សេងៗក្នុងការយកទ្រព្យ ផ្ទាល់ខ្លួន របស់អ្នកប្រកបរបរផ្លូវភេទ ដូចជានិយាយថា ទ្រព្យនេះនឹងប្រគល់ឲ្យវិញ*

នៅពេលដែលពួកគេត្រូវបានដោះលែងពី មន្ទីរឃុំឃាំងរបស់នគរបាល[103] ឬថាលុយដែលពួកគេលួចយកនោះ គឺសម្រាប់ ថ្លៃសាំងម៉ូតូរបស់ពួកគេ ដែលពួកគេជិះដេញចាប់អ្នករកប្រកបរបរផ្លូវភេទរាល់ថ្ងៃ។[104] មិនមានករណីណាមួយ ដែលសរសេរចងក្រងដោយអង្គការឃ្លាំមើលសិទ្ធិមនុស្ស ដែលអ្នកប្រកបរបរផ្លូវភេទបានរាយការណ៍ ថា នគរបាលបានប្រគល់លុយ ឬរបស់របរទៅឲ្យ ម្ចាស់ស្របច្បាប់វិញឡើយ។

ការប្រព្រឹត្តបែបបន្ទាបបន្ថោកជាទូទៅ ដែលធ្វើឡើងដោយនគរបាល មានដូចជាការបង្ខិតបង្ខំអ្នកប្រកបរបរផ្លូវភេទឲ្យដុសលាងបង្គន់នៅតាមប៉ុស្តិ៍នគរបាល ក្នុងរាជធានីភ្នំពេញ ជាពិសេសនៅប៉ុស្តិ៍នគរបាលវត្តភ្នំ និងនគរបាលទន្លេបាសាក់។[105] ឧទាហរណ៍ ស្រីស្រស់ប្រកបរបរផ្លូវភេទ ដែលគេចាប់បានក្នុងខែតុលា ឆ្នាំ២០០៨ បាននិយាយថា ប៉ូលីសវត្តភ្នំ បានបង្ខំនាងឲ្យដុសលាងបង្គន់។[106] ជួនកាល ប៉ូលីសបង្ខំអ្នកប្រកបរបរផ្លូវភេទឲ្យជ្រើសរើសថា តើត្រូវយកមួយណា រវាងការបញ្ជូនទៅកាន់មជ្ឈមណ្ឌលសង្គមកិច្ច (កន្លែងឃុំឃាំងពួកគេ) និងការផ្តល់ឲ្យនគរបាលនូវការធ្វើម៉ាស្សា ឬការសម្អាតបង្គន់។ ឧទាហរណ៍ និមល ដែលគេចាប់ខ្លួននៅចុង ឆ្នាំ២០០៧ ជាមួយនឹងអ្នកប្រកបរបរផ្លូវភេទចំនួន ១០ នាក់ផ្សេងទៀត ដោយនគរបាលសង្កាត់ទន្លេបាសាក់ បាននិយាយដូច្នេះថា ៖

> ពួកស្រីៗបីនាក់ផ្សេងទៀត ហើយនិងខ្ញុំ មិនមានលុយបង់ឲ្យប៉ូលីសទេ។ មានស្រីៗប្រាំពីរនាក់មានលុយបង់ឲ្យប៉ូលីស គេអោយចេញពីប៉ុស្តិ៍បាត់ទៅ។ ពួកយើងបានសុំអង្វរប៉ូលីសឲ្យដោះលែងយើង។ ប៉ូលីសបានឲ្យខ្ញុំដុសលាងបង្គន់ និងឲ្យអ្នកផ្សេងទៀតធ្វើសសៃឲ្យពួកគេ។ រួចហើយប៉ូលីសបានដោះលែងពួកយើង។[107]

---

103 អង្គការឃ្លាំមើលសិទ្ធិមនុស្សសម្ភាសន៍ជាមួយ លីនដា នៅភ្នំពេញ ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០៩។
104 អង្គការឃ្លាំមើលសិទ្ធិមនុស្សសម្ភាសន៍ជាមួយ មករា នៅភ្នំពេញ ថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៩។
105 សូមមើលចំណុចដែល អង្គការឃ្លាំមើលសិទ្ធិមនុស្សសម្ភាសន៍ជាមួយ កញ្ញា នៅភ្នំពេញ ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០០៩ និង អង្គការឃ្លាំមើល សិទ្ធិមនុស្សសម្ភាសន៍ជាមួយ ដារា នៅភ្នំពេញ ថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០០៩។
106 អង្គការឃ្លាំមើលសិទ្ធិមនុស្សសម្ភាសន៍ជាមួយ ស្រី ម៉ុម នៅភ្នំពេញ ថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០០៩។
107 អង្គការឃ្លាំមើលសិទ្ធិមនុស្សសម្ភាសន៍ជាមួយ និមល នៅភ្នំពេញ ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០៩។ និមល និយាយថា ការធ្វើម៉ាស្សានេះគឺជា ម៉ាស្សាពិតប្រាកដ មិនមែនជាម៉ាស្សាក្នុងន័យរួមភេទទេ។

នគរបាលឲ្យអ្នកប្រកបរបរផ្លូវភេទ ម៉ាស្សាឲ្យពួកគេ ឬរាំឲ្យពួកគេមើល។ ពេលខ្លះ នគរបាលឲ្យអ្នកប្រកបរបរផ្លូវភេទរួមភេទជាមួយពួកគេ (ដូចដែលបានពោល ខាងលើក្រោមករណីរំលោភសេពសន្ថវៈ)។ ចន្ធូ ដែលគេចាប់ខ្លួននៅចុងឆ្នាំ២០០៧ បាននិយាយដូច្នេះថា ៖

> ប៉ូលីស នៅប៉ុស្តិ៍ប៉ូលីសសង្កាត់វត្តភ្នំ បានដាក់ខ្ញុំចូលទៅក្នុងបន្ទប់មួយ បន្ទាប់ពីខ្ញុំបានបោសសម្អាតកន្លែងធ្វើការគាត់ និងដុសលាងបង្គន់។ ប៉ូលីសចាក់ភ្លេង និងបញ្ជាឲ្យខ្ញុំរាំតាមភ្លេង។ គាត់ មើលខ្ញុំរាំបណ្តើរ វាយស្មារ និងក្បាលខ្ញុំបណ្តើរ ជាមួយនឹងរំពាត់។[108]

អ្នកប្រកបរបរផ្លូវភេទ បានពិពណ៌នាផងដែរពីរបៀបដែលនគរបាលដាក់ ពួកគេនៅពីមុខពួកអ្នកថតរូប និងពីមុខម៉ាស៊ីនថត ដោយគ្មានការយល់ព្រមពីពួកគេ។ ស្រីកែវ ដែលជាស្រីស្រស់ប្រកបរបរផ្លូវភេទ ដែលត្រូវបានចាប់ខ្លួនក្នុង ខែសីហា ឆ្នាំ២០០៩ និងឃុំនៅប៉ុស្តិ៍នគរបាលវត្តភ្នំ បាននិយាយដូច្នេះថា ៖

> ប៉ូលីសបានចាក់សោរទុកខ្ញុំនៅក្នុងបង្គន់ពីម៉ោង១១យប់ ដល់ម៉ោង ៦ ព្រឹក ហើយនៅពេលដែលគេអោយខ្ញុំចេញមកក្រៅ ពួកគេបានដាក់ខ្ញុំអោយ អ្នកកាសែតថតរូប និងថតជាវីដេអូ។ ពួកយើងនៅទីនោះមានគ្នាប្រហែល ២៥ នាក់ [ជាស្រីស្រស់ និង ស្ត្រីប្រកបរបរផ្លូវភេទ]។ បន្ទាប់ម គេបញ្ជូនពួកយើងទៅកាន់មន្ទីរសង្គមកិច្ច។[109]

ដារា និង អានី ដែលគេចាប់ខ្លួនក្នុងខែកក្កដា ឆ្នាំ២០០៩ បាននិយាយដូច្នេះថា៖

> នៅពេលយើងដើរចេញក្រៅទ្វារ ប៉ុស្តិ៍នគរបាល [សង្កាត់វត្តភ្នំ] [ក្នុងខណ្ឌ ដូនពេញ] ឃើញអ្នកកាសែតមួយចំនួននៅរង់ចាំ និងថតរូបពួកយើង។

---

108 អង្គការឃ្លាំមើលសិទ្ធិមនុស្សសម្ភាសន៍ជាមួយ ចន្ធូរ នៅភ្នំពេញ ថ្ងៃទី៧ ខែសីហា ឆ្នាំ២០០៩។

109 អង្គការឃ្លាំមើលសិទ្ធិមនុស្សសម្ភាសន៍ជាមួយ ស្រីកែវ នៅភ្នំពេញ ថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០០៩។ អង្គការឃ្លាំមើលសិទ្ធិមនុស្ស បានប្រមូលអត្ថបទសារព័ត៌មានក្នុងស្រុក ដែលបោះពុម្ពរូបថតរបស់អ្នកប្រកបរបរផ្លូវភេទ រួមជាមួយនឹងអត្ថបទស្តីពីការចាប់ខ្លួនរបស់ពួកគេ។ ឧទាហរណ៍ ៖ *កាសែតកោះសន្តិភាពប្រចាំថ្ងៃ* ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ និង*កាសែត*ស្មឹកម្ពុជា*ប្រចាំថ្ងៃ* ចុះថ្ងៃទី ២២ ខែកក្កដា ឆ្នាំ២០០៩។

> រូបភាពរបស់យើងត្រូវបានឃើញនៅតាមកាសែតមួយថ្ងៃក្រោយមក។ យើងមានការខ្មាស់អៀនខ្លាំងណាស់។[110]

## ការឃុំខ្លួន សំណូក និងការយាយីនៅឯមន្ទីរសង្គមកិច្ចរាជធានី

*នៅតាមខេត្ត នគរបាលជាទូទៅប្រគល់អ្នកប្រកបរបរផ្លូវភេទ ឲ្យទៅស្ថិតនៅក្រោមការឃុំគ្រងរបស់អង្គការមិនមែនរដ្ឋាភិបាលតែម្តង។ជួនកាល បុគ្គលិកពីខាងមន្ទីរ សង្គមកិច្ចមកសម្ភាសន៍អ្នកប្រកបរបរផ្លូវភេទនៅឯការិយាល័យនគរបាល ប៉ុន្តែ មិនមាន អ្នកប្រកបរបរផ្លូវភេទណាម្នាក់ ដែលបានសម្ភាសន៍ដោយ អង្គការឃ្លាំមើល សិទ្ធិមនុស្សត្រូវបានគេដាក់ឲ្យស្ថិតក្នុងការឃុំគ្រងរបស់មន្ទីរសង្គមកិច្ចទេ។*

*ក៏ប៉ុន្តែនៅរាជធានីភ្នំពេញ ការប្រព្រឹត្តបែបបន្ទាបបន្ថោកមកលើអ្នកប្រកបរបរផ្លូវភេទនៅតែបន្តកើតមាន បន្ទាប់ពីនគរបាលបញ្ជូនពួកគេឲ្យទៅស្ថិតនៅក្រោមការឃុំគ្រងរបស់មន្ទីរសង្គមកិច្ចរាជធានីក្នុងរាជធានីភ្នំពេញ។ ក្នុងខែមករា ឆ្នាំ២០១០ អនុប្រធានផ្នែកសុខភាពសង្គមនៃមន្ទីរសង្គមកិច្ចរាជធានី បានមានប្រសាសន៍ថា មន្ទីរសង្គមកិច្ច បានទទួលអ្នកប្រកបរបរផ្លូវភេទចំនួន៤៦៩ នាក់ ក្នុងឆ្នាំ២០០៩ ដែលចំនួននេះច្រើនជាងឆ្នាំ២០០៨ ដែលមានចំនួន ៤១៥ នាក់ ។[111]*

*អ្នកប្រកបរបរផ្លូវភេទជាច្រើន ដែលត្រូវបានឃុំខ្លួននៅរាជធានីភ្នំពេញ បានប្រាប់អង្គការឃ្លាំមើលសិទ្ធិមនុស្ស ពីរបៀបដែលពួកគេត្រូវបានដាក់ នៅក្នុងបន្ទប់កខ្វក់ និងមានក្លិនស្អុយ នៅឯមន្ទីរសង្គមកិច្ចរាជធានី ដែលមានទីតាំងនៅផ្លូវ ១៦៣ ក្បែរវត្តមហាមន្ត្រី។ ពួកគេត្រូវបានគេឃុំឃាំងរួមគ្នា ជាមួយអ្នកជាប់ឃុំដទៃទៀត មានជាអាទិ៍ អ្នកសុំទាន អ្នកគ្មានផ្ទះសម្បែង កុមាររស់តាមចញ្ចើមថ្នល់ និង អ្នកប្រើប្រាស់គ្រឿងញៀន។ ទោះបីជាមន្ទីរនោះមិនមែនជាទីកន្លែងសំរាប់ឃុំឃាំង ផ្លូវការក៏ដោយ ក៏មានស្ត្រី កុមារ និងស្រីស្រស់ ត្រូវបានគេដាក់នៅក្នុងបន្ទប់រួមគ្នា ក្នុងរយៈពេលចាប់ពី បីបួនម៉ោង រហូតដល់*

---

110 អង្គការឃ្លាំមើលសិទ្ធិមនុស្សសម្ភាសន៍ជាមួយ ដារានិងជាមួយ អានី នៅភ្នំពេញ ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០០៩។
111 ម៉ុម គន្ធា និង ទេព និមល "ការចាប់ខ្លួនអ្នកប្រកបរបរផ្លូវភេទ មានចំនួនកើនឡើង" *កាសែតភ្នំពេញប៉ុស្តិ៍* ថ្ងៃទី២២ ខែមករា ឆ្នាំ២០១០។

*ពីរថ្ងៃដែរ មុនពេលមានការដោះលែង ឬបញ្ជូនទៅអង្គការក្រៅរដ្ឋាភិបាលណាមួយ ឬទៅមណ្ឌលសង្គមកិច្ចព្រៃស្ពឺ ដែល ស្ថិតនៅជាយរាជធានីភ្នំពេញ។*[112]

*នៅរាជធានីភ្នំពេញ មន្ទីរសង្គមកិច្ចរាជធានីភ្នំពេញ ជាទូទៅ មិនដោះលែង អ្នកប្រកបរបរផ្លូវភេទ ដែលនគរបាលប្រគល់ឲ្យទៅពួកគេទេ លុះត្រាតែមាន អង្គការមិនមែនរដ្ឋាភិបាលដែលមានសេវាកម្មគាំទ្រ ព្រមទទួលយកពួកគេទៅឃុំគ្រង (ដោយមិនគិតពីអាយុ) តាមរយៈការចុះហត្ថលេខាលើទម្រង់បែបបទមួយ ដើម្បីទទួលយកពួកគេចេញពីមន្ទីរសង្គមកិច្ចរាជធានី។*[113] *ដូចគ្នានឹងកង្វល់មានចំពោះអ្នកប្រកបរបរផ្លូវភេទជានីតិជនផងដែរ នោះគឺ ការតម្រូវឲ្យអង្គការមិនមែនរដ្ឋា ភិបាលចុះហត្ថលេខាជានា អ្នកប្រកបរបរផ្លូវភេទ ដែលវាមិនមានមូលដ្ឋានខាងផ្លូវច្បាប់ទាល់តែសោះ។ ពីព្រោះតែអ្នកប្រកបរបរផ្លូវភេទដែលគេឃុំនៅមន្ទីរ សង្គមកិច្ចនោះភាគច្រើនមិនត្រូវបានចោទប្រកាន់ពីបទល្មើសណាមួយទេ ដូច្នេះ អ្នកប្រកបរបរផ្លូវភេទជានីតិជន ត្រូវតែទទួលបានការដោះលែងឲ្យចាកចេញពីមន្ទីរសង្គមកិច្ចរាជធានី នៅគ្រប់ពេលដែលពួកគេចង់ចាកចេញ និងមិនត្រូវតម្រូវឲ្យមានការចុះហត្ថលេខាពីអង្គការមិនមែនរដ្ឋាភិបាល ដើម្បីអោយធានាយកពួកគេទៅឃុំគ្រងទេ ។ បទដ្ឋានគឺអាចខុសគ្នាខ្លះសម្រាប់អនុវត្តលើកុមារ ដែលការដោះលែង ពួកគេ គួរតែប្រគល់ទៅអោយ អាណាព្យាបាល ឬអង្គការសមស្របណាមួយ ដែល ការពារកុមារ។*

*តាំងពីខែឧសភា ឆ្នាំ២០១០ បុគ្គលិកនៅឯមន្ទីរសង្គមកិច្ចរាជធានី បានបង្គាប់ឲ្យអ្នកប្រកបរបរផ្លូវភេទ ចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយ មុនពេលមាន*

112 មុនខែកក្កដា ឆ្នាំ២០០៨ អ្នកជាប់ឃុំនៅឯមន្ទីរសង្គមកិច្ច ត្រូវបានគេបញ្ជូនខ្លួនទៅកាន់មជ្ឈមណ្ឌលសង្គមកិច្ចកោះគរ ប៉ុន្តែមណ្ឌលនេះមិនសកម្មក្នុងការទទួលដាក់បុគ្គលណាម្នាក់ទៀតទេ ក្នុងពេលបច្ចុប្បន្ននេះ។

113 អង្គការក្រៅរដ្ឋាភិបាលទាំងនេះ រួមមានមជ្ឈមណ្ឌលកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ, បណ្តាញស្ត្រីរួបរួមគ្នា, អង្គការអាហ្វេស៊ីប (AFESIP) មជ្ឈមណ្ឌលកម្ពុជាដើម្បីការពារសិទ្ធិកុមារ (CCPCR), ពិភពលោកនៃក្តីសង្ឃឹមអន្តរជាតិ (World Hope International), មជ្ឈមណ្ឌលថែទាំសុខភាពសម្រាប់កុមារ (HCC) និងអង្គការហាហ្គា (Haga)។ យោងតាមកិច្ចសម្ភាសន៍របស់យើង ស្រីស្រស់ប្រកបរបរផ្លូវភេទ ដែលប្រមូលបានក្នុងការបោសសម្អាត ត្រូវបានប្រគល់ទៅបណ្តាញរបស់ពួកគេតែម្តង ដោយកំរនឹងត្រូវគេបញ្ជូនទៅមណ្ឌលរបស់ អង្គការមិនមែនរដ្ឋាភិបាលណាស់។

*ការដោះលែងពួកគេ ប្រគល់ទៅឲ្យ អង្គការមិនមែនរដ្ឋាភិបាល ឃុំគ្រង។ អ្នកប្រកបរបរផ្លូវភេទភាគច្រើន យល់ព្រមចុះហត្ថលេខាលើកិច្ចព្រមព្រៀង ពីព្រោះពួកគេខ្លាច និងចង់ចេញឲ្យផុតពីការឃុំឃាំងរបស់អាជ្ញាធរ។ កិច្ចព្រមព្រៀងប្រភេទនេះមួយច្បាប់ ដែលអង្គការឃ្លាំមើលសិទ្ធិមនុស្សបានទទួល សរសេរថា៖*

> "ខ្ញុំសូមសន្យាចំពោះមុខមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារ រាជធានីភ្នំពេញថា ទៅថ្ងៃអនាគត ខ្ញុំនឹងឈប់ប្រព្រឹត្តអំពើមិនសមរម្យ ដែល ប៉ះពាល់ដល់សីលធម៌ ប្រពៃណី និងសណ្តាប់ធ្នាប់សាធារណៈ និងសូមធានាថា ខ្ញុំនឹងមិនប្រព្រឹត្តអំពើបែបនេះជាលើកទីពីរទេ និងនៅពេលដែលមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារ រាជធានីភ្នំពេញ បញ្ជូនខ្ញុំទៅអង្គការមិនមែន រដ្ឋាភិបាល ដើម្បីទទួលសេវា ខ្ញុំនឹងខិតខំប្រឹងប្រែងធ្វើឲ្យខ្លួនក្លាយជាពលរដ្ឋល្អ រស់ក្នុងសង្គមដូចគេឯង។
>
> ប្រសិនបើខ្ញុំប្រព្រឹត្តអំពើបែបនេះទៀតទៅអនាគត ខ្ញុំនឹងទទួលខុសត្រូវចំពោះ មុខច្បាប់ និងមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារ រាជធានីភ្នំពេញ។"[114]

*វាជាការដ៏គួរមន្ទិលសង្ស័យ ដែល កិច្ចព្រមព្រៀងបែបនេះមានទម្ងន់ខាងផ្លូវច្បាប់ ណាមួយ ក្រោមច្បាប់ប្រទេសកម្ពុជា និងវាប្រាកដជាគ្មានអនុភាពជាច្បាប់ទេ បើចង់ សាកល្បងដាក់វា នៅក្រោមច្បាប់អន្តរជាតិ។ ការណ៍ដែល អ្នកប្រកបរបរផ្លូវភេទ មិនមានជម្រើសអ្វីផ្សេង ក្រៅតែពីចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ បានធ្វើឲ្យ អន្តរាយដល់ទម្ងន់ខាងផ្លូវច្បាប់ណាមួយបើអាចមាន។ ក្រៅពីជា ល័ក្ខខ័ណ្ឌជាមុន ដើម្បីដោះលែងពួកគេពីការឃុំខ្លួនខុសច្បាប់ វាទៅជា ទម្រង់មួយផ្សេងទៀត នៃ ការជ្រៀតជ្រែកដោយខុសច្បាប់លើសិទ្ធិមានសេរីភាព និងសន្តិសុខផ្ទាល់ខ្លួន។*

114 សេចក្តីចម្លងនៃកិច្ចព្រមព្រៀងជាភាសាខ្មែរ គឺមានទុកជាឯកសារនៅអង្គការឃ្លាំមើលសិទ្ធិមនុស្ស។

*អ្នកប្រកបរបរផ្លូវភេទ ក៏ទទួលរងនូវអំពើរំលោភបំពានយ៉ាងហិង្សាបន្តទៀត នៅឯមន្ទីរសង្គមកិច្ចរាជធានី។ អ្នកប្រកបរបរផ្លូវភេទមួយចំនួន ដែលគេឃុំឃាំងនៅទីនោះ បាននិយាយអំពី បុគ្គលិកម្នាក់ ដែលជាបុរសពិការដៃម្ខាង ថាជាមនុស្សកាចសាហាវជាពិសេស ដោយបានវាយដំអ្នកជាប់ឃុំ និងយាយីផ្លូវភេទពួកគេ។ ស្រីផា ដែលជាប់ឃុំមួយយប់នៅក្នុងមន្ទីរនោះនៅចុងឆ្នាំ២០០៧ បាននិយាយដូច្នេះថា ៖*

> នៅពេលយប់ពូពិការដៃ និងគ្នាគាត់ពីរនាក់ផ្សេងទៀត បានចូលមកក្នុងបន្ទប់ដែលគេឃុំឃាំងពួកយើង ដើម្បីឆែករកលុយ។ ខ្ញុំបានឃើញពួកគេ យកលុយពីមនុស្សជាច្រើនដែលគេឆែករកបាន… ខ្ញុំមិនមានលុយទេ។ ពូពិការដៃ បាន វាយដំមនុស្សមួយចំនួន។ ពួកគេបានអោយពួកប្រុសៗដែលជាប់ឃុំ ដោះសម្លៀកបំពាក់ចេញ … ស្រីៗជាប់ឃុំ ក៏ទទួលរងនូវការឆែកឆេរពីពួកគេ ផងដែរ … ខ្ញុំបានលឺពីមិត្តភក្តិមួយចំនួនថា ពូពិការដៃនោះ បានយកស្រីៗ ចេញក្រៅ [ការិយាល័យ] ដើម្បី រួមភេទ និងបន្ទាប់មកដោះលែងពួកគេ។[115]

*បុទម ដែលគេចាប់ខ្លួនក្នុង ខែមិថុនា ឆ្នាំ២០០៨ បាននិយាយដូច្នេះថា ៖*

> ក្នុងខែមិថុនា ឆ្នាំ២០០៨ ប៉ូលីសចំការមន បានចាប់ខ្ញុំ និងមិត្តភក្តិខ្ញុំ ហើយគេយកខ្ញុំទៅដាក់ឃុំ នៅមន្ទីរសង្គមកិច្ច ក្បែរវត្តមហាមន្ត្រី មួយយប់ ។ ពូពិការ ដៃម្នាក់ បានចូលមកក្នុងបន្ទប់ នៅពេលយប់ ប្រាប់យើងកុំឲ្យជជែកលឺៗ និងអោយយកចេញពីខ្លួននូវរបស់របរ [ ផ្ទាល់ខ្លួន ] ដែលយើងមាន។ ពូពិការដៃបានប្រាប់អោយគ្នារបស់គាត់ ឆែកខ្លួនពួកយើងគ្រប់គ្នាដើម្បីរកលុយ។ គាត់វាយខ្ញុំពីរខ្សែក្រវាត់ ពេលគាត់ឆែករកឃើញ ថ្នាំញៀនលើខ្លួនខ្ញុំ។ ក្នុងពេល ឆែកឆេរ ខ្ញុំឃើញគាត់បង្ខំអោយពួកប្រុសៗ ដែលជាប់ឃុំ ស្រាតសម្លៀកបំពាក់ចេញនៅមុខគេឯងៗគ្រប់គ្នា។

---

115 អង្គការឃ្លាំមើលសិទ្ធិមនុស្សសម្ភាសន៍ជាមួយ ស្រីផា នៅភ្នំពេញ ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០៩។

*អ្នកប្រកបរបរផ្លូវភេទម្នាក់ទៀត ដែលត្រូវបានគេឃុំបីបួនលើកមកហើយ នៅឯមន្ទីរ សង្គមកិច្ចរាជធានីភ្នំពេញ បានពិពណ៌នាអំពីឧប្បត្តិហេតុមួយក្នុងខែកក្កដា ឆ្នាំ២០០៩ ដូច្នេះថា៖*

> ពូពិការដៃ បានចូលមកក្នុងបន្ទប់ និងប្រាប់យើងថា ពួកយើងនឹងត្រូវគេបញ្ជូន ទៅអង្គការមិនមែនរដ្ឋាភិបាល ដោយមិនមានជម្រើសអ្វីផ្សេងទៀតទេ។ បន្ទាប់មកគាត់សម្លឹងមើលមុខស្រីៗដែលស្រស់ស្អាត - គាត់ប្រាប់ទៅស្ត្រី នោះថា ប្រសិនបើ នរណាចង់ចេញ មកធ្វើម៉ាស្សាឲ្យគាត់នៅខាងក្រៅ។ ស្ត្រីម្នាក់ បានចេញទៅជាមួយគាត់ និងមិនឃើញត្រឡប់មកវិញទេ។[116]

*អ្នកដទៃទៀត រួមទាំងអ្នកគ្មានផ្ទះសម្បែង ដែលត្រូវគេចាប់ខ្លួន ក្នុងពេល បោសសម្អាតតាមដងវិថី បានរាយការណ៍ប្រាប់បុគ្គលិកសិទ្ធិមនុស្សក្នុងស្រុកផងដែរ អំពីបុរសពិការដៃ ដែលធ្វើការនៅទីនោះ បានប្រើអំពើហិង្សាលើអ្នកជាប់ឃុំ។[117] អ្នកប្រកបរបរផ្លូវភេទ បានប្រាប់អង្គការឃ្លាំមើលសិទ្ធិមនុស្សផងដែរថា មន្ត្រីនៅឯ មន្ទីរសង្គមកិច្ច បានទារលុយពីពួកគេជាថ្នូរនឹងការដោះលែង ឬជាថ្នូរនឹងការប្រគល់ ពួកគេ ទៅកាន់មណ្ឌល អង្គការមិនមែនរដ្ឋាភិបាលដែលនៅជិត "ដែលងាយស្រួល នឹងចាកចេញ។"[118] ធីតា ជាអ្នកប្រកបរបរផ្លូវភេទ អាយុ២៩ ឆ្នាំ បានពិពណ៌នា ពីការ ឃុំខ្លួននាង នៅឯមន្ទីរសង្គមកិច្ច នៅពាក់កណ្តាល ឆ្នាំ២០០៩ ដូច្នេះថា៖*

> បុគ្គលិកស្រីម្នាក់បានសួរពួកយើងថា តើយើងមានលុយទេ ឬតើមានអ្នក មក*លោះ*ខ្លួនពួកយើងទេ។ ខ្ញុំបានសុំឲ្យ ម្ចាស់ផ្ទះ ជួលពីមុនរបស់ខ្ញុំជួយយក លុយ ២០ដុល្លារមកលោះ។ គាត់ក៏បានអោយខ្ញុំចេញពី មន្ទីរសង្គមកិច្ច ដោយ មិនបញ្ជូនខ្ញុំទៅមណ្ឌល អង្គការមិនមែនរដ្ឋាភិបាលទេ។[119]

---

116 អង្គការឃ្លាំមើលសិទ្ធិមនុស្សសម្ភាសន៍ជាមួយ ដារា នៅភ្នំពេញ ថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០០៩។
117 អង្គការឃ្លាំមើលសិទ្ធិមនុស្សសម្ភាសន៍ជាមួយ អង្គការលីកាដូ នៅភ្នំពេញ ថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០០៩។
118 អង្គការឃ្លាំមើលសិទ្ធិមនុស្សសម្ភាសន៍ជាមួយ ធីតា នៅភ្នំពេញ ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៩។
119 អង្គការឃ្លាំមើលសិទ្ធិមនុស្សសម្ភាសន៍ជាមួយ ធីតា នៅភ្នំពេញ ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៩។

## អំពើរំលោភបំពាននៅឯមជ្ឈមណ្ឌលសង្គមកិច្ចរដ្ឋាភិបាល[120]

*បន្ទាប់ពីការឃុំឃាំងនៅឯប៉ុស្តិ៍នគរបាល និងមន្ទីរសង្គមកិច្ចរាជធានីភ្នំពេញ អ្នកប្រកបរបរផ្លូវភេទ ត្រូវបានគេបញ្ជូនទៅឲ្យស្ថិតនៅក្រោមការឃុំគ្រងរបស់ អង្គការមិនមែនរដ្ឋាភិបាល ឬមជ្ឈមណ្ឌលសង្គមកិច្ចរាជធានីភ្នំពេញ - ហៅជាទូទៅថា មណ្ឌលព្រៃស្តី។[121] ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ នៅពេលមានការដាក់សម្ពាធជា សាធារណៈ ច្រើនឡើងៗ ពីអំពើរំលោភបំពានក្នុងមណ្ឌលសង្គមកិច្ចរបស់រដ្ឋាភិបាល រដ្ឋាភិបាលបានឆ្លើយតបដោយការដោះលែងអ្នកប្រកបរបរផ្លូវភេទ ចេញពីមណ្ឌលឃុំឃាំងនានាដូចជាព្រៃស្តីជាដើម ឬក៏បញ្ជូនពួកគេទៅនៅតាមមណ្ឌលអង្គការក្រៅរដ្ឋាភិបាល។[122] ក្នុងមួយរយៈពេលពី ខែកក្កដា ឆ្នាំ២០០៩ រហូតដល់ខែឧសភា ឆ្នាំ២០១០ មានអ្នកប្រកបរបរផ្លូវភេទចំនួនតិចតួច ប៉ុណ្ណោះ ត្រូវបានគេឃុំឃាំង នៅព្រៃស្តី និងភាគច្រើនគេប្រគល់ទៅអង្គការមិនមែនរដ្ឋាភិបាល។[123]*

*ជំហររបស់រដ្ឋាភិបាលគឺថា ប្រជាពលរដ្ឋដែលស្នាក់នៅមណ្ឌលព្រៃស្តី ត្រូវឈរលើគោលការណ៍ស្ម័គ្រចិត្ត ដែលជំហរនេះជាការដកស្រង់ ចេញពីសេចក្តីណែនាំ ខែសីហា ឆ្នាំ២០០៨ ដែលចេញដោយរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ហាមឃាត់ការឃុំឃាំងដោយគ្មានការស្ម័គ្រចិត្តនៅតាមមណ្ឌលសង្គមកិច្ចរបស់ខ្លួន។[124] ប៉ុន្តែ*

120 នៅក្នុងខេត្តផ្សេង មានមជ្ឈមណ្ឌលសង្គមកិច្ចរបស់រដ្ឋាភិបាលបន្ថែមទៀត ក៏ប៉ុន្តែមិនមាននរណាម្នាក់ដែលអង្គការឃ្លាំមើលសិទ្ធិមនុស្សបានសម្ភាសន៍ ត្រូវបានគេបញ្ជូនទៅកាន់មជ្ឈមណ្ឌលទាំងនោះទេ។ ជាជំនួសវិញ នគរបាល បញ្ជូនអ្នកប្រកបរបរផ្លូវភេទទៅមណ្ឌលដែលគ្រប់គ្រងដោយអង្គការមិនមែនរដ្ឋាភិបាល។

121 ព្រៃស្តី មានទីតាំងស្ថិតនៅក្បែរភូមិព្រៃស្តី ឃុំចោមចៅ ខ័ណ្ឌដង្កោ រាជធានីភ្នំពេញ។

122 ឧទាហរណ៍ ជាលទ្ធផលនៃកង្វល់ដែលបានលើកឡើងដោយអង្គកាសិទ្ធិមនុស្សក្នុងស្រុក និងការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ នៅចុងខែមិថុនា ឆ្នាំ២០០៨ ក្រសួងសង្គមកិច្ច (MOSAVY) បានដោះលែងអ្នកជាប់ឃុំនៅកោះគរ និង ព្រៃស្តី។

123 នៅពេលដែលអង្គការលីកាដូ និងការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ បានចុះធ្វើទស្សនកិច្ចក្នុងខែតុលា ឆ្នាំ២០០៩ ដើម្បីធ្វើអោយមានការដោះលែងអ្នកជាប់ឃុំចំនួន ៤០ នាក់ ហើយក្នុងចំនោមនេះមាន យ៉ាងហោចណាស់ ក៏អ្នកប្រកបរបរផ្លូវភេទម្នាក់ដែរ។ សម្ភាសន៍ជាមួយអង្គការលីកាដូ នៅរាធានីភ្នំពេញ ថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០០៩។

124 ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា / គណៈកម្មាធិការជាតិដើម្បីដោះស្រាយបញ្ហាជនអនាថា។ "សេចក្តីណែនាំស្តីពីគោលនយោបាយដោះស្រាយបញ្ហារបស់ជនអនាថា" រាជធានីភ្នំពេញ ថ្ងៃទី៨ ខែសីហា ឆ្នាំ២០០៨ កថាខ័ណ្ឌ៦(២)។ សូមមើលលិខិតរបស់ក្រសួងមហាផ្ទៃផ្ញើជូនវេជ្ជបណ្ឌិត ហ្កេក ហ្កាឡាប្រ៊ូ ប្រធានអង្គការសម្ព័ន្ធកម្ពុជាដើម្បីលើកស្ទួយយ និងការពារសិទ្ធិមនុស្ស (លីកាដូ) លេខ ១២១៩ ស.ជ.ណ. ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨។

*អង្គការឃ្លាំមើលសិទ្ធិមនុស្ស បានទទួលព័ត៌មានថា ចន្លោះខែកក្កដា ឆ្នាំ២០០៩ និងខែមិថុនាឆ្នាំ២០១០ មានស្ត្រីប្រកបរបរផ្លូវភេទយ៉ាងហោចណាស់ ក៏ចំនួន ២០នាក់ដែរ ដែលត្រូវបានគេឃុំឃាំងនៅមណ្ឌលព្រៃស្ពឺ ផ្ទុយនឹងឆន្ទះរបស់ពួកគេ ដែលមានរយៈពេលពីពីរបីថ្ងៃ រហូតដល់ទៅមួយខែ។*[125] *អ្នកប្រកបរបរផ្លូវភេទចំនួន ប្រាំបីនាក់ ត្រូវគេឃុំទុកនៅទីនោះក្នុងរវាងខែឧសភា និងខែមិថុនា ឆ្នាំ២០១០។ ទោះបីជាចំនួនអ្នកប្រកបរបរផ្លូវភេទ ដែលត្រូវគេបញ្ជូនទៅឃុំនៅ ទីនោះមានការថយចុះគួរកត់សំគាល់ចាប់តាំងពីឆ្នាំ២០០៨មកក៏ដោយ ក៏ការថយចុះនេះ មួយ ចំនែកធំអាស្រ័យលើកិច្ចប្រឹងប្រែងស្វែងរកការគាំទ្រតតយប់ឈរនៃក្រុម អ្នកប្រកប របរផ្លូវភេទ និងដោយសារមានអង្គការមិនមែនរដ្ឋាភិបាលមួយចំនួន ស្ម័គ្រចិត្តទទួលយកអ្នកប្រកបរបរផ្លូវភេទពីខាងមន្ទីរសង្គមកិច្ច។ មានក្រុមដទៃទៀតដែលងាយ រងគ្រោះនឹងការចាប់ឃុំឃាំងដោយបំពាន ប៉ុន្តែ មានការគាំទ្រតិចតួច ដូចជា ក្រុម អ្នកគ្មានផ្ទះសម្បែង ត្រូវបានគេបន្តឃុំទុកនៅមណ្ឌលព្រៃស្ពឺដដែល។ អ្នកប្រកបរបរ ផ្លូវភេទ ដែលគេឃុំនៅមណ្ឌលព្រៃស្ពឺ ក្នុងខែមិថុនា ឆ្នាំ២០១០ បានប្រាប់អង្គការឃ្លាំមើលសិទ្ធិមនុស្សថា បុគ្គលិកមណ្ឌលសង្គមកិច្ចបានព្រមានពួកគេថា ពួកគេអាចនឹងត្រូវឃុំទុកនៅព្រៃស្ពឺ រហូតដល់រយៈពេលបីខែ ប្រសិនបើពួកគេត្រូវបានចាប់ជាថ្មីម្តងទៀត និងបានបញ្ជូនមកមន្ទីរសង្គមកិច្ចរាជធានីជាលើកទីពីរ។*[126] *ការគំរាម បែបនេះ គួបផ្សំនឹង ការណ៍ដែលមានយ៉ាងហោចណាស់ អ្នកប្រកបរបរផ្លូវភេទ ប្រាំបីនាក់ ត្រូវបានគេឃុំទុកដោយមិនស្ម័គ្រចិត្ត ក្នុងខែឧសភា និងខែមិថុនា ឆ្នាំ២០១០ បានធ្វើឲ្យខូចដល់ការតាំងចិត្តរបស់រដ្ឋាភិបាល ដែលអះអាងថា ការស្នាក់ នៅមណ្ឌលព្រៃស្ពឺ គឺពិតជាឈរលើគោលការណ៍ការស្ម័គ្រចិត្ត។*

---

125 អង្គការឃ្លាំមើលសិទ្ធិមនុស្សត្រូវបានគេជូនព័ត៌មាន និងទទួលបានឯកសារនានា ពីប្រភពគួរឲ្យជឿមួយ។ អត្តសញ្ញាណរបស់ប្រភពពត៌មាន ត្រូវបានរក្សាជាការណ៍សម្ងាត់។

126 អង្គការឃ្លាំមើលសិទ្ធិមនុស្សសម្ភាសន៍ជាមួយ ស្រី ថា, ស្រី ធូ, និងស្រី ធា នៅភ្នំពេញ ខែមិថុនា ឆ្នាំ២០១០ [កាលបរិច្ឆេទពិតប្រាកដត្រូវបានដកចេញ] ។

ដាក់ស្ដែងការណ៍ដែល បុគ្គលទាំងឡាយ ត្រូវបានគេដាក់អោយនៅ មជ្ឈមណ្ឌល សង្គមកិច្ច ដោយមិនស្ម័គ្រចិត្ត និងដោយគ្មានគោរពតាមនីតិវិធីត្រឹមត្រូវ តាមច្បាប់ អន្តរជាតិ វាគឺជាការឃុំឃាំងដោយបំពាន និងខុសច្បាប់ ។ អ្នកទាំងឡាយដែលជាប់ ឃុំនៅមណ្ឌលព្រៃស្ពឺ ទោះជាអ្នកប្រកបរបរផ្លូវភេទ ឬអ្នកផ្សេងទៀតក្តី មិនត្រូវបានគេ ធ្វើតាមនីតិវិធីច្បាប់ទេ មុនពេលបញ្ជូនទៅកាន់មណ្ឌល។ មិនមានមូលដ្ឋានច្បាប់ ច្បាស់លាស់ទេ ថាតើផ្អែកលើច្បាប់ណា ដែលពួកគេត្រូវបានបញ្ជូនទៅកាន់មណ្ឌល ទាំងនោះ និងឃុំឃាំងនៅទីនោះ។ មិនមានដំណាក់កាលណាមួយ ក្នុងអំឡុងពេល នៃការឃុំខ្លួន ដែលអ្នកជាប់ឃុំមានសិទ្ធិទទួលបានតំណាងខាងផ្លូវច្បាប់ឡើយ។ មិនមានការពិនិត្យផ្ទៀងផ្ទាត់តាមផ្លូវតុលាការលើការឃុំខ្លួនរបស់ពួកគេទេ ហើយ ពួកគេក៏មិនមានឱកាសសម្រាប់ប្តឹងជំទាស់ពីការឃុំខ្លួនរបស់ពួកគេដែរ។ ការឃុំខ្លួន ដោយខុសច្បាប់ ឬការដកហូតសេរីភាពដោយខុសច្បាប់ គឺជាបទល្មើសព្រហ្មទណ្ឌ នៅក្នុងប្រទេសកម្ពុជា ទោះបីជាអំពើនេះប្រព្រឹត្តដោយអ្នករាជការ ឬអ្នកមិនមែន រាជការ ក៏ដោយ។[127]

រហូតមកទល់ខែកក្កដា ឆ្នាំ២០០៨ មណ្ឌលសង្គមកិច្ចរបស់រដ្ឋាភិបាលមួយផ្សេងទៀត គឺមណ្ឌលកោះគរ (ដែលត្រូវបានគេស្គាល់ផងដែរថាជា កោះរំដួល) ក៏ត្រូវបានគេប្រើ សម្រាប់ឃុំឃាំងអ្នកប្រកបរបរផ្លូវភេទ អ្នកគ្មានផ្ទះសម្បែង អ្នកសុំទាន និងអ្នកប្រើ គ្រឿងញៀន។ មណ្ឌលកោះគរ មានទីតាំងនៅលើកោះមួយ នៅក្នុងស្រុកស្អាង ខេត្ត កណ្តាល ដែលឥឡូវនេះមិនមានសកម្មភាពទេ តែមានបុគ្គលិកម្នាក់ ឬក៏ពីរនាក់ ស្នាក់នៅទី នោះ ដូច្នេះមណ្ឌលនេះមិនបានបិទជាស្ថាពរទេ។

ការចោទពីការរំលោភបំពានដែលនៅតែមានជាបន្ត នៅមណ្ឌលព្រៃស្ពឺ និងកោះគរ នោះគឺវាជាការសំខាន់ចាំបាច់ ដែលមណ្ឌលទាំងពីរនេះត្រូវតែបិទចោលជាស្ថាពរ។

---

127 ក្រមព្រហ្មទណ្ឌ មាត្រា ២៥៤

*អង្គការសិទ្ធិមនុស្សបានចងក្រងឯកសារ និងបានរាយការណ៍អំពីការរំលោភធ្ងន់ធ្ងរនៅក្នុងមណ្ឌលទាំងពីរនេះ។[128] របាយការណ៍ឆ្នាំ២០០៩ របស់អង្គការលីកាដូ ដាក់ជូនទៅក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ក្នុងដំណើរការពិនិត្យតាមកាលកំណត់ជាសកល បានពិពណ៌នាពីការរំលោភសិទ្ធិមនុស្ស ដែលប្រព្រឹត្តនៅមជ្ឈមណ្ឌលទាំងពីរនេះ ៖*

> លក្ខខ័ណ្ឌនៅមណ្ឌលសង្គមកិច្ច [ ព្រៃស្ពឺ និងកោះគរ ] គឺធ្ងន់ធ្ងរហួសប្រមាណ - វាអាក្រក់ជាងលក្ខខ័ណ្ឌ ដែលមានក្នុងពន្ធនាគារកម្ពុជា - និងដែលរួមមានទាំងការដាក់មនុស្សហួសចំណុះយ៉ាងខ្លាំង និងខ្វះអាហារគ្រប់គ្រាន់ ទឹកស្អាត បរិភោគ និងការថែទាំសុខភាព។ ក្នុងខែមិថុនា ឆ្នាំ២០០៨ អង្គការលីកាដូ បានចូលទៅដល់មណ្ឌលកោះគរ ទោះបីជា បុគ្គលិកនៅមណ្ឌលនោះខិតខំរារាំង ក៏ដោយ និងបានថតបាននូវរូបភាព បុរស ស្ត្រី និងកុមារដែលកំពុងតែស្ថិតក្នុងស្ថានភាពស្រេកឃ្លាន ដែលត្រូវបានគេចាក់សោរឃុំឃាំងទុកក្នុងបន្ទប់។ នៅមណ្ឌលព្រៃស្ពឺ អ្នកជាប់ឃុំបានទទួលរងនូវអំពើហិង្សាដ៏សែនឃោរឃៅ ជាប្រចាំ។ ពួកសន្តិសុខបានរំលោភសេពសនវៈលើស្ត្រីដែលជាប់ឃុំឃាំង និងវាយដំយ៉ាងធ្ងន់ធ្ងរលើ អ្នកជាប់ឃុំ ដែលព្យាយាមរត់គេច ឬតវ៉ាអំពី លក្ខខ័ណ្ឌនានា យោងតាមអតីតអ្នកជាប់ឃុំឃាំង ដែលត្រូវបានសម្ភាសន៍ ដោយអង្គការលីកាដូ។ យោងតាមការស៊ើបអង្កេតរបស់អង្គការលីកាដូ យ៉ាងហោចណាស់ក៏មានអ្នកជាប់ឃុំបីនាក់ដែរ ឬក៏អាចមានច្រើនជាងនេះ  ដែលត្រូវបានឆ្មាំសន្តិសុខវាយរហូតដល់ស្លាប់ នៅមណ្ឌលព្រៃស្ពឺ ក្នុងអំឡុង ឆ្នាំ២០០៦-២០០៨ និងប្រាំនាក់ផ្សេងទៀតត្រូវបានរាយការណ៍មកថាបាន ធ្វើអត្តឃាត។[129]

128 សូមមើលលិខិតរបស់អង្គការលីកាដូ ចុះថ្ងៃទី១៨ ខែមិថុនា ២០០៨ ផ្ញើជូន ឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី និងជាប្រធានក្រុមការងារ ជាន់ខ្ពស់ ប្រឆាំងការជួញដូរមនុស្ស និងលោកជំទាវ យូ អយ រដ្ឋលេខាធិការក្រសួងកិច្ចការនារី និងជាប្រធានក្រុមការងារជាតិប្រឆាំងការជួញដូរ មនុស្ស និងលិខិតរបស់អង្គការលីកាដូ ចុះថ្ងៃទី២៨ ខែតុលា ២០០៨ ផ្ញើជូន ឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី និងជាប្រធានក្រុមការងារ ជាន់ខ្ពស់ ប្រឆាំងការជួញដូរមនុស្ស និងជូនឯកឧត្តម អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាស្តីពី "ការរំលោភ បំពាននៅក្នុងមណ្ឌលសង្គមកិច្ចព្រៃស្ពឺ និងកោះគរ។

129 សូមមើលលិខិតរបស់អង្គការលីកាដូ ចុះថ្ងៃទី១៨ ខែមិថុនា ២០០៨ ផ្ញើជូន ឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី និងជាប្រធានក្រុមការងារ ជាន់ខ្ពស់ ប្រឆាំងការជួញដូរមនុស្ស និងលោកជំទាវ យូ អយ រដ្ឋលេខាធិការក្រសួងកិច្ចការនារី និងជាប្រធានក្រុមការងារជាតិប្រឆាំងការជួញដូរ មនុស្ស។ លិខិតរបស់អង្គការលីកាដូ ចុះថ្ងៃទី២៨ ខែតុលា ២០០៨ ផ្ញើជូន ឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី និងជាប្រធានក្រុមការងារ

*ការសម្ភាសន៍របស់អង្គការឃ្លាំមើលសិទ្ធិមនុស្សជាមួយ អ្នកប្រកបរបរផ្លូវភេទ ដែលធ្លាប់បានជាប់ឃុំឃាំងនៅមណ្ឌលព្រៃស្ពឺ និងកោះគរ បានបញ្ជាក់អះអាងពី ការរំលោភ បំពាន និងស្ថានភាពអមនុស្សធម៌ ដែលបានចងក្រងឡើងដោយអង្គការលីកាដូ និងអង្គការសិទ្ធិមនុស្សដទៃទៀត។ របាយការណ៍ខែមករា ឆ្នាំ២០១០ របស់អង្គការឃ្លាំមើលសិទ្ធិមនុស្សស្តីពី "ស្បែកជាប់ខ្សែភ្លើង* [Skin on the Cable]*" ក៏បានចងក្រងនូវការរំលោភសេពសន្ថវៈលើអ្នកជាប់ឃុំជាស្ត្រីភេទក្នុងមណ្ឌលព្រៃស្ពឺផងដែរ* (*អ្នកប្រកបរបរផ្លូវភេទ និងអ្នកមិនប្រកបរបរផ្លូវភេទ*)*។*[130] *អ្នកប្រកបរបរផ្លូវភេទ បានប្រាប់អង្គការឃ្លាំមើលសិទ្ធិមនុស្សអំពីអ្វីដែលពួកគេបានទទួលរងដោយផ្ទាល់ និងបានឃើញការរំលោភសេពសន្ថវៈ ការវាយដំ និងការយាយីផ្លូវភេទ ក្នុងមណ្ឌល ព្រៃស្ពឺ និងកោះគរ។ ស្រីផា អាយុ២៧ឆ្នាំ បានពិពណ៌នាពីបទពិសោធន៍របស់នាង ដែលបានជាប់ឃុំនៅមណ្ឌលព្រៃស្ពឺ ក្នុងខែមិថុនាឆ្នាំ២០០៨ដូច្នេះថា ៖*

> ខ្ញុំបានជាប់ឃុំនៅព្រៃស្ពឺពីរថ្ងៃ។ វាដូចជារស់នៅក្នុងឋាននរកអញ្ចឹង។ គេដាក់ខ្ញុំក្នុងបន្ទប់ចាក់សោរ ជាមួយមនុស្សចំនួន៣០នាក់ ដែលមានទាំង បុរស ស្ត្រី និងកូនក្មេង។ មិនមានបង្គន់នៅក្នុងបន្ទប់ទេ ប៉ុន្តែមានធុងពីរ ដែលគេដាក់ សម្រាប់អោយពួកយើងទាំងអស់គ្នាប្រើជាបង្គន់ ។ មានស្នាមឈាមប្រឡាក់នៅពាសពេញលើជញ្ជាំង។ ខ្ញុំដេកមិនលក់ទេនៅពេលយប់ ព្រោះខ្ញុំភ័យខ្លាច និងព្រួយបារម្ភណ៍ជាខ្លាំង។ គេអោយម្ហូបអាហារយើងហូបតិចតួចណាស់ គឺពីរពេលក្នុង មួយថ្ងៃ - បាយជាមួយប្រហុក (ត្រីប្រឡាក់ប្រៃផ្អាប់) និងផ្លែអំពិល។ អត់មាន ចាន ឬស្លាបព្រាដាក់បាយអោយហូបទេ ខ្ញុំត្រូវហូបបាយពីថង់ប្លាស្ទិក។ នៅពេលយប់ពួកសន្តិសុខបានវាយបុរសម្នាក់ដែលព្យាយាមរត់យ៉ាងធ្ងន់ធ្ងរ។

---

ជាន់ខ្ពស់ ប្រឆាំងការជួញដូរមនុស្ស និងឯកឧត្តម អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាស្តីពី "ការរំលោភបំពាននៅណ្ឌលសង្គមកិច្ចព្រៃស្ពឺ និងកោះគរ។

130 អង្គការឃ្លាំមើលសិទ្ធិមនុស្ស *ស្បែកជាប់ខ្សែភ្លើង* ទំព័រ៤២-៤៣។

*អ្នកជាប់ឃុំនៅកោះគរ មានបទពិសោធន៍មិនសូវខុសគ្នាទេ។ បុទម អាយុ២៦ឆ្នាំ បាន ពិពណ៌នាពីការឃុំខ្លួននាងនៅមណ្ឌលកោះគរ ក្នុងខែមិថុនា ឆ្នាំ២០០៨ ដូច្នេះថា ៖*

> វាពិបាកខ្លាំងណាស់ នៅកោះគរ ពីព្រោះគេអោយ អាហារហូបតិចតួចមែន ទែន … គេដាក់ខ្ញុំនៅក្នុងបន្ទប់ដែលមានគ្នាប្រហែលជា ៤0 នាក់ នៅក្នុង នោះមានក្មេង ចាស់ ស្រី ប្រុស អ្នកសុំទាន អ្នកឡប់សតិ។ មានបង្គន់នៅ ក្នុងបន្ទប់។ គេប្រាប់ថា យើងនឹងត្រូវនៅកោះគរ ពីមួយឆ្នាំទៅបីឆ្នាំ។ ពេលខ្ញុំ ឮអញ្ចឹង ខ្ញុំយំរាល់ថ្ងៃ និងខ្ញុំមានអារម្មណ៍ថា ខ្ញុំចង់ស្លាប់។[131]

*អ្នកប្រកបរបរផ្លូវភេទ បានពិពណ៌នាពីរបៀបដែលឆ្មាំសន្តិសុខ វាយដំ និងទាត់ធាក់ ពួកគេ និងអ្នកដទៃទៀត ដែលមិនធ្វើតាមបញ្ជារបស់ពួកគេ និងបាននិយាយពីការ វាយដំធ្ងន់ធ្ងរដោយឆ្មាំសន្តិសុខទៅលើ អ្នកដែលបានព្យាយាមរត់គេចពីមណ្ឌល ។ អ្នកប្រកបរបរផ្លូវភេទមួយរូបបាននិយាយថា សន្តិសុខ ទាត់ធាក់ នាងនៅពេលបើក ទ្វារចូលមក។[132] ចន្ធូ ដែលបានជាប់ឃុំឃាំងនៅមណ្ឌលព្រៃស្ពឺ ក្នុងខែមិថុនា ឆ្នាំ២០០៨ អស់រយៈពេលមួយខែ បានប្រាប់អង្គការឃ្លាំមើលសិទ្ធិមនុស្សដូច្នេះថា ៖*

> អ្នកយាមបានបញ្ជាឲ្យខ្ញុំទៅដងទឹកពីស្រះ។ ខ្ញុំមិនស្រួលខ្លួនសោះ អញ្ចឹងខ្ញុំ ប្រកែកមិនធ្វើតាមបញ្ជាគាត់ទេ។ គាត់យកដំបង ឈើមកវាយលើចង្កេះខ្ញុំ ពីរដំបង … មានមួយលើកទៀត អ្នកយាមម្នាក់បានយកដំបងឈើធំមួយមក វាយលើស្មារខ្ញុំយ៉ាងខ្លាំង ក្រោយពេលគេចាប់ខ្ញុំ និងប្តីរបស់ខ្ញុំបានក្នុងពេលកំពុង តែព្យាយាមលួចរត់ចេញ[133] ។ ដៃស្តាំរបស់ខ្ញុំខ្សោយតាំងពីពេលត្រូវគេវាយ នោះមក។[134]

*ឆ្មាំសន្តិសុខ ត្រូវបានគេដឹងឮថា បានគំរាមសម្លាប់មនុស្ស ដើម្បីរារាំងពួកគេ ពីការ លួចរត់គេចចេញពីមណ្ឌល ហើយមានស្ត្រីម្នាក់បានរលូតកូន ដោយសារតែ*

---

131 អង្គការឃ្លាំមើលសិទ្ធិមនុស្សសម្ភាសន៍ជាមួយ បុទម នៅភ្នំពេញ ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០៩។
132 អង្គការឃ្លាំមើលសិទ្ធិមនុស្សសម្ភាសន៍ជាមួយ ស្រី តា នៅភ្នំពេញ ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០៩។
133 ទាំងពីរនាក់ប្តីប្រពន្ធត្រូវបានចាប់ខ្លួន អំឡុងពេលនៃការបោសសម្អាតតាមដងវិថី (ពួកគេកំពុងដេកតាមចិញ្ចើមផ្លូវ) និងត្រូវបានគេបញ្ជូន ទៅកាន់មណ្ឌលព្រៃស្ពឺ។
134 អង្គការឃ្លាំមើលសិទ្ធិមនុស្សសម្ភាសន៍ជាមួយ ចន្ធូ នៅភ្នំពេញ ថ្ងៃទី៧ ខែសីហា ឆ្នាំ២០០៩។

*ការវាយដំរបស់ឆ្មាំសន្តិសុខ។ ម៉ាលីស អាយុ២៨ឆ្នាំ ដែលគេឃុំនៅព្រៃស្អ ក្នុងខែវិច្ឆិកា ឆ្នាំ២០០៧ បាននិយាយថា ៖*

> អ្នកយាមដែលត្រូវជាកូនរបស់អ្នកកាន់សោរ ទាត់ខ្ញុំបីជើង បន្ទាប់ពីខ្ញុំមិនព្រមធ្វើតាមបញ្ជារបស់គាត់ដែល ឲ្យខ្ញុំជម្រះស្មៅ។ ខ្ញុំប្រាប់គាត់ថា ខ្ញុំមិនអាចធ្វើការងារ បានទេ ពីព្រោះខ្ញុំចាញ់កូន។ ខ្ញុំមានផ្ទៃពោះបីខែ។ តាំងពីពេលនោះមក ខ្ញុំចេះតែឈឺក្នុងផ្ទៃពោះ និងខ្ញុំបានរលូតកូននៅពេលខ្ញុំត្រឡប់មកដល់ផ្ទះវិញ ក្រោយពីការជាប់ឃុំមួយសប្តាហ៍នៅព្រៃស្អ។[135]

*អ្នកជាប់ឃុំឃាំងបានប្រាប់អង្គការឃ្លាំមើលសិទ្ធិមនុស្សថា ឆ្មាំសន្តិសុខបានរំលោភសេពសន្ថវៈស្ត្រី នៅចំពោះវត្តមាន នៃអ្នកជាប់ឃុំដទៃទៀតនៅមណ្ឌលព្រៃស្អ។ អ្នកប្រកបរបរផ្លូវភេទម្នាក់ ដែលគេឃុំខ្លួននៅទីនោះនៅដើមឆ្នាំ២០០៨ បាននិយាយ ថា មានឆ្មាំសន្តិសុខបីនាក់បានចូលមកក្នុងបន្ទប់នៅពេលយប់ ដើម្បីរំលោភលើស្ត្រីពីរនាក់ដែលដេកនៅក្បែរនាង។ ស្ត្រីពីនាក់នោះក៏ត្រូវបានគេអោយចេញពីមណ្ឌលនៅថ្ងៃបន្ទាប់។[136] នៅក្នុងមជ្ឈមណ្ឌលទាំងពីរ ឆ្មាំសន្តិសុខស្នើឲ្យស្ត្រីរួមភេទជាមួយពួកគេជាថ្នូរនឹងការដោះលែង។ អ្នកប្រកបរបរផ្លូវភេទអាយុ២៨ឆ្នាំ ដែលជាប់ឃុំនៅក្នុងខែវិច្ឆិកា ឆ្នាំ២០០៧ ក្នុងមណ្ឌលព្រៃស្អបាននិយាយដូច្នេះថា ៖*

> អ្នកយាម ដើរមករកខ្ញុំ និងសុំឲ្យខ្ញុំទៅដេកជាមួយគាត់ និងជាមួយអ្នកយាម បួននាក់ទៀត។ គាត់ចង្អុលទៅអ្នកយាមបួននាក់នោះ និងនិយាយថាប្រសិនជាខ្ញុំព្រមរួមភេទជាមួយពួកគេទាំងអស់គ្នានេះ ពួកគេនឹងដោះលែងខ្ញុំពីមណ្ឌល។ ខ្ញុំបានប្រាប់ទៅពួកគេថាខ្ញុំមិនស្រួលខ្លួនទេ ហើយគេក៏មិនបង្ខំខ្ញុំដែរ។[137]

---

135 អង្គការឃ្លាំមើលសិទ្ធិមនុស្សសម្ភាសន៍ជាមួយ ម៉ាលីស នៅភ្នំពេញ ថ្ងៃទី៧ ខែសីហា ឆ្នាំ២០០៩។

136 អង្គការឃ្លាំមើលសិទ្ធិមនុស្សសម្ភាសន៍ជាមួយ បុផ្ផា នៅភ្នំពេញ ថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៩។ ពួកសន្តិសុខ រំលោភសេពសន្ថវៈស្ត្រីមានសំរស់ស្រស់ស្អាត និងដោះលែងពួកគេចេញពីមណ្ឌលបន្ទាប់ពីការរំលោភ ក៏មានសរសេរផងដែរនៅក្នុងរបាយការណ៍ ៖ អង្គការឃ្លាំមើលសិទ្ធិមនុស្ស *ស្បែកដាច់ជាប់ខ្សែភ្លើង* ទំព័រ៤៣។

137 អង្គការឃ្លាំមើលសិទ្ធិមនុស្សសម្ភាសន៍ជាមួយ ម៉ាលីស នៅភ្នំពេញ ថ្ងៃទី៧ ខែសីហា ឆ្នាំ២០០៩។

*កុមារក៏ ស្ថិតក្នុងចំណោមអ្នកទាំងឡាយដែលត្រូវបានគេឃុំឃាំង នៅក្នុងមណ្ឌលព្រៃស្ពឺនិងកោះគរផងដែរ។*[138] *ដូចដែលបានពោលខាងលើ កុមារមិនគួរត្រូវបាន ឃុំឃាំងដោយគ្រាន់តែផ្អែកលើការពាក់ព័ន្ធរបស់ពួកគេក្នុងការងារផ្លូវភេទនោះទេ ហើយជាជំនួសវិញកុមារ ត្រូវតែទទួលបាននូវជំនួយ និងកិច្ចការពារសមស្រប ដើម្បីឲ្យពួកគេអាចឆ្ងងផុត ពីការងារបែបនោះ ដូចជា ប្រគល់ពួកគេទៅឲ្យស្ថិតនៅក្រោមការឃុំគ្រងរបស់អង្គការមិនមែនរដ្ឋាភិបាលដែលគួរជឿទុកចិត្តបាន និងដែលមានផ្តល់សេវាសមស្របសម្រាប់កុមារ ស្របតាមបទដ្ឋានអន្តរជាតិ។*

*អង្គការឃ្លាំមើលសិទ្ធិមនុស្សជឿថា យូរៗម្តង ប្រជាពលរដ្ឋនៅតែត្រូវបានគេឃុំខ្លួននៅមណ្ឌលព្រៃស្ពឺ ប្រឆាំងនឹងឆន្ទៈរបស់ពួកគេ និងពួកគេមិនអាចចាកចេញបាន ទេ។ អំឡុងពេលទស្សនកិច្ច របស់អង្គការលីកាដូ និងការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិ នៅមណ្ឌលព្រៃស្ពឺ ក្នុង ខែតុលា ឆ្នាំ២០០៩ មន្ត្រីនៃមន្ទីរ សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មិនព្រមដោះលែងអ្នកជាប់ឃុំទេ លុះត្រាណាតែមានសាច់ញាតិ ឬតំណាងអង្គការមិនមែនរដ្ឋាភិបាល ធានាឲ្យមានការដោះលែងពួកគេពីមណ្ឌល។ ប្រសិនបើមិនមានសាច់ញាតិ ឬតំណាងអង្គការមិនមែនរដ្ឋាភិបាលមកធានាទទួលយកពួកគេទៅឃុំគ្រង ទេ នោះពួកគេហ្នឹងនៅតែស្ថិតក្នុងមណ្ឌលក្នុងរយៈពេលមិនកំណត់មួយ។*[139] *ដូចគ្នានេះដែរ អ្នកប្រកបរបរផ្លូវភេទចំនួន៣នាក់ដែលត្រូវបានគេឃុំខ្លួននៅព្រៃស្ពឺ ក្នុងខែមិថុនា ឆ្នាំ២០១០ ត្រូវបានដោះលែងលុះត្រាតែមានអង្គការមកធានា និងស្នើសុំមន្ទីរ សង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទាឲ្យដោះលែងពួកគេ។*[140]

---

138 លិខិតរបស់អង្គការលីកាដូ ចុះថ្ងៃទី១៨ ខែមិថុនា ២០០៨ ផ្ញើជូន ឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី និង ជាប្រធានក្រុមការងារជាន់ខ្ពស់ប្រឆាំងការជួញដូរមនុស្ស និងលោកជំទាវ យូ អយ រដ្ឋលេខាធិការក្រសួងកិច្ចការនារី និងជាប្រធានក្រុមការងារជាតិប្រឆាំងការជួញដូរមនុស្ស។
139 អង្គការឃ្លាំមើលសិទ្ធិមនុស្សសម្ភាសន៍ជាមួយ អង្គការលីកាដូ នៅភ្នំពេញ ថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០០៩។
140 អង្គការឃ្លាំមើលសិទ្ធិមនុស្សសម្ភាសន៍ជាមួយស្រី ថា, ស្រី ធូ, និងស្រី ធា នៅភ្នំពេញ ខែមិថុនា ឆ្នាំ២០០៩ [កាលបរិច្ឆេទពិតប្រាកដត្រូវបាកដកចេញ]។

*ស្រីជា អាយុ២២ឆ្នាំ ត្រូវបានគេឃុំឃាំងនៅព្រៃស្ពឺក្នុងខែមិថុនា ឆ្នាំ២០១០។ នាងបាននិយាយថា មន្ត្រីនៅមន្ទីរសង្គមកិច្ចរាជធានី បានផ្ដល់ឲ្យរូបនាងនូវជម្រើស ស្ដីពីការបញ្ជូននាងទៅអង្គការមិនមែនរដ្ឋាភិបាល ឬទៅមណ្ឌលព្រៃស្ពឺ ប៉ុន្តែមិនមានជម្រើសនៃការត្រឡប់ទៅផ្ទះវិញទេ។ ស្រីជា ជ្រើសរើសយកជម្រើសទៅមណ្ឌលព្រៃស្ពឺ និងបើយោងទៅតាមការរៀបរាប់របស់នាងគឺ គេដាក់ឃុំឃាំងដាច់ដោយឡែកពីគ្នារវាងអ្នកដែលមិនស្ម័គ្រចិត្ត និងអ្នកដែលស្ម័គ្រចិត្តស្នាក់នៅក្នុងណ្ឌលព្រៃស្ពឺ៖*

> នៅព្រៃស្ពឺ គេដាក់យើងនៅក្នុងបន្ទប់មួយ ជាមួយស្រីៗជាច្រើននាក់។ វាមានមនុស្សច្រើនពេក ហើយយើងត្រូវដេកនៅពាសពេញបន្ទប់ ស្ទើរតែ មិនមានចន្លោះរំកិលខ្លួនបានផង។ យើងមិនមានខោអាវសម្រាប់ផ្លាស់ប្ដូរទេ ហើយ មណ្ឌលក៏មិនបានឲ្យខោអាវយើងសម្រាប់ផ្លាស់ប្ដូរដែរ ដូច្នេះ យើងត្រូវស្លៀកខោអាវដដែល ក្នុងរយៈពេលប៉ុន្មានថ្ងៃ ដែលជាប់នៅទីនោះ។ បន្ទប់មិនត្រូវបានគេចាក់សោរទេ ប៉ុន្តែមានអ្នកយាមនៅខាងមុខបន្ទប់គ្រប់ពេល។ បើយើងចង់ទៅបង្គន់ យើងត្រូវសុំ អ្នកយាម។ អ្នកយាមដើរតាមយើងទៅបង្គន់ ដើម្បីកុំឲ្យយើងរត់គេច។ មណ្ឌលនេះ ផ្ដល់អាហារបីពេលក្នុងមួយថ្ងៃ ... អាហារគេអោយហូបមិនបានគ្រប់គ្រាន់ទេ ... អ្នកនៅក្នុងបន្ទប់ជាមួយខ្ញុំ បានត្អូញត្អែរអំពីការស្រេកឃ្លាន ពីព្រោះតែពួកគេមិនមានអាហារហូបគ្រប់គ្រាន់។ ខ្ញុំបានឃើញយ៉ាងហោចណាស់ក៏ម្ដងដែរដែលអ្នកយាមរាងក្មេងម្នាក់បានវាយដៃស្ត្រីចំណាស់ម្នាក់ នៅពេលដែលគាត់កំពុងហូបបាយ។
>
> ស្ត្រីនៅក្នុងបន្ទប់ខ្ញុំ ត្រូវបានគេឲ្យចេញពីបន្ទប់ ចំនួនពីរដងក្នុងមួយថ្ងៃ នៅម៉ោង ៩ ព្រឹក និងម៉ោង ២ រសៀល ដើម្បីទៅងូតទឹក។ ដោយសារតែខ្ញុំ និងអ្នកដទៃ ក្នុងបន្ទប់នេះសុទ្ធតែជាអ្នកមិនស្ម័គ្រចិត្តស្នាក់នៅក្នុងមណ្ឌល គេអោយទៅងូត ទឹកនៅឯស្រះ។ ទឹកស្រះ ហាក់ដូចជាមិនស្អាតទេ ហើយវាធ្វើឲ្យខ្ញុំរោលកន្ទួល ពេញខ្លួន។ ចំណែកឯអ្នកដែលស្ម័គ្រចិត្តស្នាក់នៅក្នុងមណ្ឌលវិញ ត្រូវបានគេឲ្យទៅ ងូតទឹកទុយោ និងគេទុកឲ្យនៅក្នុងអាគារផ្សេង។[141]

141 អង្គការឃ្លាំមើលសិទ្ធិមនុស្សសម្ភាសន៍ជាមួយ ស្រី ជា នៅភ្នំពេញ ខែមិថុនា ឆ្នាំ២០០៩ [កាលបរិច្ឆេទពិតប្រាកដត្រូវបាកដកចេញ]។

អង្គការលីកាដូ បានរាយការណ៍ថា ប្រជាពលរដ្ឋទាំងនោះទទួលរងនូវការគំរាម ប្រើអំពើហិង្សាប្រសិនបើពួកគេព្យាយាមរត់ចេញពីមណ្ឌលព្រៃស្ពឺ និងថាវាគ្រាន់តែជាការនិយាយឲ្យតែបានប៉ុណ្ណោះ ដែលថាពួកគេត្រូវបានគេផ្តល់ឲ្យនូវ "ជម្រើស" ដើម្បីស្នាក់នៅដោយស្ម័គ្រចិត្ត នៅពេលដែលពួកគេបានមកដល់មណ្ឌលនោះ ដែលនេះជាជម្រើសគ្មានន័យ។ នៅពេលដែលពួកគេមកដល់មណ្ឌលហើយ ពួកគេមិនមានលទ្ធភាពដើម្បីចាកចេញទាល់តែសោះ ពីព្រោះមានឆ្មាំសន្តិសុខឃ្លាំចាំមើលពួកគេគ្រប់ពេលវេលា។

អង្គការឃ្លាំមើលសិទ្ធិមនុស្ស បានព្យាយាមទៅចូលធ្វើទស្សនកិច្ចនៅមណ្ឌលព្រៃស្ពឺ នៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ២០០៩ ប៉ុន្តែទ្វាររបងបានចាក់សោរជាប់ ហើយអ្នកយាមមិនព្រមឲ្យចូលនោះទេ។ អ្នកយាមទ្វារបានប្រាប់អង្គការឃ្លាំមើលសិទ្ធិមនុស្សថា ការចូលមើលមណ្ឌលតម្រូវឲ្យ មានការអនុញ្ញាតជាមុនពីមន្ទីរសង្គមកិច្ចរាជធានី។ អង្គការឃ្លាំមើលសិទ្ធិមនុស្ស បានស្នើសុំការអនុញ្ញាតសម្រាប់ការចូល ធ្វើទស្សនកិច្ចនៅមណ្ឌលព្រៃស្ពឺ នៅក្នុងលិខិតមួយ ដែលបានផ្ញើជូនក្រសួងសង្គមកិច្ច អតីត យុទ្ធជន និងយុវនីតិសម្បទា ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១០។ ប៉ុន្តែរដ្ឋាភិបាលមិនបានឆ្លើយតបចំពោះលិខិតនេះទេ។

## ទីជម្រករបស់អង្គការក្រៅរដ្ឋាភិបាល និងការឃុំខ្លួនដោយបំពាន

បន្ទាប់ពីការរៀបចំបែបបទនៅឯមន្ទីរសង្គមកិច្ចរាជធានីរួចហើយ អ្នកប្រកបរបរ ផ្លូវភេទ ដែលគេមិនបញ្ជូនទៅកាន់មណ្ឌលព្រៃស្ពឺ ត្រូវបានគេបញ្ជូនទៅកាន់អង្គការ មិនមែនរដ្ឋាភិបាល ដែលមានផ្តល់សេវា ដល់អ្នកប្រកបរបរផ្លូវភេទ ដូចជាការផ្តល់ការ ប្រឹក្សា និងការបណ្តុះបណ្តាលវិជ្ជាជីវៈជំនាញ។ ក្នុងករណីខ្លះ ការផ្តល់ជម្រកឲ្យ អ្នកប្រកបរបរផ្លូវភេទ ត្រូវប្រព្រឹត្តិទៅ ដោយទោះបីជាវាមិនច្បាស់លាស់ថា ជានិច្ចកាលថា វាធ្វើឡើងដោយឈរលើមូលដ្ឋានព្រមព្រៀង។ ក្នុងខែកក្កដា និងខែសីហា ឆ្នាំ២០០៩

អ្នកប្រកបរបរផ្លូវភេទ បានរាយការណ៍ប្រាប់អង្គការឃ្លាំមើលសិទ្ធិមនុស្សថា មណ្ឌលដែលគ្រប់គ្រងដោយអង្គការក្រៅរដ្ឋាភិបាលចំនួនពីរ បានរក្សាទុកអ្នកប្រកបរបរផ្លូវភេទជានីតិជន ផ្ទុយនឹងឆន្ទៈរបស់ពួកគេអស់មួយរយៈពេល ដែលថិរវេលានោះមានចាប់ពី បីបួនម៉ោង រហូតដល់ពីរបីថ្ងៃ។[142] មណ្ឌលមួយបានបង្ខំស្ត្រីឲ្យនៅក្នុងបន្ទប់ចាក់សោរ។[143] មណ្ឌលមួយទៀតមានរបងខ្ពស់ព័ទ្ធជុំវិញបរិវេណ ហើយទោះបីជាញឹកញយគ្មានការចាក់សោរទ្វាររបងក៏ដោយ ក៏បុគ្គលិកមណ្ឌលបានប្រាប់អ្នកប្រកបរបរផ្លូវភេទឲ្យស្នាក់នៅតែក្នុងមណ្ឌល និងអោយពួកគេ ប្រតិបត្តិតាម ទោះបីជាពួកគេចង់ចាកចេញក៏ដោយ។[144]

ជាងនេះទៅទៀត អ្នកប្រកបរបរផ្លូវភេទ បានប្រាប់អង្គការឃ្លាំមើលសិទ្ធិមនុស្សថា អង្គការក្រៅរដ្ឋាភិបាលមួយ មិនបានរៀបចំចាត់ចែងឲ្យអ្នកប្រកបរបរផ្លូវភេទ ដែលមានផ្ទុកមេរោគអេដស៍ ហើយដែលបានជាប់ឃុំនៅមណ្ឌលរបស់ខ្លួន ដើម្បីទទួលបានឱសថពន្យាអាយុទេ។ យ៉ាងហោចណាស់ ក៏មានអ្នកប្រកបរបរផ្លូវភេទពីរនាក់ដែរ ដែលកំពុងប្រើឱសថពន្យាអាយុ ប៉ុន្តែមិនមានឱសថជាប់ខ្លួនមកជាមួយពួកគេទេ នៅពេលចាប់ខ្លួនដោយអាជ្ញាធរ និងត្រូវបានគេបញ្ជូនទៅមណ្ឌល ក្នុង ខែកក្កដា ឆ្នាំ២០០៩។ ពួកគេបានខកខានប្រើឱសថចំនួនបីថ្ងៃ ពីព្រោះតែពួកគេមិនអាចរកឱសថបាននៅឯមណ្ឌលអង្គការ។ ស្ត្រីម្នាក់ក្នុងចំនោមពួកគេបាន និយាយថា ពួកគេបានស្នើសុំឲ្យសមាជិកគ្រួសារ យកឱសថពន្យាអាយុមកអោយ ពួកគេ ប៉ុន្តែបុគ្គលិកអង្គការមិនអនុញ្ញាតឲ្យពួកគេទាក់ទងសមាជិកគ្រួសារទេ។

---

142 អង្គការឃ្លាំមើលសិទ្ធិមនុស្សសម្ភាសន៍ជាមួយ អានី ថ្ងៃទី២៦ ខែកក្កដា ២០០៧, សម្ភាសន៍ជាមួយ ដារា ថ្ងៃទី២៦ ខែកក្កដា ២០០៩, សម្ភាសន៍ជាមួយ កូលាប ថ្ងៃទី៦ ខែសីហា ២០០៩, សម្ភាសន៍ជាមួយ ម៉ាឡា ថ្ងៃទី៧ ខែសីហា ២០០៩, សម្ភាសន៍ជាមួយ តុលា ថ្ងៃទី១៣ ខែសីហា ២០០៩ និង សម្ភាសន៍ជាមួយ ធីតា ថ្ងៃទី២៤ ខែសីហា ២០០៩។

143 អង្គការឃ្លាំមើលសិទ្ធិមនុស្សសម្ភាសន៍ជាមួយ អានី ថ្ងៃទី២៦ ខែកក្កដា ២០០៧, សម្ភាសន៍ជាមួយ ដារា ថ្ងៃទី២៦ ខែកក្កដា ២០០៩, សម្ភាសន៍ជាមួយ កូលាប ថ្ងៃទី៦ ខែសីហា ២០០៩, សម្ភាសន៍ជាមួយ តុលា ថ្ងៃទី១៣ ខែសីហា ២០០៩។

144 អង្គការឃ្លាំមើលសិទ្ធិមនុស្សសម្ភាសន៍ជាមួយ កូលាប ថ្ងៃទី៦ ខែសីហា ២០០៩, សម្ភាសន៍ជាមួយ ម៉ាឡា ថ្ងៃទី៧ ខែសីហា ២០០៩ សម្ភាសន៍ជាមួយ តុលា ថ្ងៃទី១៣ ខែសីហា ២០០៩ និង សម្ភាសន៍ជាមួយ ធីតា ថ្ងៃទី២៤ ខែសីហា ២០០៩។

*បុគ្គលិកនៃមណ្ឌលអង្គការនោះបានដោះលែងពួកគេ ក្រោយពេលមានអង្គការផ្សេង មួយចំនួន បានអន្តរាគមន៍អោយមានការដោះលែង។*[145]

*កិច្ចព្រមព្រៀងឆ្នាំ២០០៧ រវាងអង្គការក្រៅរដ្ឋាភិបាលមួយចំនួន អំពីការផ្តល់កន្លែង ស្នាក់នៅ ឬសេវាផ្សេងៗដល់ជនរងគ្រោះនៃអំពើជួញដូរ និងអង្គភាពនានា របស់ រដ្ឋាភិបាល បានប៉ុនប៉ងដោះស្រាយបញ្ហានេះ ដោយកំណត់នូវ បទដ្ឋានជាមូលដ្ឋាន ស្តីពីការផ្តល់ជម្រក និងសិទ្ធិរបស់អតិថិជន រួមទាំងកាតព្វកិច្ចចំពោះការមានការ យល់ព្រម ពីជនរងគ្រោះក្នុងការស្នាក់នៅក្នុងជម្រក ហើយនិងការអនុញ្ញាតឲ្យ ជនរងគ្រោះចាកចេញពីជម្រក។*[146] *ប៉ុន្តែ មិនមែន អង្គការទាំងអស់សុទ្ធតែបានចុះ ហត្ថលេខាលើកិច្ចព្រមព្រៀងនេះទេ ហើយទោះជាយ៉ាងណាក៏ដោយ ក៏វាមិន ភ្ជាប់កាតព្វកិច្ចច្បាប់ ដែរ។*

*នៅពេលសម្ភាសន៍ដោយអង្គការឃ្លាំមើលសិទ្ធិមនុស្ស ក្នុងខែវិច្ឆិកា ឆ្នាំ២០០៩ បុគ្គលិក អង្គការមិនមែនរដ្ឋាភិបាលចំនួនពីរ បានទទួលស្គាល់ថា ក្នុងអតីតកាល បុគ្គលិករបស់ ខ្លួន បានដាក់ការគាបសង្កត់ឲ្យអ្នកប្រកបរបរផ្លូវភេទ ស្នាក់នៅក្នុងមណ្ឌលចំនួន ពីរឬបីថ្ងៃ ដើម្បីផ្តល់ប្រឹក្សា និង សុវត្ថិភាពដល់ពួកគេ និងក្នុងខណៈពេលនោះ ជំរុញលើកទឹកចិត្ត ពួកគេ ឲ្យទទួលបានអត្ថប្រយោជន៍ពីការបណ្តុះបណ្តាល វិជ្ជាជីវៈជំនាញ និងកម្មវិធីដទៃទៀតដែលមានផ្តល់ដោយមណ្ឌល។ នៅពេលដែល ទង្វើបែបនេះ គឺក្នុងគោលបំណងល្អក៏ដោយ ប៉ុន្តែប្រសិនបើជាក់ស្តែង ស្ត្រីទាំងនោះ*

---

145 អង្គការឃ្លាំមើលសិទ្ធិមនុស្សសម្ភាសន៍ជាមួយ អានី និង ដារ៉ា រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែកក្កដា ២០០៩។ សូមមើលសេចក្តីថ្លែងការណ៍ សារព័ត៌មានរបស់អង្គការលីកាដូ "ដាក់ទណ្ឌកម្មអ្នកក្រ៖ ការចាប់ខ្លួនច្រើនថែមទៀតចំពោះអ្នករស់នៅតាមដងវិថី" ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០០៩។ គេហទំព័រ http://www.licadho-cambodia.org/pressrelease.php?perm=212&pagenb=0&filter=2009, (បានចូលមើលគេហទំព័រនេះ ថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០១០)។ អង្គការមិនមែនរដ្ឋាភិបាលដែលរងការចោទប្រកាន់ បានបដិសេធអំពី ការកើត មានឡើងនូវឧប្បត្តិវហេតុបែបនេះ។

146 រដ្ឋាភិបាលកម្ពុជា ក្រសួងយុត្តិធម៌ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងសុខាភិបាល កិច្ចព្រមព្រៀងស្តីពី គោលការណ៍ណែនាំសម្រាប់ការអនុវត្តន៍ និងការសហប្រតិបត្តិការ រវាងស្ថាប័នរដ្ឋាភិបាលពាក់ព័ន្ធ និងទីភ្នាក់ងារគាំទ្រជនរងគ្រោះ ក្នុងករណី នៃអំពើជួញដូរមនុស្ស ថ្ងៃទី៦ខែកុម្ភៈ ឆ្នាំ២០០៧។ http://www.humantrafficking.org/uploads/updates/Guidelines_for_Victims_Support_Agencies.pdf, (បានចូលមើលនៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១០)។

*ប្រាថ្នាចង់ចាកចេញពីមណ្ឌល តែមិនអាចចេញតាមបំណងខ្លួនបានទេនោះ វា ដូចគ្នាទៅនឹងការដកហូតសេរីភាពរបស់ពួកគេដោយខុសច្បាប់។*

*ខណៈពេលដែលអង្គការចំនួនពីរ បានហាមឃាត់អ្នកប្រកបរបរផ្លូវភេទ មិនឲ្យចាកចេញពីមណ្ឌលរបស់ពួកគេដោយប្រសិទ្ធភាព ក្នុងកាលៈទេសៈជាក់លាក់ជាច្រើន ក្នុង អតីតកាល អង្គការទាំងនោះបានថ្លែងថា គោលនយោបាយបច្ចុប្បន្នរបស់ពួកគេ គឺមិនមានឃុំនរណាម្នាក់ទេ ហើយពួកគេទាំងឡាយមានសេរីភាពនឹងចាកចេញ នៅពេលណាក៏បាន។ ក្រុមអង្គការសិទ្ធិមនុស្ស និងក្រុមគាំទ្រអ្នកប្រកបរបរផ្លូវភេទ បានអះអាងថា ការអនុវត្តន៍ពី អតីតកាលរបស់អង្គការទាំងនោះមានការផ្លាស់ប្ដូរ ហើយរយៈពេលក្រោយនេះ ។*

*អង្គការមួយដែលផ្ដល់ជម្រកស្នាក់អាស្រ័យដល់កុមាររងគ្រោះ នៃអំពើរំលោភបំពាន ប៉ុន្តែ ក៏ទទួលយកអ្នកប្រកបរបរផ្លូវភេទជានីតិជន ដែលមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា បញ្ជូនទៅឲ្យពួកគេ ពីព្រោះ "ពួកគេមិនមានទីកន្លែង ដែលត្រូវ ទៅ"។[147] អង្គការលីកាដូ បានរាយការណ៍ថា ខណៈពេលដែលអ្នកប្រកបរបរផ្លូវភេទ ចំនួន១២នាក់ ត្រូវបានឃុំខ្លួននៅក្នុងមណ្ឌលរបស់អង្គការនោះ ក្នុងខែកក្កដា ឆ្នាំ ២០០៩ បុគ្គលិកមណ្ឌលបានទុកពួកគេក្នុងបន្ទប់ចាក់សោរ និងអនុញ្ញាតឲ្យពួកគេ ចេញក្រៅបន្ទប់ តែនៅពេលទទួលទានអាហារប៉ុណ្ណោះ ដើម្បីបង្ការពួកគេពីការរត់ ចេញពីមណ្ឌល។[148] បន្ថែមពីលើបញ្ហាដែលបានលើកឡើង ស្ដីពីការអនុវត្តន៍ ដែល ដូចគ្នាទៅនឹងការដកហូតសេរីភាពដោយខុសច្បាប់នោះ គឺថា ការបញ្ជូននីតិជន ប្រកបរបរផ្លូវភេទ ទៅឲ្យស្នាក់នៅក្នុងមណ្ឌល សំរាប់កុមាររងគ្រោះដែលគ្រប់គ្រងដោយ អង្គការមិនមែនរដ្ឋាភិបាល*

---

[147] ដូចគ្នា។

148អង្គការឃ្លាំមើលសិទ្ធិមនុស្សសម្ភាសន៍ជាមួយ អានី និង ដារ៉ា រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែកក្កដា ២០០៧។ សូមមើលផងដែរ សេចក្តីថ្លែងការណ៍សារព័ត៌មានរបស់អង្គការលីកាដូ "ដាក់ទណ្ឌកម្មអ្នកក្រ៖ ការចាប់ខ្លួន ច្រើនថែមទៀតចំពោះអ្នករស់នៅតាមដងវិថី" ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០០៩។ គេហទំព័រ http://www.licadho-cambodia.org/pressrelease.php?perm=212&pagenb=0&filter=2009, (បានចូលមើលគេហទំព័រនេះ ថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០១០)។

*វានឹងបង្ហាញនូវទំនាស់ជាមិនខាន ទោះបីជា ក្នុងករណីណា ក៏ដោយ ពីព្រោះក្រុមទាំងពីរនេះមានសេចក្តីត្រូវការផ្សេងពីគ្នា ចំពោះ ប្រភេទខុសៗគ្នានៃ សេវាគាំទ្រ ។*

# V. ច្បាប់អន្តរជាតិ

*ប្រទេសកម្ពុជា គឺជាភាគីមួយនៃសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិសំខាន់ៗ មានជាអាទិ៍ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ* (ICCPR)[149] *កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌* (ICESCR)[150] *អនុសញ្ញាប្រឆាំងការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប (អនុសញ្ញាប្រឆាំងទារុណកម្ម)*[151] *អនុសញ្ញាស្តីពី សិទ្ធិកុមារ* (CRC) *និងអនុសញ្ញាស្តីពីការ បំបាត់ រាល់ទម្រង់នៃការរើសអើងប្រឆាំង នឹងស្ត្រីភេទ*(CEDAW)*ៗ*[152]

*ដូចនេះ ប្រទេសកម្ពុជាមានកាតព្វកិច្ចក្រោមច្បាប់អន្តរជាតិ ក្នុងការការពារសិទ្ធិរបស់អ្នកប្រកបរបរផ្លូវភេទ និងទប់ស្កាត់ ការរំលោភបំពានទៅលើពួកគេ រួមមាន ការចាត់វិធានការលប់បំបាត់អំពើជួញដូរមនុស្ស និងចាត់វិធានការសមស្របនានា ដើម្បីទប់ស្កាត់ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារៗ អ្វីដែលជាការពាក់ព័ន្ធច្រើនបំផុតនឹងអ្នកប្រកបរបរផ្លូវភេទ នោះគឺ សិទ្ធិមិនទទួលរងការចាប់ខ្លួន ឬឃុំខ្លួនដោយ រំលោភបំពាន និងសិទ្ធិមិនទទួលរងនូវការធ្វើទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ដែលឃោរឃៅ អមនុស្សធម៌ និងបន្ទាបបន្ថោក ព្រមទាំងសិទ្ធិទទួលបាននីតិវិធី ត្រឹមត្រូវ និងសិទ្ធិខាងសុខភាពៗ*

---

149 កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) ត្រូវបានអនុម័តនៅថ្ងៃទី១៦ខែធ្នូ ឆ្នាំ១៩៦៦ តាមរយៈសេចក្តីសម្រេចចិត្តរបស់មហាសន្និបាតលេខ 2200A (XXI), 21 U.N. GAOR Supp. (No. 16) at 52, U.N. Doc. A/6316 (1966), 999 U.N.T.S. 171, ចូលជាធរមាននៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧៦។

150 កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ (ICESCR) ត្រូវបានអនុម័តនៅថ្ងៃទី១៦ខែធ្នូ ឆ្នាំ១៩៦៦ តាមសេចក្តីសម្រេចចិត្តរបស់មហាសន្និបាតលេខ 2200A (XXI), 21 U.N. GAOR Supp. (No. 16) at 49, U.N. Doc. A/6316 (1966), 993 U.N.T.S. 3, ចូលជាធរមាននៅថ្ងៃទី៣ ខែមករា ឆ្នាំ១៩៧៦។

151 អនុសញ្ញាប្រឆាំងការធ្វើទារុណ្ណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯ ទៀតដែលឃោរឃៅ អមនុស្សធម៌ ឬ បន្ថោកបន្ទាប (អនុសញ្ញាប្រឆាំងការធ្វើទារុណកម្ម)  ត្រូវបានអនុម័តនៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៨៤ តាមសេចក្តីសម្រេចចិត្តរបស់មហាសន្និបាតលេខ 39/46, ឧបសម្ព័ន្ធ 39 U.N. GAOR Supp. (No. 51) at 197, U.N. Doc. A/39/51 (1984), ចូលជាធរមាននៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៨៧។

152 អនុសញ្ញាស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ (CEDAW), ត្រូវបានអនុម័តនៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៧៩ តាមសេចក្តីសម្រេចចិត្តរបស់មហាសន្និបាតលេខ 34/180, ចូលជាធរមាននៅថ្ងៃទី៣ ខែកញ្ញា ឆ្នាំ១៩៨១។

*មាត្រា ៩ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ជានាថា ៖*

*"ជនគ្រប់រូបមានសិទ្ធិមានសេរីភាព និងសន្តិសុខផ្ទាល់ខ្លួន។ គ្មានជនណាម្នាក់ត្រូវចាប់ខ្លួន ឬឃុំខ្លួនតាមអំពើចិត្តបានឡើយ។ គ្មានជនណាម្នាក់ត្រូវ ដកហូតសេរីភាពបាន ឡើយ លើកលែងតែមានហេតុផល និងស្របតាមនីតិវិធី ដែលមានចែងនៅក្នុង ច្បាប់។"*

*នៅពេលមានការចាប់ខ្លួន ជនដែលត្រូវបានចាប់ខ្លួន "ត្រូវមានសិទ្ធិឲ្យគេប្រាប់ឲ្យដឹង នៅពេលចាប់ខ្លួន អំពីមូលហេតុនៃការចាប់ខ្លួន និងត្រូវប្រាប់ឲ្យដឹងភ្លាមអំពី ការចោទ ប្រកាន់។"*

*ជនណាក៏ដោយដែលត្រូវបានឃុំខ្លួន ដោយមូលហេតុដែលមិនស្របតាមច្បាប់ គឺជាការឃុំខ្លួនតាមទំនើងចិត្ត និងហេតុនេះវាជាការខុសច្បាប់។ ការឃុំឃាំង អាចមានតម្លៃស្មើគ្នានឹងការឃុំឃាំងតាមទំនើងចិត្ត ទោះបីជាមានការអនុញ្ញាតដោយច្បាប់ក៏ដោយ បើការឃុំឃាំងនោះមាន "ធាតុផ្សំ នៃបទល្មើសមិនគ្រប់គ្រាន់ អយុត្តិធម៌ ខ្វះខាតភាព ជឿជាក់បាន និងខ្វះនីតិវិធីត្រឹមត្រូវ។"[153] គណៈកម្មាការសិទ្ធិមនុស្សរបស់អង្គការសហ ប្រជាជាតិបានសម្រេចថា ការឃុំឃាំងដែលច្បាប់អនុញ្ញាត គឺត្រូវតែ សមហេតុផល ចាំបាច់ និងសមាមាត្រ ដោយគិតពិចារណាទៅដល់ ស្ថានភាពជាក់លាក់នៃករណី ផង។[154]*

*ក្នុងការសិក្សាមួយអំពីបទដ្ឋានច្បាប់អន្តរជាតិ ទាក់ទងនឹងការឃុំខ្លួនជនរងគ្រោះនៃអំពើជួញដូរ ហ្គាឡាហឺ និងភាសាន់ បានផ្តល់នូវសេចក្តីណែនាំមួយចំនួន លើស្ថានភាពជាក់លាក់ ដែលបង្ហាញថាការឃុំខ្លួនក្នុងមណ្ឌល ជាអំពើឃុំខ្លួនដោយ បំពាន និងខុសច្បាប់។ នេះបើក្នុង ករណីដែល "ច្បាប់ក្នុងប្រទេសមិនមានចែងអំពី ការឃុំឃាំងទេ ឬប្រសិនបើការឃុំឃាំងត្រូវបានកំណត់ឡើងដោយ រំលោភនឹងច្បាប់*

---

153 សូមមើល, ទំនាក់ទំនងលេខ 458/1991, A. W. Mukong v. Cameroon (មតិយោបល់នេះត្រូវបានអនុម័តនៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ១៩៩៤) ក្នុង U.N. doc. GAOR, A/49/40 (vol. II), ទំព័រ 181, កថាខ័ណ្ឌ 9.8.។

154 វាន អាលហ្វេន វី។ ឌឺ នីឌឺលែន, ទំនាក់ទំនងលេខ305/1988 អនុម័តនៅថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៩០ U.N. GAOR, Hum. Rts. Comm., 39th Sess., ¶ 5.8, U.N. Doc. CCPR/C/39/D/305/1988 (1990); A v. អូស្ត្រាលី, ទំនាក់ទំនងលេខ560/1993, អនុម័តនៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៧ U.N. GAOR, Hum. Rts. Comm., 59th Sess.,¶ 9.2, U.N. Doc. CCPR/C/59/D/560/1993 (1997).

ជាការឃុំឃាំងដែលធ្វើឡើង ឬកំណត់ឡើងក្នុងលក្ខណៈរើសអើង ជាការឃុំឃាំងដែលធ្វើឡើងសំរាប់ រយៈពេលដែលមានការពន្យាពេល មិនជាក់លាក់ ឬមិនមានកាលកំណត់ ជាការឃុំឃាំងមិនមានមូលហេតុត្រឹមត្រូវ មិនអាចព្យាករណ៍ជាមុនបាន ឬមិនសមាមាត្រ ឬជាការឃុំឃាំងដែលមិនស្ថិតក្រោម ការត្រួតពិនិត្យតាមផ្នែក រដ្ឋបាល ឬផ្នែកតុលាការ ដើម្បីអាចបញ្ជាក់បានពីភាពស្របច្បាប់នៃការឃុំឃាំង និងភាពចាំបាច់នៃការបន្តឃុំក្រោមស្ថានភាពនោះ ជាមួយនឹងលទ្ធភាពនៃការ ដោះលែង នៅពេលដែលមិនមានមូលដ្ឋានឲ្យបន្តការឃុំឃាំង។"[155]

ច្បាប់អន្តរជាតិតម្រូវឲ្យរដ្ឋធ្វើឲ្យប្រាកដថា ការជានាតាមនីតិវិធីចាំបាច់ត្រូវតែមាន ដើម្បីកំណត់ និងឆ្លើយតបចំពោះស្ថានការណ៍នៃការដកហូតសេរីភាពដោយខុសច្បាប់ ឬតាមទំនើងចិត្ត។ អ្នកជាប់ឃុំឃាំងទាំងឡាយ ត្រូវមានសិទ្ធិតវ៉ាចំពោះការឃុំខ្លួនរបស់ ពួកគេ នៅក្នុងតុលាការ។[156]

នៅគ្រប់ស្ថានការណ៍ទាំងអស់ ដែលប្រជាពលរដ្ឋ ត្រូវបានគេដកហូតសេរីភាព របស់ខ្លួន កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) ចែងថា អ្នកទាំងនោះនៅតែទទួលបានការប្រព្រឹត្តមកលើខ្លួន "តាមលក្ខណៈ មនុស្សធម៌ និងការគោរពចំពោះសេចក្តីថ្លៃថ្នូរ ពីកំណើតរបស់មនុស្ស។"[157] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ក៏បានហាមឃាត់អំពើ ទារុណកម្ម ការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌

155 ហ្គាឡាហ្វឺ អេ និងភាសាន់ អ៊ី "តម្លៃខ្ពស់នៃសេរីភាព៖ ការវិភាគខាងផ្លូវច្បាប់ និងគោលនយោបាយ ស្តីពីជម្រកឃុំឃាំងសម្រាប់អ្នករងគ្រោះដោយអំពើជួញដូរមនុស្ស" របាយការណ៍សិទ្ធិមនុស្សប្រចាំត្រីមាស ខែកុម្ភៈ ឆ្នាំ២០១០ ទំព័រ ៩៥។
156 មាត្រា៩ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) ចែងថា "ជនណាដែលត្រូវដកហូតសេរីភាព ដោយការឃាត់ខ្លួន ឬឃុំខ្លួន ត្រូវតែមានសិទ្ធិដាក់ពាក្យបណ្តឹង ដើម្បីឲ្យតុលាការអាចសម្រេច ដោយមិនពន្យាពេលអំពីនីត្យានុកូលភាពនៃការឃុំខ្លួន និងបង្គាប់ឲ្យនៅក្រៅឃុំ បើការឃុំខ្លួននោះមិនស្របច្បាប់។" បន្ថែមលើសនេះទៀត "ជនណាដែលបានរងគ្រោះដោយសារការឃាត់ខ្លួន ឬឃុំខ្លួនខុសច្បាប់ មានសិទ្ធិទាមទារសំណង។"
157 កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ១០

*ឬបែបបន្ទាបបន្ថោក។[158] អំពើរំលោភសេពសន្ថវៈ និងការបៀតបៀនផ្លូវភេទ ក្នុងទីកន្លែងឃុំឃាំង ត្រូវបានពិចារណាថាជាអំពើទារុណកម្ម។[159]*

*ក្រោមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ រដ្ឋជាភាគី ត្រូវផ្តល់ "ការថែទាំផ្នែកពេទ្យគ្រប់គ្រាន់ក្នុងអំឡុងពេលនៃការឃុំខ្លួន។"[160] បទវិន័យជាបទដ្ឋានអប្បរមាស្តីពីការគ្រប់គ្រងអ្នកទោស បញ្ជាក់រឹតតែច្បាស់ថា អ្នកជាប់ឃុំមានសិទ្ធិជួបគ្រូពេទ្យដើម្បីពិនិត្យសុខភាពរាងកាយ និងសុខភាព ផ្លូវចិត្ត។[161] ការណ៍នេះ រាប់បញ្ចូលទាំងសិទ្ធិទទួលបានឱសថចាំបាច់សម្រាប់រស់រាន មានជីវិត ដូចជាឱសថពន្យាជីវិតចំពោះមេរោគអេដស៍។*

*ភាពចាំបាច់ចំពោះការឃុំខ្លួនកុមារ ដាច់ដោយឡែកពី នីតិជន មានការទទួលស្គាល់ នៅក្នុង អនុសញ្ញាស្តីពីសិទ្ធិកុមារ ចំណែកឯស្ថានភាពជាក់លាក់របស់កុមារ មានចែង នៅក្នុងវិធានអង្គការសហប្រជាជាតិចំពោះការការពារកុមារដែល ត្រូវបានដកហូត សេរីភាព។[162]*

158 កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ៧

159 អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពីទារុណ្ណកម្ម បានថ្លែងថា "អំពើរំលោភសេពសន្ថវៈ និងទម្រង់ដទៃទៀតនៃអំពើបៀតបៀនកេរ្តិ៍ខ្មាស ក្នុងទីកន្លែងឃុំឃាំង គឺជាអំពើរំលោភដ៏គួរឲ្យស្អប់ខ្ពើមបំផុត លើសេចក្តីថ្លៃថ្នូរពីកំណើត និងសិទ្ធិបូរណភាពរាង្គកាយរបស់មនុស្សគ្រប់រូប និងត្រូវចាត់ចូលជាអំពើនៃការធ្វើទារុណកម្ម។" អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពីទារុណ្ណកម្ម សេចក្តីសង្ខេបនៃកិច្ចប្រជុំលើកទី២១ **U.N. ESCOR, Comm'n Hum. Rts, 48th Sess., ¶ 35, U.N. Doc. E/CN.4/1992/SR.21 (1992)**។ តុលាការអន្តរជាតិ និងស្ថាប័នដទៃទៀត បានកំណត់ថា អំពើរំលោភសេពសន្ថវៈ ស្ថិតក្រោមការហាមឃាត់របស់ច្បាប់អន្តរជាតិ ស្តីពីអំពើទារុណកម្ម ឬការប្រព្រឹត្តមកលើខ្លួន ដែលឃោរឃៅ អមនុស្សធម៌ ឬដែលបន្ទាបបន្ថោក។ សូមមើលនូវ ឧទាហរណ៍ Aydin v. Turkey, **Eur. Ct. of H.R.**, សាលក្រមចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ១៩៩៧ កថាខ័ណ្ឌ៦២-៨៨។ ព្រះរាជអាជ្ញា និងហ្វ៊ូរាន់ឌីចា **ICTY** ករណីលេខ **IT-95-17/1-T**, សាលក្រមចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៩៨ កថាខ័ណ្ឌ ១៦៣-៨៦។

160 ពិនតូ វី ទ្រីនិដាត និងតូបាហ្គោ (ទំនាក់ទំនងលេខ **232/1987**) របាយការណ៍របស់គណៈកម្មាធិការសិទ្ធិមនុស្ស **vol. 2, U.N. Doc A/45/40**, ទំព័រ ៦៩ ។

161 បទដ្ឋានជាអប្បបរមារបស់អង្គការសហប្រជាជាតិសម្រាប់គ្រប់គ្រងអ្នកទោស (បទដ្ឋានជាអប្បបរមា) ត្រូវបានអនុម័តដោយសមាជសហប្រជាជាតិលើកទីមួយ ស្តីពីការទប់ស្កាត់បទល្មើស និងការប្រព្រឹត្តលើជនល្មើស ដែលប្រារព្ធធ្វើនៅទីក្រុងហ្សឺណែវ ក្នុងឆ្នាំ១៩៥៥ និងត្រូវបានយល់ព្រមដោយក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម តាមសេចក្តីសម្រេចចិត្តលេខ **663 C (XXIV)** ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៥៧ និងលេខ **2076 (LXII)** ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ១៩៧៧ កថាខណ្ឌ២៦ ។

162 អនុសញ្ញាស្តីពីសិទ្ធិកុមារ  មាត្រា៣៧

*សកម្មភាពរបស់នគរបាល និងមន្ត្រីរដ្ឋាភិបាលដទៃទៀត រំលោភជាដដែលៗ លើសិទ្ធិជាមូលដ្ឋានទាំងនេះ ជាសិទ្ធិដែលប្រទេសកម្ពុជាជាប់ កាតព្វកិច្ចខាងផ្លូវច្បាប់ក្នុងការអនុវត្ត តាមៗ ឧទាហរណ៍ ការចាប់ខ្លួនអ្នកប្រកបរបរផ្លូវភេទនីតិជនពីផ្ទះបន ឬតាមដងវិថី ដោយគ្រាន់តែផ្ទេរពួកគេទៅកាន់ជម្រកស្នាក់នៅ ដែលជាទីកន្លែងដែល ពួកគេមិនអាចចាកចេញដោយសេរី ហើយដែលការឃុំពួកគេនៅមណ្ឌលនេះ គ្មានមូលដ្ឋានស្របច្បាប់អ្វីឡើយ វាគឺជាការរំលោភលើសិទ្ធិមានសេរីភាព និងសន្តិសុខ ។*[163]

*សន្ធិសញ្ញាអន្តរជាតិស្តីពីទាសភាព ការអនុវត្តន៍បែបទាសភាព និងការជួញដូរមនុស្សក៏បានអំពាវនាវផងដែរដល់ប្រទេសនានា ឲ្យកំណត់និយមន័យលើអំពើជាក់លាក់ ដែលពាក់ព័ន្ធនឹងការរំលោភផ្លូវភេទដោយបង្ខំថា ជាបទឧក្រិដ្ឋ និងសុំឲ្យចាត់វិធានការ សមស្របដើម្បីដោះស្រាយស្ថានភាពទាំងនេះ រួមទាំងការការពារដល់សិទ្ធិរបស់ជនរងគ្រោះនៃបទឧក្រិដ្ឋទាំងនេះ។*[164] *ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នលើ ពិធីសារ ប៉ាឡឺម៉ូ ស្តីពី ការទប់ស្កាត់ ការបង្ក្រាប និងការផ្តន្ទាទោសការជួញដូរមនុស្ស ជា ពិសេសស្ត្រី និងកុមារ*[165] *និងអនុសញ្ញាបន្ថែមស្តីពីការលុបបំបាត់ចោលទាសភាព ជំនួញទាសករ និងការបង្កើត និង អនុវត្តន៍បែបទាសភាព។*[166] *ច្បាប់អន្តរជាតិ មិនបានបញ្ញត្តិពី*

---

163 កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា១២(១) ចែងថា "ជនណាដែលរស់នៅត្រឹមត្រូវតាមលក្ខណៈច្បាប់ ក្នុងប្រទេសណាមួយ មានសិទ្ធិធ្វើដំណើរ និងជ្រើសរើសនិវេសនដ្ឋានរបស់ខ្លួនដោយសេរី។"

164 ឧទាហរណ៍ ពិធីសារស្តីពីការជួញដូរ, អនុសញ្ញាស្តីពីការលុបបំបាត់ចោលទាសភាព, អនុសញ្ញាស្តីពីការលុបបំបាត់ចោលការអនុវត្តដូចទាសភាព។

165 ពិធីសារស្តីពីទប់ស្កាត់ ការបង្ក្រាប និងការផ្តន្ទាទោសការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ
បន្ថែមលើអនុសញ្ញាអង្គការសហប្រជាជាតិ ប្រឆាំងនឹង ឧក្រិដ្ឋកម្មឆ្លងដែន (ពិធីសារស្តីពីការជួញដូរ) ត្រូវបានអនុម័តនៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០០ តាមសេចក្តីសម្រេចរបស់ មហាសន្និបាតលេខ 55/25, ឧបសម្ព័ន្ធ II, 55U.N. GAOR Supp. (No.49) at 60, U.N. Doc. A/45/49 (Vol.I) (2001), ចូលជា ធរមានថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៣, ផ្តល់សច្ចាប័នដោយប្រទេសកម្ពុជានៅថ្ងៃទី២ ខែកក្កដា ឆ្នាំ២០០៧។

166 អនុសញ្ញាបន្ថែម អង្គការសហប្រជាជាតិស្តីពីការលុបបំបាត់ចោលទាសភាព, ជំនួញទាសករ និងការបង្កើត និងការអនុវត្តន៍ស្រដៀងនឹងទាសភាព ត្រូវបានអនុម័តនៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ១៩៥៦ លេខ 226 U.N.T.S. 3, ចូលជាធរមានថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៥៧, ត្រូវបានអនុម័តដោយសន្និបាតបុណ្ណទូតសហប្រជាជាតិអំពី អនុសញ្ញាបន្ថែមស្តីពីការលុបបំបាត់ចោលទាសភាព ជំនួញទាសករនិងការអនុវត្តន៍ស្រដៀងនឹងទាសភាព។ សន្និបាត ត្រូវបានប្រព្រឹត្តិឡើងតាមសេចក្តីសម្រេចចិត្តលេខ 608 (XXI) ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៥៦ នៃក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមរបស់អង្គការសហប្រជាជាតិ និងបានជួបប្រជុំគ្នានៅឯការិយាល័យសហភាពអឺរ៉ុប ប្រចាំអង្គការសហប្រជាជាតិក្នុងទីក្រុងហ្សឺណែវ ពីថ្ងៃទី១៣ ខែសីហា ដល់ថ្ងៃទី៤ ខែកញ្ញា ឆ្នាំ១៩៥៦។ សន្ធិសញ្ញាលេខរៀង ២២៦ ទំព័រ៣ ។

*ក្របខណ្ឌច្បាប់ជាក់លាក់ណាមួយ សម្រាប់ដាក់បញ្ញត្តិលើ ការងារផ្លូវភេទទេ។ ក៏ប៉ុន្តែ វាតែងតែអាស្រ័យទៅតាមប្រទេស ដែលអនុម័តយក ក្របខណ្ឌច្បាប់អ្វីក៏បាន អោយតែគោរពសិទ្ធិជាមូលដ្ឋានរបស់បុគ្គល ដែល ពាក់ព័ន្ធក្នុងការងារផ្លូវភេទ ទោះជាដោយការស្ម័គ្រចិត្ត ឬមិនស្ម័គ្រចិត្ត។*

*ច្បាប់អន្តរជាតិ មានភាពច្បាស់លាស់ណាស់លើការហាមឃាត់ការពាក់ព័ន្ធរបស់ កុមារ - ពោលគឺអ្នកទាំងឡាយដែលមានអាយុក្រោម ១៨ ឆ្នាំ - ក្នុងការងារផ្លូវភេទ។ ប្រទេសកម្ពុជា បានឲ្យសច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិកុមារ និងពីធីសារបន្ថែមស្តីពីការលក់កុមារ ពេស្យាចារកុមារ និងកាមសាស្ត្រកុមារ និងអនុសញ្ញាអង្គការ ការងារអន្តរជាតិលេខ១៨២ ស្តីពីទម្រង់អាក្រក់បំផុតនៃពលកម្មកុមារ។ ក្រោម សន្ធិសញ្ញាទាំងនេះ រដ្ឋជាភាគីមានកាតព្វកិច្ចការពារកុមារពីការកេងប្រវ័ញ្ចសេដ្ឋកិច្ច ការកេងប្រវ័ញ្ចផ្លូវភេទ និងការងារណាមួយដែល ប្រកបដោយគ្រោះថ្នាក់ ឬបំផ្លាញ ដល់សុខភាពកុមារ ឬអន្តរាយដល់ការលូតលាស់ខាងរាងកាយ សតិបញ្ញា ឬខាង សង្គមកុមារ។[167] "ការប្រើ, ការអូសទាញ ឬការផ្តល់" កុមារសម្រាប់ពេស្យាចារ ត្រូវ បានពិចារណាថាជា "ទម្រង់អាក្រក់បំផុតនៃពលកម្មកុមារ" ដែលរដ្ឋត្រូវដាក់ចេញ និងអនុវត្តកម្មវិធីសកម្មភាព ដើម្បីលប់បំបាត់ចោលទម្រង់ទាំងនេះជាអាទិភាព។[168] រដ្ឋក៏ត្រូវបានគេតម្រូវផងដែរឲ្យដាក់ ជាបទព្រហ្មទណ្ឌលើ "ការផ្តល់ ការបានមក ការអូសទាញ ឬការឲ្យកុមារ" សម្រាប់ប្រើប្រាស់ "ក្នុងសកម្មភាពផ្លូវភេទដើម្បីលាភការ ឬទម្រង់ដទៃណាមួយដែលស្រដៀងគ្នានេះ។"[169]*

---

167 អនុសញ្ញាស្តីពីសិទ្ធិកុមារ  មាត្រា ៣២(១) និងមាត្រា ៣៤។

168 អនុសញ្ញាILO លេខ ១៨២ ស្តីពីការហាមឃាត់ និងប្រព្រឹត្តិកម្មភ្លាមៗដើម្បីលប់ចោលទម្រង់អាក្រក់បំផុតនៃពលកម្មកុមារ (ទម្រង់អាក្រក់បំផុតនៃអនុសញ្ញាពលកម្មកុមារ) ត្រូវបានអនុម័តនៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៩, លេខ 38 I.L.M. 1207 (ចូលជាធរមានថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០០) ផ្តល់សច្ចាប័នដោយប្រទេសកម្ពុជានៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៦, មាត្រា៣(ខ) និង ៦(១)។

169 ពិធីសារ បន្ថែមលើអនុសញ្ញាស្តីពីសិទ្ធិកុមារ ពាក់ព័ន្ធនឹងការលក់កុមារ ពេស្យាកម្មកុមារ និងកាមសាស្ត្រកុមារ (Optional Protocol CRC SC), ត្រូវបានអនុម័តនៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០០ សេចក្តីសម្រេចចិត្តរបស់មហាសន្និបាតលេខ 54/263, ឧបសម្ព័ន្ធ II, 54 U.N. GAOR Supp. (No. 49) at 6, U.N. Doc. A/54/49, Vol.III (2000), ចូលជាធរមានថ្ងៃទី១៨ ខែមករា ឆ្នាំ២០០២, ផ្តល់សច្ចាប័ន ដោយប្រទេសកម្ពុជា ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០២ តាមមាត្រា២(ខ) និង៣(១)(ខ)។

ការដែរសំខាន់ នោះគឺ រដ្ឋត្រូវតែ "ចាត់វាល់វិធានការដែលអាចធ្វើបាន" ដើម្បីធានាថា កុមារទាំងអស់ដែលពាក់ព័ន្ធក្នុងសកម្មភាពផ្លូវភេទដើម្បីលាភការ ឬទម្រង់ដទៃណាមួយដែលស្រដៀងគ្នានេះ ទទួលបាន "ជំនួយសមស្របទាំងអស់ ... រួមមានការធ្វើសមាហរណកម្មពេញលេញនៃជនទាំងនោះទៅក្នុងសង្គមវិញ និងការស្តារសម្បទាខាង រាងកាយ និងខាងផ្លូវចិត្តនៃជនទាំងនោះ។"[170] ជំនួយបែបនោះគួរតែរាប់បញ្ចូលនូវ "ជំនួយដោយផ្ទាល់ដែលចាំបាច់និងសមស្រប សម្រាប់យកកុមារចេញ" ពីការងារបែបនោះ និងធានាឲ្យពួកគេ "ទទួលបានការអប់រំកំរិតមូលដ្ឋានដោយមិនបង់ថ្លៃ និងបើអាចធ្វើទៅបាន និងដែលសមស្រប ផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈ ដល់កុមារ ដែលបានយកចេញពីទម្រង់អាក្រក់បំផុតនៃពលកម្មកុមារ។"[171] ក្នុងប្រទេសកម្ពុជា ដោយមានភាពប្រងើយកន្តើយរបស់នគរបាល ចំពោះអាយុ ឬស្ថានភាព របស់អ្នកប្រកបរបរផ្លូវភេទដែលពួកគេឃុំឃាំង ដែលមានសរសេរចង្រ្កងនៅក្នុងរបាយការណ៍នេះ គឺកុមារដែលពាក់ព័ន្ធក្នុងការងារផ្លូវភេទ មិនទទួលបាននូវកិច្ចការពារពិសេស ដែលពួកគេមានសិទ្ធិនឹងទទួលបាននោះទេ។[172]

170 ដូចគ្នា មាត្រា៩(៣)

171 អនុសញ្ញាអង្គការពលកម្មអន្តរជាតិលេខ១៨២ មាត្រា៧(២)(ខ) និង(គ)

172 ដូចគ្នានេះដែរ ទាក់ទងនឹងនីតិជន និងអនីតិជន ក្រោមមាត្រា៦ នៃពិធីសារប៉ាឡឺម៉ូ រដ្ឋត្រូវខិតខំផ្តល់ឲ្យជនរងគ្រោះនៃការជួញដូរនូវនិវេសនដ្ឋាន ការថែទាំសុខភាព ជំនួយខាងផ្លូវច្បាប់ ការអប់រំ/ការហ្វឹកហ្វឺន និងឱកាសការងារ ការទទួលបានព័ត៌មានអំពីសិទ្ធិរបស់ខ្លួន និងមានអ្នកបកប្រែភាសាតាមការចាំបាច់។ គោលការណ៍ជាអនុសាសន៍ និងគោលការណ៍ណែនាំ របស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សស្តីពី សិទ្ធិមនុស្ស និងការជួញដូរមនុស្ស បានអំពាវនាវដល់រដ្ឋទាំងអស់ ក្នុងកិច្ចសហប្រតិបត្តិការ ជាមួយ អង្គការមិនមែនរដ្ឋាភិបាល ធានាឲ្យមាននូវ ជម្រកមានសុវត្ថិភាព និងគ្រប់គ្រាន់ ដែលមិនមែនជាកន្លែងឃុំឃាំង ឲ្យមានសម្រាប់ផ្តល់ដល់ ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) គោលការណ៍ជាអនុសាសន៍ និងគោលការណ៍ណែនាំស្តីពីសិទ្ធិមនុស្ស និងការជួញដូរមនុស្ស E/2002/68/Add.1, គោលការណ៍៦(១)។

## VI. និទណ្ឌភាព និងការបណ្តែតបណ្តោយឲ្យមានការរំលោភបំពាន

*ការខកខានស៊ើបអង្កេត និងការកាត់ទោសអំពើរំលោភបំពានទាំងនេះ បណ្តោយឲ្យនគរបាល និងមន្ត្រីរដ្ឋដទៃទៀត បៀតបៀនអ្នកប្រកបរបរផ្លូវភេទ ដោយគ្មានភ័យ ខ្លាចពីការដាក់ទណ្ឌកម្មឡើយ។ អង្គការក្រៅរដ្ឋាភិបាល អង្គការអន្តរជាតិ និង អង្គការដទៃទៀត បាននាំយកបញ្ហាខកខានទាំងនេះដាក់ ជូនរដ្ឋាភិបាលកម្ពុជា ម្តងហើយម្តងទៀត។ លទ្ធផលមួយដែលទទួលបាន គឺការចេញនូវគោលការណ៍ណែនាំ ច្បាប់ឆ្នាំ២០០៨ ក្នុងបំណងទប់ស្កាត់អំពើរំលោភបំពានធ្ងន់ធ្ងរ ។ ក៏ប៉ុន្តែភាពអសកម្មជាបន្តបន្ទាប់របស់រដ្ឋាភិបាល បានទុកឲ្យគោលការណ៍ណែនាំនេះមានភាពខ្សោយ ជាទូទៅជាមួយនឹងឥទ្ធិពលវិជ្ជមានបន្តិចបន្តួចរបស់វា។ ជំនួយបរទេសដែលមានគោលបំណងជួយប្រយុទ្ធប្រឆាំងអំពើរំលោភបំពាន មិនបានស្តែងចេញឲ្យឃើញនូវភាពរីកចំរើនទេ។*

### ការខកខានស៊ើបអង្កេត និងផ្តន្ទាទោសអំពើរំលោភបំពាន

*ក្រោមច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ អាជ្ញាធរកម្ពុជាមានកាតព្វកិច្ចទប់ស្កាត់ចំពោះអាកប្បកិរិយារំលោភបំពាន របស់នគរបាល និងមន្ត្រីដទៃទៀត និងត្រូវ ស៊ើបអង្កេតកាត់ទោស និងផ្តល់អោយមាននូវ ដំណោះស្រាយប្រសិទ្ធភាពនៅពេលកើតមានអំពើរំលោភបំពាន។*[173]

173 ប្រទេសកម្ពុជា បានទទួលស្គាល់ និងគោរពតាមគោលការណ៍នៃកាតិកាសញ្ញា និងអនុសញ្ញាអន្តរជាតិ ដូចមានចែងក្នុងមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញ។ មាត្រា៣៨នៃរដ្ឋធម្មនុញ្ញកម្ពុជា ហាមឃាត់ ការបង្ខិតបង្ខំ ការធ្វើបាបលើរូបរាងកាយ ឬប្រព្រឹត្តិកម្មណាមួយ ដែលបន្ថែមទម្ងន់ទណ្ឌកម្ម អនុវត្តន៍ចំពោះជនជាប់ឃុំឃាំង ឬជាប់ពន្ធនាគារ ។  មាត្រា៣៩ នៃរដ្ឋធម្មនុញ្ញ ធានាសិទ្ធិរបស់ប្រជាពលរដ្ឋខ្មែរ ក្នុងការប្តឹងបរិហារ ប្តឹងតវ៉ា ឬប្តឹងទារសំណងជួសជុលការខូចខាត ដែលបណ្តាលមកពីអំពើខុសច្បាប់របស់អង្គការរដ្ឋ របស់អង្គការសង្គម ឬរបស់បុគ្គលិកនៃអង្គការទាំងនោះ ដែលបានប្រព្រឹត្តក្នុងអំឡុងពេលបំពេញភារកិច្ច។

*អំពើរំលោភបំពាន ដែលបានចងក្រងក្នុងរបាយការណ៍នេះ មិនមែនជាអ្វីដែលថ្មីទេ។ ក្រុមសិទ្ធិមនុស្សក្នុងស្រុក និងក្រុមគាំទ្រអ្នកប្រកបរបរផ្លូវភេទ បានលើកឡើងអំពីបញ្ហាទាំងនេះពីមុនមក។ ប៉ុន្តែ និទណ្ឌភាពនៅតែមានជាបន្តចំពោះអំពើរំលោភ បំពានលើអ្នកប្រកបរបរផ្លូវភេទ អ្នកគ្មានផ្ទះសម្បែង កុមាររស់តាមចិញ្ចើមថ្នល់ និងអ្នកប្រើប្រាស់គ្រឿងញៀន។ របាយការណ៍ពីពេលមុនៗស្តីពីការរំលោភបំពាន នៅព្រៃស្ពឺ និងអំពីហិង្សារបស់នគរបាលទៅលើអ្នកប្រកបរបរផ្លូវភេទ មិនបាននាំទៅដល់ការស៊ើបអង្កេតដ៏គួរជឿទុកចិត្ត ចំពោះការចោទប្រកាន់ពីអំពើរំលោភទាំងអស់ នោះទេ។*

*ទោះបីជាមានការចាប់ខ្លួន ការឃុំខ្លួនដោយខុសច្បាប់ និងអំពើហិង្សាក៏ដោយ ក៏មិនមានអ្នកប្រកបរបរផ្លូវភេទណាម្នាក់ ដែលសម្ភាសន៍ដោយអង្គការឃ្លាំមើលសិទ្ធិមនុស្ស ធ្លាប់បានដាក់ពាក្យបណ្តឹងជាផ្លូវការទៅកាន់តុលាការ នគរបាល ឬអាជ្ញាធររដ្ឋាភិបាលដទៃទៀត អំពីការប្រព្រឹត្តទាំងនោះទេ ។ អ្នកប្រកបរបរផ្លូវភេទខ្លះ បានរាយការណ៍ពីករណីរបស់ពួកគេទៅឲ្យក្រុមគាំទ្រអ្នកប្រកបរបរផ្លូវភេទក្នុងស្រុក និងក្រុមសិទ្ធិមនុស្សបានដឹង និង ចងក្រងជាឯកសារនូវករណីទាំងនេះ ហើយដែលក្រុមទាំងនេះបានព្យាយាមចូលរួមគ្នា និងជាសាធារណៈថ្កោលទោស ចំពោះអំពើ ហិង្សា។ ប៉ុន្តែ អាជ្ញាធរមានសមត្ថកិច្ចវិញ តែងតែខកខានមិនស៊ើបអង្កេតករណី ទាំងនេះទេ។ អ្នកប្រកបរបរផ្លូវភេទជាច្រើននាក់ផ្សេងទៀតមានការភ័យខ្លាចអំពីការ សងសឹកតបវិញ ហើយអ្នកដទៃទៀតគ្មានជំនឿលើប្រព័ន្ធមួយដែលជិតដាមដោយអំពើពុករលួយ ការរើសអើង និងនិទណ្ឌភាព។ ដូចដែលអ្នកប្រកបរបរផ្លូវភេទម្នាក់គឺ ស្រីណា និយាយដូច្នេះថា ៖*

> ពួកគេ [នគរបាល] អាចបង្កើត រឿងឡើងដើម្បីចោទប្រកាន់ ពួកយើង ហើយយើងគ្មានអំណាចអ្វីដើម្បីតវ៉ាជាមួយពួកគេទេ។ យើងពិបាកខ្លាំងណាស់ និងឈឺចាប់ខ្លាំងណាស់ចំពោះការធ្វើបាបរបស់ប៉ូលីស។[174]

174 អង្គការឃ្លាំមើលសិទ្ធិមនុស្សសម្ភាសន៍ជាមួយ ស្រីណា នៅរាជធានីភ្នំពេញ ថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០០៩។

*នីកា ដែលត្រូវបានពួកសន្តិសុខការពារសួនច្បារវាយធ្វើបាបក្នុងខែតុលា ឆ្នាំ២០០៩ ចង់ដាក់ពាក្យបណ្តឹង ហើយនាងក៏មាននូវរូបថតនៃឧប្បត្តិហេតុនោះផងដែរ។ នាងបានសម្រេចចិត្តមិនដាក់ពាក្យបណ្តឹង បន្ទាប់ពីបានទទួល ដំបូន្មាន ថា នគរបាលនឹងតម្រូវឲ្យមាននូវ សេចក្តីថ្លែងអះអាងរបស់សាក្សីផ្សេងទៀត។ នាងបាននិយាយថា៖*

> វាពិបាកដើម្បីសុំឲ្យ អ្នកណាម្នាក់ ធ្វើជាសាក្សីឲ្យខ្ញុំ ពីព្រោះម្នាក់ៗសុទ្ធតែខ្លាច និងខ្វល់ខ្វាយពីសន្តិសុខផ្ទាល់ខ្លួនរបស់ពួកគេ។ មានអ្នករត់ម៉ូតូឌុបជាច្រើននាក់ និងអ្នកប្រកបរបរផ្លូវភេទយ៉ាងច្រើន បានមើលឃើញការវាយដំនោះ ប៉ុន្តែពួកគេខ្លាចមិនហ៊ានជួយខ្ញុំទេ។ ពួកគេទាំងអស់នោះមកនៅតាមសួនជារៀងរាល់ថ្ងៃ ដើម្បីរកស៊ីចិញ្ចឹមជីវិត ដូច្នេះពួកគេនឹងមិនធ្វើអ្វី ដែលប្រឆាំងនឹងអ្នកមានអំណាចនៅសួនច្បារទេ។ ពួកគេនឹងមិនមកធ្វើជាសាក្សីឲ្យខ្ញុំទេ។[175]

*អង្គការមិនមែនរដ្ឋាភិបាលដែលផ្តល់ជម្រកស្នាក់នៅដល់ជនរងគ្រោះ នៃអំពើហិង្សា ផ្លូវភេទ ក៏បានទទួលស្គាល់ផងដែរថា ការរំលោភរបស់នគរបាលគឺជាបញ្ហា ប៉ុន្តែពួកគេមានអំណាចតិចតួចណាស់ក្នុងការប្រយុទ្ធប្រឆាំងនឹងបញ្ហានេះ។[176] អង្គការមិនមែនរដ្ឋាភិបាលមួយមិនបញ្ចេញឈ្មោះ បានលើកឡើងថា ពួកគេមិនបានលើក ឡើងជាមួយនគរបាល អំពីបញ្ហា ដែលស្ត្រី និងកុមារីខ្លះ ត្រូវបានរំលោភសេពសន្ថវៈ ដោយនគរបាល ដែលបញ្ជូនមកកាន់ជម្រកស្នាក់នៅរបស់ពួកគេនោះទេ ដោយនិយាយដូច្នេះថា ៖*

> យើងត្រូវការធ្វើកិច្ចសហការជាមួយអាជ្ញាធរ ដើម្បីបន្តកិច្ចទំនាក់ទំនងការងារ និងដើម្បីឲ្យមានការចាប់ខ្លួន យ៉ាងហោចណាស់ក៏ អ្នកជួញដូរមនុស្សខ្លះៗដែរ។

---

175 អង្គការឃ្លាំមើលសិទ្ធិមនុស្សសម្ភាសន៍ជាមួយ នីកា នៅរាជធានីភ្នំពេញ ថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០០៩។

176 អង្គការឃ្លាំមើលសិទ្ធិមនុស្សសម្ភាសន៍ជាមួយតំណាងអង្គការស៊ីស៊ីភីស៊ីអា និងអាហ្វេស៊ីប នៅរាជធានីភ្នំពេញ ថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០០៩។

> នៅក្នុងគ្រប់ករណីទាំងអស់ នគរបាលបដិសេធថា ពួកគេបានជំរិតទារលុយ ឬ លួចយករបស់របរ នៅពេលដែលអ្នកណាៗក៏ដឹងថា នគរបាលពិតជាបានធ្វើ ដូច្នេះ។[177]

*មន្ត្រីនគរបាល ជាទម្លាប់គឺ តែងតែបដិសេធថា នគរបាលបានវាយដំ ឬធ្វើបាបអ្នកប្រកបរបរផ្លូវភេទ អំឡុងពេលចាប់ខ្លួន និងអំឡុងពេលបង្ក្រាប។ ឧទាហរណ៍ដូចជា ក្នុងខែធ្នូ ឆ្នាំ២០០៩ ស្នងការនគរបាលរាជធានីភ្នំពេញ លោក ទូច ណារ៉ុថ បានប្រាប់ទៅខាងសារព័ត៌មានថា នគរបាលមិនដែលបានវាយដំ ឬចាប់ខ្លួនអ្នកប្រកបរបរផ្លូវភេទទេ និងគាត់បានបន្ថអះអាងថា អំពើពេស្យាចារគឺវាផ្ទុយទៅនឹងវប្បធម៌របស់ខ្មែរ។*[178]

*ក្នុងខែមិថុនា ឆ្នាំ២០០៨ ឧត្តមសេនីយ៍ទោ ខៀវ សុភក្តិ អ្នកនាំពាក្យក្រសួងមហាផ្ទៃ បានច្រានចោលការអះអាងដែលថា នគរបាលបានប្រព្រឹត្តអំពើហិង្សាទៅលើអ្នកប្រកបរបរផ្លូវភេទ និងគាត់បានមានប្រសាសន៍ថា គ្មានអ្នកណាម្នាក់ទទួលរងនូវការធ្វើបាបក្នុងពេលមានសកម្មភាពបង្ក្រាប នោះទេ។ គាត់បានការពារចំពោះចំណាត់ការបង្ក្រាបលើអ្នកប្រកបរបរផ្លូវភេទ ដោយបានហៅការងាររខាងផ្លូវភេទថា ជាការមិនអាចទទួលយកបានទេក្នុងប្រទេសកម្ពុជា។*[179]

*នគរបាលបានបដិសេធជាផ្លូវការមិនទទួលយក និងមិនចុះបញ្ជីនូវបណ្តឹងអំពី អំពើរំលោភបំពានទេ ហើយក្រសួងមហាផ្ទៃ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា គ្រាន់តែស៊ើបអង្កេតបែបសើរៗប៉ុណ្ណោះ ដោយបានច្រានចោល អំពើរំលោភដែលបានកើតឡើង។*[180]

---

177 សម្ភាសន៍ជាមួយ [ ឈ្មោះដកចេញ ] នៅរាជធានីភ្នំពេញ ខែវិច្ឆកា ឆ្នាំ២០០៩។

178 គុច ណារ៉េន "អ្នកប្រកបរបរផ្លូវភេទចំនួន៣០០នាក់ អំពាវនាវឲ្យបញ្ឈប់ការរំលោភបំពានរបស់នគរបាល" កាសែត ឌឹ ឃែមបូឌា ដេលី ថ្ងៃពុធ ទី១៦ ខែធ្នូ ឆ្នាំ២០០៩។

179 សូផេង ឈាង, អេភី "អ្នកប្រកបរបរផ្លូវភេទកម្ពុជា ត៉វ៉ាចំពោះវិធានការបង្ក្រាបរបស់នគរបាល" ថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០០៨។ គេហទំព័រ http://www.usatoday.com/news/world/2008-06-04-622462536_x.htm, (បានចូលមើលនៅថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១០)។

180 លិខិតពីឯកឧត្តម ខៀវ សុភ័ក្តិ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ (លេខ ១២១៩ ស.ជ.ណ) ផ្ញើជូនលោកស្រី ពុង ឈីវកេក ប្រធានអង្គការលីកាដូ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨។ "សេចក្តីថ្លែងការណ៍របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា" ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០០៨។

*ក្នុងខែមិថុនា ឆ្នាំ២០០៨ អង្គការលីកាដូ បានលើកឡើងពីកង្វល់ចំពោះអំពើរំលោភបំពាននៅមណ្ឌលព្រៃស្ពឺ និងកោះគរ នៅក្នុងលិខិតមួយរបស់ខ្លួនផ្ញើជូន ឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី និងជាប្រធានក្រុមការងារជាន់ខ្ពស់ប្រឆាំងនឹងការជួញដូរ មនុស្ស និងជូន ជំទាវ យូ អយ រដ្ឋលេខាធិការក្រសួងកិច្ចការនារី និងបន្ទាប់ពីមានការប្រានចោលមានលំនាំដូចៗគ្នា តាមរយៈការឆ្លើយតបរបស់ក្រសួងមហាផ្ទៃ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ចំពោះកង្វល់អំពីការរំលោភបំពាននៅមជ្ឈមណ្ឌលសង្គមកិច្ច ដែលលើកឡើងដោយក្រុមសិទ្ធិមនុស្សក្នុងស្រុក បង្ហាញអោយ ឃើញថារដ្ឋាភិបាលគ្មានឆន្ទៈ ស៊ើបអង្កេតឲ្យបានហ្មត់ចត់លើ អំពើរំលោភទាំងនេះ ឡើយ។ ក្រសួងមហាផ្ទៃ បានឆ្លើយតបតាមរយៈលិខិតមួយ ចំពោះការចោទប្រកាន់ របស់អង្គការ លីកាដូ ដោយបដិសេធថា គ្មាននរណាម្នាក់ត្រូវបានគេឃុំឃាំងខុសច្បាប់ នៅឯព្រៃស្ពឺ៖ "មជ្ឈមណ្ឌលសង្គមកិច្ចព្រៃស្ពឺ ជាមជ្ឈមណ្ឌលបើកចំហរ គឺការស្នាក់នៅ ក្នុងមណ្ឌលឈរលើគោលការណ៍ស្ម័គ្រចិត្ត។ ជាពិសេស ជួយសង្គ្រោះដល់ អ្នកដែល រស់នៅតាមចិញ្ចើមថ្នល់ ដោយបានផ្តល់ម្ហូបអាហារ សេវាថែទាំសុខភាព ការបណ្តុះ បណ្តាលវិជ្ជាជីវៈ ដើម្បីមានលទ្ធភាពអាចរស់នៅក្នុងសហគមន៍វិញ។"[181] លិខិតនោះ បានថ្លែងផងដែរថា "មជ្ឈមណ្ឌលពុំមានសន្តិសុខ ឬឆ្មាំ ការពារមណ្ឌលទេ គឺមណ្ឌល យកអ្នកមកស្នាក់នៅរយៈពេលយូរ ជួយយាមការពារសន្តិសុខ។"[182] លិខិតនេះ មិនបង្ហាញអំពីដំណោះស្រាយចំពោះការចោទប្រកាន់ពីអំពើរំលោភទាំងអស់ដែលប្រព្រឹត្តដោយបុគ្គលិក និងពួកឆ្មាំមណ្ឌលទេ ដែលទោះបី ពួកគេគឺជាបុគ្គលិកមណ្ឌល ឬក៏ជាអ្នកធ្វើការនៅទីនោះដោយស្ម័គ្រចិត្តក៏ដោយ។*

---

181 លិខិតក្រសួងមហាផ្ទៃផ្ញើជូនលោកស្រីវេជ្ជបណ្ឌិត ពុង ឈីវកេក ប្រធានអង្គការសម្ព័ន្ធភាពខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស (លីកាដូ) លេខ ១២១៩ ស.ជ.ណ. ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨។

182 លិខិតក្រសួងមហាផ្ទៃផ្ញើជូនលោកស្រីវេជ្ជបណ្ឌិត ពុង ឈីវកេក ប្រធានអង្គការសម្ព័ន្ធភាពខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស (លីកាដូ) លេខ ១២១៩ ស.ជ.ណ. ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨។

*ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ បាន ស៊ើបអង្កេតផ្ទាល់ខ្លួនចំពោះអំពើរំលោភបំពានក្នុងមជ្ឈមណ្ឌលសង្គមកិច្ច ប៉ុន្តែលទ្ធផល នៃការស៊ើបអង្កេតនេះ (បានដាក់ជូនរដ្ឋាភិបាលនៅដើមឆ្នាំ២០០៩) មិនដែលបានបង្ហាញជាសាធារណៈទេ។ តាំងពីឆ្នាំ២០០៩មក ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ បានធ្វើទស្សនកិច្ចដោយមិនជូនដំណឹងមុន ជាទៀងទាត់ទៅកាន់មណ្ឌលព្រៃស្ពឺ ។ មន្ត្រីនៃការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សអង្គការសហប្រជាជាតិមួយរូប បានពន្យល់ថា វិធីសាស្ត្ររបស់ការិយាល័យនេះ គឺ ផ្តោតអាទិភាពនៃការតស៊ូមតិលើបញ្ហានេះដោយផ្ទាល់ និងដោយលាក់ការណ៍ ជាមួយរដ្ឋាភិបាល ហើយខណៈពេលដែលការអនុវត្តន៍នៅតែជាបញ្ហា សេចក្តីណែនាំខែសីហា ឆ្នាំ២០០៨ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដែលស្នើឲ្យ អាជ្ញាធរឈប់ឃុំខ្លួនមនុស្សក្នុងមជ្ឈមណ្ឌលសង្គមកិច្ច នោះថា គឺជាការបោះជំហានមួយក្នុងទិសដៅដ៏ត្រឹមត្រូវ។*[183]

## ការគាបសង្កត់របស់សហរដ្ឋអាមេរិកឲ្យដោះស្រាយបញ្ហាជួញដូរមនុស្ស ធ្វើឲ្យស្ថានការអាក្រក់ កាន់តែអាក្រក់ឡើង

*សហរដ្ឋអាមេរិក គឺជាប្រទេសម្ចាស់ជំនួយទ្វេភាគីដ៏ធំបំផុតមួយរបស់ប្រទេសកម្ពុជា និងជាម្ចាស់ជំនួយដ៏សំខាន់ ដែលគាំទ្រដល់កិច្ចប្រឹងប្រែងប្រយុទ្ធប្រឆាំងនឹង អំពើជួញដូរមនុស្សក្នុងប្រទេសកម្ពុជា។ នៅក្រោមរដ្ឋកាលគ្រប់គ្រងរបស់លោកប៊ូស រដ្ឋាភិបាលសហរដ្ឋអាមេរិក រក្សាជំហរថា ដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស បណ្តាប្រទេសទាំងឡាយត្រូវចាត់វិធានការប្រឆាំងនឹង ពេស្យាចារ។ សេចក្តីបង្គាប់ លេខ២២ របស់ប្រធានាធិបតី ស្តីពី សន្តិសុខជាតិ ចែងថា "គោលនយោបាយរបស់យើង គឺផ្អែកលើវិធីសាស្ត្រនៃការដោះស្រាយបញ្ហាដោយ លុបបំបាត់អំពើជួញដូរមនុស្ស ... ក្នុង*

183 ទំនាក់ទំនងតាមសារអេឡិចត្រូនិចទទួលបានពីការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សអង្គការសហប្រជាជាតិ នៅថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១០។

*ន័យនេះគឺ រដ្ឋាភិបាលសហរដ្ឋអាមេរិកប្រឆាំងនឹង ពេស្យាចារ និងសកម្មភាពពាក់ព័ន្ធ នានា រួមមានទាំងអំពើសញ្ចារកម្ម អំពើអូសទាញ និង/ឬការបើកផ្ទះបន ដែលវា រួមចំណែកក្នុងបាតុភូតនៃការជួញដូរមនុស្ស។"*[184]

*ចាប់តាំងពីឆ្នាំ២០០៣មក ច្បាប់សហរដ្ឋអាមេរិក ទាក់ទងនឹងបញ្ហាមេរោគអេដស៍/ជំងឺអេដស៍ និងការជួញដូរមនុស្ស តម្រូវឲ្យអ្នកទទួលថវិការ ជាអន្តរជាតិសំរាប់ការងារប្រឆាំងនឹងជំងឺអេដស៍ មាននូវគោលនយោបាយ "ប្រឆាំងនឹងពេស្យាចារ និងការជួញដូរផ្លូវភេទ" ដែលជាល័ក្ខខ័ណ្ឌមួយ ក្នុងការទទួលបានមូលនិធិ។*[185] *ច្បាប់នោះហាមប្រាមការប្រើប្រាស់មូលនិធិដើម្បី "លើកស្ទួយ គាំទ្រ ឬស្វែងរកការគាំទ្រឲ្យពេស្យាចារទៅជាស្របច្បាប់ ឬឲ្យមានការអនុវត្ត ពេស្យាចារ។"*[186] *បទប្បញ្ញត្តិនេះត្រូវបានរក្សាទុក ខណៈពេលដែល ច្បាប់ត្រូវបានផ្តល់ការអនុញ្ញាត ឡើងវិញក្នុងឆ្នាំ២០០៨ និងវាស្ថិតនៅជាធរមាន។ ក្នុងខែឧសភា ឆ្នាំ២០១០*

---

184 "ការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស" សេចក្តីបង្គាប់របស់ប្រធានាធិបតីស្តីពីសន្តិសុខជាតិ/**NSPD-22,** (សេតវិមាន វ៉ាស៊ីនតោន) ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០២។ គេហទំព័រ **http://www.combat-trafficking.army.mil/documents/policy/NSPD-22.pdf,** (បានចូលមើលគេហទំព័រនេះនៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១០)។

185 ច្បាប់នេះគឺជាច្បាប់ឆ្នាំ២០០៣ សម្រាប់ដឹកនាំ សហរដ្ឋអាមេរិកប្រឆាំងនឹងមេរោគអេដស៍/ជំងឺអេដស៍ ជំងឺរបេង និងជំងឺគ្រុនចាញ់ជាសាកល **P.L. 108-25, (S. 250, H.R. 1298),** ដែលវាត្រូវបានគេស្គាល់ជាទូទៅថាជា **PEPFAR**។ ច្បាប់ការពារជនរងគ្រោះពីអំពើជួញដូរមនុស្ស ក៏ត្រូវបានគេធ្វើពិសោធន៍កម្មផងដែរក្នុងឆ្នាំ២០០៣ ដើម្បីដាក់បញ្ចូលនូវ ការដាក់កំហិតលើការចំណាយ (ច្បាប់ប្រគល់អំណាចឲ្យការពារជនរងគ្រោះនៃអំពើជួញដូរមនុស្ស ឆ្នាំ២០០៣)។

186 ក្នុងបទបញ្ញត្តិ ស្តីពីជំនួយទ្វេភាគី, ច្បាប់នេះបញ្ចូលនូវការដាក់កំហិតលើចំណាយនៃមូលនិធិសមស្របតាមច្បាប់នេះ ៖ "ការដាក់កំហិត [LIMITATION]"(g)"(e) គឺ មិនត្រូវផ្តល់មូលនិធិក្រោមការអនុវត្តច្បាប់នេះ ឬក៏ធ្វើវិសោធនកម្មណាមួយដោយច្បាប់នេះបានទេ ក្នុងករណីដែលមូលនីធិត្រូវបានយកមកប្រើប្រាស់ដើម្បីលើកស្ទួយ ឬគាំទ្រដល់ការធ្វើឲ្យទៅជាស្របច្បាប់ ឬការអនុវត្តន៍ពេស្យាចារ ឬការជួញដូរផ្លូវភេទ។ គ្មានបទបញ្ញត្តិណាមួយក្នុងប្រយោគខាងដើម ត្រូវយកមកបកស្រាយ ដើម្បីរារាំងដល់ការផ្តល់ដល់បុគ្គលទាំងឡាយ នូវការថែទាំដោយឱសថ ការព្យាបាល ឬការបង្ការរោគដោយប្រើឱសថ និងជាពិសេស ការផ្តល់ទំនិញនិងឱសថ រួមទាំងកញ្ចប់សាកល្បង ស្រោមអនាម័យ និងអតិសុខុមឃាដ នៅពេលបង្ហាញថាមានប្រសិទ្ធិភាព។ កំហិត(ច) [LIMITATION (f)] គឺ មិនត្រូវយកមូលនិធិ ដែលអនុវត្តក្រោមច្បាប់នេះ ឬធ្វើវិសោធន៍កម្មណាមួយដោយច្បាប់នេះ អាចយកមកប្រើដើម្បីផ្តល់ជំនួយដល់ក្រុមណាមួយ ឬអង្គការណាមួយ ដែលមិនមានគោលនយោបាយច្បាស់លាស់ប្រឆាំងនឹងអំពើពេស្យាកម្ម និងការជួញដូរផ្លូវភេទ។"

រដ្ឋាភិបាលសហរដ្ឋអាមេរិក បានចេញបទបញ្ជាអនុវត្តន៍ ដែលធ្វើឱ្យមានការរឹតបន្តឹង ចំពោះបទប្បញ្ញត្តិទាំងឡាយ ដែលបានដាក់ឲ្យប្រើដោយរដ្ឋបាលលោកប៊ូស។[187]

ជំហរប្រឆាំងពេស្យាចារ គួបផ្សំនឹងឥទ្ធិពលរបស់របាយការណ៍ប្រចាំឆ្នាំស្តីពីការជួញដូរមនុស្ស របស់ក្រសួងការបរទេសសហរដ្ឋអាមេរិក ហាក់ដូចជាបង្ហាញពីការគាំទ្ររបស់សហរដ្ឋអាមេរិកចំពោះកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលកម្ពុជា ដើម្បីដាក់ជាបទព្រហ្មទណ្ឌលើការរកស៊ីផ្លូវភេទស្ម័គ្រចិត្ត ។ តាំងពីឆ្នាំ២០០១ មក របាយការណ៍ស្តីពីការជួញដូរមនុស្សបានផ្តល់ចំណាត់ថ្នាក់ដល់បណ្តាប្រទេសនានា ទៅតាមកិច្ចប្រឹងប្រែងរបស់ពួកគេ ដើម្បីដោះស្រាយបញ្ហាជួញដូរមនុស្ស។ ប្រសិនបើប្រទេសណាមួយត្រូវដាក់ឲ្យនៅចំណាត់ថ្នាក់ទី៣ (ចំណាត់ថ្នាក់ទាបបំផុត) នោះជាលទ្ធផលនឹងនាំឲ្យមានការដកហូតជំនួយមិនមែនមនុស្សធម៌ និងជំនួយ មិនមែនពាណិជ្ជកម្ម។[188] ប្រទេសជាច្រើន រួមមានទាំងប្រទេសកម្ពុជាផង បានយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះ ការដាក់ចំណាត់ថ្នាក់ប្រឆាំងការជួញដូរមនុស្សប្រចាំឆ្នាំ ឥទ្ធិពលរបស់វាលើកេរ្តិ៍ឈ្មោះរបស់ប្រទេស និងការគំរាមដាក់ទណ្ឌកម្ម ដែលអាចមានចំពោះ ចំណាត់ថ្នាក់លំដាប់ទី៣។

---

187 45 CFR PART 89, គេហទំព័រ http://edocket.access.gpo.gov/2010/pdf/2010-8378.pdf, (បានចូលមើលនៅថ្ងៃទី៧ កក្កដា ឆ្នាំ២០១០)។ បទបញ្ជាតម្រូវថា លក្ខខ័ណ្ឌមួយក្នុងការទទួលបានថវិកាគឺ អ្នកទទួលត្រូវតែយល់ព្រមថា ពួកគេ "ប្រឆាំងនឹងការអនុវត្តនៃពេស្យាចារ និងការជួញដូរផ្លូវភេទ ពីព្រោះតែគ្រោះថ្នាក់ខាងរាងកាយ និងផ្លូវចិត្ត ដែលប្រឈមចំពោះ បុរស ស្ត្រី និងកុមារ។

188 ក្នុងរយៈពេលកន្លងមកនេះ របាយការណ៍ទាំងនេះមានការសរសេរបានប្រសើរជាងមុន ទាំងក្នុងមាតិកា និងបញ្ហាគ្របដណ្តប់កដោយរបាយការណ៍ ហើយឥឡូវនេះវាគ្របដណ្តប់ជាទូទៅលើ អំពើជួញដូរគ្រប់រូបភាពទាំងអស់។ ទោះជាយ៉ាងណាក៏ដោយ ក៏ការប្រើប្រាស់ចំណាត់ថ្នាក់ក្នុងរបាយការណ៍ស្តីពីការជួញដូរមនុស្ស TIP សម្រាប់ប្រទេសមួយចំនួន បានទទួលរងនូវការរិះគន់យ៉ាងច្រើន ចំពោះការជាប់ជំពាក់នឹងហេតុផលនយោបាយរបស់ខ្លួន ជាមួយបណ្តាប្រទេសដែលជាសត្រូវរបស់សហរដ្ឋអាមេរិក ដែលជាញឹកញាប់ត្រូវបានគេដាក់ឲ្យចំណាត់ថ្នាក់នៅលំដាប់ទី៣ ខណៈពេលដែលប្រទេសទាំងឡាយដែលមានទំនាក់ទំនងល្អជាមួយសហរដ្ឋអាមេរិក ទទួលបានចំណាត់ថ្នាក់នៅលំដាប់ទី១ ។ ចំណាត់ថ្នាក់ដែលមានទាំងអស់គឺ លំដាប់ទី១(ល្អបំផុត) លំដាប់ទី២ លំដាប់ទី២ក្នុងបញ្ជីក្រោមការឃ្លាំមើល និងលំដាប់ទី៣ (អាក្រក់បំផុត)។ សូមមើល Chuang, J. "សហរដ្ឋអាមេរិកជា តំណាងរបស់ពិភពលោក ៖ ប្រើប្រាស់ទណ្ឌកម្មជាឯកតោភាគី ដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស" ទនានុប្បវត្តិ មិឈិហ្គែនស្តីពីច្បាប់អន្តរជាតិ លេខ ២៧,៤៣៧ ទំព័រ៤៨៦-៤៨៧ ។

*ក្នុងឆ្នាំ២០០៨ របាយការណ៍ប្រចាំឆ្នាំស្តីពីការជួញដូរមនុស្ស បានដាក់ចំណាត់ថ្នាក់ឲ្យប្រទេសកម្ពុជាឡើងទៅលំដាប់ទី២ ចេញពី លំដាប់ទី២ក្នុងបញ្ជីក្រោមការឃ្លាំមើលចំពោះការទទួលស្គាល់ការអនុម័តច្បាប់ឆ្នាំ ២០០៨ របស់ប្រទេសកម្ពុជា។ អង្គការនានារួមទាំងអង្គការឃ្លាំមើលសិទ្ធិមនុស្សផង បានទាញចំណាប់អារម្មណ៍ របស់ក្រសួងការបរទេសសហរដ្ឋអាមេរិកចំពោះការពិតដែលថា ការផ្តល់ចំណាត់ថ្នាក់សំរាប់ការរីកចម្រើននេះ ធ្វើឡើងដោយទោះបីជា មានអំពើរំលោភបំពានដែល ប្រឈមដោយអ្នកប្រកបរបរផ្លូវភេទក៏ដោយ។ ក្នុងឆ្នាំ២០០៩ របាយការណ៍ប្រចាំឆ្នាំ ស្តីពីការជួញដូរមនុស្ស បានដាក់ចំណាត់ថ្នាក់អោយ ប្រទេសកម្ពុជាចុះមកនៅ លំដាប់ទី២ក្នុងបញ្ជីក្រោមការឃ្លាំមើល ដែលមួយផ្នែក ដោយសារតែផលប៉ះពាល់ដ៏អន្តរាយ នៃវិធានការបង្រ្កាបរបស់នគរបាល និងការផ្តោតការប្រតិបត្តិ ដ៏ច្របូលច្របល់របស់រដ្ឋាភិបាលលើបទប្បញ្ញត្តិពាក់ព័ន្ធនឹង ពេស្យាចារនៃច្បាប់ឆ្នាំ ២០០៨ ជាជាងលើ បទប្បញ្ញត្តិទាំងឡាយដែលពាក់ព័ន្ធនឹងអំពើជួញដូរ។*[189]

*តាមរយៈការគាំទ្ររបស់* USAID *រដ្ឋាភិបាលអាមេរិកបានយល់ព្រមផ្តល់ឲ្យកម្ពុជានូវទឹកប្រាក់ចំនួន ៧.៣លានដុល្លារ ដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស នៅរវាងខែសីហាឆ្នាំ២០០៦ និងខែកញ្ញា ឆ្នាំ២០១១។ យោងតាមអនុស្សរណៈនៃការ យោគយល់រវាង* USAID *និងរដ្ឋាភិបាលកម្ពុជា គោលបំណងនៃជំនួយគឺ ជួយដល់ ប្រទេសកម្ពុជាដើម្បីការពារជនរងគ្រោះនៃអំពើជួញដូរ បង្កើនការកាត់ទោស ជនជួញដូរមនុស្សសម្របសម្រួលដល់ការទប់ស្កាត់តាមក្រុមគោលដៅ និង សកម្មភាពលើកកម្ពស់ការយល់ដឹងនិងជួយធ្វើសមាហរណកម្មជនរងគ្រោះនៃ អំពើជួញដូរចូលទៅក្នុងសង្គមកម្ពុជាវិញ។*[190]

---

189ក្រសួងការបរទេស សហរដ្ឋអាមេរិក, *របាយការណ៍ជួញដូរមនុស្សសំរាប់ប្រទេសកម្ពុជាឆ្នាំ ២០០៩* ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩។ គេហទំព័រ **http://www.unhcr.org/refworld/docid/4a4214c82d.html,** (បានចូលមើល ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១០)។
190ការិយាល័យអគ្គអធិការកិច្ច, "សវនកម្មរបស់ **USAID** /គម្រោងប្រឆាំងការជួញដូរមនុស្សរបស់ប្រទេសកម្ពុជា, របាយការណ៍សវនកម្មលេខ **9-000-10-002-P,** ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០០៩, គេហទំព័រ http://www.usaid.gov/oig/public/fy10rpts/9-000-10-002-p.pdf, (បានចូលមើល ថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០១០) ទំព័រ ៤។

គួរកត់សម្គាល់ថា "ផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរ ការរត់ពន្ធ មនុស្ស ការធ្វើអាជីវកម្មលើពលកម្មមនុស្ស និងអាជីវកម្មផ្លូវភេទលើស្ត្រីនិងកុមារ" ខែកក្កដា ឆ្នាំ២០០៧ អនុម័តដោយក្រសួងមហាផ្ទៃ បានចែងនូវទិសដៅមួយ ក្នុងចំនោមទិសដៅទាំងបីថា "ដើម្បីអនុវត្តអនុស្សរណៈនៃការយោគយល់គ្នា ឆ្នាំ២០០៦ រវាងរដ្ឋាភិបាលកម្ពុជា និង USAID ស្តីពីការអនុវត្តកម្មវិធីប្រឆាំងនឹងការជួញដូរ មនុស្ស។"[191] ផែនការនោះអនុញ្ញាតឲ្យមានការបង្រ្កាបលើទីកន្លែងនានា ដែលមាន ការប្រកបរបររួមភេទ និងវាក៏ជាកត្តាទាក់ទងនឹងហេតុផលសំខាន់ សម្រាប់ការឆ្មក់ ចូលផ្ទះបន និងការបោសសម្អាតតាមដងវិថីនៅចុងឆ្នាំ២០០៧។[192]

ខណៈពេលដែលអនុស្សរណៈ មិនមាននិយាយ ទាក់ទងនឹងការដាក់ជាបទល្មើស ព្រហ្មទណ្ឌ ចំពោះការរក្សាផ្លូវភេទ ថាជាមធ្យោបាយ ដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរ មនុស្សក៏ដោយ ក៏គោលនយោបាយរបស់សហរដ្ឋអាមេរិក ស្តីពីការរក្សាផ្លូវភេទ ក្រោម រដ្ឋបាលលោកប៊ូស គឺវាច្បាស់លាស់រួចទៅហើយ។ ក្នុងការគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងទាំងនេះក្នុងប្រទេសកម្ពុជា សហរដ្ឋអាមេរិកមិនបានពិចារណាពី បរិបទនៃបញ្ហារបស់កងកម្លាំងនគរបាល ដែលមានភាពល្បីល្បាញជាយូរមកហើយ ទាក់ទងនឹងអំពើពុករលួយ និងការប្រព្រឹត្តរំលោភបំពានលើអ្នកប្រកបរបរផ្លូវភេទ ជាមួយនឹងនិទណ្ឌភាព ខណៈពេលដែលមានការជំរុញឲ្យអនុវត្តច្បាប់ឆ្នាំ២០០៨។[193]

---

191 ផែនការយុទ្ធនាការដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មមនុស្ស និងអាជីវកម្មផ្លូវភេទលើស្ត្រីនិងកុមារ" ក្រសួងមហាផ្ទៃ រាជរដ្ឋាភិបាលកម្ពុជា លេខ 012 ផ.ក. ចុះហត្ថលេខានៅរាជធានីភ្នំពេញ ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៧។

192សូមមើល សម្ព័ន្ធភាពកម្ពុជាដើម្បីប្រយុទ្ធនឹងមេរោគអេដស៍/ជំងឺអេដស៍ (CACHA) គេហទំព័រ http://www.actionaid.org/cambodia/index.aspx?PageID=3176, (បានចូលមើល ថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០១០)។ អង្គការលីកាដូ (Licadho) គេហទំព័រ http://www.licadho-cambodia.org/articles/20080702/79/index.html, (បានចូលមើល ថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០១០)។

193 ចេនឃិន, ខារ៉ូល, ស៊ីភីយូ (CPU) ឌៃបែលយូអិនយូ (WNU) និងសែនប៊ីរី ស៊ី "អំពើហិង្សា និងការប្រឈមចំពោះ មេរោគអេដស៍ ក្នុងចំណោមអ្នកប្រកបរបរផ្លូវភេទ ក្នុងរាជធានីភ្នំពេញ ប្រទេសកម្ពុជា" រៀបចំចងក្រងឡើងសំរាប់ USAID ខែមីនា ឆ្នាំ២០០៦។ គេហទំព័រ http://www.hivpolicy.org/Library/HPP001702.pdf, (ចូលមើលគេហទំព័រនេះ ថ្ងៃទី៧ កក្កដា ឆ្នាំ២០១០)។

ជំនួយបច្ចេកទេសរបស់ USAID  នៅពេលបច្ចុប្បន្ននេះដែលផ្តល់ឲ្យប្រទេសកម្ពុជា សំរាប់ការងារប្រឆាំងការជួញដូរ  ប៉ុនប៉ងដោះស្រាយចំពោះអំពើរំលោភបំពាន ដោយនគរបាល។ របាយការណ៍សវនកម្មរបស់ USAID កត់សម្គាល់ថា ថវិកាត្រូវបាន កំពុងប្រើប្រាស់ ៖

> "ដើម្បីបង្កើនសមត្ថភាពរបស់មន្ត្រីប្រតិបត្តិច្បាប់ ដើម្បីការពារសិទ្ធិមនុស្សរបស់ អ្នកដែលត្រូវបានគេជួញដូរ និងកេងប្រវ័ញ្ច ... គម្រោងនេះគឺជាឧបករណ៍ សម្រាប់បង្កើតកម្មវិធីហ្វឹកហ្វឺនដល់មន្ត្រីប្រតិបត្តិច្បាប់ លើច្បាប់ស្តីពីការបង្ក្រាប អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលបានអនុម័តដោយ រាជរដ្ឋាភិបាលកម្ពុជា កាលពីក្នុងខែកុម្ភៈ ឆ្នាំ២០០៨។  សេចក្តីពន្យល់ច្បាប់ ជាផ្លូវការ ដែលពន្យល់ពីច្បាប់ថ្មីត្រូវបានព្រាង ហើយ និងត្រូវចេញដាក់អោយ ប្រើក្នុងឆ្នាំ២០០៩។ ដើម្បីលើកកម្ពស់ឲ្យកាន់តែប្រសើរឡើង លើកិច្ចប្រឹងប្រែង កសាងសមត្ថភាពរបស់គម្រោង សៀវភៅហ្វឹកហ្វឺនមួយស្តីពី ប្រតិបត្តិការឆ្មក់ ចូល និងជួយសង្គ្រោះ ដោយមិនមានការរំលោភសិទ្ធិរបស់ជនរងគ្រោះ ត្រូវបាន បង្កើតឡើង និងអនុវត្តន៍បាន សម្រាប់ទាំងនគរបាល និងអ្នកផ្តល់សេវាខាង សង្គម។"[194]

*ប៉ុន្តែ ថ្វីបើមានកិច្ចប្រឹងប្រែងប្រកបដោយគោលបំណងល្អទាំងនេះលើការហ្វឹកហ្វឺនក៏ដោយ ក៏អំពើរំលោភបំពាននៅតែមានជាបន្ត។ យោងតាមអ្នកប្រកបរបរផ្លូវភេទ ដែលបានសម្ភាសន៍ដោយអង្គការឃ្លាំមើលសិទ្ធិមនុស្ស បាននិយាយថា សូម្បីតែ នគរបាលផ្នែកឯកទេសខាងការប្រឆាំងអំពើជួញដូរ ដែលបានទទួលការហ្វឹកហ្វឺន សិទ្ធិមនុស្ស ក៏ ជាប់ទាក់ទិននឹងការព្យាយាមឲ្យអ្នកប្រកបរបរផ្លូវភេទ សូកប៉ាន់ពួកគេ ដែរ។ សហគមន៍នៃប្រទេសម្ចាស់ជំនួយ បានខិតខំប្រឹងប្រែងអស់ពេលជាយូរ ដើម្បី ហ្វឹកហ្វឺនកងកម្លាំងនគរបាលកម្ពុជាស្តីពីសិទ្ធិមនុស្ស។[195] កំណែទម្រង់លើការងារ*

---

194 USAID "សវនកម្មរបស់ USAID/គម្រោងប្រឆាំងការជួញដូរមនុស្សរបស់ប្រទេសកម្ពុជា, របាយការណ៍សវនកម្មលេខ 9-000-10-002-P, ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០០៩, គេហទំព័រ http://www.usaid.gov/oig/public/fy10rpts/9-000-10-002-p.pdf, (បានចូលមើល ថ្ងៃទី១១ ខែមេសា ឆ្នាំ២០១០) ។

195 អាណត្តិការងាររបស់ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា តាំងពីឆ្នាំ១៩៩៣ គឺ ផ្តល់ការហ្វឹកហ្វឺនដល់ស្ថាប័ននានា ដែលទទួលខុសត្រូវចំពោះរដ្ឋបាល យុត្តិធម៌។ ការិយាល័យនេះបានបង្កើតនូវកម្មវិធីហ្វឹកហ្វឺនសិទ្ធិមនុស្ស និងបានធ្វើការហ្វឹកហ្វឺនក្នុងរវាងពី ឆ្នាំ១៩៩៥ ដល់ឆ្នាំ២០០២ ជាពេលដែលការទទួលខុសត្រូវ ត្រូវបានផ្ទេរទៅឲ្យក្រសួងការពារជាតិ

*គ្រប់គ្រងរបស់នគរបាល និងកំណែទម្រង់លើកម្លាំងនគរបាល គឺជាសមាសធាតុមួយនៃសមាសធាតុទាំងប្រាំពីរ ក្នុងអាណត្តិរបស់អ៊ុនតាក់នៅប្រទេសកម្ពុជា (១៩៩២-១៩៩៣)។[196] ប៉ុន្តែការពិតនៅត្រង់ថា លុះត្រាតែ និងរហូតទាល់តែ មានការ ផ្តន្ទាទោសមន្ត្រីនគរបាលចំពោះបទល្មើសរបស់ពួកគេ និង មានសារខ្លាំងៗថា គ្មានការអន់អោនចំពោះអំពើរំលោភបំពានលើអ្នកប្រកបរបរផ្លូវភេទ នោះ ប្រសិទ្ធភាពនៃការហ្វឹកហ្វឺនអំពីសិទ្ធិមនុស្ស នឹងនៅតែមានកម្រិត។*

---

ក្រសួងមហាផ្ទៃ និងអង្គការក្រៅរដ្ឋាភិបាល។ សូមមើល អគ្គេលខាធិការ "សេវាផ្តល់យោបល់ និងកិច្ចសហប្រតិបត្តិការបច្ចេកទេសក្នុងវិស័យសិទ្ធិមនុស្ស៖  តួនាទី និងលទ្ធផលសម្រេចបាន របស់ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ក្នុងការជួយរដ្ឋាភិបាល និងប្រជាពលរដ្ឋកម្ពុជា ក្នុងកិច្ចការ លើកស្ទួយ និងការពារសិទ្ធិមនុស្ស" **UN Doc E/CN.4/2003/113** ថ្ងៃទី៩ មករា ២០០៣។ ទោះជាយ៉ាងណាក៏ដោយ ក៏ការហ្វឹកហ្វឺន ទាំងនេះ មានភាពទូលំទូលាយ ហើយដែលត្រឹមតែ ពាក់កណ្តាលឆមាសទី២នៃឆ្នាំ២០០១ប៉ុណ្ណោះ ការិយាល័យនេះរាយការណ៍ថា គ្រូបង្គោល របស់ខ្លួនបានហ្វឹកហ្វឺនកងកម្លាំងនគរបាលបាន ២,១៥៥ នាក់ក្នុងខេត្តចំនួន១៤។ សូមមើល របាយការណ៍ប្រចាំឆ្នាំរបស់ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សសម្រាប់ឆ្នាំ២០០១ នៅគេហទំព័រ **http://cambodia.ohchr.org/WebDOCs/DocReports/3-SG-RA-reports/A_HRC_CMB27122001E.pdf,** (បានចូលមើលគេហទំព័រនេះ ថ្ងៃទី៧ កក្កដា ២០១០)។ គម្រោងដែលផ្តល់មូលនិធិដោយរដ្ឋាភិបាលសហរដ្ឋអាមេរិក រដ្ឋាភិបាលដែនីស និងអូស្ត្រាលី បានផ្តល់អោយមាននូវការហ្វឹកហ្វឺនដ៏ទូលំទូលាយអំពីសិទ្ធិមនុស្សដល់នគរបាលក្នុងប្រទេសកម្ពុជា។

**196** យោងតាមសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខលេខ **745 (1992)** គេហទំព័រ **http://daccess-dds-ny.un.org/doc/RESOLUTION/GEN/NR0/011/04/IMG/NR001104.pdf?OpenElement,** (បានចូលមើលគេហទំព័រនេះ ថ្ងៃទី៧ កក្កដា ឆ្នាំ២០១០)។ បេសកកម្មនេះមានរាប់ទាំងនគរបាលស៊ីវិលរបស់អង្គការសហប្រជាជាតិចំនួន ៣,៦០០ នាក់ មកធ្វើការហ្វឹកហ្វឺន និងផ្តល់ប្រឹក្សាដល់នគរបាលកម្ពុជា មានជាអាទិ៍ការងារគ្រប់គ្រងរបស់នគរបាលតាមបែបប្រជាធិបតេយ្យ សិទ្ធិមនុស្ស និងការទប់ស្កាត់បទល្មើស ។ នៅចុងអាណត្តិការងាររបស់ខ្លួន អ៊ុនតាក់ បានហ្វឹកហ្វឺនដល់នគរបាលចំនួន ៩,០០០ នាក់។ សូមមើលវិលស្តុនផាក (**Wilton Park**) "ប្រតិបត្តិការគ្រប់គ្រងរបស់នគរបាល ក្រោយជម្លោះជាអន្តរជាតិ ៖ ការលើកកម្ពស់កិច្ចសម្របសម្រួល និងភាពប្រសិទ្ធិភាព" របាយការណ៍កិច្ចប្រជុំ ថ្ងៃទី២៦-៣០ ខែមករា ឆ្នាំ២០០៤ គេហទំព័រ **http://www.wiltonpark.org.uk/documents/conferences/WPS04-3/pdfs/WPS04-3.pdf,** (បានចូលមើលគេហទំព័រនេះ ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១០)។

## VII. អនុសាសន៍

**ចំពោះរដ្ឋាភិបាលកម្ពុជា ៖**

- *បង្កើតគណៈកម្មាការពិសេសមួយ ដើម្បីដឹកនាំការស៊ើបអង្កេតហ្មត់ចត់ និង ឯករាជ្យ ទៅលើអំពើហិង្សា និងការជំរិតទារលុយទាំងអស់ ដែលប្រព្រឹត្តដោយ មន្ត្រីប្រតិបត្តិច្បាប់ ថ្នាំសន្តិសុខសួនច្បារ និងបុគ្គលិក ឬអ្នកស្ម័គ្រចិត្តក្នុងមណ្ឌល សង្គមកិច្ចរាជធានី។ គណៈកម្មាការ គួរតែមានសមាសភាពពីតំណាងរដ្ឋាភិបាល ដែលមានសមត្ថភាព និងមានការគោរព រួមទាំងតំណាងមកពីក្រសួងមហាផ្ទៃ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ទីភ្នាក់ងារអង្គការសហ ប្រជាជាតិ អង្គការមិនមែនរដ្ឋាភិបាល រួមទាំងក្រុមសិទ្ធិមនុស្ស និងក្រុមអ្នក ប្រកបរបរផ្លូវភេទ។ គណៈកម្មាការនេះ គួរតែបង្កើតឡើងភ្លាម មានអំណាចកោះ ហៅសាក្សី និងផលិតរបាយការណ៍សាធារណៈ។ គណៈកម្មាការគួរមានអំណាច ដាក់ចេញនូវអនុសាសន៍សម្រាប់ការស៊ើបអង្កេតខាងព្រហ្មទណ្ឌ ដើម្បីធ្វើឲ្យ ប្រាកដថាជនប្រព្រឹត្តល្មើសនឹងត្រូវបាននាំយកមកផ្តន្ទាទោសចំពោះបទល្មើស របស់ពួកគេ។*

**ចំពោះក្រសួងមហាផ្ទៃ ៖**

- *គោរពសិទ្ធិរបស់អ្នកប្រកបរបរផ្លូវភេទ ជាពិសេសសិទ្ធិបូរណភាពខាងរាងកាយ សេរីភាព និងសិទ្ធិមានសន្តិសុខ នីតិវិធីត្រឹមត្រូវ និងការមិនរើសអើង ហើយត្រូវការពារពួកគេឲ្យរួចផុតពីរាល់ទម្រង់ទាំងអស់នៃទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មដែលបន្ទាបបន្ថោក និងអមនុស្សធម៌ រួមទាំងរាល់ទម្រង់ទាំងអស់នៃហិង្សាផ្លូវភេទ។*

- *បញ្ឈប់ការចាប់ខ្លួន និងឃុំខ្លួន អ្នកប្រកបរបរផ្លូវភេទដោយបំពាន - រួមទាំងស្ត្រី កុមារ និងស្រីស្រស់ដែលប្រកបរបរផ្លូវភេទ - ជនរងគ្រោះនៃអំពើជួញដូរ និងអ្នកដទៃទៀត*

រួមទាំងអ្នកប្រើប្រាស់គ្រឿងញៀន អ្នកគ្មានផ្ទះសម្បែង អ្នកសុំទាន កុមាររស់តាមចិញ្ចើមថ្នល់ និងអ្នកជំងឺវិកលចរិត។

- ស៊ើបអង្កេត និងនាំមកផ្តន្ទាទោស ជនប្រព្រឹត្តល្មើស ដែលរំលោភលើ សិទ្ធិមនុស្សរបស់អ្នកប្រកបរបរផ្លូវភេទ រួមមានទាំងនគរបាល និងមន្ត្រី រដ្ឋាភិបាល។

- ទទួលស្គាល់ និងថ្កោលទោសជាសាធារណៈ ចំពោះការរំលោភរបស់ នគរបាល និងបុគ្គលិកមណ្ឌលសង្គមកិច្ច ទៅលើអ្នកប្រកបរបរផ្លូវភេទ ។

- ផ្សព្វផ្សាយយ៉ាងទូលំទូលាយភ្លាមៗ និងណែនាំមន្ត្រីប្រតិបត្តិច្បាប់ទាំងអស់ ជាពិសេស នគរបាលមូលដ្ឋាននៅកម្រិតឃុំ/សង្កាត់ ខណ្ឌ/ស្រុក រាជធានី/ខេត្ត និងមន្ត្រីមូលដ្ឋាននៅកម្រិតឃុំ/សង្កាត់ ខណ្ឌ/ស្រុក រាជធានី/ខេត្ត ឲ្យប្រកាន់ ខ្ជាប់នូវគោលការណ៍ណែនាំឆ្នាំ២០០៨ ស្តីពីការអនុវត្តច្បាប់ស្តីពីការបង្ក្រាប អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

- ដោយប្រឹក្សាជាមួយ ក្រុមសហគមន៍ ក្រុមអ្នកប្រកបរបរផ្លូវភេទ ក្រុមសិទ្ធិមនុស្ស ក្រុមប្រឆាំងអំពើជួញដូរមនុស្ស ក្រុមធ្វើការងារខាងវិស័យសុខភាព និងទីភ្នាក់ងារអង្គការសហប្រជាជាតិ ត្រូវ ពិនិត្យមើលឡើងវិញនូវច្បាប់ ឆ្នាំ២០០៨ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងផលប៉ះពាល់របស់ច្បាប់នេះលើអ្នកប្រកបរបរផ្លូវភេទ មុនពេលអនុវត្តបទប្បញ្ញត្តិនៃច្បាប់ ទាក់ទងនឹងមុខរបរផ្លូវភេទទាំងនោះ។

- ក្រើនរំឭកដល់បុគ្គលិកមិនមែនជានគរបាល មានដូចជា ឆ្មាំសន្តិសុខសួនច្បារ និងក្រុមសន្តិសុខខណ្ឌ ថាពួកគេមិនមានអំណាច ចាប់ខ្លួនទេ និងសូមផ្តល់ដំបូន្មានដល់ពួកគេថា ប្រសិនពួកគេដកហូតសេរីភាពអ្នកដទៃដោយ ខុសច្បាប់ នោះពួកគេត្រូវប្រឈមនឹងការនាំខ្លួនទៅកាត់ទោសតាមច្បាប់។

- បង្កើនចំនួនមន្ត្រីប្រតិបត្តិច្បាប់ភេទស្រី ដែលមានការហ្វឹកហ្វឺនក្នុងកិច្ចការដោះស្រាយស្ថានការណ៍ទាក់ទិននឹងហិង្សា ផ្អែកលើយ៉េនឌ័ និងជានាថា មន្ត្រីភេទស្រីត្រូវបានប្រគល់កិច្ចការអោយកាន់កាប់ករណីទាក់ទងនឹង ស្ត្រី និងស្រីស្រស់ប្រកបរបរផ្លូវភេទ។ ក្នុងកំរិតអប្បរមាក៏ដោយ ត្រូវបង្កើនចំនួនមន្ត្រីនគរបាលជាស្ត្រី តាមស្ថានីយ៍នគរបាល នៅទួលគោក ចំការមន និងដូនពេញជាតំបន់ដែលមានរបាយការណ៍ពីការរំលោភយ៉ាងច្រើន។ ហ្វឹកហ្វឺនដល់មន្ត្រី ទាំងនេះពីរបៀបនៃការសម្ភាសន៍ស្ត្រីប្រកបរបរផ្លូវភេទ ដើម្បីកំណត់បានថា តើពួកគេជាជនរងគ្រោះនៃអំពើជួញដូរ ឬនៃអំពើរំលោភលើរូបរាងកាយ និងត្រូវធ្វើស្របទៅតាមបទដ្ឋានសិទ្ធិមនុស្ស ក្នុងការដោះស្រាយបញ្ហាជាមួយ នីតិជន និងអនីតិជនក្នុងមុខរបរផ្លូវភេទ ។ ហ្វឹកហ្វឺនពួកគេផងដែរ លើសេចក្តី ពន្យល់ខាងផ្លូវភេទនិងអត្តសញ្ញាណខាងយ៉េនឌ័ និងការសម្តែងផ្នែកយ៉េនឌ័ រួមទាំងអត្តសញ្ញាណស្រីស្រស់។

- ណែនាំមន្ត្រីប្រតិបត្តិច្បាប់ថា ពួកគេអាចឃុំខ្លួនបានតែអ្នកប្រកបរបរផ្លូវភេទ ជានីតិជន តែក្នុងករណីដែលពួកគេបានប្រព្រឹត្តបទល្មើសជាក់ស្តែង ប្រឆាំង នឹងច្បាប់ និងដែលពួកគេមានបំណងចោទប្រកាន់ពួកគេភ្លាមៗនិងនាំពួកគេទៅផ្តន្ទាទោសចំពោះបទល្មើសនោះ។ ប្រសិនបើអ្នកប្រកបរបរផ្លូវភេទជានីតិជនត្រូវប្រគល់ទៅអង្គការមិនមែនរដ្ឋាភិបាល ការប្រគល់នេះ ត្រូវធ្វើឡើងដោយឈរលើគោលការណ៍ស្ម័គ្រចិត្តយ៉ាងពិតៗ និងត្រូវប្រគល់ទៅអង្គការ មិនមែនរដ្ឋាភិបាលដែលមានផ្តល់សេវា និងកន្លែងស្នាក់នៅសមស្រប។

- ណែនាំដល់មន្ត្រីប្រតិបត្តិច្បាប់ ឲ្យប្រគល់កុមារ និងជនរងគ្រោះនៃអំពើ ជួញដូរ ទៅអង្គការមិនមែនរដ្ឋាភិបាលដែលមានសេវាសមស្រប ដែលផ្តល់ការការពារដល់ពួកគេ ស្របតាមបទដ្ឋានអន្តរជាតិ។

- *ណែនាំដល់មន្ត្រីប្រតិបត្តិច្បាប់ថា កុមារក្នុងមុខរបរផ្លូវភេទ មិនត្រូវទទួលរង នូវការប្រព្រឹត្តមកលើខ្លួនគេដូចជាអ្នកទោសទេ និងមិនត្រូវឃុំឃាំងពួកគេ ដោយគ្រាន់តែពួកគេមានមុខរបរជាអ្នករកស៊ីផ្លូវភេទនោះដែរ។*

- *ទាំងក្នុងករណី នីតិជន ឬអនីតិជន អោយតែមានការចង្អុលបង្ហាញថាបុគ្គល នោះ អាចត្រូវបានរងនូវការជួញដូរ ត្រូវប្រគល់ពួកគេជាបន្ទាន់ទៅ អង្គការ មិនមែន រដ្ឋាភិបាល ដែលផ្តល់ជំនួយដល់ជនរងគ្រោះនៃអំពើជួញដូរ និងដែល សេវារបស់អង្គការនោះមានលក្ខណៈស្របតាមបទដ្ឋានអន្តរជាតិ។*

- *រៀបចំ និងប្រតិបត្តិគោលនយោបាយ សម្រាប់អង្គការមិនមែនរដ្ឋាភិបាល ដែលជួយអ្នកប្រកបរបរផ្លូវភេទ ដោយតម្រូវឲ្យសេវាទាំងអស់ រួមទាំងការ ដឹកជញ្ជូន និង ជម្រកស្នាក់នៅផង ផ្តល់ឲ្យដោយឈរលើគោលការណ៍ស្ម័គ្រចិត្ត និងការយល់ព្រម។ ចាត់វិធានការចំពោះ អង្គការទាំងឡាយណាដែលក្នុង ការអនុវត្តជាក់ស្តែង បានបង្ខិតបង្ខំ បុគ្គលនានាឲ្យស្នាក់នៅ ក្នុងមណ្ឌលផ្ទុយ នឹងឆន្ទៈរបស់ពួកគេ។*

**ចំពោះក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ៖**

- *បិទមជ្ឈមណ្ឌលព្រៃស្ពឺ និងកោះគរជាស្ថាពរ រួមទាំងមណ្ឌលដទៃទៀត របស់ ក្រសួងសង្គមកិច្ច ដែលបានឃុំឃាំងប្រជាពលរដ្ឋរំលោភលើ ច្បាប់ជាតិ និង អន្តរជាតិ។*

- *ព្យួរការងារបុគ្គលិក ដែលជាប់ចោទពីបទរំលោភដែលគួរជឿបានសិន នៅខណៈពេលការស៊ើបអង្កេតលើការចោទប្រកាន់នោះកំពុងដំណើរការ ។*
- *ទទួលស្គាល់ និងថ្កោលទោសជាសាធារណៈ ចំពោះអំពើរំលោភដោយ នគរបាល និងបុគ្គលិកមជ្ឈមណ្ឌលសង្គមកិច្ច ទៅលើអ្នកប្រកបរបរផ្លូវភេទ និងអំពាវនាវឲ្យមានការស៊ើបអង្កេតលើពួកគេ។*

- *ប្រឹក្សាជាមួយក្រុមអ្នកប្រកបរបរផ្លូវភេទ ដើម្បីរួមគ្នាបង្កើតកម្មវិធី និងសេវា ដែល អាចផ្តល់អំណាចដល់ អ្នកប្រកបរបរផ្លូវភេទ និងដែលឆ្លុះបញ្ចាំង អំពីសេចក្តី ត្រូវការពិតរបស់ពួកគេ។ សេចក្តីត្រូវការមានរួមទាំងជំនួយផ្នែកច្បាប់ ការថែទាំ សុខភាព ការថែទាំកុមារ ឬការហ្វឹកហ្វឺនវិជ្ជាជីវៈ ប្រសិនបើ អ្នកប្រកបរបរផ្លូវភេទ កត់សំគាល់ឃើញថា វាពាក់ព័ន្ធសម្រាប់ពួកគេ។*

**ចំពោះសាលារាជធានីភ្នំពេញ ៖**

- *បញ្ឈប់ការចាប់ខ្លួន និងឃុំខ្លួនដោយបំពានលើអ្នកប្រកបរបរផ្លូវភេទ - រួមទាំង ស្ត្រី បុរស កុមារ និងស្រីស្រស់ប្រកបរបរផ្លូវភេទ - ជនរងគ្រោះនៃអំពើជួញដូរ និងអ្នកដទៃទៀត រួមមានអ្នកប្រើប្រាស់គ្រឿងញៀន អ្នកគ្មានផ្ទះសម្បែង អ្នកសុំទាន កុមាររស់តាមចិញ្ចើមថ្នល់ និងអ្នកមានជំងឺវិកលចរិត។*

- *ទទួលស្គាល់ និងថ្កោលទោសជាសាធារណៈ ចំពោះអំពើរំលោភដោយ នគរបាល និង បុគ្គលិកមជ្ឈមណ្ឌលសង្គមកិច្ចទៅលើអ្នកប្រកបរបរផ្លូវភេទ និងអំពាវនាវឲ្យមានការស៊ើបអង្កេតលើពួកគេ។*

- *ផ្សព្វផ្សាយ និងណែនាំឲ្យបានទូលំទូលាយ ដល់មន្ត្រីមូលដ្ឋានទាំងអស់ នៅកម្រិតឃុំ/សង្កាត់ ស្រុក/ខណ្ឌ រាជធានី/ខេត្ត ដើម្បីឲ្យប្រតិបត្តិគោលការណ៍ណែនាំស្តីពីការ អនុវត្តច្បាប់បង្ក្រាបអំពើការជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។*

**ចំពោះរដ្ឋសភាជាតិនៃប្រទេសកម្ពុជា ៖**

- *ទទួលស្គាល់ និងថ្កោលទោសជាសាធារណៈ ចំពោះអំពើរំលោភដោយ នគរបាល និងបុគ្គលិកមជ្ឈមណ្ឌលសង្គមកិច្ច ទៅលើអ្នកប្រកបរបរផ្លូវភេទ និងអំពាវនាវឲ្យមានការស៊ើបអង្កេតលើពួកគេ។*

- *បង្កើតស្ថាប័នឯករាជ្យមួយ ដើម្បីទទួលពាក្យបណ្តឹងស្តីពី ទារុណកម្ម ការប្រព្រឹត្តដែលឃោរឃៅ បន្ទាបបន្ថោក និងអមនុស្សធម៌ និងការរំលោភផ្សេងៗទៀត ដែលប្រព្រឹត្ត ដោយមន្ត្រីប្រតិបត្តិច្បាប់ និងបុគ្គលិកនៅមជ្ឈមណ្ឌលសង្គមកិច្ច។*

- *រហូតទាល់តែមានការដោះស្រាយបញ្ហាដ៏ពលដាលនៃការរំលោភលើអ្នកប្រកបរបរផ្លូវភេទ សូមព្យួរមាត្រា២៤ ស្តីពី "អំពើអួសទាញ" ក្នុងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។ បទប្បញ្ញត្តិនេះផ្តល់ឲ្យនគរបាលនូវ អំណាចបន្ថែមដើម្បីជំរិតទាលុយ និងប្រព្រឹត្តអំពើហិង្សាទៅលើអ្នកប្រកបរបរផ្លូវភេទ និងសម្រួលឲ្យមាន ការរំលោភ។*

- *សូមលុបចោលមាត្រាដែលមិនច្បាស់លាស់ គឺមាត្រា២៥(៣)នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលបទប្បញ្ញត្តិនេះ ចាត់ជា "ការរាំងរាំងដល់សកម្មភាពបង្ការ ការជួយ ឬការអប់រំឡើងវិញ" របស់អ្នកប្រកបរបរផ្លូវភេទ ដែលមានន័យស្មើនឹងសញ្ចារកម្ម។*

**ចំពោះទីភ្នាក់ងារសហប្រជាជាតិ និងរដ្ឋាភិបាលម្ចាស់ជំនួយពាក់ព័ន្ធ មានជាអាទិ៍ សហរដ្ឋអាមេរិក សហគមន៍អឺរ៉ុប ជប៉ុន និងអូស្ត្រាលី ៖**

- *ស្នើសុំឲ្យបិទមជ្ឈមណ្ឌលព្រៃស្ពឺ និងកោះគរជាស្ថាពរ រួមទាំងមណ្ឌលដទៃទៀតរបស់ក្រសួងសង្គមកិច្ច ដែលបានឃុំឃាំងប្រជាពលរដ្ឋ រំលោភលើច្បាប់ជាតិ និងច្បាប់អន្តរជាតិ។*

- *ស្នើសុំឲ្យរដ្ឋាភិបាលនៃប្រទេសកម្ពុជា ស៊ើបអង្កេតជាបន្ទាន់ និងដោយឯករាជ្យលើរាល់ការចោទប្រកាន់ទាំងអស់អំពីអំពើរំលោភទៅលើ អ្នកប្រកបរបរផ្លូវភេទ ដោយនគរបាល និងបុគ្គលិកមជ្ឈមណ្ឌលសង្គមកិច្ច។*

- *ពិនិត្យមើលឡើងវិញនូវរាល់មូលនិធិ កម្មវិធី និងសកម្មភាពទាំងអស់ ដែល ជួយដល់ក្រសួងសង្គមកិច្ចរបស់ប្រទេសកម្ពុជា ដើម្បីធ្វើឲ្យប្រាកដថា គ្មាន មូលនិធិណាមួយកំពុងតែគាំទ្រដល់គោលនយោបាយ ឬកម្មវិធីដែលរំលោភច្បាប់សិទ្ធិមនុស្សអន្តរជាតិ ដូចជាការហាមឃាត់ចំពោះការចាប់ខ្លួន និងឃុំខ្លួនដោយបំពាន អំពើទារុណកម្ម និងការប្រព្រឹត្តបែបបន្ទាបបន្ថោក និងអមនុស្សធម៌ទៅលើ អ្នកប្រកបរបរផ្លូវភេទ ។*

- *ពិនិត្យមើលឡើងវិញលើរាល់មូលនិធិ កម្មវិធី និងសកម្មភាពទាំងអស់ ដែលបានគ្រោងឡើង ដើម្បីជួយដល់នគរបាលកម្ពុជា និងក្រសួងសង្គមកិច្ច រហូត ទាល់តែមានការស៊ើបអង្កេតមួយដែលឯករាជ្យពេញលេញ ចំពោះការចោទប្រកាន់ពីអំពើរំលោភ និងការនាំខ្លួនជនទាំងឡាយ ដែលរកឃើញថាបានទទួលខុសត្រូវចំពោះ អំពើរំលោភទាំងនោះ មកផ្តន្ទាទោស និង បិទជាស្ថាពរនូវមជ្ឈមណ្ឌលព្រៃស្ពឺ និងកោះគរ ជាមុនសិន។*

- *ជំរុញយ៉ាងសកម្មឲ្យរដ្ឋាភិបាលកម្ពុជាអនុម័ត និងដាក់ឲ្យអនុវត្តនូវសេវាកម្មនិងកម្មវិធីសម្រាប់អ្នកប្រកបរបរផ្លូវភេទ ដោយឈរលើគោលការណ៍ស្ម័គ្រចិត្ត និងដោយមានការចូលរួមពីក្រុមអ្នកប្រកបរបរផ្លូវភេទ ។*

- *គាំទ្រដល់ក្រុមអង្គការសិទ្ធិមនុស្សក្នុងស្រុក និងក្រុមគាំទ្រអ្នកប្រកបរបរផ្លូវភេទ ដែលកំពុងជួយដល់អ្នកប្រកបរបរផ្លូវភេទផ្អែកតាមគោលការណ៍ស្ម័គ្រចិត្ត និងតាមបែបចូលរួម។*

- *គាំទ្រ តែចំពោះក្រុមសង្គមស៊ីវិលណា ដែលគ្រប់គ្រង ទីជម្រក ឬមណ្ឌលរបស់ខ្លួនស្របទៅតាមបទដ្ឋានអន្តរជាតិ។*

- *ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ គួរស៊ើបអង្កេត ដោយឯករាជ្យ និងឥតលំអៀង លើអំពើហិង្សា និងអំពើជំរិត របស់កងកម្លាំង សន្តិសុខ និងឆ្មាំសន្តិសុខសួនច្បារ និងបញ្ចេញជាសាធារណៈនូវ លទ្ធផល នៃការស៊ើបអង្កេតរបស់ខ្លួន។*

**ចំពោះរដ្ឋាភិបាលសហរដ្ឋអាមេរិក ៖**

- *បន្ថែមទៅនឹងការស្វែងរកការគាំទ្រចំពោះ អនុសាសន៍ខាងលើ ទទួលស្គាល់ពី ស្ថានភាពងាយរងគ្រោះរបស់ អ្នកប្រកបរបរផ្លូវភេទ និងធានាថា ពួកគេនឹង មិនទទួលរងការដាក់ទណ្ឌកម្មតទៅទៀត ដោយសារតែលទ្ធផលនៃ គោលនយោបាយសហរដ្ឋអាមេរិកឡើយ។*

- *ទទួលស្គាល់ផលប៉ះពាល់នៃរបាយការណ៍ប្រចាំឆ្នាំស្តីពីការជួញដូរមនុស្ស ទៅ លើបណ្តាប្រទេសផ្សេងៗ និងទទួលស្គាល់ និងដោះស្រាយចំពោះគ្រោះថ្នាក់ ដែលបានកើតចេញមកពីយុទ្ធនាការប្រឆាំងការជួញដូរមនុស្ស ដែលខុសឆ្គងកន្លងមក ដោយត្រូវសរសេរចងក្រងអំពីផលប៉ះពាល់លើ ជនរងគ្រោះនៃការ ជួញដូរ លើអ្នកប្រកបរបរផ្លូវភេទ និងលើក្រុមដែលគេចាត់ជាកាកសំណល់ សង្គមដទៃទៀត ដូចជាអ្នកធ្វើចំណាកស្រុកដែល មិនបានចុះបញ្ជីជាដើម។*

**ចំពោះអង្គការមិនមែនរដ្ឋាភិបាល ដែលជួយជនរងគ្រោះនៃអំពើជួញដូរ និងអ្នកប្រកបរបរផ្លូវភេទ ៖**

- *អនុវត្តឲ្យបានពេញលេញទៅតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ លើការ ប្រព្រឹត្តចំពោះអ្នករងគ្រោះនៃអំពើជួញដូរ និងអំពើអាជីវកម្មផ្លូវភេទ។ ជា ពិសេស ត្រូវធានាថា រាល់គោលនយោបាយទាំងអស់ ស្តីពីការទទួលឲ្យចូល ស្នាក់ និងឲ្យចេញពីមណ្ឌលខ្លួន គឺត្រូវផ្អែកលើ ការគោរពយ៉ាងខ្ជាប់ខ្ជួនចំពោះ សិទ្ធិមានសេរីភាព និងសន្តិសុខផ្ទាល់ខ្លួន និងសេរីភាពក្នុងការធ្វើដំណើរ ស្វ័យភាព*

*និងភាពជាឯកជន ការមិនរើសអើង និងការហាមឃាត់លើការប្រព្រឹត្តបែបបន្ទាបបន្ថោក និងអមនុស្សធម៌។ ប្ដេជ្ញាចិត្តចំពោះគោលនយោបាយនេះជាលាយល័ក្ខអក្សរ។*

**HUMAN RIGHTS WATCH**

350 Fifth Avenue, 34th Floor
New York, NY 10118-3299
Tel: 212-290-4700
Fax: 212-736-1300

HUMAN RIGHTS WATCH

www.hrw.org

# សេចក្តីបន្ថែម |៖ លិខិតផ្ញើជូនរដ្ឋាភិបាលនៃប្រទេសកម្ពុជា

*លិខិតផ្ញើជូនក្រសួងមហាផ្ទៃ ៖ ផ្ញើថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១០*

**ASIA DIVISION**
Brad Adams, *Executive Director*
Elaine Pearson, *Deputy Director*
Phil Robertson, *Deputy Director*
Sophie Richardson, *Advocacy Director*
Kanae Doi, *Tokyo Director*
Nicholas Bequelin, *Senior Researcher*
Sara Colm, *Senior Researcher*
Meenakshi Ganguly, *Senior Researcher*
Ali Dayan Hasan, *Senior Researcher*
Sunai Phasuk, *Senior Researcher*
Mickey Spiegel, *Senior Researcher*
Phelim Kine, *Researcher*
David Mathieson, *Researcher*
Rachel Reid, *Researcher*
Kay Seok, *Researcher*
Andrea Cottom, *Senior Associate*
Pema Abrahams, *Associate*
Diana Parker, *Associate*
Riyo Yoshioka, *Associate*

**ADVISORY COMMITTEE**
Joanne Leedom-Ackerman, *Chair*
Orville Schell, *Vice Chair*
Maureen Aung-Thwin
Edward J. Baker
Harry Barnes
Robert L. Bernstein
Jagdish Bhagwati
Jerome Cohen
John Despres
Clarence Dias
Mallika Dutt
Merle Goldman
Jonathan Hecht
Paul Hoffman
Sharon Hom
Rounaq Jahan
Perry Link
Andrew J. Nathan
Yuri Orlov
Bruce Rabb
Balakrishnan Rajagopal
Victoria Riskin
Barnett Rubin
James Scott
Frances Seymour
Barbara Shailor
Steven Shapiro
Eric Stover
Ko-Yung Tung

**HUMAN RIGHTS WATCH**
Kenneth Roth, *Executive Director*
Michele Alexander, *Development & Outreach Director*
Carroll Bogert, *Associate Director*
Emma Daly, *Communications Director*
Barbara Guglielmo, *Finance & Administration Director*
Peggy Hicks, *Global Advocacy Director*
Iain Levine, *Program Director*
Andrew Mawson, *Deputy Program Director*
Suzanne Nossel, *Chief Operating Officer*
Dinah PoKempner, *General Counsel*
James Ross, *Legal & Policy Director*
Joe Saunders, *Deputy Program Director*
Jane Olson, *Chair, Board of Directors*

*ថ្ងៃទី១៩ខែមេសាឆ្នាំ២០១០*

**គោរពជូន ឯកឧត្តម ស ខេង**
ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
ប្រធានក្រុមការងារដឹកនាំការប្រយុទ្ធប្រឆាំងអំពើជួញដូរការរត់ពន្ធ
ការធ្វើអាជីវកម្មលើពលកម្មមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ

អាស័យដ្ឋានៈ លេខ២៧៥មហាវិថីព្រះនរោត្តម
ភ្នំពេញ ប្រទេសកម្ពុជា

ផ្ញើរតាមទូរសារៈ +(៨៥៥) ២៣ ៧២១ ៩០៥
ផ្ញើតាមសារអេឡិចត្រូនិកៈ info@interior.gov.kh
moi@interior.gov.kh

**កម្មវត្ថុៈ ការប្រព្រឹត្តលើអ្នកប្រកបរបរផ្លូវភេទ**

ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ស ខេង ជាទីគោរព

អង្គការឃ្លាំមើលសិទ្ធមនុស្ស (Human Rights Watch) គឺជាអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ ដែលឃ្លាំមើលការរំលោភសិទ្ធិមនុស្សដោយភ្នាក់ងាររដ្ឋ និងភ្នាក់ងារមិនមែនរដ្ឋ នៅបណ្តាប្រទេសជាង៨0នៅជុំវិញពិភពលោក។

អង្គការ Human Rights Watch កំពុងតែរៀបចំរបាយការណ៍មួយទាក់ទងនឹងការប្រព្រឹត្តលើស្ត្រី និងកុមារដែលកំពុងប្រកបមុខរបរផ្លូវភេទនៅក្នុងប្រទេសកម្ពុជា។ របាយការណ៍របស់យើងខ្ញុំ បង្ហាញអំពីការប្រមូលតាមដងផ្លូវ អំពើហិង្សា និងអំពើ



BERLIN · BRUSSELS · CHICAGO · GENEVA · JOHANNESBURG- LONDON · LOS ANGELES · MOSCOW · NEW YORK · PARIS · SAN FRANCISCO - TOKYO · TORONTO · WASHINGTON

អមនុស្សធម៌ដ៏ទៃទៀត ព្រមទាំងការចាប់ខ្លួន និងឃុំខ្លួនដោយបំពានមកលើអ្នកប្រកប របរផ្លូវភេទ។

យើងខ្ញុំសរសេរលិខិតនេះមកកាន់ឯកឧត្តម ដើម្បីធានាថា របាយការណ៍យើងខ្ញុំឆ្លុះបញ្ចាំងដោយត្រឹមត្រូវ នូវទស្សនៈ គោលនយោបាយ និងការអនុវត្តរបស់រាជរដ្ឋាភិបាលកម្ពុជា ចំពោះការប្រព្រឹត្តលើស្ត្រី និងកុមារ ដែលជាអ្នកប្រកបរបររកស៊ីផ្លូវភេទនិងចំពោះកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ប្រយុទ្ធប្រឆាំងអំពើជួញដូរ និងការធ្វើអាជីវកម្មផ្លូវភេទ។

អង្គការ Human Rights Watch មានសុឆន្ទៈចងក្រងនូវរបាយការណ៍ ដែលផ្តល់នូវព័ត៌មានគ្រប់គ្រាន់ និងជាក់ស្តែង។ យើងខ្ញុំសង្ឃឹមថា ឯកឧត្តម ឬបុគ្គលិកក្រោមឱវាទឯកឧត្តមនឹងឆ្លើយតប ដោយផ្តល់ចម្លើយចំពោះ សំណួរដូចមានជូនភ្ជាប់មកជាមួយនេះដើម្បីឆ្លុះបញ្ចាំងឲ្យបានត្រឹមត្រូវនូវទស្សនៈរបស់ឯកឧត្តម នៅក្នុងរបាយការណ៍របស់យើងខ្ញុំ។ ដើម្បីអាចឲ្យយើងខ្ញុំបានពិចារណា ព័ត៌មានដែលនឹងផ្តល់តាមរយៈការឆ្លើយតបរបស់ឯកឧត្តម និងដាក់បញ្ចូលក្នុងរបាយការណ៍នាពេលខាងមុខនេះ យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះការឆ្លើយតបជាលាយល័ក្ខអក្សរមកកាន់យើងខ្ញុំ នៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១០។

សូមឯកឧត្តមមេត្តាផ្ញើរមកយើងខ្ញុំផងដែរនូវឯកសារពាក់ព័ន្ធផ្សេងៗ ដូចជា ស្ថិតិ និងរបាយករណ៍អំពីសកម្មភាពរដ្ឋាភិបាលទាក់ទងនឹងការប្រព្រឹត្តិលើស្ត្រីនិងកុមារ ដែលជាអ្នកប្រកបរបររកស៊ីផ្លូវភេទ កិច្ចខិតខំប្រឹងប្រែងទាក់ទងនឹងការផ្តន្ទាទោសលើអំពើជួញដូរ និងការធ្វើអាជីវកម្មផ្លូវភេទ ក្រោមច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ២០០៨ ព្រមទាំង កិច្ចខិតខំក្នុងការអប់រំបណ្តុះ បណ្តាលដល់ភ្នាក់ងារ ឬមន្ត្រីនគរបាល ឬការដាក់ពិន័យដល់ភ្នាក់ងារ ឬមន្ត្រីនគរបាល និងមន្ត្រីរដ្ឋាភិបាលចំពោះអំពើរំលោភច្បាប់នានា។

តាមរយៈលិខិតនេះ យើងខ្ញុំក៏ស្នើសុំការអនុញ្ញាតជាផ្លូវការ ដើម្បីធ្វើទស្សនកិច្ចនៅមជ្ឈមណ្ឌលសង្គមកិច្ចរាជធានីភ្នំពេញនៅព្រៃស្ពី។ យើងខ្ញុំសង្ឃឹមថានឹងពង្រឹងកិច្ចពិភាក្សាជាមួយរដ្ឋាភិបាលកម្ពុជា។

សូមថ្លែងអំណរគុណដល់ការចំណាយពេលវាលារបស់ឯកឧត្តម ឆ្លើយតបចំពោះបញ្ហាដ៏បន្ទាន់នេះ។

សូមឯកឧត្តមទទួលនូវការគោរពដោយស្មោះស្ម័គ្រអំពីខ្ញុំ។

**ប្រាដ អេដាម** (Brad Adams)

**នាយកប្រតិបត្តិ**

**តំបន់អាស៊ី**

*ចម្លងជូន ៖*

**ឯកឧត្តម អ៊ិត សំហេង**
**រដ្ឋមន្ត្រី ក្រសួងសង្គមកិច្ច ការងារ អតីតយុទ្ធជននិងយុវនិតិសម្បទា**
លេខ៧៨៨B មហាវិថីព្រះមុន្នីវង្ស
ភ្នំពេញ ប្រទេសកម្ពុជា
ទូរសារៈ +(៨៥៥) ២៣ ៧២១ ៩០៥
សារអេឡិចត្រូនិកៈ mosalvy@cambodia.gov.kh

**ឯកឧត្តម កែប ជុតិមា**
**អភិបាលរាជធានីភ្នំពេញ**
លេខ៦៩ មហាវិថីព្រះមុនីវង្ស
១២២០១ភ្នំពេញ ប្រទេសកម្ពុជា

ទូរសារៈ +(៨៥៥) ២៣ ៧២២ ០៥៤
សារអេឡិចត្រូនិកៈ phnompenh@phnompenh.gov.kh

## យើងខ្ញុំសូមថ្លែងអំណរគុណការផ្តល់ចម្លើយចំពោះសំណួរដូចខាងក្រោម ៖

១. អង្គការឃ្លាំមើលសិទ្ធិមនុស្ស Human Right Watch បានដឹងថា មានការចាប់ខ្លួនជាប្រចាំទៅលើអ្នកប្រកបរបររកស៊ីផ្លូវភេទ អ្នកប្រើប្រាស់គ្រឿងញៀន ជនគ្មានផ្ទះសម្បែង អ្នកសុំទាន កុមារអនាថា និងអ្នកជំងឺវិកលចរិត នៅរាជធានីភ្នំពេញ។

សូមផ្តល់ព័ត៌មានខាងក្រោម សម្រាប់ឆ្នាំ២០០៧ ឆ្នាំ២០០៨ ឆ្នាំ២០០៩ និងឆ្នាំ២០១០រហូតដល់បច្ចុប្បន្ន ៖

- ចំនួននៃការចាប់ខ្លួនក្នុងឆ្នាំនីមួយៗនៅរាជធានីភ្នំពេញទៅតាមប្រភេទនៃប្រជាពលរដ្ឋទាំងៈ អ្នកប្រកបរបររកស៊ីផ្លូវភេទ អ្នកប្រើប្រាស់គ្រឿងញៀន ជនគ្មានផ្ទះសម្បែង អ្នកសុំទាន កុមារអនាថា និងអ្នកជំងឺវិកលចរិត ចំនួនកុមារសារុប និងចំនួនមនុស្សពេញវ័យសារុប។ បើសិនជាឯកឧកត្តមមិនអាចផ្តល់ទិន្នន័យទាំងនេះបានសូមមេត្តាពន្យល់ពីមូលហេតុ។

- ច្បាប់ ឬគោលនយោបាយដែលផ្តល់សិទ្ធិអំណាចដល់នគរបាល និងអាជ្ញាធរដទៃទៀតអនុវត្តការចាប់ខ្លួនប្រជាពលរដ្ឋទាំងនេះ។

២. តើមានការចាប់ខ្លួន ចោទប្រកាន់និងកាត់ឲ្យជាប់ទោស អ្នកដែលត្រូវបានចោទថា ប្រកបរបររកស៊ីផ្លូវភេទចំនួនប៉ុន្មាននាក់ក្នុងមួយឆ្នាំៗចាប់តាំងពីឆ្នាំ២០០៨មក ពីបទអំពើអូសទាញ តាមមាត្រា២៤ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទឆ្នាំ២០០៨?

៣. តើមានមនុស្សចំនួនប៉ុន្មាននាក់ ត្រូវបានចោទប្រកាន់ កាត់ទោស និងសម្រេចឲ្យជាប់ទោសពីបទល្មើសផ្សេងៗក្រោមច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទឆ្នាំ២០០៨? សូមមេត្តាផ្តល់ពត៌មានពីបទចោទជាក់លាក់ទាំងនេះ (តាមមាត្រាណានៃច្បាប់) និងកម្រិតទោស។

៤. សូមរៀបរាប់ពីនិតិវិធី ចាប់តាំងពីពេលដែលអ្នកប្រកបរបរផ្លូវភេទត្រូវបានចាប់ខ្លួន រហូតដល់ពេលដោះលែងជាយថាហេតុ ឬក៏បញ្ជូនបន្តទៅកាន់មណ្ឌលសង្គមកិច្ចរបស់រដ្ឋាភិបាល ឬក៏អង្គការក្រៅរដ្ឋាភិបាល។ តើនីតិវិធីចំពោះមនុស្សពេញវ័យ និងកុមារ មានភាពខុសគ្នាដូចម្តេចខ្លះ? តើមានការព្យាយាមដើម្បីវិភាគមើលថាតើអ្នកប្រកបរបរផ្លូវភេទ អាចជាជនរងគ្រោះដោយអំពើជួញដូរដែរឬទេ? តើមានចាត់វិធានការអ្វីខ្លះចំពោះអ្នកដែលរកឃើញថាជនរងគ្រោះពីអំពើជួញដូរ?

៥. តើការឃុំឃាំងអ្នកប្រកបរបរផ្លូវភេទ នៅតាមទីកន្លែងឃុំឃាំងរបស់នគរបាល និង/ឬមន្ទីរសង្គមកិច្ចរាជធានីភ្នំពេញ និងមណ្ឌលសង្គមកិច្ចរាជធានីភ្នំពេញឈរលើមូលដ្ឋានច្បាប់ណាខ្លះ? សូមចង្អុលបង្ហាញនូវបញ្ញត្តិជាក់លាក់នានាក្រោមកម្ពុជា និងថាតើសមត្ថកិច្ចស្របច្បាប់ណាខ្លះ ដែលអនុញ្ញាតការឃុំឃាំងនេះ។

៦. តើនរណាខ្លះដែលមានសមត្ថកិច្ចដោះលែងអ្នកប្រកបរបរផ្លូវភេទ ដែលជាប់ឃុំឃាំងចេញពីការិយាល័យនគរបាល ឬមន្ទីរសង្គមកិច្ច និងមណ្ឌលសង្គមកិច្ចរបស់រដ្ឋាភិបាល ហើយថាតើពិចារណាលើ

កត្តាអ្វីខ្លះ ក្នុងការសម្រេចបញ្ជូនអ្នកប្រកបរបរផ្លូវភេទ ពីមន្ទីរសង្គមកិច្ចរាជធានីភ្នំពេញទៅកាន់ អង្គការក្រៅរដ្ឋាភិបាលណាមួយ? តើចំណាត់ការនេះខុសគ្នាដូចម្ដេចខ្លះ រវាងមនុស្សពេញវ័យនិងកុមារ?

៧. តើមានពាក្យបណ្ដឹងទាក់ទងនឹងការបំពារបំពានការចាប់ខ្លួន និងឃុំខ្លួនដោយបំពាន ការជំរិតយកប្រាក់ និងការរំលោភផ្សេងៗលើអ្នកប្រកបមុខរបរផ្លូវភេទ ចំនួនប៉ុន្មាន ត្រូវបានដាក់តាំងពីឆ្នាំ២០០៧មក? មានចំណាត់ការបែបណាទៅលើពាក្យបណ្ដឹងទាំងនេះ? តើមានការដាក់ទោសឬដាក់ទណ្ឌកម្មអ្វីខ្លះចំពោះជនដែលរកឃើញថាជាអ្នកទទួលខុសត្រូវ? សូមផ្ដល់ព័ត៌មានលំអិត។

៨. អង្គការ Human Rights Watch បានដឹងថារដ្ឋាភិបាលកំពុងតែព្រាងសេចក្ដីពន្យល់ សម្រាប់ការអនុវត្តច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ ដោយមានការឧបត្ថម្ភគាំទ្រពីអង្គការ UNICEF។

តើសេចក្ដីពន្យល់ទាំងនេះស្ថិតក្នុងដំណាក់កាលណា ហើយនិង ថាតើអនុម័តសេចក្ដីពន្យល់ទាំងនេះនៅពេលណា? តើរដ្ឋាភិបាលនឹងកំណត់យុទ្ធសាស្ត្រអ្វីខ្លះ ដើម្បីអនុវត្តឲ្យបាននូវសេចក្ដីពន្យល់ណែនាំទាំងនេះ?

៩. សូមរៀបរាប់ពីវគ្គហ្វឹកហ្វឺនអ្វីខ្លះ ដែលបានរៀបចំឡើងសម្រាប់មន្ត្រីប្រតិបត្តិច្បាប់ដែលទាក់ទងនឹងអំពើជួញដូរមនុស្សពេស្យាចារកុមារ និងការការពារសិទ្ធមនុស្ស? ដោយឡែក តើមានវគ្គហ្វឹកហ្វឺនអ្វីខ្លះដែលបានរៀបចំឡើងលើការអនុវត្តច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទឆ្នាំ២០០៨? តើមានវគ្គហ្វឹកហ្វឺនប្រព្រឹត្តទៅចំនួនប៉ុន្មានវគ្គ ហើយតើនរណាខ្លះទទួលបានការហ្វឹកហ្វឺនទាំងនេះ? តើនគរបាលនៅគ្រប់កម្រិតទាំងអស់ដូចជាកម្រិតខេត្ត/ក្រុង ស្រុក/ខ័ណ្ឌ និងឃុំជាអ្នកទទួលបាននូវវគ្គហ្វឹកហ្វឺនទាំងនេះដែរទេ? តើមានអ្វីដើម្បីវាស់ស្ទង់ពីប្រសិទ្ធភាពនៃវគ្គហ្វឹកហ្វឺនទាំងនេះដែរឬទេ?

**HUMAN RIGHTS WATCH**

350 Fifth Avenue, 34th Floor
New York, NY 10118-3299
Tel: 212-290-4700
Fax: 212-736-1300

# លិខិតជូនក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ៖ ផ្ញើនៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១០

HUMAN RIGHTS WATCH

www.hrw.org

**ASIA DIVISION**
**Brad Adams**, *Executive Director*
**Elaine Pearson**, *Deputy Director*
**Phil Robertson**, *Deputy Director*
**Sophie Richardson**, *Advocacy Director*
**Kanae Doi**, *Tokyo Director*
**Nicholas Bequelin**, *Senior Researcher*
**Sara Colm**, *Senior Researcher*
**Meenakshi Ganguly**, *Senior Researcher*
**Ali Dayan Hasan**, *Senior Researcher*
**Sunai Phasuk**, *Senior Researcher*
**Mickey Spiegel**, *Senior Researcher*
**Phelim Kine**, *Researcher*
**David Mathieson**, *Researcher*
**Rachel Reid**, *Researcher*
**Kay Seok**, *Researcher*
**Andrea Cottom**, *Senior Associate*
**Pema Abrahams**, *Associate*
**Diana Parker**, *Associate*
**Riyo Yoshioka**, *Associate*

**ADVISORY COMMITTEE**
**Joanne Leedom-Ackerman**, *Chair*
**Orville Schell**, *Vice Chair*
Maureen Aung-Thwin
Edward J. Baker
Harry Barnes
Robert L. Bernstein
Jagdish Bhagwati
Jerome Cohen
John Despres
Clarence Dias
Mallika Dutt
Merle Goldman
Jonathan Hecht
Paul Hoffman
Sharon Hom
Rounaq Jahan
Perry Link
Andrew J. Nathan
Yuri Orlov
Bruce Rabb
Balakrishnan Rajagopal
Victoria Riskin
Barnett Rubin
James Scott
Frances Seymour
Barbara Shailor
Steven Shapiro
Eric Stover
Ko-Yung Tung

**HUMAN RIGHTS WATCH**
**Kenneth Roth**, *Executive Director*
**Michele Alexander**, *Development & Outreach Director*
**Carroll Bogert**, *Associate Director*
**Emma Daly**, *Communications Director*
**Barbara Guglielmo**, *Finance & Administration Director*
**Peggy Hicks**, *Global Advocacy Director*
**Iain Levine**, *Program Director*
**Andrew Mawson**, *Deputy Program Director*
**Suzanne Nossel**, *Chief Operating Officer*
**Dinah PoKempner**, *General Counsel*
**James Ross**, *Legal & Policy Director*
**Joe Saunders**, *Deputy Program Director*
**Jane Olson**, *Chair, Board of Directors*

ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១០

**គោរពជូន ឯកឧត្តម អ៊ិត សំហេង**

រដ្ឋមន្ត្រី ក្រសួងសង្គមកិច្ច ការងារ អតីតយុទ្ធជននិងយុវនិតិសម្បទា
អាស័យដ្ឋានៈ លេខ២៧៥មហាវិថីព្រះនរោត្តម
ភ្នំពេញ ប្រទេសកម្ពុជា
ផ្ញើរតាមទូរសារៈ +(៨៥៥) ២៣ ៧២៦ ០៨៦
ផ្ញើតាមសារអេឡិចត្រូនិកៈ mosalvy@cambodia.gov.kh

**កម្មវត្ថុៈ ការប្រព្រឹត្តលើអ្នកប្រកបរបរផ្លូវភេទ**

ឯកឧត្តម អ៊ិតសំហេង ជាទីគោរព

អង្គការឃ្លាំមើលសិទ្ធមនុស្ស (Human Rights Watch) គឺជាអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ ដែលឃ្លាំមើលការរំលោភសិទ្ធិមនុស្សដោយភ្នាក់ងាររដ្ឋ និងភ្នាក់ងារមិនមែនរដ្ឋ នៅបណ្តាប្រទេសជាង៨០នៅជុំវិញពិភពលោក។

អង្គការ Human Rights Watch កំពុងតែរៀបចំរបាយការណ៍មួយទាក់ទងនឹងការប្រព្រឹត្តលើស្ត្រី និងកុមារដែលកំពុងប្រកបមុខរបរផ្លូវភេទនៅក្នុងប្រទេសកម្ពុជា។ របាយការណ៍របស់យើងខ្ញុំ បង្ហាញអំពីការប្រមូលតាមដងផ្លូវ អំពើហិង្សា និងអំពើអមនុស្សធម៌ដទៃទៀតព្រមទាំងការចាប់ខ្លួន និងឃុំខ្លួនដោយបំពានមកលើអ្នកប្រកបរបរផ្លូវភេទ។

យើងខ្ញុំសរសេរលិខិតនេះមកកាន់ឯកឧត្តម ដើម្បីធានាថា របាយការណ៍យើងខ្ញុំឆ្លុះបញ្ចាំងដោយ ត្រឹមត្រូវនូវទស្សនៈ គោលនយោបាយ



BERLIN · BRUSSELS · CHICAGO · GENEVA · JOHANNESBURG · LONDON · LOS ANGELES · MOSCOW · NEW YORK · PARIS · SAN FRANCISCO · TOKYO · TORONTO · WASHINGTON

និងការអនុវត្តរបស់រាជរដ្ឋាភិបាលកម្ពុជាចំពោះការប្រព្រឹត្តលើស្ត្រី និងកុមារដែលជាអ្នកប្រកបរបរផ្លូវភេទ និងចំពោះកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ប្រយុទ្ធប្រឆាំង អំពើជួញដូរ និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

អង្គការ Human Rights Watch មានសុឆន្ទៈចងក្រងនូវរបាយការណ៍ ដែលផ្តល់នូវព័ត៌មានគ្រប់គ្រាន់ និងជាក់ស្តែង។ យើងខ្ញុំសង្ឃឹមថា ឯកឧត្តម ឬបុគ្គលិកក្រោមឱវាទឯកឧត្តមនឹងឆ្លើយតប ដោយផ្តល់ចម្លើយចំពោះ សំណួរដូចមានជូនភ្ជាប់មកជាមួយនេះដើម្បីឆ្លុះបញ្ចាំងឲ្យបានត្រឹមត្រូវនូវទស្សនៈរបស់ឯកឧត្តម នៅក្នុងរបាយការណ៍របស់យើងខ្ញុំ។ ដើម្បីអាចឲ្យយើងខ្ញុំបានពិចារណា ព័ត៌មានដែលនឹងផ្តល់តាមរយៈការឆ្លើយតបរបស់ឯកឧត្តម និងដាក់បញ្ចូលក្នុងរបាយការណ៍នាពេលខាងមុខនេះ យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះការឆ្លើយតបជាលាយល័ក្ខអក្សរមកកាន់យើងខ្ញុំ នៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១០។

សូមឯកឧត្តមមេត្តាផ្ញើរមកយើងខ្ញុំផងដែរ នូវឯកសារពាក់ព័ន្ធផ្សេងៗ ដូចជាស្ថិតិ និងរបាយការណ៍អំពីសកម្មភាពរដ្ឋាភិបាលទាក់ទងនឹងការប្រព្រឹត្តលើស្ត្រី និងកុមារដែលជាអ្នកប្រកបរបរផ្លូវភេទ។

តាមរយៈលិខិតនេះ យើងខ្ញុំក៏ស្នើសុំការអនុញ្ញាតជាផ្លូវការ ដើម្បីធ្វើទស្សនកិច្ចនៅមជ្ឈមណ្ឌលសង្គមកិច្ចរាជធានីភ្នំពេញនៅព្រៃស្ពឺ។ យើងខ្ញុំសង្ឃឹមថានឹងពង្រឹងកិច្ចពិភាក្សាជាមួយរដ្ឋាភិបាលកម្ពុជា។

សូមថ្លែងអំណរគុណ ដល់ការចំណាយពេលវេលារបស់ឯកឧត្តម ឆ្លើយតបចំពោះបញ្ហាដ៏បន្ទាន់នេះ។

សូមឯកឧត្តមទទួលនូវការគោរពដោយស្មោះស្ម័គ្រអំពីខ្ញុំ។

ប្រាដ អេដាម (Brad Adams)
**នាយកប្រតិបត្តិ**
**តំបន់អាស៊ី**

ចម្លងជូន ៖

**ឯកឧត្តម ស ខេង**
**ឧបនាយករដ្ឋមន្ត្រីនិងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ប្រធានក្រុមការងារដឹកនាំការប្រយុទ្ធប្រឆាំងអំពើជួញដូរ ការរត់ពន្ធ ការធ្វើអាជីវកម្មលើពលកម្មមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ**
លេខ ២៧៥ មហាវិថីព្រះនរោត្តម
ភ្នំពេញ ប្រទេសកម្ពុជា
ទូរសារៈ +(៨៥៥) ២៣ ៧២១ ៩០៥
សារអេឡិចត្រូនិកៈ info@interior.gov.kh
moi@interior.gov.kh

ឯកឧត្តម កែប ជុតិមា
អភិបាលរាជធានីភ្នំពេញ
លេខ៦៩ មហាវិថីព្រះមុនីវង្ស
១២២០១ភ្នំពេញ ប្រទេសកម្ពុជា
ទូរសារៈ +(៨៥៥) ២៣ ៧២២ ០៥៤
សារអេឡិចត្រូនិកៈ ២២ ០៥៤
សារអេឡិចត្រូនិកៈ phnompenh@phnompenh.gov.kh

## យើងខ្ញុំសូមថ្លែងអំណរគុណការផ្តល់ចម្លើយសំណួរដូចខាងក្រោម ៖

១. អង្គការ Human Right Watch បានដឹងថា មានការចាប់ខ្លួនជាប្រចាំទៅលើអ្នកប្រកបរបរផ្លូវភេទ អ្នកប្រើប្រាស់គ្រឿងញៀន ជនគ្មានផ្ទះសំបែងអ្នកសុំទាន កុមារអនាថា និងអ្នកជំងឺវិកលចរិត នៅទីរាជធានីភ្នំពេញ។

សូមផ្តល់ព័ត៌មានខាងក្រោម ដោយគិតចាប់តាំងពីឆ្នាំ ២០០៧ រហូតដល់បច្ចុប្បន្ន ៖

- ចំនួនអ្នកប្រកបរបរផ្លូវភេទ នៅរាជធានីភ្នំពេញ ដែលបានបញ្ជូនមកកាន់មន្ទីរសង្គមកិច្ចរាជធានីភ្នំពេញ ទៅមណ្ឌលសង្គមកិច្ចរបស់រដ្ឋាភិបាលបញ្ជូនបន្តទៅអង្គការក្រៅរដ្ឋាភិបាល និងអ្នកដែលត្រូវបានដោះលែងក្នុងឆ្នាំនីមួយៗ។ សូមផ្តល់ព័ត៌មានជាក់លាក់អំពីចំនួនកុមារសារុបដែលស្ថិតក្នុងចំណោមអ្នកដែលត្រូវបានបញ្ជូនទៅកាន់មណ្ឌលទាំងនេះ។ បើសិនជា ឯកឧត្តម មិនអាចផ្តល់ទិន្នន័យទាំងនេះបានទេ សូមមេត្តាពន្យល់ពីមូលហេតុ។

- ច្បាប់ ឬគោលនយោបាយដែលផ្តល់សិទ្ធិអំណាចដល់នគរបាល និងអាជ្ញាធរដទៃទៀត អនុវត្តការចាប់ខ្លួនប្រជាពលរដ្ឋទាំងនេះ។

២. សូមរៀបរាប់ពីនិតិវិធី ចាប់តាំងពីពេលដែលអ្នកប្រកបរបរផ្លូវភេទត្រូវបានចាប់ខ្លួន រហូតដល់ពេលដោះលែងជាយថាហេតុ ឬក៏បញ្ជូនបន្តទៅកាន់មណ្ឌលសង្គមកិច្ចរបស់រដ្ឋាភិបាល ឬក៏អង្គការក្រៅរដ្ឋាភិបាល។ តើនីតិវិធីចំពោះមនុស្សពេញវ័យ និងកុមារ មានភាពខុសគ្នាដូចម្តេចខ្លះ? តើមានការព្យាយាមដើម្បីវិភាគមើលថាតើអ្នកប្រកបរបរផ្លូវភេទ អាចជាជនរងគ្រោះដោយអំពើជួញដូរដែរឬទេ? តើមានចាត់វិធានការ អ្វីខ្លះចំពោះអ្នកដែលរកឃើញថាជនរងគ្រោះពីអំពើជួញដូរ?

៣. តើការឃុំឃាំងអ្នកប្រកបរបរផ្លូវភេទ នៅមន្ទីរសង្គមកិច្ចរាជធានីភ្នំពេញឬ មណ្ឌលសង្គមកិច្ចរាជធានីភ្នំពេញ ឈរលើមូលដ្ឋាច្បាប់ណាខ្លះ? សូមចង្អុលបង្ហាញ នូវបញ្ញត្តជាក់លាក់ក្រោមច្បាប់កម្ពុជា និងថាតើសមត្ថកិច្ចស្របច្បាប់ណាខ្លះដែលអនុញ្ញាតការឃុំឃាំងនេះ។

៤. តើនរណាខ្លះដែលមានសមត្ថកិច្ចដោះលែងអ្នកប្រកបរបរផ្លូវភេទដែលជាប់ឃុំឃាំង ចេញពីមន្ទីរសង្គមកិច្ច ឬមណ្ឌលសង្គមកិច្ចរបស់រដ្ឋាភិបាល ហើយថាតើពិចារណាលើកត្តាអ្វីខ្លះ ក្នុងការសម្រេចបញ្ជូនអ្នកប្រកបរបរផ្លូវភេទ ពីមន្ទីរសង្គមកិច្ចរាជធានីភ្នំពេញ ទៅកាន់អង្គការក្រៅរដ្ឋាភិបាលណាមួយ? តើចំណាត់ការនេះខុសគ្នាដូចម្តេចខ្លះរវាងមនុស្សពេញវ័យនិងកុមារ? តើចំណាត់ការនេះខុសគ្នាដែរឬទេចំពោះមុខជនរងគ្រោះពីអំពើជួញដូរ?

៥. តើផ្អែកលើហេតុផលអ្វីខ្លះ ក្នុងការបញ្ជូនអ្នកប្រកបរបរផ្លូវភេទ ដែលជាជនពេញវ័យ ពីមន្ទីរសង្គមកិច្ចទៅឲ្យអង្គការក្រៅរដ្ឋាភិបាល?

៦. តើឯកឧត្តមបានដឹងអំពីពាក្យបណ្តឹងចំនួនប៉ុន្មានទាក់ទងនឹងការបំពាន អំពើអមនុស្សធម៌ ការឃុំខ្លួនដោយបំពាន ទៅលើអ្នកប្រកបមុខរបរផ្លូវភេទ ដែលកើតមានឡើងនីមន្ទីរសង្គមកិច្ចរាជធានី ឬ មណ្ឌលសង្គមកិច្ចរបស់រដ្ឋាភិបាល? តើមានចំណាត់ការបែបណាទៅលើពាក្យបណ្តឹងទាំងនេះ? តើមានការដាក់ទោស ឬដាក់ទណ្ឌកម្មអ្វីខ្លះ ចំពោះបុគ្គលដែលរកឃើញថាជាអ្នកទទួលខុសត្រូវ? សូមផ្តល់ព័តមានលំអិតអំពីករណីដែលបានចាត់វិធានការទាំងអស់។
៧. តើមានវគ្គហ្វឹកហ្វឺនអ្វីខ្លះ ដែលបានរៀបចំឡើងសម្រាប់បុគ្គលិកនិងមន្ត្រីនៅមន្ទីរសង្គមកិច្ចរាជធានី ឬមណ្ឌលសង្គមកិច្ចរបស់រដ្ឋាភិបាល? តើមានវគ្គហ្វឹកហ្វឺនចំនួនប៉ុន្មានវគ្គ ដែលបានរៀបចំឡើង ហើយតើបុគ្គលិកនិងមន្ត្រីណាខ្លះទទួលបានការហ្វឹកហ្វឺនទាំងនេះ? តើមានអ្វីដើម្បីវាស់ស្ទង់ពីប្រសិទ្ធភាព នៃវគ្គហ្វឹកហ្វឺនទាំងនេះដែរឬទេ?

៨. មន្ត្រីរដ្ឋាភិបាលបានថ្លែងជាសាធារណៈជាច្រើនលើកថា ប្រតិបត្តិការ និងអន្តរាគមន៍នានា ជាការចំបាច់ដើម្បី "អប់រំណែនាំ" សល់អ្នកប្រកបរបរផ្លូវភេទ និងផ្តល់ដល់ពួកគេនូវការបណ្តុះបណ្តាលវិជ្ជាជីវៈជំនាញដើម្បីឲ្យពួកគេផ្លាស់ប្តូរមុខរបរ។ តើរដ្ឋាភិបាលមានកម្មវិធីអ្វីខ្លះសម្រាប់"អប់រំណែនាំ" និងបណ្តុះបណ្តាលវិជ្ជាជីវៈជំនាញដល់ពួកគេ ហើយមណ្ឌលដែលមានផ្តល់កម្មវិធីទាំងនេះស្ថិតនៅកន្លែងណាខ្លះ? តើមានមណ្ឌលចំនួនប៉ុន្មាន ដែលបំពាក់នូវគ្រឿងបរិក្ខា និងសេវាគ្រប់គ្រាន់ក្នុងការដំណើរការកម្មវិធីទាំងនេះ? តើកម្មវិធីទាំងនេះដំណើរការទៅដោយមានការចូលរួមពិគ្រោះជាមួយ ក្រុមអ្នកប្រកបរបរផ្លូវភេទដែរឬទេ ហើយថាតើកម្មវិធីទាំងនេះផ្តល់ដល់ពួកគេដោយឈរលើគោលការស្ម័គ្រចិត្តដែរទេ?

# VIII. សេចក្តីថ្លែងអំណរគុណ

*របាយការណ៍នេះ ត្រូវបានពិនិត្យដោយអ្នកស្រី អេឡេន ភាសាន់ នាយករងប្រចាំ តំបន់អាស៊ី របស់អង្គការឃ្លាំមើលសិទ្ធិមនុស្ស, លោក ភីល រ៉ូបឺតសាន់ នាយករងប្រចាំ តំបន់អាស៊ី និងអ្នកស្រី សារ៉ា ខុម អ្នកស្រាវជ្រាវជាន់ខ្ពស់ប្រចាំតំបន់អាស៊ី។ លោក អេសលីង រេដឌី ទីប្រឹក្សាច្បាប់ជាន់ខ្ពស់ និងលោក ចូសិប សនឌឺ នាយករង ការិយាល័យកម្មវិធី ដែលបានត្រួតពិនិត្យមើលលើផ្លូវច្បាប់ និងលើកម្មវិធីពាក់ព័ន្ធ រៀងៗខ្លួន។ ការត្រួតពិនិត្យផ្ទៀងផ្ទាត់ សម្រាប់ការបោះពុម្ពត្រូវបានធ្វើឡើងដោយ កាសាន់ជ្រា កាវ៉ាណាហ្វ ទីប្រឹក្សា ការិយាល័យកម្មវិធីនៃអង្គការឃ្លាំមើលសិទ្ធិមនុស្ស។*

*ការត្រួតពិនិត្យតាមឯកទេសត្រូវបានធ្វើឡើងដោយ លោក បិត សីបប៉ាត អ្នកស្រាវជ្រាវនៅក្នុងផ្នែកសិទ្ធិកុមារ, កញ្ញា នីសា វ៉ារា អ្នកស្រាវជ្រាវជាន់ខ្ពស់ក្នុងផ្នែកសិទ្ធិស្ត្រី, អ្នកស្រី ម៉ារីអាន ម៉ុលមែន នាយកស្វែងរកការគាំទ្រក្នុងផ្នែកសិទ្ធិនារី, អ្នកស្រី លីសល ហ្គឺនថល នាយកផ្នែកសិទ្ធិស្ត្រី, និងលោក ឌិពិកា ណាត អ្នកស្រាវជ្រាវកម្មវិធីអិលហ្ជីប៊ីធី (LGBT)។*

*អង្គការឃ្លាំមើលសិទ្ធិមនុស្សសូមថ្លែងអំណរគុណផងដែរដល់ កញ្ញា អេលីនន័រ តៃលឺ-នីកុលសាន់ សហជីវិនរួមការងារនៅរដូវក្តៅជាមួយផ្នែកអាស៊ី ដែលបានជួយ ស្រាវជ្រាវ និង លោក ចាសុន បាបប៊ី ជាអ្នកជំនាញដទៃក្រៅពីអង្គការឃ្លាំមើលសិទ្ធិមនុស្ស ដែលបានត្រួតពិនិត្យមើលរបាយការណ៍នេះ និងអ្នកត្រួតពិនិត្យដទៃផ្សេងទៀត ដែលផ្តល់យោបល់លើសេចក្តីព្រាងរបាយការណ៍។ ជំនួយការសម្រាប់ការផលិតរបាយការណ៍នេះមាន កញ្ញា ពីម៉ា អាប្រាហាំ សហការី ក្នុងផ្នែកអាស៊ីរបស់អង្គការឃ្លាំមើលសិទ្ធិមនុស្ស, លោក គ្រេស ធ័រ នាយកបោះពុម្ព, លោក*

ហ្វីតរ៉យ ហេពគិន អ្នកគ្រប់គ្រងការផលិត និង អ្នកស្រី អាណា ឡូព្រើរ៍ អ្នកពិនិត្យផ្ទៀងផ្ទាត់រូបភាព និងលោក ហ្គីលីអូ ប្រាិកហ្គីរិ ចំពោះការបង្កើតផែនទី។

HUMAN RIGHTS WATCH
350 Fifth Avenue, 34th Floor
New York, NY 10118-3299

www.hrw.org

HUMAN RIGHTS WATCH

# បោសសម្អាតចេញពីដងវិថី

## *ការឃុំខ្លួនដោយបំពាន និងអំពើរំលោភផ្សេងៗលើអ្នកប្រកបរបរផ្លូវភេទនៅក្នុងប្រទេសកម្ពុជា*

នៅក្នុងប្រទេសកម្ពុជា ជនដែលមានមុខងារការពារច្បាប់ ជាញឹកញាយគឺជាជនដែលប្រព្រឹត្តអំពើរំលោភបំពានដ៏អាក្រក់បំផុត។ ជាពិសេស ស្ត្រី ប្រកបរបរផ្លូវភេទ ដឹងការពិតទាក់ទងនឹងរឿងនេះ។ ស្ត្រី និងកុមារ ដែលពាក់ព័ន្ធក្នុងមុខរបរផ្លូវភេទប្រឈមមុខនឹងការវាយដំ ការរំលោភសេពសន្ថវៈ ការបៀតបៀនកេរ្តិ៍ខ្មាស់ ការជំរិតយកលុយ ការចាប់ខ្លួន និងឃុំខ្លួនដោយបំពាន និងការរំលោភបំពានដទៃទៀតពីសំណាក់មន្ត្រីនានាដែលមានមុខងារប្រតិបត្តិច្បាប់។ ជនល្មើសទាំងនេះរួមមានទាំង នគរបាល ឆ្មាំសន្តិសុខការពារសួនច្បារសាធារណៈ មន្ត្រីដែលធ្វើការនៅក្នុងមជ្ឈមណ្ឌល និងការិយាល័យដែលគ្រប់គ្រងដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា (MOSAVY)។

“បោសសម្អាតចេញពីដងវិថី” សរសេរចងក្រងឡើងនូវបញ្ហារំលោភបំពាន ដោយផ្អែកលើការសម្ភាសន៍ពិស្តារជាបុគ្គលជាមួយអ្នកប្រកបរបរផ្លូវភេទចំនួន ៩១ នាក់ និងបានពិភាក្សាជាក្រុមជាមួយអ្នកប្រកបរបរផ្លូវភេទ ជាច្រើននាក់ផ្សេងទៀត។ អ្នកប្រកបរបរផ្លូវភេទបានប្រាប់អង្គការឃ្លាំមើលសិទ្ធិមនុស្សថា មន្ត្រីនគរបាល បានវាយលើពួកគេដោយប្រើ កណ្តាប់ដៃ ព្រនង់ ដំបងឈើ និងប្រើដំបងឆក់។ មន្ត្រីនគរបាល ក៏បានគំរាមកំហែងអ្នកប្រកបរបរផ្លូវភេទដោយអាវុធផងដែរ។ ក្នុងឱកាសខ្លះ មន្ត្រីនគរបាលបានរំលោភសេពសន្ថវៈ ស្ត្រីប្រកបរបរផ្លូវភេទ ក្នុងអំឡុងពេលដែលពួកគេស្ថិតក្នុងការឃុំឃាំងរបស់នគរបាល។ អ្នក ប្រកបរបរផ្លូវភេទខ្លះ បានពិពណ៌នាអំពីស្ថានភាពនៃការជាប់ឃុំឃាំងរបស់ពួកគេនៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋាភិបាលថាជាការគួរឲ្យរន្ធត់ ជាមួយនឹងការដាក់កំហិតដល់សេរីភាពក្នុងការធ្វើដំណើរ ទទួលរង ឬបានឃើញការវាយដំ ឬ ការរំលោភសេពសន្ថវៈ និង មានអាហារ និងការថែទាំសុខភាពមិនគ្រប់គ្រាន់។ បទល្មើសដែលប្រព្រឹត្ត លើអ្នកប្រកបរបរផ្លូវភេទដោយមន្ត្រីទាំងអស់នេះ ស្ទើរតែមិនទទួលបាននូវការផ្តន្ទាទោសទេ។

របាយការណ៍នេះក៏បានវិភាគផងដែរលើផលប៉ះពាល់នៃច្បាប់ឆ្នាំ២០០៨ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។ ខណៈពេលដែលច្បាប់ថ្មីមានបញ្ញត្តិ ដែលមានអត្ថប្រយោជន៍ចំពោះអំពើជួញដូរ ច្បាប់នេះបានដាក់ជាបទព្រហ្មទណ្ឌនូវ “អំពើអូសទាញ” ប្រព្រឹត្តដោយអ្នកប្រកបរបរផ្លូវភេទ ក្នុងបែបផែនដែលបើកផ្លូវឲ្យមានការរំលោភបំពានជាបន្តរបស់នគរបាលទៅលើបុគ្គលប្រកបរបរផ្លូវភេទ។

អង្គការឃ្លាំមើលសិទ្ធិមនុស្ស ជំរុញរដ្ឋាភិបាលកម្ពុជាឲ្យបញ្ចប់បញ្ហានិទណ្ឌភាព ដោយដាក់ឲ្យអ្នកប្រព្រឹត្តអំពើរំលោភបំពានទាំងនេះទទួលខុសត្រូវចំពោះបទល្មើសរបស់ពួកគេ និង បិទមជ្ឈមណ្ឌលសង្គមកិច្ចដែល កើតមានឡើងនូវអំពើរំលោភបំពាន។ ម្ចាស់ជំនួយ និងភ្នាក់ងារអង្គការសហប្រជាជាតិនានា គួរតែប្រើប្រាស់ឥទ្ធិពលរបស់ខ្លួន នៅពេលធ្វើការងារជាមួយរដ្ឋាភិបាលកម្ពុជា ដើម្បីធ្វើឲ្យប្រាកដថា អ្វីដែលជាការជំរុញ របស់អង្គការឃ្លាំមើលសិទ្ធិមនុស្សនេះនឹងកើតមានឡើង។




*អ្នកប្រកបរបរផ្លូវភេទកម្ពុជារួមគ្នាធ្វើការតវ៉ាប្រឆាំងនឹងការបង្ក្រាបរបស់នគរបាលលើពេស្យាកម្ម។ អ្នកប្រកបរបរផ្លូវភេទរាយការណ៍ថានគរបាលរំលោភបំពានលើរាងកាយនិងផ្លូវភេទពួកគេក្នុងអំឡុងពេលនៃការឃុំឃាំងរបស់នគរបាល។*

*© 2008 AP Photo*